ទស្សនាវដ្តី

# វិទ្យាស្ថានភាសាជាតិ
## នៃ រាជបណ្ឌិត្យសភាកម្ពុជា

Revue semestrielle de l’Institut de la Langue Nationale
de l’Académie Royale du Cambodge


ឆ្នាំទី ៣ | លេខ ៣ | ខែ ឧសភា

ព.ស. ២៥៤៦ | គ.ស. ២០០២

Troisième année | No. 3 | Mai 2002


ភ្នំពេញ
Phnom Penh

**គណៈកម្មការអំណាន :**

- ប្រធានកិត្តិយស : បណ្ឌិត សាស្ត្រាចារ្យ ស៊ន សំណាង
- ប្រធាន : បណ្ឌិត សាស្ត្រាចារ្យ ឡុង សៀម
- អនុប្រធាន : បណ្ឌិត អ៊ីវ ច័ន
- សមាជិក រាយការណ៍ : បណ្ឌិត ព្រុំ ម៉ល់
- សមាជិក :
  - បណ្ឌិត ឆយ យីហ៊ាង
  - បណ្ឌិត ឃិន សុខ
  - បណ្ឌិត ថោង ថែល
  - បណ្ឌិត ស៊ុំ ឈុំប៊ុន
  - បណ្ឌិត សោម សុមុនី

**ក្រុមការងារ :**

បុគ្គលិក នៃ វិទ្យាស្ថានភាសាជាតិ

**Comité de Lecture :**

- Président d'honneur : Dr Sorn Samnang
- Président ...... : Dr Long Seam
- Vice-Président : Dr Iv Chan
- Membre rapporteur : Dr Prum Moal
- Membres :
  - Dr Chhay Yiheang
  - Dr Khin Sok
  - Dr Thong Thel
  - Dr Sum Chhumbun
  - Dr Som Somuny

**Réalisation :**

Personnel de l'Institut de la Langue Nationale

ចេញផ្សាយដោយ : វិទ្យាស្ថានភាសាជាតិ នៃ រាជបណ្ឌិត្យសភាកម្ពុជា

Publié par : Institut de la Langue Nationale de l'A. R. C.

អាស័យដ្ឋាន : ក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២ ផ្លូវសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Adresse : Université Royale de Phnom Penh, Campus II<br>Boulevard de la Fédération de Russie,<br>Phnom Penh, Cambodge

Téléphone : 023 89 02 84 , 023 89 01 80

E-mail : racademy@camnet.com.kh

No 3 - mai 2002

# បុព្វកថា

ក្នុងទស្សនាវដ្ដីលេខ២ នៃវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា ដែលបានចុះតែអត្ថបទស្ដីពីភាសា យើងបានសន្យាថានឹងខំព្យាយាមឱ្យមានអត្ថបទអក្សរសិល្ប៍ផង ក្នុងទស្សនាវដ្ដីលេខក្រោយៗ ពីព្រោះ អក្សរសិល្ប៍ក៏ជាមុខវិជ្ជាដែលនៅក្នុងរង្វង់ស្រាវជ្រាវរបស់វិទ្យាស្ថានយើងដែរ ។ ប៉ុន្តែ ដោយឱកាសនៅមិនទាន់ល្អពេញលេញ យើងមានអត្ថបទអក្សរសិល្ប៍តែមួយសម្រាប់ទស្សនាវដ្ដីលេខ៣ ដែលចេញលើកនេះ : យើងស្ដាយណាស់ដោយសារសភាពការណ៍បែបនេះ។

យើងក៏បានសន្យា ផងដែរ ថានឹងខំស្វែងរកគុណភាពឱ្យទស្សនាវដ្ដីយើង ហើយ យើងសង្ឃឹមថា លោកអ្នកអាននឹងមើលឃើញបន្លែក រវាង ទស្សនាវដ្ដីលេខ២ និង លេខ៣នេះ។ ចំពោះការភ្លាំងភ្លាត់ក្នុងទស្សនាវដ្ដីលេខ២ យើងសុំសេចក្ដីអនុគ្រោះពីសំណាក់លោកអ្នកអាន : សូមលោកមេត្តាអភ័យទោស បើលោកបានសង្កេតឃើញថា ក្នុងអត្ថបទខ្លះមានសេចក្ដីមិនសមស្របតាមស្ថានភាព។

ម្យ៉ាងទៀត យើងសុំបញ្ជាក់ឡើងវិញថា គំនិតនិងទ្រឹស្ដីនៃអត្ថបទ ដែលចុះក្នុងទស្សនាវដ្ដីយើង មិនមែនសុទ្ធតែស្របតាមគោលជំហររបស់វិទ្យាស្ថានទេ : យើងទុកលទ្ធភាពឱ្យម្ចាស់អត្ថបទបញ្ចេញគំនិតនិងប្រើទ្រឹស្ដី តាមចំណូលចិត្ត និង ក្រោមការទទួលខុសត្រូវរបស់គេ។

ជ. គណៈកម្មការអំណាន
សមាជិករបាយការណ៍ ទទួលបន្ទុកបោះពុម្ពទស្សនាវដ្ដី

Dans la Revue n°2 de l'Institut de la Langue Nationale de l'Académie Royale du Cambodge, dont les articles ne concernaient que des problèmes de langues, nous avons promis de faire en sorte que la littérature soit également représentée dans les numéros à paraître : cette matière étant également celle qui relève de la compétence de notre Institut . Mais les conditions n'étant pas encore très favorables, nous n'avons qu'un article sur la littérature pour le présent numéro : nous le regrettons beaucoup.

Notre deuxième objectif était la recherche de la qualité pour notre Revue et nous espérons que la différence sera perceptible entre le numéro 2 et le numuéro 3. Quant à ce qui pourrait être perçu comme des maladresses ou excès de langage dans certains articles du n°2, nous prions nos aimables lecteurs de nous excuser pour notre manque de vigilance dans notre contrôle.

Enfin, nous tenons à préciser à nouveau que les idées et les théories contenues dans les articles de notre Revue ne reflètent pas nécessairement notre position : nous laissons aux auteurs la responsabilité de leurs idées et celle du choix des théories qu'ils utilisent.

P. le Comité de Lecture
Le membre rapporteur,
chargé de la publication de la Revue.

In the previous publication (issue n°2) of the National Language Institute of the Royal Academy of Cambodia , only articles in relation to language problems have been published and we promised to include articles on Khmer literature in the next issues, because Khmer literature forms part of the object of study for our Institute. Up to this moment, we have received only one article in this domain for this issue and we regret very much for this situation.

We also promised to improve the quality of our Review and we hope that our readers will notice the difference between the issue n°2 and that of n°3. We wish to apologize to our readers for some shortcomings that occurred in the publication of the issue n°2 in June 2001.

We wish to remind our readers that theories and ideas in articles of this Review do not necessary reflect the philosophy of our Institute. It is the sole responsibility of its authors.

For the Reading Committee
The rapporteur, in charge of
the publication of this Review.

# សិលាចារឹកកម្ពុជា (សតវត្សទី៦ដល់ទី១៤) និងការអភិវឌ្ឍន៍សង្គមវប្បធម៌នៅតំបន់ភ្នំដងរែក

រៀបរៀង ដោយ បណ្ឌិត ឡុង សៀម[1]

តាមអត្ថាធិប្បាយរបស់លោក Etienne Aymonier នៅក្នុងសៀវភៅ (Cambodge,Tome II ឆ្នាំ ១៩០១) មានបញ្ជាក់ថា តំបន់ភ្នំដងរែកជាតំបន់ដ៏សំខាន់ ដែលបែងចែកទឹកដីប្រទេសកម្ពុជាសម័យបុរាណ នៅតំបន់ដីទំនាប ដែលមានបឹងទន្លេសាបជាមជ្ឈមណ្ឌលកំណត់នូវការរីកចំរើនខាងសេដ្ឋកិច្ច និងវប្បធម៌នៅទិសទក្សិណ ហើយនៅទិសឧត្តរ គឺជាតំបន់ដីគោក ដែលអាចលាតសន្ធឹងរហូតទៅដល់ទន្លេមូន ដែលជាដៃទន្លេមួយយ៉ាងធំ នៃទន្លេមេគង្គ។ នៅក្នុងភាសាខ្មែរទំនើប ភ្នំដងរែកមានន័យថា "ភ្នំដែលមានរាងវែងដូចដងរែក" ប៉ុន្តែ នៅក្នុងភាសាខ្មែរបុរាណ តាមសិលាចារឹកប្រាសាទខ្នា (K.660) គេប្រើពាក្យ វ្នំកំវេង Vnam Kamven ដែលមានន័យថា "ភ្នំកំពែង" គឺជានិយមន័យ ជានិមិត្តរូបបញ្ជាក់នូវការបែងចែកស្ថានភាពខាងភូមិសាស្ត្រនូវដែនដីខាងឧត្តរ និងខាងទក្សិណនៃភ្នំដងរែក។ ការហៅឈ្មោះបុរាណនៃប្រទេសកម្ពុជា ដែលបានត្រូវចែកជាពីរប្រភេទ គឺ ចេនឡាដីគោក និងចេនឡាលិចទឹក ក៏អាចកើតឡើងដោយសារឥទ្ធិពលនៃស្ថានភាពរបស់តំបន់ដីទំនាបដែលស្ថិតនៅខាងត្បូងភ្នំដងរែក និងដីគោកឬដីខ្ពស់ ដែលស្ថិតនៅខាងជើងភ្នំដងរែក ។

តាមដងភ្នំដងរែក តាំងពីប៉ែកខាងកើតរហូតដល់ប៉ែកខាងលិចនៃភ្នំ គេប្រទះឃើញស្ថានីយបុរេ-ប្រវត្តិសាស្ត្រ ដូចជា ស្ថានីយបុរេប្រវត្តិសាស្ត្រម្លូព្រៃដែលត្រូវបានសិក្សាដោយលោក Paul Levi និង ស្ថានីយបុរេប្រវត្តិសាស្ត្រភូមិស្នាយដែលត្រូវបានសិក្សានៅពេលថ្មីៗ ដោយសាស្ត្រាចារ្យមួយក្រុមនៃមហាវិទ្យាល័យបុរាណវិទ្យា នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈភ្នំពេញ ។

បន្ទាប់ពីស្ថានីយបុរេប្រវត្តិសាស្ត្រ ដូចមានចែងខាងលើ គឺមានស្ថានីយប្រវត្តិសាស្ត្រ នៅក្នុងសម័យបុរាណ ដែលយើងអាចចែកចេញជាស្ថានីយប្រវត្តិសាស្ត្រនាសម័យនគរភ្នំ ឬសម័យចេនឡា នាសតវត្សទី៧ ទី៨ (មានជាអាទិ៍ សិលាចារឹកប្រាសាទកំណើម សិលាចារឹកប្រាសាទព្រះអ្នកបួស សិលាចារឹកថមប្រាសាទ ហើយនៅប៉ែកខាងលិចនៃភ្នំដងរែក គេអាចរាប់ប្រាសាទខៅរាំង ប្រាសាទខៅណយ សិលាចារឹកប្រាសាទកំពែងញ៉ាយ ។

នៅសម័យអង្គរ គឺពីសតវត្សទី៩ ដល់ទី១៣ គឺនៅប៉ែកខាងជើង និងខាងកើតភ្នំដងរែកមានប្រាសាទ

---

[1]- សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ជាប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា និងជាសាស្ត្រាចារ្យភាសាវិទ្យា និង សិលាចារឹកវិទ្យា នៅមហាវិទ្យាល័យបុរាណវិទ្យា នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ភ្នំពេញ។

ម្លូព្រៃ ប្រាសាទខ្នា ហើយនិងប៉ែកខាងលិចមានប្រាសាទបន្ទាយឆ្មារ ប្រាសាទសង្កែកូន ប្រាសាទទួលរល់ទឹម ហើយនៅក្នុងចំនួនប្រាសាទទាំងនេះ គេក៏អាចបញ្ចូលប្រាសាទស្តុកកក់ធំផងដែរ។ នៅតាមប្រាសាទទាំងនេះ មានសិលាចារឹកសំខាន់ៗសរសេរជាភាសាសំស្ក្រឹត និងភាសាខ្មែរ នាសតវត្សចាប់ពីទី IX ដល់ទី XIII នៃគ្រិស្តសករាជ ។ ប៉ុន្តែនៅតាមជើងភ្នំដងរែក ដែលស្ថិតនៅទទឹងថ្ងៃ ទាំងនៅទិសខាងជើងក៏ដូចនៅទិសខាងត្បូងនៃភ្នំ ជាពិសេសនៅតាមដីទំនាបដែលលាតសន្ធឹងពីជើងភ្នំ មានប្រាសាទបុរាណសម័យអង្គរជាច្រើន ដែលពុំទាន់មានការស្រាវជ្រាវដ៏ល្អិតល្អន់ នេះគឺជាសម្តីរបស់លោក Aymonier ដែលមានចែងនៅក្នុងសៀវភៅរបស់គាត់។ ប៉ុន្តែ គេមិនអាចបំភ្លេចបានទេថា ស្ថានីយប្រវត្តិសាស្ត្រដ៏ធំសំបើម ហើយ ដែលស្ថិតនៅលើកំពូលដ៏ខ្ពស់នៃភ្នំដងរែក គឺប្រាសាទព្រះវិហារ ដែលនៅសម័យអង្គរមានឈ្មោះថា កំម្រតេងជគតស៊ីខារិស្វារៈ ។

នៅប្រាសាទព្រះវិហារមានសិលាចារឹកចំនួនប្រាំមួយដែលត្រូវចារឡើងនៅតាមផ្ទាំងសិលានៃច្រកចូល និងតាមសិលាស្តម្ភ ។ សិលាចារឹកទាំងនេះបានត្រូវចារឡើងនៅសម័យនៃអធិរាជអង្គរដ៏ធំពីរ គឺព្រះបាទសូរ្យវរ្ម័នទី១ នាសតវត្សទី១១ និងព្រះបាទ សូរ្យវរ្ម័នទី២ នាសតវត្សទី១២ ។

គឺនៅលើមូលដ្ឋាននៃឯកសារសិលាចារឹកទាំងឡាយ ដែលមានចារនៅលើប្រាសាទនានា ដែលមានពណ៌នាខាងលើ យើងនឹងសាកល្បងធ្វើវិភាគនិងអត្ថាធិប្បាយអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ សង្គមបរិយាកាស និងការត្រួសត្រាយទឹកដី នៅតំបន់ភ្នំដងរែក ដើម្បីកសាងប្រាសាទទាំងឡាយដែលមានតាំងពីប្រាសាទតូចៗ រហូតដល់ប្រាសាទធំមហិមា គឺប្រាសាទព្រះវិហារជាដើម និងដើម្បីកសាងភូមិស្ថាន ស្រុក និងខេត្តទាំងឡាយ ហើយការពណ៌នាអំពីការអភិវឌ្ឍន៍ យើងអាចចែកចេញជាពីរផ្នែក គឺសម័យមុនអង្គរ និងសម័យអង្គរ ។

ស្ថានភាពខាងវប្បធម៌នៃភ្នំដងរែកនៅសតវត្សទី៦-ទី៧ ប្រកបដោយការចាប់ផ្តើមស្ថាបត្យកម្មប្រាសាទឥដ្ឋតូចៗនានា តាមជើងភ្នំដងរែក និងការសាងសង់ជនបទ និងស្រុក។

តាមឯកសារសិលាចារឹកប្រាសាទ ហាន់ ជ័យ ខេត្តកំពង់ចាមសរសេរជាភាសាសំស្ក្រឹតនៅសតវត្សទី៦ មានការពណ៌នាអំពីព្រះបាទភវវរ្ម័នទី១ ដែលបានលើកទ័ពទៅច្បាំងពង្រីកទឹកដីប្រទេសចេនឡានៅទិសខាងជើង ដោយការធ្វើដំណើរដោយដីរ ហើយឆ្លងកាត់តាមព្រៃព្រឹក្សានិងដងភ្នំដ៏ធំៗ ដែលប្រកបដោយជ្រោះទឹកដ៏ជ្រៅទាំងឡាយ។ យើងអាចបញ្ជាក់បន្ថែមផងដែរថា ព្រះបាទភវវរ្ម័នទី១ជាចៅរបស់អធិរាជនគរភ្នំ (ហ្វូណន) ដែលបានឡើងសោយរាជនៅប្រទេសចេនឡា (ដែលមានរាជធានីស្ថិតនៅតំបន់វត្តភូចំប៉ាសាក់)។ តមក ព្រះអង្គបានធ្វើចម្បាំងបង្រួបបង្រួមប្រទេសចេនឡានិងប្រទេសហ្វូណន។ ព្រះអង្គបានកសាងរាជធានីមួយឈ្មោះភវបុរៈ នៅតំបន់សំបូរព្រៃគុក(ឥសានបុរៈ)នៅក្នុងខេត្តកំពង់ធំ ក្នុងភូមិភាគខាង

ឧត្តរនៃប្រទេស ហើយ ស្ថិតនៅមិនឆ្ងាយពីតំបន់ភ្នំដងរែក។ គឺប្រហែលព្រះអង្គបានចាប់ធ្វើដំណើរព្យុះហយាត្រាប្រយុទ្ធនានា ពីទីនេះទៅ ហើយឆ្លងកាត់តាមច្រកជ្រោះដ៏លំបាកលំបិននៃភ្នំដងរែករហូតដល់ទន្លេមូន។ ហើយ ប្រហែលជាយុទ្ធនាការកាន់កាប់ទឹកដីអនុវត្តដោយព្រះអង្គបានធ្វើដំណើរទៅដល់តំបន់ដ៏ឆ្ងាយ គឺដល់ទីក្រុងស៊ីទេព ទៀតផង។ ដោយហេតុថា នៅទីនេះគេបានរកឃើញសិលាចារឹកសតវត្សទី៦ ដែលមានចារជាភាសាសំស្ក្រឹតស្តីអំពីកិត្យានុភាពរបស់ព្រះអង្គ។ ហើយបើយោងទៅលើសិលាចារឹករបស់ព្រះបាទមហេន្ទ្រវរ្ម័ន ជាអតីតមហាសេនាកងពលរបស់ព្រះអង្គផង ជារាជអនុជរបស់ព្រះអង្គផងនោះ ឃើញថា សិលាចារឹករបស់ព្រះបាទមហេន្ទ្រវរ្ម័ន នាសម័យដើមសតវត្សទី៧ បានត្រូវចារឡើងនៅតំបន់សុរិន្ទ និងតំបន់ដទៃទៀតនៅលើទឹកដីដ៏ធំនៃប្រទេសចេនឡាបុរាណបែកខាងឧត្តរ។ តាមឯកសារសិលាចារឹករបស់ព្រះបាទមហេន្ទ្រវរ្ម័នទាំងឡាយ(ដែលបោះពុម្ពផ្សាយនៅក្នុងសៀវភៅសិលាចារឹកនៃប្រទេសថៃឡង់ ខ្សែទី៤) គឺរមែងមានសេចក្តីរំលឹកអំពីនាមរបស់ព្រះបាទភវវរ្ម័នជានិច្ចជាកាល ។

តាមការវិភាគឯកសារសិលាចារឹក ព្រះបាទភវវរ្ម័ន និងព្រះបាទមហេន្ទ្រវរ្ម័ន សាសនាដ៏សំខាន់ ដែលមានចារនៅទិសឧត្តរប្រទេស ដែលអ្នកស្រុកប្រកាន់យកនៅពេលនោះ គឺព្រាហ្មណ៍សាសនាដែលមានជានិមិត្តរូប គឺព្រះរូបសីវលិង្គ មានរូបឧសភៈ (គោបា) ដែលជាយានជំនិះរបស់ព្រះឥសូរ ។ ព្រះរូបសីវលិង្គគឺជានិមិត្តរូបនៃមហិទ្ធិឫទ្ធិរបស់ព្រះសីវា និងជានិមិត្តរូបនៃព្រះមហាក្សត្រដែលជាតំណែងអាទិទេពនៅលើផែនដី (តាមភាសាខ្មែរបុរាណ គឺវ្រះកម្រតាងអញ្ច្ចែកភោម) ជាសម័យដែលទើបនឹងមានការចាប់ផ្តើមការសាងសង់វត្តអារាមខាងព្រហ្មញ្ញសាសានាទាំងឡាយ ក៏ប៉ុន្តែតាមសិលាចារឹក ខៅរាំង ខៅណយ K.505 , K.506 ខាងដើមសតវត្សទី៧ គឺមានពណ៌នាអំពីពិធីសក្ការៈបូជា នូវការសាងសង់ព្រះវិហារខាងពុទ្ធសាសនាមហាយាន។ វត្តអារាមខាងព្រាហ្មណ៍សាសនាក្តី ខាងពុទ្ធសាសនាក្តី គេអាចចាត់ទុកថា ជាមជ្ឈមណ្ឌលអភិ-វឌ្ឍន៍ ខាងវប្បធមិ ខាងសេដ្ឋកិច្ចដ៏សំខាន់នៅសម័យនោះ ព្រោះថា វត្តអារាមទាំងនោះមានកម្មសិទ្ធិលើដីធ្លីដ៏ធំធេង មានភូមិ ស្រុក និងពុទ្ធបរិស័ទអ្នកជើងវត្តជាអ្នកបំពេញការងារគ្រប់យ៉ាង ដើម្បីផ្គត់ផ្គង់ជីវភាពបរិស័ទទាំងអស់ ដែលនៅក្នុងបណ្តាអ្នកទាំងនោះ គឺមានអាចារ្យបូជាព្រះ មានអ្នកប្រគុំដូរ្យជន្ត្រី មានអ្នកចំរៀងស្មូត្រ មានអ្នកសូត្រធម៌ជាដើម ។ នៅក្នុងសិលាចារឹកប្រាសាទវាលកន្ទេលនៅខេត្ត ទន្លេរពៅ ស្ថិតនៅប៉ែកអាគ្នេយ៍នៃភ្នំដងរែក មានការពណ៌នាអំពីសំណូត្រជាភាសាសំស្ក្រឹតនៃទេវកថា រឿងរាមាយណៈ និងមហាភារតៈជា អចិន្ត្រៃយ៍ ។

នៅសម័យអង្គរមានការរក្សានូវកេរដំណែលនៃតំបន់ទាំងឡាយ នៃប្រាសាទទាំងឡាយនៅជើងភ្នំដងរែក ហើយមិនតែប៉ុណ្ណោះមានការសាងសង់វត្តអារាម ប្រាសាទផ្សេងៗជាច្រើនកន្លែង ដូចមានចែងនៅខាងលើ។ តាមសិលាចារឹកនៃប្រាសាទរលំទឹម មានការពណ៌នាដ៏ក្បោះក្បាយអំពីរឿងក្តីក្តាំនៅតុលាការទាក់

ទងទៅនឹងបញ្ហាបំណុលនិងខ្ញុំបំរើ ។ ទាំងអស់នេះបញ្ជាក់ឱ្យយើងយល់ថា នៅតំបន់បែកខាងលិចនិងខាងត្បូងនៃភ្នំដងរែក មានប្រព័ន្ធតុលាការដ៏វែងមាំរួចទៅហើយ ។ គឺប្រព័ន្ធតុលាការនេះហើយដែលជួយពង្រីងការអភិវឌ្ឍន៍ខាងសង្គមកិច្ច និងសេដ្ឋកិច្ចរបស់តំបន់ ។

នៅក្នុងសិលាចារឹកមួយដ៏ធំ ( Ka.17 ) មាន១១៤បន្ទាត់ ហើយសរសេរជាភាសាខ្មែរ ជាសិលាចារឹកដែលមានឈ្មោះស្ថាននាម សូវេន លិង្គបុរៈ និងមធ្យទេសៈ ហើយជាហេតុធ្វើឱ្យយើងធ្វើការសន្និដ្ឋានថា ជាសិលាចារឹកដែលត្រូវបានចារនិងតំកល់ទុកនៅប្រាសាទមួយឈ្មោះ លិង្គបុរៈ ហើយដែលស្ថិតនៅតំបន់ភ្នំដងរែក។ សិលាចារឹកនេះបានបោះពុម្ពជាដំបូងដោយយើងខ្ញុំ នៅក្នុងទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា លេខ១ ឆ្នាំ២០០០។ គឺជាសិលាចារឹកដ៏សំខាន់ដែលផ្ដល់ពត៌មានខាងប្រវត្តិសាស្ត្រផងខាងជីវភាពសង្គមសេដ្ឋកិច្ចនៅតំបន់នោះផង នាឆ្នាំ៩៣៦ នៃមហាសករាជ ។ តាមសិលាចារឹកនេះគេអាចសន្មតបានថា ទោះបីជាព្រះបាទសូរ្យវរ្ម័នទី១ មានមរណៈនាមថា ជាព្រះបរមនិព្វានក្ដី ក៏មានព្រឹត្តិការណ៍ពិតជាក់ស្ដែង ព្រះអង្គមិនមែនពុទ្ធបរិស័ទទេ ក៏ប៉ុន្តែព្រះអង្គជាបរិស័ទខាងសិវនិយមយ៉ាងខ្ជាប់ខ្ជួនបំផុត ។

សិលាចារឹកស្ដុកកក់ធំ ដែលស្ថិតនៅប៉ែកខាងលិចនៃភ្នំដងរែក អាចចាត់ទុកថា ជាសិលាចារឹកដ៏វែងជាងគេ ហើយដែលផ្ដល់ពត៌មានខាងប្រវត្តិសាស្ត្រ ខាងជំនឿសាសនា ខាងការកសាង និងថែរក្សាប្រាសាទខាងការត្រួសត្រាយដីថ្មីៗ ដែលពីដើមពុំមែនជាស្រុក ពុំមែនជាស្រែនិងខាងជីវភាពវប្បធម៌ ។ គឺជាសិលាចារឹកចារដោយតំណាងមហាគ្រួសារមួយដែលបំរើព្រះមហាក្សត្រក្នុងពិធីសក្ការៈបូជាកម្រតេងជគតដ៏រាជា (ទេវរាជ) អស់រយៈពេល២៥០ឆ្នាំ គឺតាំងពីសម័យព្រះបាទជ័យវរ្ម័នទី២ រហូតដល់ព្រះបាទឧទ័យទិត្យាវរ្ម័នទី២។ តាមអត្ថបទសិលាចារឹកស្ដុកកក់ធំ គេអាចឃើញនូវការប្រឹងប្រែងព្យាយាមអភិវឌ្ឍន៍ផ្នែកខាងភាសាជាតិ គឺភាសាខ្មែរ ដែលនៅក្នុងនេះភាសាខ្មែរបានត្រូវគេប្រើប្រាស់ស្មើភាពទៅនឹងភាសាសំស្ក្រឹត ដើម្បីកត់ត្រាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ។

សិលាចារឹកទាំង៦ ដែលមានចារនៅប្រាសាទព្រះវិហារ ក៏អាចចាត់ទុកថា ជាសិលាចារឹកដ៏សំខាន់បំផុតដែលបញ្ចាំងឱ្យឃើញនូវព្រឹត្តិការណ៍ខាងប្រវត្តិសាស្ត្រដ៏សំខាន់ៗ គឺ ជាពិសេសមូលហេតុនៃការស្ថាបនាប្រាសាទព្រះវិហារនៅលើកំពូលភ្នំដងរែក ។ មូលហេតុនេះស្ថិតនៅលើសេចក្ដីប៉ងប្រាថ្នារបស់ព្រះបាទសូរ្យវរ្ម័នទី១ ដើម្បីផ្លាស់ប្ដូរទីកន្លែងនៃទេវស្ថាននៅវត្តភូ (ចំប៉ាសាក់) ឈ្មោះភទ្រេស្វរៈមកកំពូលភ្នំដងរែក ឬ ទេវស្ថានសិខរិស្វរៈ គឺប្រាសាទព្រះវិហារបច្ចុប្បន្ន។ យោងទៅលើជំនឿសាសនា មានសេចក្ដីបញ្ជាក់នៅក្នុងសិលាចារឹកថា (K.380 K.381, K.382) នៅពេលធ្វើវិបស្សនា ព្រះបាទសូរ្យវរ្ម័នទី១បានទតឃើញប្រត្យក្សនូវរូបរបស់អាទិទេព គឺព្រះឥស្វរប្រកបដោយតេជានុភាពប្រទូរភាវៈ (ដែលមានឈ្មោះថា សិខរិស្វរៈ "អាទិទេពនៃកំពូលភ្នំ") មកបង្គាប់បញ្ជាឱ្យផ្លាស់ប្ដូរទេវស្ថានរបស់ព្រះអង្គមកនៅលើកំពូលភ្នំដងរែកវិញ ឬ

មួយលើកំពូលភ្នំកំពែងវិញ(តាមសិលាចារឹក"ត្នំកំរេង") ហើយដែលលំនៅស្ថាននេះឈ្មោះថា កម្រតេងជគត ស្រីសិខរិស្វារៈ។

ដោយយោងទៅលើជំនឿអច្ឆរិយភាពខាងព្រហ្មញ្ញសាសនាបែបនេះដែលថា ប្រាសាទព្រះវិហារមានបារមីខ្លាំងក្លា បានជានៅពេលក្រោយមកមានចលនាក្រើនមហាជនដែលស្ថិតនៅក្នុងស្រទាប់សង្គមនានា និងនៅតាមភូមិស្រុកនិងខេត្តនានា ជាពិសេសនៅជើងភ្នំឱ្យធ្វើធម្មយាត្រាទៅធ្វើសម្បថ សម្តែងភក្តីភាពដ៏ស្មោះ-ស្ម័គ្រចំពោះព្រះកម្រតេងជគតស្រីសិខរិស្វារៈ ឰដ៏កំពូលភ្នំកំពែង។ តាមបង្គាប់បញ្ជារបស់ព្រះបាទសូរ្យវរ្ម័នទី១ គម្ពីរនិងលិខិតទាំងឡាយស្តីអំពីរាជវង្សានុវង្ស ជាសន្តតិវង្សរបស់មហាឥសីកម្ពុ បានត្រូវរក្សាទុកដោយវង្សត្រកូលរបស់ព្រះកំស្តែងសកម្មិនៅឯប្រាសាទព្រះវិហារជាចំណេរកាលតរៀងមក។ យោងតាមការវិភាគសិលាចារឹកនានាចារឡើងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ គេអាចសន្និដ្ឋានថា ព្រះអង្គជាស្ថាបត្យករដ៏ពិតប្រាកដនៃប្រាសាទព្រះវិហារ។ តាមសិលាចារឹកប្រាសាទព្រះវិហារ មហាព្រាហ្មណាចារ្យគឺ ធុលីជើងកម្រតេងអញស្រីទិវាករៈបណ្ឌិត ដែលបានធ្វើពិធីអភិសេកព្រះបាទសូរ្យវរ្ម័នទី២ ឱ្យឡើងគ្រងរាជសម្បត្តិនៅកម្ពុជទេស បានបន្តរបៀបរបបគ្រប់គ្រងប្រាសាទ ផ្តល់គ្រឿងឧបភោគ និងបរិភោគដ៏បរិបូរដល់ប្រាសាទ ភូមិ និងស្រុកទាំងឡាយ ដែលស្ថិតនៅជើងភ្នំជិតប្រាសាទព្រះវិហារ។ សិលាចារឹកដែលមានចារនៅប្រាសាទព្រះវិហារ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ ក៏អាចចាត់ទុកបានថា ជាឯកសារខាងប្រវត្តិសាស្ត្រដ៏សំខាន់បំផុតនៅសម័យអង្គរ ដោយហេតុថា តាមសិលាចារឹកប្រាសាទភ្នំសន្ដក និងប្រាសាទភ្នំព្រះវិហារ មានការឃើញច្បាស់ថា មហាព្រាហ្មណាចារ្យស្រីទិវាករៈបណ្ឌិតជាឥស្សរជនប្រវត្តិសាស្ត្រមួយរូប ដែលបានបំពេញតួនាទីជាព្រះរាជគ្រូ (ឬជាព្រះរាជកូលមហាមន្ត្រីមួយរូប)ដែលបានប្រារព្ធពិធីអភិសេកជាបន្តបន្ទាប់នូវព្រះមហាក្សត្រសម័យអង្គរបួនព្រះអង្គឱ្យឡើងគ្រប់គ្រងរាជសម្បត្តិជាបន្តបន្ទាប់ នៅរាជធានីអង្គរគឺព្រះបាទជ័យវរ្ម័នទី៦ ព្រះបាទធរណីន្ទ្រវរ្ម័ន ព្រះបាទសូរ្យវរ្ម័នទី២ និងព្រះបាទជ័យវរ្ម័នទី៧។

## គន្ថនិទ្ទេស


Au, Chhieng; (1966) Etude de Philologie indo-khmère III., L'indo-européen grow vu à travers le khmer; Etudes de philologie indo-khmère IV. Un changement de toponyme ordonné par Jayavarman III,- Journal Asiatique CCL. 4 p. 575-591.

Aymonier, M; (1904) Le Cambodge 3 Vol. Paris, 1900-1903

Barth, A; (1885) Inscriptions sanscrites du Cambodge, avec Atlas. Paris

Chuon, Nath; (1968-1969) Dictionnaire Cambodge. Phnom Penh

Coedès, G; (1937) Inscription du Cambodge, BEFEO, Vol. 1, Hanoi; (1942) Inscriptions du Cambodge, BEFEO, Vol 2, Hanoi; (1951) Inscriptions du Cambodge, BEFEO, Vol 3, Paris (1952) Inscriptions du Cambodge, Vol. 4, Paris; (1953) Inscriptions du Cambodge, BEFEO, Vol. 5, Paris (1954) Inscriptions du Cambodge, BEFEO, Vol. 6, Paris; (1964) Inscriptions du Cambodge, BEFEO, Vol. 7, Paris; (1966) Inscriptions du Cambodge, BEFEO, Vol. 7, Paris;

Coedès, G.; (1954) La stèle de Toul Rolum Tim; essai d'interprétation par la langue bahnar d'un texte juridique khmer du Xè siècle - JA, t.242, fasc. 1

Jacob, J.M.; (1978) The Ecology of Angkor. Evidence from the Khmer Inscriptions - Nature and Man in South- East Asia, London, p. 109-127.

Lajonquière, L.; (1902-1911) Inventaire descriptif des monuments du Cambodge, 3 Vol., Paris.

Levi, Paul; (1970) Thala Borivath ou Stun Tren, site de la capitale du souverain khmer Bhavavarman I er, Journal Asiatique, p. 114-129.

Lewitz. S; (1967) la toponymie khmère, BEFEO.t.LIII, fase.2, Paris, p. 378-450.

Long Seam; (1981) Contacts externes des langues Mon-Khmer, BEFEO, tome LXX, Paris, p/ 196-230.

Long Seam; (1989) Toponymes et réalités socio-économiques et culturelles de l'ancien Cambodge (d'après les textes des Inscriptions)- Premier Symposium franco-soviétique sur l'Asie du Sud-Est : "la réappropriation du patrimoine culturel dans le contexte du mouvement nationaliste et de la colonisation en Asie du Sud-Est, Moscou, p. 144-150.

Long Seam; (1994) Etudes de toponymie en ancien khmer, in cahiers d'études franco-Cambodgiens N2; édité par le Centre culturel et de coopération linguistique de l'Ambassade de France à Phnom Penh, 1994 ( 80 pages).

Long Seam; (2000) Dictionnaire du khmer ancien (d'après les inscriptions du Cambodge du VIe-VIIIe.siècles) Phnom Penh.

Martin Marie A; (1971) Introduction à l'Ethnobotanique du Cambodge, thèse pour le doctorat du 3 è. cycle, Paris.

Maspéro, G; (1925) la géographie politique de l'Indochine aux environs de 960 A.D. Etudes Asiatique t. 2; Paris.

Parmentier, M; (1916) Cartes de l'empire khmer d'après les situations des inscriptions datés, BEFEO, t. 16.3;

Parmentier, M; (1937) L'art Khmère primitif 2 Vol. Paris.

Pou, Saveros; (1992) Dictionnaire vieux Khmer-Français-Anglais, Paris;

# បញ្ហាប្រើប្រាស់ និង ឯកភាពភាសាជាតិ
# ក្នុងសង្គមកម្ពុជា នាពេលបច្ចុប្បន្ន

រៀបរៀង ដោយ បណ្ឌិត ស៊ុំ ឈុំប៊ុន

ក្នុងចំណោមបញ្ហាស្មុគ្រស្មាញជាច្រើន ដែលមាននៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ ការប្រើប្រាស់ភាសាខ្មែរ តាមការយល់ឃើញរៀង១ខ្លួន និង ការសរសេរដោយខ្វះឯកភាពគ្នានោះ ក៏ជាបញ្ហាមួយធំដែលកំពុងចោទឡើងដែរ។ អ្នកចេះដឹងខ្មែរពីរក្រុមបានចែកផ្លូវគ្នាដើរតាំងពីទសវត្សឆ្នាំ ១៩៦០មក មួយក្រុមជាអ្នកប្រពៃណីនិយម និង មួយក្រុមទៀតជាអ្នកទំនើបនិយម។

## យើងត្រូវតែហ៊ានទទួលស្គាល់ថា មានទំនាស់ក្នុងការប្រើប្រាស់ភាសាជាតិ !

សព្វថ្ងៃនេះ អ្នកប្រពៃណីនិយមពិនិត្យឃើញថា ក្នុងអក្ខរក្រមខ្មែរ មានព្យញ្ជនៈមួយចំនួនដែលគេលែងយកមកប្រើការដោយសារក្បួន"ទំនាញសូរ" ឯស្រៈពេញតួវិញត្រូវគេ "បញ្ឈរជើង" លែងយកមកប្រើការ[1]។ ក្រុមអ្នកទំនើបនិយមយល់ថា គេគួរកាត់បន្ថយភាពស្មុគ្រស្មាញក្នុងអក្ខរក្រមខ្មែរ ដោយកុំទុកឱ្យមានស្រៈ និងព្យញ្ជនៈច្រើនពេក ដើម្បីឱ្យកូនខ្មែរ និងជាពិសេសជនបរទេស មានការងាយស្រួលក្នុងការសិក្សា[2]។ ក្រុមទីពីរនេះក៏គិតយកឃ្លាប្រយោគខ្មែរទៅរៀបឱ្យដូចឃ្លាប្រយោគបារាំង ដូចជាពាក្យបំរាម"ហាមមិនឱ្យចូល" (ពាក្យចាស់) ត្រូវបានផ្លាស់មកជា"ហាមចូល" (ពាក្យថ្មី)ដោយគិតថា អវិជ្ជមានកម្មពីរជាប់គ្នា ក្នុងប្រយោគតែមួយ មានន័យវិជ្ជមានកម្ម[3]។

តាមការសង្កេតពេលថ្មី១កន្លងមកនេះឃើញថា និស្សិតដែលបានសិក្សាភាសាខ្មែរតាមបែបចាស់នៅប្រទេសក្រៅមួយចំនួន ពេលមកដល់ស្រុកខ្មែរមានការចំឡែកចិត្ត ដោយឃើញចរន្តទាំងពីរខាងលើនេះមានអត្ថិភាពនៅក្នុងប្រទេសតែមួយ និងនៅក្នុងចំណោមមនុស្សពីរ ឬ បីជំនាន់(ឪពុក កូន និង ចៅ) ដែលកំពុងរស់នៅជាមួយគ្នា។ អ្នកភាសាវិទ្យាបរទេសខ្លះពោលថា ដោយខ្មែរមិនអាចជំរុញការអភិវឌ្ឍន៍សង្គមបាននោះ គេចេះត្រឹមតែកកូរកកាយអ្វី១ដែលមានស្រាប់ហើយនោះ ឱ្យវិលវល់ ប៉ុណ្ណោះ។

ការខ្វះឯកភាព ក្នុងបញ្ហាភាសាសាស្ត្រជាតិនេះ បានចាប់ផ្ដើមតាំងពីមានការរៀបចំកម្មវិធី "ខេមរ-

---

(1) - ដូចជា ចំណោទ > ចំនោទ - សំណួរ > សំនួរ - អំណាច > អំនាច - ឫ > រឺ - ឱ្យ > អោយ - ឥឡូវ > អីលូវ។

(2) - ក្រុមទំនើបនិយមនេះទំនងបានទទួលឥទ្ធិពលពីភាសាបារាំងជាច្រើន ដូចជាចង់ឱ្យអក្ខរក្រមខ្មែរមានតិច ដូចភាសាបារាំងដែលមានត្រឹមតែ២៦តួ។

(3) - គេយល់ថា "ហាមមិនឱ្យចូល" = ឱ្យចូល (Double négation = Affirmation) - "ហាមចូល = មិនចូល"។

យានកម្ម" នៅមធ្យមសិក្សា នាពាក់កណ្ដាលទសវត្សឆ្នាំ ១៩៦០[4] ។ ភាសាបារាំង ដែលពីមុននេះជាភាសាយាន បានក្លាយមកជាជីវភាសា ដែលសិស្សភាគច្រើនលែងចង់សិក្សា។ សិស្សខេមរយានកម្មជំនាន់ទីមួយនៃមហាវិទ្យាល័យ បានចាប់ផ្ដើមនៅឆ្នាំសិក្សា ១៩៧៤-៧៥។ បញ្ហាពុំទាន់មានកម្មវិធីខេមរយានកម្មបន្តនៅឧត្តមសិក្សាឱ្យបានច្បាស់លាស់នេះធ្វើឱ្យនិសិត្សឆ្នាំទីមួយនៅជំនាន់នោះមានការលំបាក ដោយស្ដាប់ភាសាបារាំងមិនសូវយល់។

បញ្ហាមិនចុះសម្រុងក្នុងការប្រើប្រាស់ភាសាជាតិបានត្រូវបញ្ចប់ នៅពេលដែលប្រទេសកម្ពុជាយើងធ្លាក់ចូលទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(ប៉ុលពត)។

ក្រោយថ្ងៃ៧ មករា ក្រសួងអប់រំក៏បានរៀបចំដំណើរការខេមរយានកម្មនៅមធ្យមសិក្សាជាបន្តទៀត[5]។ មកដល់ឆ្នាំ១៩៨៧ ចលនាខេមរយានកម្មត្រូវបានជំរុញ រហូតដល់ថ្នាក់ឧត្តមសិក្សាជាលើកដំបូងក្នុងកម្មវិធីសិក្សានៅសកលវិទ្យាល័យភ្នំពេញ។ នៅពេលដែលចលនាខេមរយានកម្មបែបទំនើបនិយមកំពុងឈានទៅមុខនោះ ប្រតិកម្មពីក្រុមអ្នកប្រពៃណីនិយមក៏បានលេចឡើងជាថ្មីម្ដងទៀត ដូចកាលពីមុនឆ្នាំ ១៩៧០ ដែរ។ វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនៃក្រសួងអប់រំ ដែលមានភារកិច្ចអនុវត្តវិធីខេមរយានកម្មបន្តនោះ បានទទួលការរិះគន់យ៉ាងខ្លាំងក្លាពីវិទ្យាស្ថានសង្គមវិទ្យា នាពាក់កណ្ដាលទសវត្សឆ្នាំ ៨០។ វិទ្យាស្ថានសង្គមវិទ្យាបានចេញផ្សាយស្នាដៃមួយដែលមានចំណងជើងថា "មតិរិះគន់របស់អនុគណៈកម្មាធិការពិនិត្យ និង ស្រាវជ្រាវស្ដីអំពីការកែប្រែអក្ខរាវិរុទ្ធខ្មែរ[6]។ ស្នាដៃនេះបានរិះគន់ចំពោះបញ្ហាប្រើប្រាស់អក្ខរាវិរុទ្ធ និង បញ្ហាភាសាសាស្ត្រក្នុងសង្គមជាតិ ពិសេសក្នុងវិស័យអប់រំ។ នៅពេលនោះ មជ្ឈដ្ឋានធំទាំងពីរខាងលើបានរិះរកហេតុផលសមរម្យមកសំអាងរៀង១ខ្លួន។

បញ្ហាមិនចុះសម្រុងក្នុងការប្រើប្រាស់ភាសា និង ឯកភាពភាសាជាតិចេះតែប្រឈមជាប់ជាបន្តក្នុងមជ្ឈដ្ឋានសង្គមកម្ពុជា។ រហូតមកដល់សម័យកាលក្រោយការបោះឆ្នោតលើកទី១ ដែលរៀបចំដោយអង្គការសហប្រជាជាតិ(UNTAC 1993) បង្កើតបានជារាជរដ្ឋាភិបាលថ្មីហើយក៏ដោយ ក៏បញ្ហាទំនាស់នៃការប្រើប្រាស់ភាសា និង ឯកភាពក្នុងការសរសេរភាសាជាតិ នៅតែមានលក្ខណៈចម្រូងចម្រាស់រហូតដល់ករណីពាក្យខ្លះក្រសួងអប់រំ យុវជន និង កីឡាអនុញ្ញាតឱ្យសរសេរបានពីរបែប។

នៅពេលថ្មី១កន្លងមកនេះ ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សាបានពិចារណាលើបញ្ហាប្រើប្រាស់ភាសាជាតិផងដែរ។ ក្រុមនេះយល់ថា ត្រូវរៀបចំឱ្យមានគោលការណ៍ច្បាស់លាស់សំរាប់សរសេរ និង

---

[4] - កម្មវិធីខេមរយានកម្ម នៅមធ្យមសិក្សា បានចាប់ផ្ដើមចាប់ពីអនុវិទ្យាល័យ។

[5] - ក្រសួងអប់រំជាឈ្មោះដែលប្រើជាផ្លូវការនៅសម័យនោះ។

[6] - សូមអានស្នាដៃនេះដែលបោះពុម្ពលើកទី២ ឆ្នាំ១៩៨៧។

និយាយភាសាជាតិ។ ក្រុមការងារនេះក៏បានសំគាល់ថា ការប្រើប្រាស់ភាសាខ្មែរក្នុងវិស័យអប់រំនៅឧត្តមសិក្សាបានរីកចម្រើនទាទសវត្សឆ្នាំ ១៩៨០ ប៉ុន្តែ នៅក្នុងភាពប្រថុយប្រថាន និង មិនច្បាស់លាស់[7]។

រហូតមកដល់បច្ចុប្បន្ននេះ យើងនៅតែមិនទាន់អាចចាប់ផ្តើមដំណើរការដោះស្រាយបញ្ហានេះបាននៅឡើយ ហើយការប្រទាញប្រទង់គ្នានៅតែបន្តដំណើរទៅមុខយ៉ាងសកម្ម។

ភាពមិនចុះសម្រុង និង មិនឯកភាពក្នុងការប្រើប្រាស់ភាសាជាតិ ជាការឆ្លុះបញ្ចាំងមួយផ្នែកធំ នូវភាពមិនចុះសម្រុង និង ការមិនឯកភាពនៃប្រជាជាតិ។ ការឯកភាពភាសាជាតិរួមចំណែកក្នុងការឯកភាពជាតិ ស្ថេរភាពជាតិ និង អភិវឌ្ឍន៍សង្គម។ យើងចង់ឃើញ ចង់បានការឯកភាព និង ភាពជាធរមាន ក្នុងការប្រើប្រាស់ភាសាជាតិ គ្រប់មជ្ឈដ្ឋាន ក្នុងសង្គមជាតិ។

យើងកត់សំគាល់ឃើញថា ខ្វះឯកភាពក្នុងការប្រើប្រាស់ភាសាជាតិ នាំឱ្យបាត់ឯកភាពក្នុងស្មារតី ទាំងនៅក្នុងគ្រួសារ ទាំងនៅក្នុងសាលារៀន និង ក្នុងសង្គមជាតិ។ ជីតា ឬ ឪពុកដែលធ្លាប់សរសេរតាមរបៀបចាស់ កាលគាត់នៅសិក្សា អាចមានការមិនយល់ស្របនឹងកូនចៅ ដែលសរសេរតាមបែបថ្មី។ លោកគ្រូ ដែលកាន់របៀបទំនើបនិយម អាចមានការរំខានក្នុងចិត្ត បើមានកូនសិស្សណាសរសេរតាមបែបប្រពៃណីនិយម។ នៅក្នុងទំនាក់ទំនងសង្គមវិញ បើយើងនាំគ្នាជជែកលេងអំពីបញ្ហាភាសានេះ យើងតែងជួបប្រទះនូវនិន្នាការចាស់ និង ថ្មី មិនស្របគ្នាជាញឹកញាប់ ហើយជួនកាលបណ្តាលឱ្យមានការសៅហ្មងខាងផ្លូវចិត្តទៅវិញទៅមក ថែមទៀត។

យើងសង្កេតឃើញថា ឯកភាពខាងភាសាជាកត្តាចម្បងឈានទៅរកការអភិវឌ្ឍន៍សង្គម។ ប្រទេសអភិវឌ្ឍន៍ទាំងឡាយនាសម័យបច្ចុប្បន្ននេះ សុទ្ធសឹងតែមានឯកភាព និង ស្ថេរភាព ខាងភាសាជាតិរបស់ខ្លួនជាពិសេស ភាពមិនប្រែប្រួលខាងអក្ខរាវិរុទ្ធ អស់ពេលរាប់សតវត្សមកហើយ។ ដោយសារឯកភាព និង ស្ថេរភាពខាងភាសា ជាយូរមកហើយនេះ កូនចៅជំនាន់ក្រោយមិនបានបង្ខាតពេល ដើម្បីស្វែងយល់អំពីអក្ខរាវិរុទ្ធដែលសរសេរ ឬ បោះពុម្ពជាឯកសារពីសតវត្សមុនៗ។ គេមានការងាយស្រួលនឹងចាប់យកចំណេះដឹងពីដូនតាដែលជាមូលដ្ឋានគ្រឹះ សំរាប់ការអភិវឌ្ឍន៍សង្គមរបស់ខ្លួនប្រកបដោយនិរន្តភាព ក្នុងស្មារតីឯកភាពជាតិ ដ៏រឹងមាំជាបន្តទៅទៀត។

ដូនតាយើងបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការពង្រីក និង អភិវឌ្ឍន៍អក្សរសាស្ត្រជាតិ ភាសាជាតិ។ ប្រទេសកម្ពុជាជារដ្ឋដ៏ចំណាស់មួយនៅក្នុងអាស៊ីអាគ្នេយ៍នេះ។ សម័យអាណាចក្រភ្នំ( រវាង ពីស.វទី១-៦ នៃគ.ស) ជាសម័យដំបូងនៃប្រវត្តិសាស្ត្ររដ្ឋកម្ពុជា ដែលដូនតាយើងបានយកភាសាសំស្ក្រឹតមកប្រើ

---

[7] - សូមមើលផែនការសកម្មភាពជាតិ ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សានៃរាជរដ្ឋាភិបាល ១៥ មេសា ១៩៩៧ ភាគទី១ ទំព័រ៥៦។

ប្រាស់ជាផ្លូវការ។ បើសំអាងទៅលើសិលាចារឹកទាំងបួនផ្ទាំង ដែលគេរកឃើញរហូតដល់សព្វថ្ងៃ យើងឃើញថា ភាសាផ្លូវការនាសម័យនោះ គឺភាសាសំស្ក្រឹត[8]។ ភាសាខ្មែរនីយកម្ម(ខេមរយានកម្ម)បានពង្រឹង និងពង្រីកយ៉ាងខ្លាំងក្លានាសម័យអាណាចក្រចេនឡា(រវាង ពីស.វទី៦ ដល់ ស.វទី៩)។ ក្រៅពីភាសាសំស្ក្រឹតដែលបានប្រើតាំងពីដើមរៀងមក សិលាចារឹកវត្តផ្គាំ ខេត្តតាកែវ (K28)សរសេរជាភាសាខ្មែរ បញ្ជាក់ឱ្យយើងឃើញថា ភាសាខ្មែរបានឡើងឋានៈជាភាសាប្រកបដោយលាយលក្ខណ៍អក្សរ គឺនៅស.វទី៦ ហើយសិលាចារឹកនៅអង្គរបុរី(K600)មានកាលបរិច្ឆេទពិតប្រាកដនាឆ្នាំ៥៣៣ នៃមហាសករាជ(ត្រូវនឹងឆ្នាំ៦១១ គ.ស) គឺជាសិលាចារឹក ដែលមានលក្ខណៈជាឯកសាររដ្ឋការ ចារជាភាសាខ្មែរសុទ្ធសាធ[9]។ ការពង្រឹង និងពង្រីកភាសាខ្មែរនីយកម្ម ក៏ជាកត្តាមួយយ៉ាងសំខាន់រួមចំណែកក្នុងការពង្រីកអាណាចក្រចេនឡា និង ចក្រភពអង្គរផង។ ទោះបីជាសម័យអង្គរ សង្គមកម្ពុជានៅតែប្រើប្រាស់ភាសាសំស្ក្រឹត ជាផ្លូវការ ជាភាសាអ្នកប្រាជ្ញក៏ដោយ ក៏នៅក្នុងមជ្ឈដ្ឋានសង្គមជាន់ទាប និង ថ្នាក់មធ្យម ដូនតាយើងបានប្រើប្រាស់ភាសាខ្មែរយ៉ាងទូលំទូលាយ។ មានសិលាចារឹកជាច្រើនដែលបន្សល់ទុករហូតដល់សព្វថ្ងៃនេះសរសេរជាភាសាខ្មែរបុរាណ នៅទន្ទឹមនឹងសិលាចារឹកដែលចារជាភាសាសំស្ក្រឹត។ សិលាចារឹកជាភាសាខ្មែរមានចំនួនទាំងអស់ ៦១៩ អត្ថបទ។ សិលាចារឹកសម័យអង្គរ(គឺពី ស.វទី៩ ដល់ ស.វទី១៥)មានចំនួន៤៥៥អត្ថបទ[10] ដែលយើងបានស្រាវជ្រាវរកឃើញរហូតមកដល់បច្ចុប្បន្ននេះ។

ក្រោយសម័យអង្គរដ៏រុងរឿង រហូតមកដល់បច្ចុប្បន្នមានរយៈកាលជាង៥សតវត្សមកហើយ ដែលប្រទេសកម្ពុជាបានធ្លាក់ស្រុតថមថយឥទ្ធិពល ដោយត្រូវរងនូវការទន្ទ្រាន ឈ្លានពានឥតឈប់ឈរពីសំណាក់ជនបរទេស តែសង្គមខ្មែរទាំងមូលនៅតែអាចរក្សាបាន និងប្រើប្រាស់ភាសាខ្មែរជាសាកល។ ហើយ សូម្បីតែអតីតទឹកដីរបស់រដ្ឋកម្ពុជាយើង ដែលត្រូវបានជនបរទេសជិតខាងលេបត្របាក់យកទៅធ្វើជាអាណាខេត្តរបស់គេអស់រាប់សតវត្សហើយក៏ដោយ ក៏មនុស្សខ្មែរនៅទីនោះរាប់លាននាក់ នៅតែនិយាយ និង ប្រើប្រាស់ភាសាខ្មែរ ក្នុងជីវភាពប្រចាំថ្ងៃរហូតមកដល់សម័យបច្ចុប្បន្ននេះ។ ដូចជា នៅខេត្តសុរិន្ទ(ប្រទេសថៃ) នាបច្ចុប្បន្ននេះក៏ដោយ "បេក្ខជនអភិបាលខេត្តត្រូវមានល័ក្ខខ័ណ្ឌមួយ ដើម្បីឱ្យបានជាប់ឆ្នោតទៅជាចៅហ្វាយខេត្ត គឺត្រូវចេះនិយាយភាសាខ្មែរ"។ រីឯ នៅតំបន់កម្ពុជាក្រោមវិញ (បច្ចុប្បន្នជាប្រទេសវៀតណាមភាគខាងត្បូង) ខ្មែរក្រោមទាំង៤លានប្លាយនាក់និយាយភាសាខ្មែរ សរសេរភាសាខ្មែរ គោរពទំនៀមទំលាប់ប្រពៃណី

---

(8) - ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរភាគ១, ១៩៧៣ ទំព័រ ១០៤។

(9) - ឡុង សៀម, ស្ថាននាមវិទ្យាខ្មែរ, ១៩៩៧ ទំព័រគ- អារម្ភកថា។

(10) - ឡុង សៀម, ស្ថាននាមវិទ្យាខ្មែរ, ១៩៩៧ ទំព័រ ៧។

ខ្មែរ ..[11] ។

តាមរយៈឯកសារប្រវត្តិសាស្ត្របានបញ្ជាក់ថា ដូនតាខ្មែរយើងបានខិតខំចាក់ឫសបន្សល់ទុកនូវមរតកដ៏មានតម្លៃមិនអាចកាត់ថ្លៃបានជាច្រើន ដែលក្លាយទៅជាសម្បត្តិវប្បធម៌ដ៏ថ្លៃថ្លា បង្ហាញនូវមោទនភាពជាតិ និង អត្តសញ្ញាណជាតិយ៉ាងច្បាស់លាស់ ហើយក្នុងនោះក៏រួមមានទាំងមរតកភាសាខ្មែរដ៏ប្រពៃផងដែរ ។

ដូចនេះ តើយើងត្រូវអភិវឌ្ឍន៍ និង ពង្រីកភាសាជាតិយើងបែបណា ដើម្បីរក្សាបាននូវមរតកដូនតា ដើម្បីបញ្ចៀសនូវភាពមិនឯកភាពក្នុងការប្រើប្រាស់ភាសាជាតិ និង ដើម្បីអភិវឌ្ឍន៍ភាសាជាតិយើងឱ្យសមស្របនឹងល្បឿនវិវត្តន៍នៃសង្គម?

យើងសូមទទួលស្គាល់នូវការខិតខំរបស់បុព្វអ្នកអានអក្សរសាស្ត្រជាតិ និង រៀមច្បង អ្នកសិក្សាស្រាវជ្រាវផ្នែកភាសាសាស្ត្រជាតិ ដែលមានសមិទ្ធិគុណក្នុងការរួមចំណែក ពង្រីង និង អភិវឌ្ឍន៍ភាសាជាតិ។ យើងចង់ឃើញការចូលរួមចំណែកយ៉ាងសកម្ម និង មានប្រសិទ្ធភាពប្រកបដោយមនសិការជាតិ ពីសំណាក់អ្នកសិក្សាស្រាវជ្រាវ ផ្នែកភាសាសាស្ត្រចំពោះ បញ្ហាឯកភាព និង អភិវឌ្ឍន៍ភាសាជាតិ ។

យើងគប្បីរំលឹកថា ចាប់ពីឆ្នាំ ១៩១១មក គេឃើញមានការយកចិត្តទុកដាក់ចំពោះការសិក្សាភាសាខ្មែរ។ រាជបញ្ញត្តិមួយចុះ ថ្ងៃទី១០ វិច្ឆិកា ១៩១១ បានតម្រូវឱ្យកុមារាចាប់ពីអាយុ៨ឆ្នាំ ចូលសិក្សាដោយទៀងទាត់ នៅគ្រប់វត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះ សាលាវត្តកែប្រែថ្មី (Ecole de pagode rénovée) ដែលមានថ្នាក់រៀន កាលវិភាគ និង កម្មវិធីសិក្សាទៀងទាត់នោះ ត្រូវបានរៀបចំឡើងជាលើកដំបូងនៅខេត្តកំពង់ចាម (ឆ្នាំ ១៩០៨-១៩១៦)។ ដោយ ផ្អែកលើបទពិសោធន៍នៅកំពង់ចាម ខេត្តកំពតបានរៀបចំសាលាវត្តកែប្រែថ្មីចាប់ពីឆ្នាំ១៩២៤។ ផ្តើមពីជោគជ័យនៅខេត្តកំពត សាលាវត្តកែប្រែថ្មីត្រូវបានពង្រីកនៅលើផ្ទៃប្រទេស ចាប់ពីឆ្នាំ១៩៣០។ ភាសាខ្មែរជាភាសាតែមួយគត់ដែលយកមកប្រើប្រាស់ក្នុងការបង្រៀន[12] ។

ចាប់ពីចុងទសវត្សឆ្នាំ១៩៣០ តាមរយៈសាលាវត្ត ភាសាខ្មែរត្រូវបានផ្សព្វផ្សាយទៅដល់តំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។ ព្រះសង្ឃខ្មែរដែលជា"បេសកជន" ស្ម័គ្រចិត្តនិមន្តទៅបង្កើតសាលារៀននៅតំបន់ទាំងនោះ ដើម្បីបង្រៀនភាសាខ្មែរដល់ជនជាតិភាគតិចនានា ដូចជា ថៃនៅកោះកុង ឡាវ និង ថៃ

---

[11] - គីម សាអ៊ីល: ដែនដីកម្ពុជាក្រោម ១៩៧១ ទំព័រ ៧។

[12] - សូមមើល ស៊ន សំណាង : "បញ្ហាចោទនៅក្នុងសង្គមជាតិខ្មែរ និង ដំណោះស្រាយតាមរយៈចំណេះដឹងប្រវត្តិសាស្ត្រ" ក្នុងទស្សនាវដ្ដី អក្សរសាស្ត្រ-មនុស្សសាស្ត្រ ឆ្នាំទី១ ខែឧសភា ១៩៩៩ ទំព័រ ៩-១០។

នៅបាត់ដំបង សំរែ និង កួយនៅកំពង់ធំ ស្មៀង និង ភ្នងនៅក្រចេះ ជាដើម[13]។

ទន្ទឹមនឹងនេះ ភាសាខ្មែរត្រូវបានរៀបចំកែលំអឡើងវិញ តាមរយៈការបង្កើតគណៈកម្មការតាក់តែងវចនានុក្រម(Commission d'élaboration du dictionnaire) នៅឆ្នាំ ១៩១៥[14]។ វចនានុក្រមខ្មែរត្រូវបាននិពន្ធចប់នៅឆ្នាំ១៩៤៣[15]។ នៅពេលដែលការសម្រិតសម្រាំងពាក្យខ្មែរទើបតែរៀបចំរួច ស្រាប់តែលោក រ៉េស៊ីដង់ជាន់ខ្ពស់ ហ្សក ហ្គោទីយ៉េ(Georges Gautier)[16] ប៉ុនប៉ងកែប្រែអក្សរខ្មែរទៅជាអក្សរឡាតាំងវិញ។ ដោយការប៉ុនប៉ងនេះមិនបានសម្រេច អក្សរខ្មែរនៅមានជីវិតជារៀងរហូតមក។ ការរៀបចំលំអភាសានាពេលនេះបានប្រព្រឹត្តទៅអស់ពេលប្រហែលកន្លះសតវត្ស (១៩១៥-១៩៦៥)។ ពាក្យមួយចំនួនដែលប្រើកាលពីស.វទី១៩ និង ដើមស.វទី២០ ត្រូវបានកែសម្រួលឡើងវិញ ដូចជា :

| ប្រភពឯកសារពិគ្រោះ | | ពាក្យស័ព្ទចាស់ | | ថ្មី (ទសវត្សឆ្នាំ១៩៦០) |
|---|---|---|---|---|
| ក្រមទសភរិយា (៩ ឧសភា ១៨៩១) | (ទំព័រ២) : | កន្តាល | > | កណ្តាល |
| | (ទំព័រ៤) : | បន្តើរ | > | បណ្តើរ |
| | (ទំព័រ៥) : | អន្តាប់ | > | បណ្តាប់ |
| ក្រមទទួលបន្ទឹងកាត់បន្ទឹង (៩-៥-១៨៩១) | | បន្តឹង | > | បណ្តឹង |
| ក្រមព្រហ្មទណ្ឌខេមរៈ (ឆ្នាំ ១៩០៩) | (ទំព័រ១៤) : | អានាព្យាបាល | > | អាណាព្យាបាល |
| | (ទំព័រ២៣) : | កន្ទាល | > | កណ្តាល |
| | (ទំព័រ២៣) : | សន្ទោស | > | សណ្តោស ។ល។ |

នេះជាឧទាហរណ៍ខ្លះៗ ដែលបង្ហាញឱ្យឃើញថា អក្ខរាវិរុទ្ធក្នុងភាសាខ្មែរត្រូវបានកែលំអរួចទៅហើយ ដោយសេចក្តីព្យាយាមរបស់អ្នកចេះដឹងខ្មែរស្រករមុន ជាពិសេសសម្តេចសង្ឃរាជ ជួន ណាត។ នៅពេលដែលវចនានុក្រមរបស់ព្រះអង្គត្រូវបានរៀបចំចប់សព្វគ្រប់ និង បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នៅឆ្នាំ ១៩៦៧នោះ ស្រាប់តែមានចលនាមួយផ្សេងទៀតមកកែប្រែអក្ខរាវិរុទ្ធដែលនៅក្នុង

---

(13) - សូមមើល ស៊ន សំណាង : ការវិវត្តន៍នៃសង្គមកម្ពុជា នៅចន្លោះសង្គ្រាមលោកទាំងពីរលើក (១៩១៩-១៩៣៩) និក្ខេបបទថ្នាក់ប្រវត្តិសាស្ត្រ (ជាភាសាបារាំង) សាកលវិទ្យាល័យប៉ារីសទី៧ ឆ្នាំ១៩៩៩ ទំព័រ ២២៩-២៣០។

(14) - ស៊ន សំណាង : ការវិវត្តន៍នៃសង្គមកម្ពុជា នៅចន្លោះសង្គ្រាមលោកទាំងពីរលើក..... ទំព័រ ២៩២។

(15) - តាមរបាយការណ៍របស់អគ្គលេខាធិការនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ជូនលោករ៉េស៊ីដង់ជាន់ខ្ពស់បារាំង ចុះថ្ងៃទី០១ កញ្ញា ឆ្នាំ ១៩៤៣។

(16) - លោក ហ្សក ហ្គោទីយ៉េ ត្រូវបានតែងតាំងជារ៉េស៊ីដង់ជាន់ខ្ពស់នៅកម្ពុជា ដោយក្រឹត្រចុះថ្ងៃទី២ មិនា ១៩៤៣។

នោះពាក្យមួយចំនួនត្រូវសរសេរដូចកាលពីសតវត្សទី១៩ និងដើមសតវត្សទី២០វិញ ដូចជា អាណាព្យាបាល > អានាព្យាបាល ។

តើនេះជាទម្លាប់របស់ខ្មែរ ដែលមិនចង់សាងស្នាដៃបន្តពីអ្នកជំនាន់មុន ឬ យ៉ាងណា? បើគិតពីសម័យអង្គរមកដល់ចុងសម័យឧត្តុង្គ ខ្មែរបានផ្លាស់ទីតាំងរាជធានីជាច្រើនលើក សឹងតែមិនអាចចាំឈ្មោះអស់ ។

ភាពខ្វះខាតមួយក្នុងការបង្កើត ប្រើ នឹង វិនិច្ឆ័យពាក្យប្រកបទៅដោយឯកភាព របៀបរៀបរយហើយ និងមានដំណើរការទៀងទាត់តាមសេចក្តីត្រូវការរបស់សង្គមនោះ គឺការមិនបានបង្កើតអង្គការកណ្តាល "បណ្ឌិតសភា"(17) មួយ ដែលសហការប្រាស្រ័យទាក់ទងគ្នាជាឯកភាព និង របៀបរៀបរយជាមួយអង្គការសិក្សាស្រាវជ្រាវតាមជំនាញនិងអង្គការវប្បធម៌ផ្សេងៗ។ ភាពខ្វះខាតនេះជាការខ្វះចន្លោះដ៏ធំមួយលើបញ្ហាឯកភាព និង អភិវឌ្ឍន៍ភាសាជាតិ ដែលសង្គមជាតិខ្មែរយើងពុំអាចសំរេចបង្កើតបានជាមូលដ្ឋានចាប់តាំងពីប្រទេសកម្ពុជាទទួលឯករាជ្យពីបារាំងនាឆ្នាំ១៩៥៣ រហូតមកដល់បច្ចុប្បន្ន។ អង្គការកណ្តាលនេះត្រូវតែមានលក្ខណៈជាអង្គការជាតិ ដែលមានភារកិច្ចតាមផ្លូវការសំរាប់ចោទ ហើយដោះស្រាយបញ្ហាបង្កើត ប្រើ និង វិនិច្ឆ័យពាក្យ ដើម្បីសំរេចយកជាផ្លូវការ អង្គការបែបនេះច្រើនតែមានឈ្មោះហៅថា "បណ្ឌិតសភា" (Académie) ។

ដោយសារខ្វះអាជ្ញាធរផ្នែកភាសាដ៏រឹងមាំមានលក្ខណៈជាសកលនៅក្នុងមជ្ឈដ្ឋានសង្គមជាតិទាំងមូល ដូច្នេះហើយ ទើបសង្គមខ្មែរ ដែលដាច់ដាចដោយសារសង្គ្រាម និងមហាវិនាសកម្មអស់រយៈកាល ពាទសវត្សកន្លងមកនេះបានជួបប្រទះនូវភាពស្រអាប់ក្នុងបញ្ហាប្រើប្រាស់ និង ឯកភាពភាសាជាតិយ៉ាងខ្លាំង ។

គ្រាន់តែឧទាហរណ៍ដ៏ខ្លី តែក៏អាចមានន័យគួរបារម្ភ បានបង្ហាញនូវភាពអាណាធិបតេយ្យខាងការប្រើប្រាស់ និងឯកភាពភាសាជាតិ។ បច្ចុប្បន្ននេះយើងសង្កេតឃើញថា ក្នុងមជ្ឈដ្ឋានសង្គមខ្មែរ ចាប់តាំងពីសិស្សានុសិស្សរហូតដល់មន្ត្រីថ្នាក់ខ្ពស់ ឬ សេចក្តីថ្លែងការជាផ្លូវការ ភាគច្រើនបានប្រើប្រាស់ពាក្យ "មួយកោដិ" ស្មើនឹងចំនួន១០០០លានដែរ គឺគេទទួលយកដោយភ័ន្តច្រឡំ ដោយខុសច្បាប់ថា ពាក្យកោដិ = Milliard* = Billion* ។ តាមភាពជាធរមាន ពាក្យ "កោដិ" ស្មើនឹង១០លាន(18) ( ការរាប់ចំនួនរបស់ខ្មែរខុសពី

---

(17) - កេង វ៉ាន់សាក់ មូលភាពនៃការបង្កើតពាក្យថ្មី ១៩៦៤ ទំព័រ៦៣៧ ។

*- Milliard ( ពាក្យបារាំង) ស្មើ១០០កោដិ ( ១ ០០០ លាន) - សម ថាំង - វចនានុក្រមបារាំង-ខ្មែរ ១៩៩៦ ទំព័រ ៨០៧ ។

*- Billion ( ពាក្យអង់គ្លេស-អាមេរិកកាំង) ស្មើ១០០កោដិ ( ១ ០០០ លាន) -ច័ន្ទ វិទ្យា- វចនានុក្រមអង់គ្លេស-ខ្មែរ ១៩៩៧ ទំព័រ ៨៩ ។

(18) - ជួន ណាត វចនានុក្រមខ្មែរ ( បោះពុម្ពគ្រាទី៥) ទំព័រ៥១ ភាគ១ ។

ការរាប់ចំនួនរបស់បារាំង-អង់គ្លេស!)។ ហើយបច្ចុប្បន្ននេះ បើយើងពិនិត្យទៅតាមផ្លាកយីហោនានានៅទីក្រុងភ្នំពេញ គេសង្កេតឃើញថា ជាទូទៅពាក្យ"ផ្សារ[19]ដែក ផ្សារទ្វារ" ជាដើម គឺគេពុំសរសេរដាក់"រ" ឱ្យបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធខ្មែរទេ ភាគច្រើនគេសរសេរពាក្យ "ផ្សាដែក ផ្សាទ្វា"...។...។ នេះ គឺជាសញ្ញាស្រុតចុះនៃ ភាសា (និងវប្បធម៌) របស់ជាតិយើង។

ហើយក៏មាននមតិទំនើបជ្រុលមួយចំនួនចង់លុបបំបាត់និន្នាការ "ឫសពាក្យបាលី សំស្ក្រឹតនៅក្នុងភាសាខ្មែរ"ស្រេចតែតាមការគិតឃើញរបស់គេ។ មតិចង់លុបបំបាត់ឫសពាក្យ បាលី-សំស្ក្រឹត ចេញពីភាសាជាតិនោះ ដោយគេសំអាងទៅលើហេតុផលថា ភាសា បាលី-សំស្ក្រឹត ជាភាសាងាប់មិនអាចអភិវឌ្ឍន៍ ក្នុងការបង្កើតពាក្យថ្មីៗបាន សមស្របទៅតាមការរីកចំរើនរបស់សង្គមទេ។ ប៉ុន្តែបើយើងពិនិត្យទៅលើនិន្នាការអភិវឌ្ឍន៍ក្នុងការបង្កើតពាក្យថ្មីនៅលើសកលលោក គឺមានលក្ខណៈសំបូរបែប។ មានការបង្កើតពាក្យចេញពីមជ្ឈដ្ឋានទីផ្សារ ឬ ការបង្កើតពាក្យដោយខ្ចីពាក្យពីបរទេស ឬ ការបង្កើតពាក្យដោយយកឫសភាសា ដែលមានឥទ្ធិពលដ៏យូរយា នៅក្នុងភាសាជាតិខ្លួនជាដើម។ តែបញ្ហាជាសារវន្ត គឺការបង្កើតពាក្យប្រើ និង វិនិច្ឆ័យពាក្យពេចន៍ត្រូវតែទទួលការឯកភាពក្នុងក្របខ័ណ្ឌជាតិ និង មានលក្ខណៈជាធរមានច្បាស់លាស់។ ប្រទេសមួយចំនួននៅទ្វីបអឺរ៉ុប តែងបង្កើតពាក្យថ្មីៗមួយចំនួនតម្រូវតាមការអភិវឌ្ឍន៍នៃសង្គម និងវិស័យស្រាវជ្រាវ ដោយផ្អែកលើឫសគល់នៃភាសាឡាតាំង។ ប្រទេសនៅប៉ែកបូព៌ាមាន ចិន-ជប៉ុន,កូរ៉េ,ជាដើម តែងបង្កើតពាក្យថ្មីៗមួយចំនួន ទៅតាមតំរូវការនៃសង្គមជាតិគេ ដោយផ្អែកលើឫសគល់នៃភាសាហាន។ ប្រទេសនៅអាស៊ីអាគ្នេយ៍មួយចំនួនដូចជា ប្រទេសកម្ពុជា,ថៃ,ឡាវ... ភាសាដែលប្រើប្រាស់មួយចំនួន ជាពិសេសពាក្យវប្បធម៌ ភាគច្រើនតែងតែមានឫសគល់ចេញមកពីភាសា បាលី-សំស្ក្រឹត។ នេះ គឺជាក្រឹតក្រមនៃការអភិវឌ្ឍន៍ផ្នែកភាសាសាស្ត្រ មានលក្ខណៈសំបូរបែប ដែលយើងមិនអាចមិនទទួលស្គាល់។

យើងគាំទ្រ និង យល់ថា អង្គការកណ្តាលមួយជាអាជ្ញាធរជាតិខាងភាសា ត្រូវតែជាទីស្ថានស្រាវជ្រាវជាន់ខ្ពស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលផ្ទាល់ និង មានលទ្ធភាពបំពេញកាតព្វកិច្ចរបស់ខ្លួនយ៉ាងសកម្មដោយសហការ ឯកភាព ប្រកបដោយរបៀបរៀបរយជាមួយអង្គការសិក្សាស្រាវជ្រាវតាមជំនាញ និង អង្គការវប្បធម៌ផ្សេងៗ។ អង្គការបែបនេះបរទេសគេបានបង្កើតឡើងតាំងពីយូរយាណាស់មកហើយ រាប់ទាំងប្រទេសនៅជិតខាងរបស់យើងផង។

នៅប្រទេសថៃមានទីប្រជុំអ្នកប្រាជ្ញបែបនេះដែរ គេហៅថា រាជបណ្ឌិតស្ថាន[20]។ ឯប្រទេស

---

[19] - ជួន ណាត វចនានុក្រមខ្មែរ (បោះពុម្ពគ្រាទី៥) ទំព័រ៧១៦ ភាគ១។

[20] - អៀវ កើស ភាសាខ្មែរ ១៩៤៧ បោះពុម្ពឡើងវិញ ១៩៩២ ទំព័រ ២០។

វៀតណាមក៏មានវិទ្យាស្ថានជាតិមួយឈ្មោះ វិទ្យាស្ថានភាសា ឋិតក្នុងមជ្ឈមណ្ឌលជាតិនៃមនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គមវៀតណាម (National Center Social Sciences and Humanities of Viet Nam) ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលផ្ទាល់ ហើយមាននាទីជាទីស្ថាន បង្កើត ប្រើ និង វិនិច្ឆ័យភាសាជាតិដោយសហការនឹងផ្នែកជំនាញផ្សេងៗ។ នៅប្រទេសរុស្ស៊ី ក៏មានបណ្ឌិតសភាជាតិមួយ ដែលជាទីប្រជុំអ្នកប្រាជ្ញខាងភាសាវិទ្យា។ ហើយក្រុមនេះបានបំពេញការងារ ដែលជាមុខនាទីរបស់គេយ៉ាងហ្មត់ចត់ និង មានលក្ខណៈជានិរន្តភាព។ ឯនៅប្រទេសបារាំងវិញ ក៏មានទីប្រជុំអ្នកប្រាជ្ញខាងអក្សរសាស្ត្រមួយ សំរាប់ពិចារណា អារកាត់អំពីរឿងអក្សរសាស្ត្រ ដូចសាលាតុលាការជំនុំជំរះពីរឿងក្ដីផ្សេងៗ[21]។ ទីប្រជុំនេះមានឈ្មោះថា បណ្ឌិតសភាបារាំង (Académie française)[*] បង្កើតឡើងនៅឆ្នាំ ១៩៣៥ ដោយ រីសីលិយើ (Richelieu) ដែលមានសមាជិកបណ្ឌិតសភាពេញសិទ្ធិ ៤០រូប[22] បំពេញការងារក្នុងមុខនាទីជាប់ជាអចិន្ត្រៃយ៍។

រាល់អង្គការជាតិដែលពិចារណាការបង្កើតពាក្យ ប្រើ និង វិនិច្ឆ័យពាក្យពេចន៍ និង អភិវឌ្ឍន៍ភាសាជាតិ ដែលមានលក្ខណៈជាសកល តែងតែអនុវត្តទៅតាមនិតិវិធីយ៉ាងច្បាស់លាស់។

យើងសូមអំពាវនាវដល់អ្នកដឹកនាំជាតិ ដល់អ្នកស្រឡាញ់ភាសាជាតិ សូមគិតគូរដល់ប្រយោជន៍ជាតិ គិតគូរចំពោះភាសាជាតិ ដោយឧត្ដមគតិជាតិ និង ប្រកបដោយគតិបណ្ឌិតខ្ពស់។

វិបត្តិភាសាជាតិរបស់យើង តម្រូវឱ្យយើងជាខ្មែរខិតខំរកមធ្យោបាយដោះស្រាយជាបន្ទាន់បំផុត។ ការដោះស្រាយនេះនឹងត្រូវធ្វើប្រកបដោយវិចារណញ្ញាណ ដោយមិនទំលាក់កំហុសទៅលើនិន្នាការណាមួយនោះឡើយ ប៉ុន្តែគួរនាំគ្នាពិភាក្សាប្រមូលយកហេតុផលខាត និង ចំណេញ ចំពោះជាតិមកពិចារណាឱ្យបានល្អិតល្អន់ និង គ្រប់ជ្រុងជ្រោយ ក្នុងស្មារតីបង្រួបបង្រួមជាតិ។ លទ្ធផលដ៏ប្រពៃនៃដំណោះស្រាយនោះ គឺ ឯកភាពនៃអក្ខរាវិរុទ្ធក្នុងភាសាជាតិ ពោល គឺការសរសេរតាមរបៀបណាមួយឱ្យច្បាស់លាស់ ហើយចាប់ពីពេលនោះទៅ យើងមិនត្រូវអនុញ្ញាតឱ្យសរសេរស្រេចតែចិត្តដូចសព្វថ្ងៃនេះឡើយ។

នៅដើមអាណត្តិនៃរាជរដ្ឋាភិបាលសេដ្ឋកិច្ច យើងមានលទ្ធភាពរៀបចំបង្កើតរាជបណ្ឌិតសភាបានឡើងវិញ។ នេះជាឱកាសដ៏ប្រពៃមួយសំរាប់ប្រជាជាតិខ្មែរ ដើម្បីចាប់ផ្ដើមនូវកិច្ចប្រឹងប្រែងទាំងឡាយឆ្ពោះទៅរកការរៀបចំសណ្ដាប់ធ្នាប់ និង ឯកភាពនៃភាសាជាតិ ដែលជាការរួមវិភាគទានយ៉ាងសំខាន់ចំពោះការពង្រឹងសាមគ្គី និង ឯកភាពនៃប្រជាជាតិខ្មែរទាំងមូល។

---

(21) - អៀវ កើស ភាសាខ្មែរ ១៩៤៧ បោះពុម្ពឡើងវិញ ១៩៩២ ទំព័រ ១៩។

(*) - ការកំណត់ឈ្មោះអង្គការស្រាវជ្រាវនៃប្រទេសនីមួយៗមិនឯកភាពគ្នាទាំងស្រុងទេ។

(22) - ស៊ន សំណាង ទស្សនាវដ្ដីអក្សរសាស្ត្រ-មនុស្សសាស្ត្រ លេខ ខែមេសា-ឧសភា-មិថុនា ១៩៩៩ ទំព័រ១៨។

យើងសូមគាំទ្រចំពោះគំនិតផ្តួចផ្តើមរៀបចំសន្និសីទវិទ្យាសាស្ត្រថ្នាក់ជាតិមួយ ដើម្បីធ្វើការពិចារណាពិភាក្សាអំពីប្រធានបទ ឯកភាព និង អភិវឌ្ឍន៍ភាសាជាតិ ដោយធ្វើការអញ្ជើញអ្នកមានចំណេះដឹង អ្នកឯកទេសផ្នែកភាសាសាស្ត្រជាតិ និង អន្តរជាតិ មកចូលរួមជួយជាវិភាគទានក្នុងការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ សំរាប់ក្រោលដំណើរការសាងសង់ ការឯកភាពភាសាជាតិ ការប្រើប្រាស់ភាសាជាតិ និង អភិវឌ្ឍន៍ភាសាជាតិ ឆ្លងចូលសហស្សវត្សថ្មី ប្រកបដោយកិត្តិយស និង សមធម៌។

**ភាសារលត់ ជាតិរលាយ ភាសាចណ្ណរាយ ជាតិថ្កើងថ្កាន !**

x x
x

## គន្ថនិទ្ទេស


- កេង វ៉ាន់សាក់ - មូលភាពនៃការបង្កើតពាក្យថ្មី, ១៩៦៤
- គីម សារ៉ុល - ដែនដីកម្ពុជាក្រោម, ១៩៧១
- ជួន ណាត - វចនានុក្រមខ្មែរភាគ១-ភាគ២, បោះពុម្ពគ្រាទី៥
- ត្រឹង ងា - ប្រវត្តិសាស្ត្រខ្មែរ ភាគ១, ១៩៧៣
- រាជរដ្ឋាភិបាល - ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា-ផែនការសកម្មភាពជាតិ ១៥ មេសា ១៩៩៧ ភាគ១
- វិទ្យាស្ថានសង្គមវិទ្យា - មតិរិះគន់របស់អនុគណៈកម្មាធិការពិនិត្យស្រាវជ្រាវស្តីពីការកែប្រែអក្ខរាវិរុទ្ធខ្មែរ, បោះពុម្ពលើកទី២ ឆ្នាំ ១៩៨៧
- ស៊ន សំណាង - អត្ថន័យជាប្រវត្តិសាស្ត្រ និង អត្ថប្រយោជន៍នៃការបង្កើតរាជបណ្ឌិតសភាឡើងវិញ, ទស្សនាវដ្តីអក្សរសាស្ត្រ-មនុស្សសាស្ត្រ ខែមេសា-ឧសភា-មិថុនា ១៩៩៩
- ឡុង សៀម - ស្ថាននាមវិទ្យាខ្មែរ, ១៩៩៧
- អៀវ កើស - ភាសាវិទ្យាខ្មែរ, ១៩៤៧, បោះពុម្ពឡើងវិញ ឆ្នាំ ១៩៩២

# ការប្រើប្រាស់ភាសានៅតំបន់អន្លង់វែង

សិក្សាស្រាវជ្រាវដោយ ក្រុមនិស្សិតភាសាវិទ្យាជំនាន់ទី១ នៃ រាជបណ្ឌិតសភាកម្ពុជា

**សេចក្តីផ្តើម :**

ចាប់ពីថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០១ រហូតដល់ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០១ និស្សិតបរិញ្ញាប័ត្រជាន់ខ្ពស់ ជំនាន់ទី១ នៃរាជបណ្ឌិតសភាកម្ពុជា បានធ្វើដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវនៅតំបន់ភូមិភាគខាងជើងនៃប្រទេសកម្ពុជា មានតំបន់ប្រាសាទបុរាណ នៅក្នុងខេត្តសៀមរាប និងតំបន់អន្លង់វែង ។ ទិសដៅសំខាន់នៃដំណើរសិក្សាស្រាវជ្រាវនេះ គឺសិក្សាស្វែងយល់ពីស្ថានភាព ការអភិវឌ្ឍនៅតំបន់អន្លង់វែង ដែលជាតំបន់ធ្វើសមាហរណកម្មចុងក្រោយបង្អស់ជាមួយរាជរដ្ឋាភិបាល ពីសំណាក់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ។ ដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវនេះ រៀបចំឡើងដោយរាជបណ្ឌិតសភាកម្ពុជា ក្រោមការឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ។

ក្នុងចំណោមនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី១ ទាំង១០មុខវិជ្ជា ដែលស្ថិតក្រោមការដឹកនាំរបស់សាស្ត្រាចារ្យ និងថ្នាក់ដឹកនាំរបស់រាជបណ្ឌិតសភាកម្ពុជា និស្សិតផ្នែកភាសាវិទ្យា ក៏បានចូលរួមក្នុងទស្សនកិច្ចសិក្សាស្វែងយល់ពីស្ថានភាពតំបន់អន្លង់វែងនេះផងដែរ ។ ការសិក្សាស្រាវជ្រាវរបស់និស្សិតភាសាវិទ្យា គឺផ្តោតទៅលើការប្រើប្រាស់ភាសា នៅក្នុងតំបន់អន្លង់វែង ដោយយកគម្រោងសម្ភាសន៍សង្គមភាសារបស់បណ្ឌិត ព្រុំ ម៉ល់ និងគម្រោងស្រាវជ្រាវផ្នែកភាសាវិទ្យារបស់បណ្ឌិត រស់ ចន្ត្រាបុត្រ ដែលរៀបចំឡើង សំរាប់ជាជំនួយក្នុងការស្រាវជ្រាវនេះមកធ្វើជាគោល ។ ការស្រាវជ្រាវនេះឈរលើមូលដ្ឋាននៃសង្គមភាសាវិទ្យា ដែលហៅថា "រយៈត្រិះ ឬ Diaschise" ដែលចែកចេញជា រយៈក្រុម រយៈកាល រយៈតំបន់ ។ បំណងនៃការស្រាវជ្រាវ គឺចង់ដឹងថា តើប្រជាជនដែលរស់នៅក្នុងតំបន់នេះប្រើប្រាស់ភាសាខុសប្លែកពីភាសាកណ្តាល (ភាសាស្តង់ដារ) យ៉ាងណាខ្លះ ? ក្រៅពីនេះយើងក៏ស្វែងយល់ផងដែរថាតើប្រជាជននៅក្នុងតំបន់នេះមានប្រើភាសាអ្វីក្រៅពីភាសាខ្មែរដែរឬទេ ? តើភាសាបរទេសដែលមានព្រំប្រទល់ជាប់គ្នាមានឥទ្ធិពលទៅលើការប្រើប្រាស់ភាសាប្រចាំថ្ងៃរបស់ប្រជាជនដែរឬយ៉ាងណា ? តើការបន្លឺសំឡេងរបស់ប្រជាជននៅទីនោះមានការខុសប្លែកពីភាសាកណ្តាលដូចម្តេចខ្លះ ? តើប្រជាជនមានប្រើវាក្យស័ព្ទប្លែកពីភាសាកណ្តាលដែរឬទេ ? ។

ដើម្បីស្វែងយល់ពីស្ថានភាព និងការប្រើប្រាស់ភាសានៅតំបន់អន្លង់វែង យើងក៏គប្បីស្វែងយល់ពីស្ថានភាពទូទៅនៅតំបន់នេះផងដែរ ។

អន្លង់វែងជាតំបន់មួយស្ថិតនៅភាគខាងជើង នៃប្រទេសកម្ពុជា ជាប់ភ្នំដងរែក( ព្រំប្រទល់ ខ្មែរ-ថៃ) ចម្ងាយ ១៣៤គ.ម ពីទីរួមខេត្តសៀមរាប តាមផ្លូវលេខ ៦៧ ដែលមានស្ថានភាពព្រៃក្រាស់នៃតំបន់ព្រៃ

ភ្នំ ។ តំបន់នេះធ្លាប់ជាតំបន់ដែលកាន់កាប់ដោយកងកម្លាំងតស៊ូកម្ពុជាប្រជាធិបតេយ្យ ហើយជាតំបន់ចុងក្រោយដែលបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល។ ក្រោយពេលធ្វើសមាហរណកម្ម តំបន់អន្លង់វែងបានក្លាយជាស្រុកមួយក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តឧត្តរមានជ័យ ។ ស្រុកនេះមាន ៥ឃុំ គឺ ឃុំអន្លង់វែង ឃុំថ្លាត ឃុំលំទង ឃុំត្រពាំងតាវ និងឃុំត្រពាំងប្រីយ៍ ។ អន្លង់វែង គឺជាទឹកដីដែលគ្របដណ្ដប់ដោយព្រៃក្រាស់នៃជួរភ្នំដងរែក ។ ទីតាំងដែលនិស្សិតភាសាវិទ្យាបានចុះទៅដល់ដើម្បីធ្វើសម្ភាសន៍ស្រាវជ្រាវ ក្រៅពីទីប្រជុំជនស្រុក គឺមានភូមិមួយចំនួនទៀត ដែលស្ថិតនៅក្នុងព្រៃ ដូចជាភូមិអូរគគីរក្រោម ក្នុងឃុំលំទង ចម្ងាយ ៧ គ.ម. ខាងត្បូងឆៀងខាងលិចទីប្រជុំជនស្រុកភូមិសន្តិភាព ( ឬភូមិចំការចេក ) ចម្ងាយប្រហែល ៦ គ.ម. ខាងជើងឆៀងខាងកើត ទីប្រជុំជនស្រុក ស្ថិតនៅក្នុងឃុំត្រពាំងប្រីយ៍ និង ភូមិ ១០៥ ចម្ងាយប្រហែល ១៨ គ.ម. ពីទីប្រជុំជនស្រុក ស្ថិតក្នុងឃុំត្រពាំងប្រីយ៍ដែរ ។

ស្រុកអន្លង់វែងមានប្រជាជនជាង៤០០០គ្រួសារ (បួនពាន់គ្រួសារ) ត្រូវជាជាង៤០០០០ (បួនម៉ឺននាក់)។ ប្រជាជនភាគច្រើន ដែលរស់នៅតំបន់អន្លង់វែង គឺជាអតីតយុទ្ធជនដែលបានចូលរួមក្នុងចលនាតស៊ូកម្ពុជាប្រជាធិបតេយ្យដែលមួយចំនួនបានត្រឡប់មករស់នៅក្នុងជីវភាពជាប្រជាជនស៊ីវិលវិញ ក្រោយពេលធ្វើសមាហរណកម្ម ។ ប្រជាជនភាគច្រើនពុំមែនជាអ្នកដែលមានកំណើតនៅក្នុងតំបន់នេះឡើយ គឺជាអ្នកមានដើមកំណើតពីខេត្តផ្សេងៗ ដូចជា ខេត្តតាកែវ កំពត ព្រៃវែង កំពង់ធំ និងខេត្តកំពង់ចាម ដែលបានទៅរស់នៅធ្វើជាយុទ្ធជន ឬជនស៊ីវិល តាំងពីឆ្នាំ ១៩៧៨ ឬ ឆ្នាំ១៩៧៩ មកម្លេះ ។ ប្រជាជន ដែលរស់នៅក្នុងទីប្រជុំជនស្រុក ភាគច្រើនជាអ្នកចំណូលស្រុកដែលទើបតែទៅរស់នៅ ក្រោយពេលបញ្ចប់សង្គ្រាម ។ ក្រៅពីប្រជាជនចំណូលស្រុក ក៏នៅមានប្រជាជនដែលមានដើមកំណើតនៅក្នុងតំបន់ គឺជាជនជាតិភាគតិច ដូចជា កួយ កាវ៉ែត ចារ៉ាយ គ្រឹង ទំពួន ហើយក៏មានជនជាតិលាវផងដែរ ដែលរស់នៅតាមភូមិក្នុងព្រៃក្រាស់ ។ ភូមិដែលមានជនជាតិភាគតិចរស់នៅច្រើន គឺភូមិ ១០៥ ឃុំត្រពាំងប្រីយ៍ ដែលនៅទីនោះក្រៅពីភាសាខ្មែរប្រជាជនជនជាតិភាគតិច ក៏បានប្រើប្រាស់ជាភាសាកំណើតរបស់ខ្លួន ភាសាជនជាតិក្នុងទំនាក់ទំនងប្រចាំថ្ងៃផងដែរ ។

គួររំលឹកដែរថា ប្រជាជនដែលរស់នៅតំបន់អន្លង់វែង តាំងពីមុនបញ្ចប់សង្គ្រាម តែងមានទំនាក់ទំនងជាមួយជនជាតិថៃ ព្រោះថា ជាញឹកញាប់ពេលមានការប្រយុទ្ធគ្នារវាងកងកម្លាំងរដ្ឋាភិបាល និងកងកម្លាំងតស៊ូកម្ពុជាប្រជាធិបតេយ្យ ប្រជាជនស៊ីវិល និងយុទ្ធជន តែងតែភៀសខ្លួនឡើងលើភ្នំដងរែកទៅរស់នៅទល់ដែនកម្ពុជា- ថៃ ជួនកាលអាចចូលទៅរស់នៅក្នុងទឹកដីថៃទៀតផង ។ ការប្រាស្រ័យទាក់ទងជាមួយជនជាតិថៃញឹកញាប់ ធ្វើឱ្យប្រជាជនមួយចំនួនធំអាចធ្វើទំនាក់ទំនងជាភាសាថៃបាន ។

តទៅនេះ យើងនឹងសិក្សាពិនិត្យមើលអំពីការប្រើប្រាស់ភាសារបស់ប្រជាជននៅតំបន់អន្លង់វែងដូចតទៅ :

## ជំពូកទី១

## បម្រែបម្រួលសូរស្រៈ ព្យញ្ជនៈ វាក្យស័ព្ទ និង ទិដ្ឋភាពប្លែកៗមួយចំនួន នៃភាសានៅភូមិល្បាយប្រជាជន និង ភូមិជនជាតិភាគតិច

ឆ្លងតាមការសម្ភាសន៍ជាមួយប្រជាជន យើងសង្កេតឃើញថា ការប្រើប្រាស់ភាសានៅតំបន់អន្លង់វែងនេះមានលក្ខណៈខុសប្លែកពីភាសាកណ្ដាលលើបញ្ហាមួយចំនួន ។ ក៏ប៉ុន្តែ ក្នុងការប្រើប្រាស់ដែលមានលក្ខណៈខុសប្លែកគ្នានេះមិនមែនបានសេចក្ដីថា យើងនិយាយស្ដាប់គ្នាពុំបាននោះទេ គឺថាយើងអាចធ្វើការទាក់ទងគ្នាបាន ស្ដាប់គ្នាបានទៅវិញទៅមក ដោយគ្រាន់តែការបញ្ចេញសំឡេងរបស់ប្រជាជននៅតំបន់នោះមានលក្ខណៈផ្សេងពីភាសាកណ្ដាល តែប៉ុណ្ណោះ ។

តាមរយៈពាក្យសម្ដី និងសូរសំឡេងប្រជាជននៅតំបន់អន្លង់វែង យើងអាចធ្វើការកត់សម្គាល់ឃើញថា ការបញ្ចេញសំឡេងរបស់ប្រជាពលរដ្ឋនៅតំបន់នោះមានភាពប្រែប្រួលនៅលើ សូរស្រៈ ការផ្លាស់ប្ដូរព្យញ្ជនៈ និង មានការប្រើប្រាស់ពាក្យខ្លះនៃភាសាខ្មែរស្ដង់ដារក្នុងន័យផ្សេងតិចតួច ឬផ្សេងទាំងស្រុង ។ ហេតុដូច្នេះហើយទើបយើងអាចធ្វើការសិក្សាវិភាគ បកស្រាយ ទៅលើចំណុចខ្លះ ដែលយើងបានប្រមូលទិន្នន័យពីការធ្វើបទសម្ភាសន៍ជាមួយពួកគាត់[១] ដូចតទៅ :

### ១. សូរស័ព្ទ

ចំពោះបញ្ហាសូរស័ព្ទរបស់ប្រជាជននៅតំបន់នេះ យើងឃើញថា ការបញ្ចេញសំឡេងមានលក្ខណៈរដឹនបន្តិច តែភាពរដឹនរបស់គាត់មានលក្ខណៈពីរោះ ពាក្យសម្ដីទន់ភ្លន់ ដែលគួរឱ្យយើងចង់ស្ដាប់ ចង់សាសងជាមួយគ្នា។ ការបញ្ចេញសូរស័ព្ទនេះយើងអាចកត់សម្គាល់ឃើញថា មានការប្រែប្រួលសូរស្រៈ និងព្យញ្ជនៈ។

### ១.១- ការផ្លាស់ប្ដូរសូរស្រៈ :

#### ១.១.១- ការផ្លាស់ប្ដូរសូរស្រៈនៅភូមិល្បាយប្រជាជន :

តាមការសម្ភាសន៍យើងឃើញថា សំឡេងស្រៈមួយចំនួនមានការផ្លាស់ប្ដូរក្នុងការបន្លឺសំឡេងរបស់គាត់ ។ យើងនឹងលើកយកបញ្ហាផ្លាស់ប្ដូរសូរស្រៈមកធ្វើការវិភាគមួយៗ ដូចខាងក្រោមនេះ :

---

១. ឈ្មោះលោកអ៊ំ សាត់ យី និងបងប្រុស ឈ្មោះ ធឿង ថាវ ព្រមទាំងភរិយា នៅភូមិអូរគគីរក្រោម ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ និង តំបន់១០៥ . ភូមិសន្តិភាព ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ ។

**១.១.១.១- ការផ្លាស់ប្ដូរស្រៈ " ែ " ទៅជាស្រៈ " េ " :**

វាក្យស័ព្ទជាច្រើនដែលបានប្រើប្រាស់ស្រៈ " ែ " ដែលប្រើប្រកបជាមួយព្យញ្ជនៈ ដើម្បីបង្កើតពាក្យឱ្យមានអត្ថន័យគ្រប់គ្រាន់ក្នុងការសម្គាល់បញ្ញត្តិ មនុស្ស សត្វ វត្ថុអ្វីមួយនោះ តែចំពោះប្រជាជននៅតំន់នេះ សូរសំឡេងរបស់គាត់មានការផ្លាស់ប្ដូរគ្នាពីស្រៈ " ែ " ក្លាយទៅជាស្រៈ " េ " ទាំងអស់ ដូចមានអំណះអំណាងមួយចំនួន ខាងក្រោមនេះ :

ឧទាហរណ៍ :

- ម៉ែ /maɛ/ ដែលជាស្រៈផ្សំក្លាយទៅជា មេ /me: / ស្រៈ អ៊េ / e: / ដែលជាស្រៈទោល ហើយជាស្រៈមុខ ។
- ស្រែ / sraɛ/ > ស្រេ /chre:/
- ឆ្កែ /chkaɛ/ > ឆ្កេ /chre:/
- ត្របែក /trɑ:baɛk/ > ត្របេក / trɑ:be:k /
- ប្រឡែង /prɑ:laɛŋ/ > ប្រឡេង / prɑ:le:ŋ/
- កន្សែង /kɑnsaɛŋ/ > កន្សេង /kɑnse:ŋ/
- សែង /saɛŋ/ > សេង /se:ŋ/
- ចំបែង /cɑmbaɛŋ/ > ចំបេង /cɑmbe:ŋ/
- សំដែង /sɑmdaɛŋ/ > សំដេង /sɑmde:ŋ/
- កែប / kaɛp/ > កេប /ke:p/
- ឆ្អែត /chʃsɛt/ > ឆ្អេត /chʃe:t /
- ខែត្រ . ខេត្ត /khaɛt/ > ខេត្ត /khe:t /
- ហែក /ha kɛ/ > ហេក /he:k/
- ផ្អែម /phʃaɛm/ > ផ្អេម /phʃe:m/

... និងមានពាក្យជាច្រើនទៀតដោយយើងពុំបានលើកយកមកធ្វើជាឧទាហរណ៍ ដែលភាសាស្តង់ដារប្រើស្រៈអែ " ែ " ហើយភាសានៅតំបន់អន្លង់វែងប្រើផ្លាស់ប្ដូរជាស្រៈអេ " េ " ។

**១.១.១.២- ការផ្លាស់ប្ដូរស្រៈ អើ " ើ " ទៅជាស្រៈអឺ " ឺ "**

យើងឃើញថា ពាក្យមួយចំនួនធំក្នុងការប្រើប្រាស់ស្រៈ អើ " ើ " នេះក៏មានការប្រែប្រួលដែរ ។

ឧទាហរណ៍ :

- ដើរ /daə/ > ដឺរ /dɯ:/

- ដើម /daəm/ > ដឺម /dɯːm/
- ថើប /thaəp/ > ថឺប /thɯːp/
- កើប /kaəp/ > កឺប /kɯːp/
- បើក /baək/ > បឺក /bɯːk/
- សើច /saəc/ > សឺច /sɯːc/
- ហើម /haəm/ > ហឺម /hɯːm/
- សើម /saəm/ > សឺម /sɯːm /
- កើន /kaən/ > កឺន /kɯːn/
- កើត /kaət/ > កឺត /kɯːt/
- អើត /aət/ > អឺត /ɯːt/
- ច្រើន /craən / > ច្រឺន /crɯːn/
- ល្បើក /lbaək/ > ល្បឺក /lbɯːk/
- ឆ្នើម /chnaəm/ > ឆ្នឺម /chnɯːm /

.......នឹងនៅមានពាក្យជាច្រើនទៀត ដែលយើងពុំបានលើកយកមកអធិប្បាយអោយអស់ឡើយ ពីព្រោះវាក្យស័ព្ទមានច្រើនលើសលប់ ។

**១.១.១.៣- ការផ្លាស់ប្តូរស្រះអឿ "ៀ-ឿ" ដែលជាស្រះផ្សំប្តូរទៅជាស្រះអឺ "ឺ" ជាស្រះកណ្តាលហើយជាស្រះទោល :**

ឧទាហរណ៍ :

- រឿង /rɯəŋ/ > រ៉ឺង /rɯːŋ/
- នឿយ /nɯəːj/ > នឺយ /nɯːj/
- រឿយ /rɯəj / > រ៉ឺយ /rɯːj/
- ភឿន /phɯən/ > ភឺន /phɯːn/
- ក្បឿង /kbɯəŋ/ > ក្បឺង /kbɯːŋ/ ...... ។

**១.១.១.៤- ការផ្លាស់ប្តូរស្រះអា " ា " ដែលជាស្រះទោលហើយជាស្រះមុខប្តូរទៅជាស្រះអៀ "ៀ-ៀ":**

ឧទាហរណ៍ :

- ពាង /piːəŋ/ > ពៀង /piːeŋ/

- រាង /ri:əŋ/ > រៀង /ri:eŋ/
- ពាក្យ /pi:ək / > ពៀក /pi:ek/
- វាល /vi:əl/ > វៀល /vi:el/
- ពាល /pi:əl/ > ពៀល /pi:el/
- ទាញ /ti:əɲ/ > ទៀញ /ti:eɲ/
- យាម /ji:əm/ > យៀម /ji:em/
- វាយ /vi:əl/ > វៀល /vi:ei/
- រាវ /ri:əu/ > រៀវ /ri:eu/

**១.១.១.៥- ការផ្លាស់ប្តូរស្រៈ អោ "ើ-ា" /ao/ ដែលជាស្រៈផ្សំ ប្តូរទៅជាស្រៈអូ " ូ " / o: / ជាស្រៈទោល ទីបន្ទីក្រអូមក្រោយវិញ :**

ឧទាហរណ៍ :

- កោត /kaot/ > កូត /ko:t/
- កោស /kaoh/ > កូស /ko:h/
- កោយ /kaoi/ > កូយ /ko:i/
- បោល /baol/ > បូល /bo:l/
- សោយ /saoi/ > សូយ /so:i/
- កោង /kaoŋ/ > កូង /ko:ŋ/
- ថោក /thaok/ > ថូក /tho:k/

**១.១.១.៦- ការផ្លាស់ប្តូរស្រៈអឺ " ឺ " / œ/ ដែលជាស្រៈទោល ទីបន្ទីក្រអូមកណ្តាល ប្តូរទៅជាស្រៈអេ " េ " / e: / ជាស្រៈទោល ទីបន្ទីក្រអូមមុខវិញ :**

ឧទាហរណ៍ :

- ដឹង /dœŋ/ > ដេង /de: ŋ/
- អីចឹង /i:cœŋ/ > អីចេង /i:ce: ŋ/
- ខឹង /khœŋ/ > ខេង /khe: ŋ/
- ដឹក /dœk/ > ដេក /de:k/
- ត្រឹម /trœm/ > ត្រេម /tre:m/
- ចង្កឹះ /caŋkœh/ > ចង្កេះ /caŋke:h/

**១.១.១.៧- ការផ្លាស់ប្តូរស្រៈ អិ " ិ " / i / ដែលជាស្រៈខ្លី ទីបន្ទីក្រអូមមុខប្តូរទៅជាស្រៈ អ៊ី " ី " / iː / ខ្លីក្រអូមមុខដូចគ្នា :**

ឧទាហរណ៍ :

- គិត /kit/ > គីត /kiːt/
- ទិច /tic/ > ទីច /tiːc/
- គិញ /kiɲ/ > គីញ /kiːɲ/
- វិល /vil/ > វីល /viːl/

**១.១.១.៨- ការផ្លាស់ប្តូរស្រៈ អឹ " ឹ " / œ / ដែលជាស្រៈខ្លី ទីបន្ទីក្រអូមកណ្តាល ប្តូរទៅជាស្រៈ អ៊ី " ី " / iː / ជាស្រៈខ្លី ទីបន្ទីក្រអូមមុខវិញ :**

ឧទាហរណ៍ :

- ងងឹត /ŋɔːŋœt/ > ងងីត /ŋɔːŋiːt/
- ល្ងឹត /lŋœt/ > ល្ងីត /lŋiːt/

**១.១.១.៩- ការផ្លាស់ប្តូរពីស្រៈ អៀ " ៀ " ទៅជាស្រៈ អេ " េ " វិញ :**

ឧទាហរណ៍ :

- ភ្លៀង /phlieŋ/ > ភ្លេង /phleŋ/

**១.១.១.១០- ការផ្លាស់ប្តូរផ្នត់ដើម " អំម " ទៅជាផ្នត់ដើម " អំន " :**

ឧទាហរណ៍ :

- សម្តី /samdɛi/ > សន្តី /sandɛi/
- សម្ល /samlaː/ > សន្ល /sanlaː/
- សម្លេង /samdaɛŋ/ > សន្លេង /sandeːŋ/
- សម្លុត /samlut/ > សន្លុត /sanlut/

**១.១.២ ការផ្លាស់ប្តូរសូរស្រៈនៅភូមិជនជាតិ**

យើងឃើញថាតាមការចុះទៅស្រាវជ្រាវដល់មូលដ្ឋានរបស់បងប្អូនជនជាតិភាគតិច ដែលមានស្ថិត នៅភូមិ ១០៥ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែងដែរនោះ យើងបានសង្កេតឃើញថាតាមរយៈការនិយាយ

ស្តី ការបន្លឺសំឡេងមានការផ្លាស់ប្តូរស្រៈមួយចំនួនដូចប្រជាជនទៅល្បាយចូលគ្នាដែរ ។ ក៏ប៉ុន្តែការបន្លឺសំឡេងនៃសូរស្រៈខ្លះខុសពីភូមិដែលមានល្បាយប្រជាជនរស់នៅលាយឡំគ្នាជាអន្លើ ។

**១.១.៧.១- ការផ្លាស់ប្តូរស្រៈ " ែ " ទៅជាស្រៈ " េ " ដូចនៅភូមិ ដែលមានប្រជាជនរស់នៅលាយគ្នាដែរ :**

ឧទាហរណ៍ :

- ស្រែ /sraɛ/ > ច្រេ /chre:/

**១.១.៧.២- ការផ្លាស់ប្តូរស្រៈ " ា " ទៅជាស្រៈ" អ " ដែលជាស្រៈកប់**

ឧទាហរណ៍ :

- ងាប់ /ŋoəp/ > ង៉ប់ /ŋɑp/
- រនាស់ /rɔ:noah/ > រណស់ / rɔ:noah/

**១.២- ការផ្លាស់ប្តូរព្យញ្ជនៈ :**

**១.២.១- ការផ្លាស់ប្តូរព្យញ្ជនៈនៅភូមិល្បាយប្រជាជន :**

នៅភូមិដែលមានប្រជាជនរស់នៅលាយឡំចម្រុះគ្នា ដែលក្រុមនិស្សិតយើងខ្ញុំបានចុះទៅដល់មូលដ្ឋានផ្ទាល់បានសង្កេតឃើញថា វាក្យស័ព្ទមួយចំនួនមានការផ្លាស់ប្តូរតួព្យញ្ជនៈ ក្នុងការបន្លឺសំឡេងរបស់ប្រជាជនពលរដ្ឋនៅតំបន់នេះ យើងសូមលើកយកឧទាហរណ៍មួយចំនួនមកបង្ហាញ ដូចតទៅ :

**១.២.១.១- ការផ្លាស់ប្តូរពីព្យញ្ជនៈ "ខ " ទៅជាព្យញ្ជនៈ " ឃ "**

ឧទាហរណ៍ :

- ខោ /khao/ > ឃោ /kho:/
- ខោក /khaok/ > ឃោក /kho:k/
- ខ្ញង /kho:ŋ/ > ឃ្ញង /khu:ŋ/

**១.២.១.២- ការផ្លាស់ប្តូរព្យញ្ជនៈ " ព " ជាព្យញ្ជនៈ " ភ " វិញ :**

ឧទាហរណ៍ :

- ពួក /puək/ > ភួក /phuək/
- ពួន /puən/ > ភួន /phuən/
- ពុន /pun/ > ភុន /phun/

- ទាំងពួង /Teaŋ puəŋ/ > ទាំងភួង / teaphu/

**១.២.១.៣- ការផ្លាស់ប្តូរពីព្យញ្ជនៈ " រ " ទៅជាព្យញ្ជនៈ "ល "**

ឧទាហរណ៍ :

- រលួយ /rɔ:luəj/ > លលួយ /lɔ:luəj/
- រលំ /rɔ:lɑm / > លលំ /lɔ:lɑm/
- រង្គោះ /rɔŋkɔ'h / > លង្គោះ /lɔŋkɔh /
- រលាស់ / r loas / > លលាស់ /lɔ:loas /

**១.២.២- ការផ្លាស់ប្តូរព្យញ្ជនៈនៅភូមិថ្មជាតិ :**

តាមការសាកសួរស្រង់ពតិមាន យើងអាចសង្កេតនិងកត់សម្គាល់ឃើញថា មានការផ្លាស់ប្តូរព្យញ្ជនៈ ក្នុងការបញ្ចេញសំឡេងរបស់ប្រជាពលរដ្ឋទៅលើពាក្យស័ព្ទមួយចំនួន នៅតំបន់នេះ ។ ហើយការបន្លឺសំឡេង នៅមានលក្ខណៈជិតភាសាខ្មែរបុរាណ តាមរយៈសិលាចារឹក និង មានសំឡេងប្រហាក់ប្រហែលគ្នាជាមួយ ប្រជាជនមួយចំនួននៅខេត្តតាកែវ តើនេះបណ្តាលមកពីអ្វី កត្តានេះគួរតែយើងធ្វើការសិក្សាឱ្យបានស៊ីជម្រៅ បន្តទៀតនៅពេលអនាគត ទើបអាចរកមូលហេតុនៃបញ្ហានេះឃើញ ។ តួព្យញ្ជនៈមួយចំនួនដែលខុសពី ភាសាស្តង់ដារ ( ភាសាកណ្តាល ) ហើយបញ្ហានេះយើងនឹងយកមកធ្វើការបកស្រាយ ដូចតទៅនេះ :

**១.២.២.១- ការផ្លាស់ប្តូរព្យញ្ជនៈ " ស " ទៅព្យញ្ជនៈ " ឆ "**

ឧទាហរណ៍ :

- ស៊ី /si:/ > ឈី /chi:/
- សិន /sin/ > ឆិន /chi:/
- ស្អី /s?i:/ > ឆ្អី /ch?i:/
- ស្វាយ /sva:j/ > ឆ្វាយ /chva:j/
- ស្អុយ /s?uj/ > ឆ្អុយ /ch?uj/
- ស្រែ /sra/ > ឆ្រែ /chre:/

**១.២.២.២- ការផ្លាស់ប្តូរព្យញ្ជនៈ "ឆ " ទៅជា " ស "**

ឧទាហរណ៍ :

- ឆ្មប /chmɑ:p/ > ស្មប /smɑ:p/

**១.២.២.៣- ការផ្លាស់ប្ដូរព្យញ្ជនៈ " ផ " ទៅជា " ភ "**

ឧទាហរណ៍ :

- ផ្លែ /phlaɛ/ > ភ្លែ /phlẹ/

**១.២.២.៤- ការផ្លាស់ប្ដូរព្យញ្ជនៈ "ប " ទៅជា " ប៊ "**

ឧទាហរណ៍ :

- បុណ្យ /bon/ > ប៊ុន /bun/

**១.២.២.៥- ការផ្លាស់ប្ដូរព្យញ្ជនៈ "ន" ទៅជា "ណ"**

ឧទាហរណ៍ :

- រនាស់ /rɔnoah/ > រណស់ /rɔ:ṇoah/

**២. វាក្យស័ព្ទ :**

តាមរយៈការសម្ភាសន៍របស់ក្រុមនិស្សិតទៅប្រជាជននៅក្នុងភូមិអូរគគីរក្រោម និងភូមិសន្តិភាព យើងពិនិត្យឃើញថា ពាក្យ ឬវាក្យស័ព្ទដែលប្រជាជនបានប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃនោះ មានភាពប្លែកគ្នាច្រើនទៅនឹងប្រជាជននៅក្នុងតំបន់ប្រជាជនផ្សេងទៀត។ យើងសំគាល់ឃើញថា ភាគច្រើននៃពាក្យ ឬ វាក្យស័ព្ទ ប្រជាជនបានប្រើប្រាស់ភាសាតំបន់អ្នកសៀមរាប និងបានបញ្ចូលភាសារបស់ជនជាតិលាវ និងសៀមផងដែរ សំរាប់ទំនាក់ទំនងជាទំលាប់ប្រចាំថ្ងៃ។

ប្រៀបធៀបទឹងភាសាស្តង់ដារ វាក្យស័ព្ទតំបន់នេះមានលក្ខណៈប្លែកពីរយ៉ាង ដូចខាងក្រោមនេះ:

**២.១. ពាក្យប្លែកពីភាសាស្តង់ដារ**

ខាងក្រោមនេះ គឺជាការប្រៀបធៀបភាសាស្តង់ដារ និងភាសាដែលប្រជាជនបានប្រើប្រាស់ ក្នុងភូមិអូរគគីរក្រោម និង ភូមិសន្តិភាព[២] :

ឧទាហរណ៍ :

| ភាសាស្តង់ដារ | | ភាសាអន្លង់វែង |
|---|---|---|
| - ទៅត្បូងត្រង់ | អ្នកភូមិថា : | ទៅត្បូងក្រឡុញ |
| - ឈើទាល | អ្នកភូមិថា : | យាង[៣] |

[២] ធ្វើសម្ភាសន៍ចំនួនពីរគ្រួសារ ( មិនប្រាប់ឈ្មោះ ) ភូមិសន្តិភាព ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

[៣] - សម្ដីបងប្រុសឈ្មោះ ធឿង ថាវ នៅភូមិអូរគគីរក្រោម ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

| | | | |
|---|---|---|---|
| - | រាំងនន | អ្នកភូមិថា : | នាងនួន |
| - | និយាយ | អ្នកភូមិថា : | និញ៉ី |
| - | អស់កម្លាំង | អ្នកភូមិថា : | សោ .អស់ |
| - | ល្ហុងទុំ | អ្នកភូមិថា : | ទុំល្ហុង |
| - | ស្វាយទុំ | អ្នកភូមិថា : | ទុំស្វាយ |
| - | កូនក្មេង | អ្នកភូមិថា : | អាង៉ា |
| - | កម្ពោតព្រៃ | អ្នកភូមិថា : | ដុបព្រៃ |
| - | មើមដំឡូង | អ្នកភូមិថា : | ចុះដំឡូង |
| - | លំបាកតោកយ៉ាក | អ្នកភូមិថា : | យ៉ាក |
| - | ទាន់សម័យ | អ្នកភូមិថា : | ដេញសម័យ |
| - | តំលៃប៉ុន្មាន | អ្នកភូមិថា : | តាឡៃប្លា |
| - | ល្ងិតខ្ទាក់ | អ្នកភូមិថា : | ល្ងីតខ្ទាក់ |
| - | មិនដឹងអ្វីទេ | អ្នកភូមិថា : | មិនដេងអ៊ុយទេ |
| - | បងថ្លៃស្រី | អ្នកភូមិថា : | ថៃ |
| - | វែង | អ្នកភូមិថា : | យ៉ារំ |
| - | បងថ្លៃប្រុស | អ្នកភូមិថា : | អ្នក |
| - | ធ្វើការមិនស្អាត | អ្នកភូមិថា : | ធ្វើការអីចេះ |

ស្តែងឡើងតាមរយៈការប្រៀបធៀបនេះ យើងឃើញថា មានភាពប្លែកគ្នាពីរយ៉ាង ទៅនឹងភាសាស្តង់ដារគឺ :

### ២.១.១. ភាពប្លែកគ្នាទាំងស្រុងរវាងសំនៀង និងន័យវាក្យស័ព្ទ

ឧទាហរណ៍ :

| | | | |
|---|---|---|---|
| - | ទៅត្រង់ | ទៅជា : | ទៅក្រឡុញ |
| - | អស់កម្លាំង | ទៅជា : | សោ |
| - | ឈើទាល | ទៅជា : | យាង |

### ២.១.២. ភាពស្រដៀងគ្នាខ្លះរវាងសំនៀង និងន័យវាក្យស័ព្ទ

ឧទាហរណ៍ :

- មិនដឹងអីទេ ទៅជា : មីនដេងអ៊ុយទេ
- តំលៃប៉ុន្មាន ? ទៅជា : តាឡៃប្ចា ?
- ល្ងីតខ្វាក់ ទៅជា : ល្ងីតខ្វាក់

សរុបមក ភាពប្លែកគ្នានៃភាសារបស់ប្រជាជនក្នុងតំបន់នេះ ទៅនឹងភាសាស្តង់ដារគឺខុសគ្នាត្រង់ពាក្យស័ព្ទដែលប្រជាជនបន្លឺឡើងមានលក្ខណៈបង្ហួរវែង និងរាងរដឹនបន្តិចផង ហើយជាមួយគ្នានោះដែរ វាក្យស័ព្ទខ្លះ បានសម្តែងឡើងដោយបញ្ញត្តិខុសគ្នាពីភាសាស្តង់ដារតែម្តង ។

**២.២. ពាក្យដូចភាសាស្តង់ដារតែផ្លាស់ប្តូរន័យ**

វាក្យស័ព្ទភាគខ្លះទៀត ដែលសម្ភាសន៍បានមកពីប្រជាជននៅក្នុងភូមិនេះ ឃើញថាមានលក្ខណៈដូចគ្នាភាសាស្តង់ដារដែរ តែការយល់នៃពាក្យនេះមានលក្ខណៈខុសគ្នាទៅវិញ ។

ឧទាហរណ៍ :

| ភាសាស្តង់ដារ | | ភាសាអន្លង់វែង |
|---|---|---|
| - ទៅលើ "ន័យនៃពាក្យនេះគឺខាងលើ " | អ្នកភូមិថា : | ទៅលើ "ន័យនៃពាក្យនេះគឺទៅភ្នំ" |
| - ទៅក្រោម"ន័យនៃពាក្យនេះគឺខាងក្រោម" | អ្នកភូមិថា : | ទៅក្រោម"ន័យពាក្យនេះគឺទៅភូមិ" |

**៣. ប្រយោគ :**

ឆ្លងតាមការសម្ភាសន៍ និងសាកសួរពត៌មានប្រជាជនដែលនៅភូមិបានរៀបរាប់ខាងលើ យើងអាចធ្វើការវិនិច្ឆ័យទៅឃើញថា ការប្រើប្រាស់ល្បះ ឬប្រយោគពុំមានលក្ខណៈអ្វីខុសប្លែកអំពីភាសាស្តង់ដារ ( ភាសាកណ្តាល ) បានសេចក្តីថា ការនិយាយស្តី ការរៀបលំដាប់ពាក្យ ការចងល្បះមានលក្ខណៈដូចគ្នា ដោយមានប្រធាន បំរាប់ប្រធាន ដូចការប្រើប្រាស់នៃភាសាកណ្តាលដែរ ។

**៤.ល្បាយភាសា**

ដោយឡែកអំពីល្បាយនៃភាសា យើងសង្កេតឃើញថា ប្រជាជននៅតំបន់អន្លង់វែងមានការប្រើប្រាស់លាយភាសាបរទេសមួយចំនួនតូច គឺល្បាយនៃភាសាថៃដែលប្រជាជននៅតំបន់នោះយកមកប្រើប្រាស់ដើម្បីទាក់ទងគ្នាតាមស្រុកភូមិរបស់គេ។ ក្នុងនោះតាមការសិក្សាអស់រយៈខ្លីមួយ ទៅលើភូមិអូរគគីរក្រោម និងភូមិសន្តិភាព ដែលស្ថិតនៅក្នុងស្រុកដូចបានរៀបរាប់ខាងលើ យើងសង្កេតឃើញថា ប្រជាជននៅក្នុងតំបន់នោះ យកភាសាបរទេសមួយចំនួនមកច្របល់ប្រើ នៅក្នុងភាសាខ្មែរ បានក្លាយទៅជាភាសាខ្មែរ ហើយ

ប្រើប្រាស់ល្បាយភាសានេះពុំមានភាពលំបាកអ្វីដល់ប្រជាជននៅក្នុងតំបន់នេះឡើយ គឺថា ពួកគេយល់គ្នាទៅវិញទៅមក នៅពេលពួកគេយកមកប្រើប្រាស់ភាសាទាំងនោះ។

ឧទាហរណ៍ទី១ : ម៉េវកន្ទុយយ៉ាវ។

នៅក្នុងឃ្លានេះយើងឃើញថា :

- ពាក្យ "ម៉េវ" < ភាសាថៃថា "ម៉េវ" ( แมว ) = ដែលបកប្រែជាភាសាខ្មែរស្តង់ដារថា "សត្វឆ្មា"
- ពាក្យ "យ៉ាវ" < ភាសាថៃថា "យ៉ាវ" ( ยาว ) = ដែលបកប្រែជាភាសាខ្មែរស្តង់ដារថា "វែង"

ដូច្នេះឃ្លាខាងលើនេះ ( ម៉េវកន្ទុយយ៉ាវ ) ត្រូវនឹងពាក្យខ្មែរស្តង់ដារថា : ឆ្មាកន្ទុយវែង ។

ឧទាហរណ៍ទី២ : យ៉ាកដល់ហើយ។

នៅក្នុងឃ្លានេះយើងឃើញថា :

-ពាក្យ "យ៉ាក" < ភាសាថៃថា "យ៉ាក" ( ยาก ) = ដែលបកប្រែជាភាសាខ្មែរស្តង់ដារថា "លំបាក" ។ ក៏ប៉ុន្តែពាក្យខ្មែរស្តង់ដារយើង ក៏មានប្រើប្រាស់ថា "ក្រតោកយ៉ាក" ដែរ ។

ដូច្នេះឃ្លាខាងលើនេះ ( យ៉ាកដល់ហើយ ) ត្រូវនឹងពាក្យខ្មែរស្តង់ដារថា : លំបាកដល់ហើយ ។

ឧទាហរណ៍ទី៣ : នៅព្រំដែន

ពាក្យ " ព្រំដែន " ពាក្យនេះជាពាក្យរបស់ខ្មែរស្តង់ដារមានរួចជាស្រេចទៅហើយ ក៏ប៉ុន្តែភាសាថៃក៏មានពាក្យថាព្រំដែននេះដែរ ( พรมแดน ) ដែលធ្វើឱ្យប្រជាជននៅតំបន់នោះប្រើប្រាស់ពាក្យ នេះយ៉ាងសាមញ្ញបំផុត ហាក់បីដូចជាពាក្យនេះជាពាក្យនៅក្នុងភាសាថៃអ៊ីចឹង។

ក្រៅពីឧទាហរណ៍ទាំងបីខាងលើ ក្រុមអ្នកស្រាវជ្រាវយើងសង្ឃឹម និងជឿជាក់ថា នឹងមានវាក្យស័ព្ទបន្ថែមទៅទៀតព្រោះថា ឧទាហរណ៍ខាងលើ គឺគ្រាន់តែជាការសិក្សាក្នុងរយៈពេលខ្លីមួយតែប៉ុណ្ណោះ។

## ជំពូកទី២

## ជនជាតិភាគតិចនៅតំបន់១០៥ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

តំបន់១០៥ គឺជាតំបន់មួយដែលស្ថិតនៅក្នុងឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង។ តំបន់នេះគឺជាតំបន់ដែលប្រជុំទៅដោយជនជាតិភាគតិចដែលបានធ្វើដំណើរមកពីភាគឥសាននៃប្រទេស។ នៅក្នុងតំបន់ទាំងនេះ មានជនជាតិជាច្រើនរស់នៅរួមគ្នា ដូចជាជនជាតិខ្មែរ, ចារាយ, ម្នង, ទំពួន និងលាវ ។ ក្នុងចំណោមជនជាតិទាំងនេះ ជនជាតិម្នងមានចំនួនច្រើនជាងគេ។ នៅឆ្នាំ១៩៩២ បងប្អូនទាំងនេះបានធ្វើដំណើរពីលើភ្នំដងរែកចុះមកកសាងភូមិនេះឡើង។ ប្រជាជនភាគច្រើនប្រកបរបរធ្វើស្រែនិងចំការ។ ផលដំណាំដែលបាន

មក បងប្អូនជនជាតិទាំងនេះបានយកទៅលក់នៅទីរួមស្រុកអន្លង់វែង។ ក្រៅពីការធ្វើស្រែចំការពួកគាត់បានដាក់មងយកត្រីនៅអូរជីកលើ និងអូរជីកក្រោម[៤]។

ដោយសារនៅតំបន់នេះមានជនជាតិភាគតិចរស់នៅច្រើនលាយឡំគ្នា នៅពេលជួបគ្នាម្តងៗ ពិសេសក្នុងពិធីបុណ្យទាន បងប្អូនតែងតែធ្វើការប្រាស្រ័យទាក់ទងគ្នាដោយប្រើភាសាខ្មែរជាមធ្យោបាយចម្បង។ ប៉ុន្តែនៅក្នុងគ្រួសារ និង ក្នុងចំណោមជនជាតិដូចគ្នាវិញ ពួកគាត់ប្រើប្រាស់ភាសាជនជាតិផ្ទាល់របស់គាត់។

## ខាងក្រោមនេះជាឧទាហរណ៍មួយចំនួន ក្នុងភាសាថ្មង[៥]

**១-ការរាប់លេខ**

ម៉ាយ [ma:i] = មួយ

ពៀរ [pier] = ពីរ

របុី [rɔ:pi] = បី

រពោន់ [rɔ:poan] = បួន

ប្រាំ [bra:m] = ប្រាំ

ត្រាវ [tra:u] = ប្រាំមួយ

របុឹស [rɔ:pa:əh] = ប្រាំពីរ

ផាន [pha:n] = ប្រាំបី

ស៊ីន [si:n] = ប្រាំបួន

ចិត [cit] = ដប់

តួរយ៉ាង [tu: ər yean] = មួយរយ

តួរម៉ឺន [tu:ər mw:n] = មួយម៉ឺន

ឆ្លាង [chla:n] = ផ្ទះ

ចៅ [cau] = ចៅ

អ៊ុរ [ʔulr] = ប្រពន្ធ

សាង [sa:n] = ប្តី

---

[៤] បទសម្ភាសន៍ជាមួយ សៅ សារុន នៅតំបន់១០៥ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០០១។

[៥] បទសម្ភាសន៍ជាមួយបងស្រី សឿន នៅតំបន់១០៥ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០០១។

អាជេ [?a:ce] = កូនម៉ែត

ម្និះរ៉ាញ [mni:hra:n] = មនុស្សចាស់

ផ្លៅ [phlao] = ប្រុស

ផ្លួរ [phlu:ər] = ស្រី

ផ្អោស [ph?aoh] = ប្អូន

ផ្នៅ [phnao] = បង

ម៉ែព [maɛpoa:] = ម្តាយក្មេក

ម្រឹសព [mroehpoa:] = ឪពុកក្មេក

កូនត្រោស [kontraoh] = កូនក្រមុំ

កូនអណ្តាំ [kon?ntam] = កូនកម្លោះ

ចៃ [ca ] = ជីតា

អ៊ូ [?o:] = ជីដូន

២-ពាក្យទាក់ទងនឹងសត្វ

យ៉ាល់រ [ya:lr] = មាន់

ឆុង [chon] = ឆ្កែ

អរោក [?roak] = គោ

៣-ពាក្យទាក់ទងនឹងខ្លួនប្រាណ

តី [ti] = ដៃ

ចង់ [caŋ] = ជើង

រង្វង់ [rɔ:ŋvɔŋ] = មាត់

ម៉ាត់ [mat] = ភ្នែក

ទោលរ [to:lr] = ត្រចៀក

រឹងពែង [rwnpe̞ŋ] = ថ្ងាស

ពោក [poak] = ក្បាល

កាង [ka:n] = ចង្កា

ឈីក [chi:k] = ធ្មេញ

កាយយ [ka:yɔ:i] = បប្ចូរមាត់

តាងតះ [ta:ntah] = ដើមទ្រូង

កើយ [ka:əi] = ខ្មើយ

ក្ដា [kda:] = ក្ដា

ភ្លូ [phlu:] = ភ្លៅ

រមាំងរយ៉ាល [rɔ:meaŋrɔyal] = ស្មងជើង

ក្លោង [klaoŋ] = ម្រាមជើង

**៤-ពាក្យផ្សេងៗទៀតមាន :**

ម៉ង់ [mɑn] = ថ្ងៃស

រកាយ [rɔ:ka:i] = ស្ដម

ប្រែះ [brẹh] = ខ្ពស់

ត្រែស [traεh] = លិច

នីលរម [ni:lrɔm] = ចម្ការ

ណាប្រែះ [na:breh] = ថ្ងៃរះ

ណារញ៉ាប់ [na:rɔɲa:p] = ថ្ងៃលិច

មាំង [mean] = យប់

ខៃ [khai] = ព្រះចន្ទ

ត្រួប [tro:p] = ពពក ឬមេឃ

តើមខ្នុលរ [ta:əmkhnolr] = ដើមខ្នុរ

មិះ [mih] = ភ្លៀង

ត្រួបមិះ [tro:pmih] = មេឃភ្លៀង

អស់ចិតថាន់ [ ʔ:hcitthan] = ប្អូនទៅណា ? ។

**សេចក្ដីសន្និដ្ឋាន**

តាមរយៈការសិក្សាប្រៀបធៀបខាងលើ យើងសង្កេតឃើញថានៅតំបន់អន្លង់វែង ប្រជាពលរដ្ឋប្រើប្រាស់ភាសាខ្មែរជាទូទៅសំរាប់ជាមធ្យោបាយទំនាក់ទំនងគ្នាក្នុងជីវភាពប្រចាំថ្ងៃ។ ប៉ុន្តែយើងកត់សំគាល់ឃើញថា ភាសាខ្មែរដែលជាមធ្យោបាយចម្បង ក្នុងជីវភាពរបស់ប្រជាពលរដ្ឋនៅទីនោះ មានលក្ខណៈប្លែកពី

ភាសាកណ្ដាល(Standard)ខ្លះ១ ជាពិសេសលើផ្នែកសូរស័ព្ទ ដែលនាំឱ្យមានការប្រែប្រួលសំឡេងស្រៈ និងព្យញ្ជនៈមួយចំនួន។ លើសពីនេះយើងក៏សង្កេតឃើញថា មានវាក្យស័ព្ទខ្លះត្រូវបានប្រជាពលរដ្ឋក្នុងតំបន់ប្រើប្រាស់ប្លែកពីវាក្យស័ព្ទនៃភាសាខ្មែរកណ្ដាល។ ក្រៅពីនេះ យើងឃើញថា ប្រជាពលរដ្ឋនៅទីនោះបានខ្ចីវាក្យស័ព្ទតិចតួចពីភាសាជិតខាង ដូចជាពីភាសាថៃ ឡាវមកប្រើលាយជាមួយភាសាខ្មែរ។ ចំពោះបញ្ហារចនាសម្ព័ន្ធឃ្លាប្រយោគវិញ យើងឃើញថា ពុំមានខុសប្លែកពីភាសាកណ្ដាលឡើយ។ ប្រជាពលរដ្ឋមួយភាគធំដែលរស់នៅតំបន់អន្លង់វែង មានដើមកំណើតពីខេត្តនានានៃប្រទេសកម្ពុជា ប្រើប្រាស់ភាសាខ្មែរគ្រប់ពេលវេលាក្នុងជីវភាព តែចំពោះជនជាតិភាគតិចដែលមានដើមកំណើតក្នុងតំបន់នេះស្រាប់ និងមកពីភូមិភាគឥសាន ក្រៅពីប្រើភាសាខ្មែរសំរាប់ទំនាក់ទំនងទូទៅជាមួយអ្នកចំណូលស្រុក និងជាមួយក្រុមជនជាតិផ្សេងគ្នា គាត់ក៏ប្រើភាសាជនជាតិជាភាសាកំណើតរបស់ខ្លួន ក្នុងកាលៈទេសៈពិសេសសំរាប់ទំនាក់ទំនងក្នុងចំណោមក្រុមជនជាតិជាមួយគ្នាផងដែរ ។

x x
x

## គន្ថនិទ្ទេស

១- ក្រសួងអប់រំ " វេយ្យាករណ៍ថ្នាក់ទី៥ " ១៩៨៣, ភ្នំពេញ ។

២- ពុទ្ធសាសនបណ្ឌិត្យ, វចនានុក្រមខ្មែរ ( ភាគ១,២) , បោះពុម្ពឆ្នាំ១៩៦៧, ភ្នំពេញ ។

៣- ព្រុំ, ម៉ល់ " កំណត្រឹះទ្រឹស្ដី ដើម្បីសង្គមភាសាវិទ្យា ប្រព័ន្ធភាព " ទស្សនាវដ្ដី លេខ៣២ ឆ្នាំ១៩៨៦ វិទ្យាស្ថានភាសាវិទ្យាអនុវត្តន៍សាកលវិទ្យាល័យ អាប៊ីឡង់ ប្រទេសកូឌីវ័រ។

៤- អុក ចូន, " សូរវិទ្យាខ្មែរ " ក្រសួងអប់រំ សាលាគរុវិជ្ជាជាន់ខ្ពស់ , ១៩៨៧, ភ្នំពេញ ។

ឯកសារ

១- ឯកសារតាមខ្សែអាត់ :

១.១-បទសម្ភាសន៍ជាមួយប្រជាពលរដ្ឋបីគ្រួសារ ( មិនប្រាប់ឈ្មោះ) នៅភូមិសន្តិភាព ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ ។

១.២- បទសម្ភាសន៍ជាមួយបងប្រុស ធឿង ថាវ និងលោកអ៊ុំ សាត់ យី ភូមិអូរគគីរក្រោម ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ ។

១.៣- បទសម្ភាសន៍ជាមួយលោក សៅ សារុន និងបងស្រី ស្រឿន នៅភូមិ១០៥ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ ។

# មាតិកាបស់អត្ថបទ


សេចក្តីផ្តើម ................................................................................ ទំព័រ១៧

ជំពូកទី១ ៖ បម្រែបម្រួលសូរស្រៈព្យញ្ជនៈ វាក្យស័ព្ទ និងទិដ្ឋភាពប្លែកៗមួយចំនួននៃភូមិល្បាយប្រជាជន និងនៅភូមិជនជាតិភាគតិច ............................ --១៩

១- សូរស័ព្ទ ................................................................................ --១៩

១.១- ការផ្លាស់ប្តូរសូរស្រៈ ................................................................ --១៩

១.១.១- ការផ្លាស់ប្តូរសូរស្រៈនៅភូមិល្បាយប្រជាជន ................................ --១៩

១.១.១.១- ការផ្លាស់ប្តូរសូរស្រៈ"អែ"(ែ) ទៅជាស្រៈ"អេ" (េ) ............................ --២០

១.១.១.២- ការផ្លាស់ប្តូរសូរស្រៈ"អើ"(ើ) ទៅជាស្រៈ"អឺ" (ឺ) ............................ --២០

១.១.១.៣- ការផ្លាស់ប្តូរស្រៈ"អឿ" (ឿ) ទៅជាស្រៈដែលជាស្រៈផ្សំប្តូរទៅជាស្រៈ"អឺ"(ឺ) ជាស្រៈកណ្តាល ហើយជាស្រៈទោល ............................ --២១

១.១.១.៤- ការផ្លាស់ប្តូរស្រៈ"អា"( ) ទៅជាស្រៈ"អៀ" (ៀ) ............................ --២១

១.១.១.៥- ការផ្លាស់ប្តូរស្រៈ"អោ"(ោ) ទៅជាស្រៈ"អូ"(ូ) ............................ --២២

១.១.១.៦- ការផ្លាស់ប្តូរស្រៈ"អឺ"(ឺ) ទៅជាស្រៈ"អេ"(េ) ............................ --២២

១.១.១.៧- ការផ្លាស់ប្តូរស្រៈ"អិ"(ិ) ទៅជាស្រៈ"អុឺ"(ឺ) ............................ --២៣

១.១.១.៨- ការផ្លាស់ប្តូរស្រៈ"អឺ"(ឺ) ទៅជាស្រៈ"អុឺ"(ឺ) ............................ --២៣

១.១.១.៩- ការផ្លាស់ប្តូរស្រៈ"អៀ"(ៀ) ទៅជាស្រៈ"អេ"(េ) ............................ --២៣

១.១.១.១០- ការផ្លាស់ប្តូរផ្នត់ដើម"អំម" ទៅជាផ្នត់ដើម"អំន" ............................ --២៣

១.១.២- ការផ្លាស់ប្តូរសូរស្រៈនៅភូមិជនជាតិ ............................................ --២៣

១.១.២.១- ការផ្លាស់ប្តូរស្រៈ"អែ"(ែ) ទៅជាស្រៈ"អេ"(េ) ............................ --២៤

១.១.២.២- ការផ្លាស់ប្តូរស្រៈ"អា"(ា) ទៅជាស្រៈ"អ"( ) ............................ --២៤

១.២- ការផ្លាស់ប្តូរព្យញ្ជនៈ ................................................................ --២៤

១.២.១- ការផ្លាស់ប្តូរព្យញ្ជនៈនៅភូមិល្បាយប្រជាជន ................................ --២៤

១.២.១.១- ការផ្លាស់ប្តូរពីព្យញ្ជនៈ"ខ" ទៅជាព្យញ្ជនៈ"ឃ" ............................ --២៤

១.២.១.២- ការផ្លាស់ប្តូរពីព្យញ្ជនៈ"ព" ទៅជាព្យញ្ជនៈ"ភ" ............................ --២៤

១.២.១.៣- ការផ្លាស់ប្តូរពីព្យញ្ជនៈ"រ" ទៅជាព្យញ្ជនៈ"ល" ........................................ --២៥

១.២.២- ការផ្លាស់ប្តូរព្យញ្ជនៈនៅភូមិជនជាតិ ........................................ --២៥

១.២.២.១- ការផ្លាស់ប្តូរពីព្យញ្ជនៈ"ស" ទៅជាព្យញ្ជនៈ"ឆ" ........................................ --២៥

១.២.២.២- ការផ្លាស់ប្តូរពីព្យញ្ជនៈ"ឆ" ទៅជាព្យញ្ជនៈ"ស" ........................................ --២៥

១.២.២.៣- ការផ្លាស់ប្តូរពីព្យញ្ជនៈ"ផ" ទៅជាព្យញ្ជនៈ"ភ" ........................................ --២៦

១.២.២.៤- ការផ្លាស់ប្តូរពីព្យញ្ជនៈ"ប" ទៅជាព្យញ្ជនៈ"ប៉" ........................................ --២៦

១.២.២.៥- ការផ្លាស់ប្តូរពីព្យញ្ជនៈ"ន" ទៅជាព្យញ្ជនៈ"ណ" ........................................ --២៦

២- វាក្យស័ព្ទ........................................ --២៦

២.១- ពាក្យប្លែកពីភាសាស្តង់ដារ ........................................ --២៦

២.១.១- ភាពប្លែកគ្នាទាំងស្រុងរវាងសំនៀង និង ន័យវាក្យស័ព្ទ ........................................ --២៧

២.១.២- ភាពស្រដៀងគ្នាខ្លះរវាងសំនៀង និង ន័យវាក្យស័ព្ទ ........................................ --២៧

២.២- ពាក្យដូចភាសាស្តង់ដារ តែផ្លាស់ប្តូរន័យ ........................................ --២៨

៣- ប្រយោគ ........................................ --២៨

៤- ល្បាយភាសា ........................................ --២៨

ជំពូកទី២ : ភាសាជនជាតិភាគតិចនៅតំបន់១០៥ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ.--២៩

១- ពាក្យទាក់ទងនឹងការរាប់លេខ ........................................ --៣០

២- ពាក្យទាក់ទងនឹងសត្វ ........................................ --៣១

៣- ពាក្យទាក់ទងនឹងខ្លួនប្រាណ ........................................ --៣១

៤- ពាក្យផ្សេងៗទៀត ........................................ --៣២

សេចក្តីសន្និដ្ឋាន ........................................ --៣២

គន្ថនិទ្ទេស ........................................ --៣៣

# អំពី លក្ខណៈវិនិច្ឆ័យ រូបនិយម

រៀបរៀង ដោយ បណ្ឌិត ព្រុំ ម៉ល់

------

<u>ចុង្គយោគ</u> :

បើយើងពិនិត្យសៀវភៅវេយ្យាករណ៍ខ្មែរមួយចំនួន យើងអាចសម្គាល់ឃើញថា អ្នកនិពន្ធសៀវភៅច្រើនយកលំនាំតាមវេយ្យាករណ៍បាលី/សំស្ក្រឹត ឬ តាមវេយ្យាករណ៍និយាមនៃភាសាអឺរ៉ុប ជាពិសេស តាមវេយ្យាករណ៍បារាំង/អង់គ្លេស។ ដូច្នេះ គប្បីយើងចាំឬដឹងថា វេយ្យាករណ៍និយាមនៃភាសាអឺរ៉ុប ដែលមានមកមុនកំណើតភាសាវិទ្យា គឺជាវេយ្យាករណ៍ដែលផ្អែកលើទស្សនវិជ្ជា ជាពិសេស ផ្អែកលើទស្សនវិជ្ជារបស់អារីស្តូត (Aristote)ដែលបានប្រកាសថា ភាសាជាអំណោយផល( ស្រមោល) របស់ចក្រវាឡ (univers) ដូចមានបដិសញ្ញា ខាងក្រោមនេះ :

**ក្នុង<u>ចក្រវាឡ</u> មាន <u>វត្ថុ</u> ប្រកបដោយ<u>សកម្មភាព</u>ផ្សេងៗ និង ដោយ<u>លក្ខណៈ</u>បែបណាៗ**

**ចក្រវាឡ ↓ ភាសា → វត្ថុ ↓ នាមស័ព្ទ    សកម្មភាព ↓ កិរិយាស័ព្ទ    លក្ខណៈ ↓ គុណនាម**

ក្នុងទស្សនៈនេះ គេផ្អែកលើន័យដើម្បីផ្តល់លក្ខណៈដល់ប្រភេទពាក្យ គឺ គេប្រើលក្ខណៈវិនិច្ឆ័យន័យនិយម (critères sémantiques) : <u>នាម</u>ស័ព្ទមានន័យថា ជាពាក្យសម្រាប់សម្គាល់<u>នាម</u>/ឈ្មោះវត្ថុ [1] ; <u>កិរិយា</u>ស័ព្ទមានន័យថា ជាពាក្យសម្រាប់សម្គាល់<u>កិរិយា</u>/អំពើនៃវត្ថុ។ល។ គេប្រើវិធីនេះគ្រប់វិស័យ : ក្រៅពីនិយមន័យសម្រាប់ប្រភេទពាក្យ គេប្រើវា ដើម្បីសម្គាល់លិង្គ វចនៈ មុខងារពាក្យ។ ល។ ផងទៀត។ ម្យ៉ាងទៀត ការយល់ ថាភាសាជាស្រមោលនៃចក្រវាឡ បានបណ្តាលឱ្យមានមតិចក្រពត្រនិយម ដោយគេសំអាងថា ភាសាដែលចេញពីប្រភពតែមួយមិនអាចមានទម្រង់ប្លែកគ្នាទេ ( អាចប្លែកគ្នាតែត្រង់ទិដ្ឋភាពលំអិត)។ ភាសាណា ដែលមានទម្រង់មិនដូចទម្រង់ភាសាឥណ្ឌា-អឺរ៉ុបដែលជាភាសារបស់គេ ជាភាសាមិនទាន់ពេញលេញ ជាអប្បភាសា ( des sous-langues) ។

ចាប់ពីលោកសោស្សៀរ( Ferdinand de Saussure) មក ភាសាវិទ្យាបានផ្តាច់ខ្លួនចេញពីវិធីដែលយកទស្សនវិជ្ជាជាមូលដ្ឋាន។ វិជ្ជានេះបានយកវិធីរបស់រូបវិទ្យាមកធ្វើជាគំរូវិញ គឺ ប្រើវិធីសង្កេត-អង្កេត : ធ្វើសម្មតិកម្ម ធ្វើការពិនិត្យ / ពិសោធន៍ និង ធ្វើសេចក្តីសន្និដ្ឋាន ( ពិតមែនតែ ក្នុងករណីខ្លះ គេត្រូវរំលងដំណាក់កាលខ្លះក៏ដោយ)។ ក្រោយពីការពិនិត្យ/ពិសោធន៍ បើលទ្ធផលមិនស្របតាមសម្មតិកម្មទេ

---

[1]- ឥឡូវនេះ គេបានពង្រីកនិយមន័យនៃនាមស័ព្ទដល់សភាវៈ ( មនុស្ស និង សត្វ) និង ដល់គំនិត/បញ្ញត្តិ ផងទៀត។

ភាសាវិទូត្រូវធ្វើការស្រាវជ្រាវឡើងវិញ ចាប់ពីដំណាក់ទី១រហូតមក គឺមិនត្រូវបង្កើតទ្រឹស្ដី ដើម្បីវាយភាសាបញ្ចូលនោះទេ : ទ្រឹស្ដីត្រូវកើតក្រោយការពិនិត្យសង្កេត ដូចក្នុងវិស័យវិទ្យាសាស្ត្រជាក់ស្ដែង ) ដែរ ។

**<u>លក្ខណៈវិនិច្ឆ័យរូបនិយម</u> :**

**១- <u>ប្រភេទនៃលក្ខណៈវិនិច្ឆ័យរូបនិយម</u>[(1)] :**

លក្ខណៈវិនិច្ឆ័យរូបនិយម (critères formels) ជាវិធី ដែលភាសាវិទូនិយមប្រើ ទោះគេប្រកាសបញ្ជាក់ក្ដី ឬ ទោះគេមិនប្រកាសក្ដី ។ ម្យ៉ាងទៀត គប្បីយើងរំលឹកឡើងវិញថា ភាសាវិទ្យាជាការសិក្សាបែបថ្មីស្ដីពីភាសា គឺជាវិធីដែលមានលោក សោស្សៀរ ជាអ្នកផ្ដួចផ្ដើម ។

ក្នុងវិធីនេះ គេមិនបដិសេធន័យទេ។ ន័យតែងតែមាននៅខាងក្រោយ/ខាងក្រោមរូប-សម្ព័ន្ធ : បើគ្មានន័យជាលំនាំទេ សេចក្ដីដែលគេពោលចេញមក ឬ ល្បះដែលគេចងក្រងឡើង គឺគ្រាន់តែជាល្បែងប៉ុណ្ណោះ។ ប៉ុន្តែ ទិដ្ឋភាពដែលអាចឱ្យយើងចៀសអញ្ញថាភាព [(2)] (subjectivité) ហើយ ដែលអាចឱ្យយើងចាប់ជាប់ដោយងាយ គឺលក្ខណៈវិនិច្ឆ័យរូបនិយមនេះឯង ពីព្រោះ លក្ខណៈវិនិច្ឆ័យបែបនេះមានទិដ្ឋភាពរូបិយចេញជាសូរស្ដាប់ឮ ឬ ចេញជាសញ្ញាមើលឃើញ ( បើ ភាសាត្រូវគេកត់ត្រាដោយអក្សរ) ។

**១,១- លក្ខណៈវិនិច្ឆ័យរូបនិយម ផ្អែកលើ លក្ខណៈរូបសាស្ត្រ/រូបពាក្យ (traits morphologiques) :**

ឧ. កិរិយាស័ព្ទ "ចាំ" + /-m-/ > នាមស័ព្ទ "ឆ្មាំ"
------ "ចាំ" + /-amn-/ > នាមស័ព្ទ "ចំណាំ"
------ "ដឹង" + /p-/ > កិរិយាហេតុ "ប្ដឹង"[(3)]
គុណនាម "ទុំ" + /p-/ > កិរិយាហេតុ "បន្ទុំ"

**១,២- លក្ខណៈវិនិច្ឆ័យរូបនិយម ផ្អែកលើ សូរលេកក្នុងល្បះ (traits intonatifs) :**

ល្បះពីរដែលមានពាក្យដូចគ្នា និងមានលំដាប់ពាក្យដូចគ្នា អាចជាល្បះខុសគ្នា មានន័យខុសគ្នា ដូចល្បះ (១ក) & (១ខ) ឬ (២ក) & (២ខ) ខាងក្រោមនេះ [(4)] :

(១ក) - បើឯងមិនប្រាប់គាត់ ប្រាកដជាមានរឿងធំមិនខាន ។



(១ខ) - បើឯងមិនប្រាប់ គាត់ប្រាកដជាមានរឿងធំមិនខាន ។



---

(1) - លក្ខណៈវិនិច្ឆ័យរូបនិយមមានប្រើវិធីជាច្រើន ប៉ុន្តែ យើងសុំរំលឹកតែវិធីសំខាន់ៗដែលយើងត្រូវការក្នុងអត្ថបទនេះ ។

(2) - ពាក្យនេះមាននៅក្នុង វចនានុក្រមបារាំង-ខ្មែរ របស់ លោក តិប យក់ & ចាវ គន្ធ ។

(3) - រូបស័ព្ទ (morphème) /p-/ មានបណ្ដាស័ព្ទ (allomorphes) ជាច្រើន ដូចជា [ប៉-] , [ផ-] , [បញ្-] , [បន់-] , ។ល។ ( យោង : សទ្ទតាវិទ្យា & ន័យកម្មវិទ្យា) ។

(4) - ឧទាហរណ៍ខ្ចីពី លោក ប៊ី សុខគង់ សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ ឆ្នាំ២០០២ រាជបណ្ឌិតសភាកម្ពុជា ។

(២ក) - គាត់ផឹកតែ ពីរកែវ ។

(២ខ) - គាត់ផឹក តែពីរកែវ ។

**១,៣- លក្ខណៈវិនិច្ឆ័យរូបនិយម ផ្អែកលើ ស្នៀង/កម្ពស់សូរសំឡេង** (traits tonologiques ) :

នៅក្នុងភាសាមានស្នៀង [1] ដូចជា ភាសាចិន ភាសាសៀម ភាសាយួន ជាដើម ពាក្យមួយចំនួន ដែលមានរូបសាស្ត្រ/រូបពាក្យដូចគ្នា តែជាពាក្យផ្សេងពីគ្នា ដោយសារតែពាក្យទាំងនោះមានស្នៀងប្លែកពីគ្នា ឧ : ក្នុងភាសាបារ៉ូឡេ (នៅប្រទេសកូឌីវ័រ) : អែទី (សូរខ្ពស់) = ក្បាលយើង ≠ អែទី (សូរទាប) = យើងយល់ ។

**១,៤- លក្ខណៈវិនិច្ឆ័យរូបនិយម ផ្អែកលើ លក្ខណៈសម្ព័ន្ធ** ( traits syntaxiques) :

ពាក្យមួយចំនួនដែលមានរូបសាស្ត្រដូចគ្នា ឬ កន្សោមក្នុងឃ្លាខ្លះដែលមានទិដ្ឋភាពក្រៅដូចគ្នា អាចស្ថិតក្នុងប្រភេទផ្សេងគ្នា ដោយសារពាក្យ ឬ កន្សោមទាំងនោះ មានលក្ខណៈសម្ព័ន្ធខុសគ្នា :

◆- ក្នុងភាសាខ្មែរ :

- "ទំនាក់ទំនង"ជានាមស័ព្ទ នៅក្នុង : "ទំនាក់ទំនងរវាងកម្ពុជា និង ប្រទេសថៃ " តែ ជាកិរិយាស័ព្ទ នៅក្នុង "ចំពោះពត៌មានលម្អិត សូមអញ្ជើញទំនាក់ទំនងជាមួយ..." ។
- "ពង"ជានាមស័ព្ទ ក្នុង "ពងមាន់" តែ ជាកិរិយាស័ព្ទ ក្នុង "មាន់ពង" ។
- "ផ្កា"ជានាមស័ព្ទ ក្នុង "ផ្កាស្វាយ" តែ ជាកិរិយាស័ព្ទ ក្នុង "ស្វាយផ្កា" ។

។ល។

◆- ក្នុងភាសាបារាំង កម្មវងពីរដែលមានទិដ្ឋភាពក្រៅដូចគ្នា អាចមានលក្ខណៈសម្ព័ន្ធជម្រៅខុសគ្នា ដូចមានក្នុងឧទាហរណ៍ ខាងក្រោមនេះ :

(1a)- Pierre a dessiné <u>ce paysage</u>;
(2a)- Pierre a dessiné <u>ce matin</u>.

ពិតមែនតែទិដ្ឋភាពក្រៅមានសភាពដូចគ្នា (ភ្ជាប់ផ្ទាល់ទៅកិរិយាស័ព្ទ ដូចគ្នា) តែ កម្មវង <u>ce paysage</u> និង កម្មវង <u>ce matin</u> មានប្រភេទផ្សេងគ្នា ពីព្រោះ វិធីឆ្លងឃ្លាបង្ហាញលទ្ធផលផ្សេងគ្នា ដូចតទៅ :

(១) - បន្លែកបានមក ពី កម្មវាចកៈនីយកម្ម (passivation):

(1b)- Ce paysage a été dessiné par Pierre (ឃ្លាត្រឹមត្រូវ);
(2b)- *Ce matin a été dessiné par Pierre (ឃ្លាមិនត្រឹមត្រូវ).

(២) - បន្លែកបានមក ពី ផ្ទេរនីយកម្ម (détachement) :

(1c)- Ce paysage, Pierre <u>l'</u>a dessiné (reprise <u>obligatoire</u> de "paysage" par le pronom personnel l' );
(2c)- Ce matin, Pierre a déssiné (<u>pas</u> de reprise de "matin" par un pronom).

---

[1] - ភាសាខ្មែរគ្មានស្នៀងទេ ។

(៣)-បន្ថែកបានមក ពី បុព្វឋាននីយកម្ម (antéposition) :

(1d)- *Ce paysage, Pierre a dessiné(ល្បះមិនត្រឹមត្រូវ). ;
(2d)- Ce matin, Pierre a dessiné ...(ល្បះត្រឹមត្រូវ).

(៤)-បន្ថែកបានមក ពី សព្វនាមនីយកម្ម (pronominalisation) :

(1e)-Pierre l'a dessiné (ល្បះត្រឹមត្រូវ);
(2e)- សព្វនាមនីយកម្ម នៃ កម្មរង "ce matin" ដោយប្រើ "l'" ទៅមិនរួចទេ តាមវេយ្យាករណ៍បារាំង ។

(៥)-បន្ថែកបានមក ពី "relativisation" វិធីប្រើសព្វនាមភ្ជាប់ "que" (=ដែល) :

(1f)- Ce paysage que Pierre a dessiné + SV (ល្បះត្រឹមត្រូវ) ;
(2f)- * Ce matin que Pierre a dessiné + SV (ល្បះមិនត្រឹមត្រូវ).

(៦)-បន្ថែកបានមកពី វិធីប្រើ "a fait ça" ជំនួស "a dessiné":

(1g)- *Pierre a fait ça ce paysage (ល្បះមិនត្រឹមត្រូវ). ;
(2g)- Pierre a fait ça ce matin (ល្បះត្រឹមត្រូវ) ។

(៧)-បន្ថែកបានមកពី វិធី "សំណួរ" (questionnements) :

(1h)- *Qu'est-ce qui s'est passé ce paysage? (ល្បះមិនត្រឹមត្រូវ).
(2h)- Qu'est-ce qui s'est passé ce matin ? (ល្បះត្រឹមត្រូវ) ។

កំណត់សម្គាល់ : វេយ្យាករណ៍បុរាណថា "ce paysage" ជាកម្មរងផ្ទាល់សម្គាល់វត្ថុ ពីព្រោះ ពាក្យ "paysage" នេះជាពាក្យសម្គាល់វត្ថុ ... ថា "ce matin" ជាកម្មរងទេសកាល ពីព្រោះ ពាក្យ "matin" នេះជា ពាក្យសម្គាល់កាល ។

**២- ចំណោលថ្លែកលើចំណុចខ្លះៗ ក្នុងសៀវភៅវេយ្យាករណ៍មួយចំនួន ខាងវយ:លក្ខណៈវិនិច្ឆ័យរូបនិយម :**

កាលណា ក្នុងសៀវភៅវេយ្យាករណ៍ខ្លះ[1] គេអះអាងថា ឈ្មោះស្រុក ឈ្មោះខេត្ត ឈ្មោះក្រុង ។ល ។ ជាឥត្ថីលិង្គ គឺគេផ្អែកលើអ្វីដែលយើងស្តាប់មិនឮ/មើលមិនឃើញ ផ្ទុយពីពាក្យ "កុមារី", "ឧបាសិកា" ជាដើម ដែលមានព្យាង្គខាងចុង "-រី" និង "-សិកា" ប្លែកពីព្យាង្គខាងចុងនៃពាក្យ "កុមារ", "ឧបាសក" ។ ពាក្យ "យាយ" មានរូបសាស្ត្រដូចពាក្យ "រាយ" ឬ ពាក្យ "នាយ",...ដែរ : ពិតមែនតែពាក្យនេះគ្មានសញ្ញារូបសាស្ត្រអ្វីដែលអាចបង្ហាញថា វាជាពាក្យឥត្ថីលិង្គក៏ដោយ ប៉ុន្តែ យ៉ាងហោចណាស់ ក៏តាមរយៈន័យ វាជាពាក្យទាក់ទងនឹងស្ត្រីភេទដែរ ។ រីឯ ការចាត់ទុកពាក្យសម្គាល់ឈ្មោះស្រុក/ខេត្ត/ក្រុង ជាឥត្ថីលិង្គវិញ គឺជាការសន្មតអាជ្ញាភាព (arbitraire) សុទ្ធសាធ សូម្បីតែលក្ខណៈវិនិច្ឆ័យន័យនិយមក៏គ្មានផង ។

កាលណា គេសិក្សាពីគុណនាមកម្មសិទ្ធិ (adjectifs possessifs) ក្នុងភាសាខ្មែរ[2] គឺ គេយកន័យជាបង្អែកផង ហើយ គេយកវេយ្យាករណ៍បារាំងជាលំនាំផង ។ គេអាចប្រៀបធៀប រវាងកន្សោមពាក្យបារាំង និងកន្សោមពាក្យខ្មែរ ដូចនេះ : mon livre = សៀវភៅខ្ញុំ ; mon ជា adjectif possessif → ដូច្នេះ "ខ្ញុំ"

---

(1) - សូមមើល ពូរ អ៊ុម *វេយ្យាករណ៍ខ្មែរ* បណ្ណាគារគីម សេង ១៩៥៨ ទំព័រ ២៧ និង ទំព័របន្ទាប់ៗ ។

(2) - សូមមើល *វេយ្យាករណ៍* ថ្នាក់ទី៧ ក្រសួងអប់រំ ឆ្នាំ១៩៨២ ទំព័រ៧៤...៧៦ ។

ជាគុណនាមកម្មសិទ្ធ ។ បើ កុំតែមានប្រភេទពាក្យនៃភាសាបារាំងជាប់ក្នុងស្មារតីអ្នកវេយ្យាករណ៍ខ្មែរ គេប្រាកដជាមិនទីកភ្នកទៅរកប្រភេទគុណនាមកម្មសិទ្ធនេះទេ ពីព្រោះ "ខ្ញុំ"ក្នុង"សៀវភៅខ្ញុំ" ឥតមានទិដ្ឋភាព រូប-សម្ព័ន្ធ (aspect morphosyntaxique) អ្វីប្លែកពីទិដ្ឋភាពរូប-សម្ព័ន្ធរបស់ពាក្យ"វេយ្យាករណ៍" ឬ ពាក្យ"និស្សិត"ជាដើម ដែលជានាមស័ព្ទប្រើជាគុណវិសេសន៍ (complétif) ក្នុងកន្សោម "សៀវភៅវេយ្យាករណ៍/សៀវភៅនិស្សិត"នោះទេ : "ខ្ញុំ"ជាសព្វនាម ប្រើជាគុណវិសេសន៍របស់ពាក្យ"សៀវភៅ" ដូចគ្នានឹងនាមស័ព្ទ"វេយ្យាករណ៍" ឬ នាមស័ព្ទ"និស្សិត" ដែរ [1] ។

ដោយគេយកន័យជាមូលដ្ឋាន គេបានចែកគុណនាមក្នុងភាសាខ្មែរជា "គុណនាមប្រក្រតី" និង "គុណនាមកំនត់"[2] ដែលត្រូវនឹង "adjectifs qualificatifs" និង "adjectifs"ដែលមិនមែនជា"adjectifs qualificatifs"ក្នុងភាសាបារាំង។ ក្នុងភាសានេះ "adjectifs qualificatifs"ឥតមានមុខងារសម្ព័ន្ធ (fonction syntaxique) ជា "déterminants" (នាមវិសេសន៍)ទេ ផ្ទុយពី "adjectifs" ឯទៀតដែលសុទ្ធតែជានាមវិសេសន៍ទាំងអស់[3] ។ ចំពោះភាសាខ្មែរវិញ ទាំងគុណនាមប្រក្រតី ទាំងគុណនាមកំណត់ គ្មានគុណនាមណាមួយជានាមវិសេសន៍ទេ (បើ យើងយករូប-សម្ព័ន្ធ ឬ មុខងារ/លក្ខណៈសម្ព័ន្ធជាមូលដ្ឋាន) ។

ក្នុងវេយ្យាករណ៍និយាមបុរាណរបស់គាត់ លោក ម៉ូរីស គ្រេវីស (Maurice Grevisse)បានបញ្ចូលក្នុងបញ្ជីនៃគុណនាមមិនច្បាស់លាស់នូវពាក្យ quelconque, autre & même ក្នុងចំណោមគុណនាមមិនច្បាស់លាស់ឯទៀត ដូច aucun, chaque, plusieurs,... ផងដែរ ។ បើគេយកតែន័យសុទ្ធសាធ គេត្រូវបញ្ចូលពាក្យខ្លះទៀត ដូច nombreux, multiple, indéfini / infini ។ល។ ផងដែរ ពីព្រោះពាក្យទាំងនេះសុទ្ធតែមានន័យមិនច្បាស់លាស់។ ប៉ុន្តែ គេឥតបានបញ្ចូលពាក្យទាំងនោះទេ ពីព្រោះ ក្រៅពីន័យ"មិនច្បាស់លាស់" ដែលជាលក្ខណៈវិនិច្ឆ័យន័យនិយម"ផ្លូវការ" វេយ្យាករណ៍និយាមបុរាណបារាំងបានយកលក្ខណៈវិនិច្ឆ័យមួយទៀត ដោយឥតប្រកាស"ជាផ្លូវការ" គឺលក្ខណៈសម្ព័ន្ធដែលជាលក្ខណៈវិនិច្ឆ័យរូបនិយម។ ពាក្យ aucun / chaque / plusieurs [4] មានមុខងារ(ក្នុង)សម្ព័ន្ធ ដូចមុខងារ articles (ការន្ត) [5] le, la, les ឬ un / une, des ដែរ ផ្ទុយពីពាក្យ nombreux / multiple / indéfini / infini... ដែលមាន

---

(1) - សូមមើល Prum Moal , "Analyse sommaire des structures du cambodgien", revue n°1 - p.51, de l'Institut de la Langue Nationale de l'Académie Royale du Cambodge, décembre 2000;

(2) - សូមមើល *វេយ្យាករណ៍* ថ្នាក់ទី៧ ក្រសួងអប់រំ ឆ្នាំ១៩៨៣ ទំព័រ៧៤ និង ទំព័របន្ទាប់ៗ។

(3) - សូមមើលសេចក្តីនិងឧទាហរណ៍ ខាងក្រោមនិងនៅទំព័រខាងក្រោយ នៃ អត្ថាធិប្បាយដែលកំពុងប្រព្រឹត្តទៅនេះ ទាក់ទងនឹងគុណនាមមិនច្បាស់លាស់ តាមវេយ្យាករណ៍លោក ម៉ូរីសគ្រេវីស (Maurice Grevisse) ។

(4) - សុំយកតែពាក្យទាំងប៉ុន្មាននេះ ក្នុងចំណោមគុណនាមមិនច្បាស់លាស់ដែលមាន។

(5) - ពាក្យ "ការន្ត" ជាពាក្យដែលសាស្ត្រាចារ្យផ្នែកអក្សរសាស្ត្រខ្មែរ នៃសកលវិទ្យាល័យភ្នំពេញ បានប្រើរួចមកហើយ ដើម្បីសម្គាល់ articles របស់ភាសាបារាំង/អង់គ្លេស។

មុខងារ(ក្នុង)សម្ព័ន្ធមិនដូចមុខងារការន្តទេ : គុណនាមមិនច្បាស់លាស់ក្នុងភាសាបារាំងជាការន្តមួយបែប ដែលនៅក្នុងក្រុម déterminants [1] (នាមវិសេសន៍) រីឯ ពាក្យ nombreux / multiple / indéfini / infini មិនអាចដើរតួក្នុងសម្ព័ន្ធជានាមវិសេសន៍ ដូចការន្តឡើយ ។

ដោយវេយ្យាករណ៍និយាមយកលក្ខណៈវិនិច្ឆ័យរូបនិយមមកប្រើដោយលួចលាក់ លក្ខណៈវិនិច្ឆ័យនេះត្រូវគេប្រើមិនទៀងទាត់ : ម្តងប្រើ ម្តងមិនប្រើ។ ពីព្រោះគេភ្លេចប្រើលក្ខណៈវិនិច្ឆ័យរូបនិយម (មុខងារក្នុងសម្ព័ន្ធ) គេក៏បានបញ្ចូលពាក្យ quelconque, autre & même ក្នុងចំណោមគុណនាមមិនច្បាស់លាស់របស់គេ <u>ដោយភាន់ច្រឡំ</u> : ភាន់ច្រឡំ ពីព្រោះ ពាក្យទាំងបីនេះមិនអាចដើរតួជានាមវិសេសន៍ដូចការន្តទេ។ ដើម្បីបង្ហាញឱ្យដឹងថា ណាជាគុណនាមមិនច្បាស់លាស់ (ដែលដើរតួបានដូចការន្ត) ណាមិនមែនជាគុណនាមមិនច្បាស់លាស់ (តែ គឺជាគុណនាមប្រក្រតី / បកតិគុណនាម ទៅវិញ) គប្បី យើងពិនិត្យប្រយោគមួយចំនួន ដូចតទៅ :

(១) - Aucun homme n'est venu .................................... : ល្បះត្រឹមត្រូវ;
(២) - Chaque robe coûte cent francs ........................... : ល្បះត្រឹមត្រូវ;
(៣) - Plusieurs personnes attendent dans le salon ......... : ល្បះត្រឹមត្រូវ;
(៤) - ∗[2] Nombreuses personnes attendent dans le salon : ល្បះ<u>មិន</u>ត្រឹមត្រូវ;
(៥) - ∗ Cherchez <u>quelconque objet</u> pour bloquer la porte : ល្បះ<u>មិន</u>ត្រឹមត្រូវ;
(៦) - ∗ J'ai vu <u>autre personne</u> .................................. : ល្បះ<u>មិន</u>ត្រឹមត្រូវ;
(៧) - ∗ Même personne ne doit pas avoir plusieurs billets : ល្បះ<u>មិន</u>ត្រឹមត្រូវ ។

ថ្វីដ្បិតតែគាត់មិនមែនជាអ្នកអក្សរសាស្ត្រក៏ដោយ (គាត់បានបំភ្លឺក្នុង "ពាក្យលំនាំ" នៃ "ភាសាខ្មែរ" របស់គាត់) ក៏លោក អៀវ កើស បានសិក្សាពីភាសាខ្មែរ ដោយប្រើវិធីបែបភាសាវិទូដែរ : ទិដ្ឋភាពនិងលក្ខណៈនៃភាសាខ្មែរទាំងប៉ុន្មាន ដែលគាត់បានបង្ហាញ សឹងសុទ្ធជាលទ្ធផលនៃការពិនិត្យសង្កេត។ ពិតមែនតែគាត់បានចាត់ទុកពាក្យ ដែលកើតពីការភ្ជាប់ជាមួយ "អ្នក/សេចក្តី/ការ/ទី" ថា ជាពាក្យគួប[3] តែគាត់បានបញ្ជាក់យ៉ាងច្បាស់ថា ពាក្យគួបប្រភេទនេះជាពាក្យគួបប្រភេទទី២ ប្លែកឆ្ងាយពីពាក្យគួបប្រភេទទី១ ដែលជាពាក្យគួបធម្មតា ដូច "កូនកាត់"/ "សៀតផ្កា" ជាដើម។ គាត់បានចាត់ទុក "អ្នក/ សេចក្តី/ការ/ទី" ថា ជា"សព្ទវេយ្យាករណ៍ (instruments grammaticaux" [4]) : គាត់ឥតច្រឡំពាក្យគួបប្រភេទទី១ និង

---

[1] - ក្នុងភាសាបារាំង បើគ្មាន déterminants(នាមវិសេសន៍) ទេ ល្បះមិនអាចមានលក្ខណៈត្រឹមត្រូវឡើយ (លើកលែងតែក្នុងករណីកម្របំផុត) ។

[2] - គួររំលឹកថា សញ្ញាផ្កាយ ∗ មានន័យថា ល្បះនៅខាងស្តាំនៃសញ្ញានេះជាល្បះមិនត្រឹមត្រូវ ។ ល្បះទាំងប៉ុន្មានខាងលើនេះ ដែលមានសញ្ញាផ្កាយ ជាល្បះមិនត្រឹមត្រូវ ពីព្រោះវាគ្មាននាមវិសេសន៍ ។

[3] - សូមអាន អៀវ កើស *ភាសាខ្មែរ* បណ្ណាគារ "មិត្តសើរី" ឆ្នាំ១៩៦៧ ទំព័រ ២១៦ . ២១៧ . ២១៨ ។

[4] - ភាសាវិទូបារាំងច្រើនប្រើថា "outils grammaticaux" ទៅវិញ ។

ពាក្យគួបប្រភេទទី២ទេ ដូចមានពាំនោលរបស់គាត់ ដូចនេះស្រាប់ : "ពាក្យ **អ្នក សេចក្តី ការ ទី** ខ្ញុំចាត់ជាសព្ទវេយ្យាករណ៍ ព្រោះក្នុងទីនេះ ពាក្យទាំងនោះលែងសំដែងសេចក្តីសម្គាល់តាមប្រក្រតីដូចកាល នៅជានាមនាមធម្មតាត្រឡប់មានមុខការដូចបុព្វបទទៅវិញ ហើយពាក្យជំពូកនេះក៏ស្រដៀងគ្នានឹងពាក្យ ផ្សំ"(គំនូសក្រោមបន្ទាត់ជាទង្វើរបស់អ្នកសរសេរអត្ថបទ)។ លោក អៀវ កើស ប្រើ"ពាក្យផ្សំ"ក្នុងន័យថា "ពាក្យកម្លាយ" ឧ. បន់ + ដើរ = បណ្ដើរ : ស្រដៀងគ្នានឹងពាក្យផ្សំ = ស្រដៀងគ្នានឹងពាក្យកម្លាយ។

**៣- លក្ខណៈវិនិច្ឆ័យរូបនិយម និង បញ្ហាបច្ចុប្បន្នភាព : អត្ថិភាពគុណនាមក្នុងភាសាខ្មែរ :**

លោកស្រី ពៅ សាវរស បានប្រកាសថា ភាសាខ្មែរគ្មានគុណនាមទេ។ និស្សិតខ្មែរបានបញ្ចេញប្រតិកម្មសើស្បែកតបទៅវិញ។ ទំនាស់ឥតប្រយោជន៍បានកើតឡើង។ បើ លោកស្រី សាវរស មានអំណត់ ហើយ បើ និស្សិតខ្មែរសុំឱ្យគាត់ពន្យល់គំនិតរបស់គាត់ រួចចាំសួរដេញដោលក្នុងស្មារតីស្ថាបនា ដោយផ្អែកលើភាសាវិទ្យា ការសន្ទនាប្រហែលជាបានផ្តល់គំនិតថ្មីៗជាច្រើន ដែលនាំឱ្យយើងកាន់តែយល់ពីភាសាខ្មែរ។

លោក ហ៊ុហ្វម៉ាន (Franklin Huffman)[1] ហៅគុណនាមខ្មែរថា "adjectival verbs" គឺជាកិរិយាស័ព្ទមួយបែបដែលមានលក្ខណៈដូចកិរិយាស័ព្ទអង់គ្លេសផង និង ដូចគុណនាមអង់គ្លេសផង។ ពិតមែនតែគាត់ភ្ជាប់ពាក្យ"verbs"ទៅជាមួយពាក្យ"adjectival" ហើយ ពិតមែនតែគាត់ឥតបានប្រកាសថា ភាសាខ្មែរគ្មានគុណនាមទេក៏ដោយ ក៏ប៉ុន្តែ គាត់បានដាក់ "adjectival verbs"ទាំងប៉ុន្មានក្នុងក្រុមកិរិយាស័ព្ទ : គំនិតគាត់មិនសូវប្លែកពីគំនិតរបស់លោកស្រី សាវរស ប៉ុន្មានទេ។

ពីព្រោះ អ្នកជំនាញទាំងពីរនាក់មិនបានពន្យល់គំនិតរបស់គាត់ដោយក្បោះក្បាយ គប្បីយើងយកបញ្ហានេះមកពិចារណាឱ្យឃើញថា តើយោបល់អ្នកទាំងពីរជាយោបល់ប្រកបដោយមូលដ្ឋានកម្មវិស័យភាព[2] (sur une base objective) មាំទាំ ឬ យ៉ាងណា។ ដើម្បីឱ្យដឹងថា គុណនាមខ្មែរមានអត្ថិភាពប្លែកពីកិរិយាស័ព្ទឬឥតមាន យើងត្រូវប្រៀបធៀបកិរិយាស័ព្ទទៅនឹងពាក្យដែលយើងបានចាត់ទុកថា ជាគុណនាមនោះឯង។ និស្សិតឈ្មោះ ប៊ី សុខគង់ នឹងសិក្សាពីបញ្ហានេះឱ្យស៊ីជម្រៅ ក្នុងសារណារបស់គាត់ ដែលមានចំណងជើងថា "ប្រភេទពាក្យ ក្នុងភាសាខ្មែរទំនើប"។ យើងរង់ចាំពន្លឺពីការស្រាវជ្រាវរបស់គាត់។ ប៉ុន្តែភ្លាមៗនេះ យើងគ្រាន់តែថា "ផ្សែងបានចេញពីភ្លើង" : មានហេតុសិន ទើបមានផលជាក្រោយ។ អ្វីដែលនាំ

---

[1] - សូមមើល Franklin Huffman, Modern Spoken Cambodian, Yale University Press, pp. 56 & 57, New Haven & London, 1970.

[2] - ពាក្យខ្ចីពីវចនានុក្រម បារាំង-ខ្មែរ របស់លោក តិប យក់ និង ថាវ គន្ធ។

អ្នកជំនាញទាំងពីរនាក់ឱ្យមានយោបល់បែបនេះ គឺមកពីគុណនាមខ្មែរមានលក្ខណៈដូចកិរិយាស័ព្ទលើចំណុចជាច្រើន :

- គេបានសង្កេតឃើញថា នាម "ទំហំ" បានចេញពីគុណនាម "ធំ" ដូចគ្នានឹងនាម "ជំហាន" ដែលបានចេញពីកិរិយាស័ព្ទ "ឈាន" ដែរ ។
- គេអាចប្រើ "មិន" ឬ "កុំ" ជាមួយគុណនាមខ្មែរ ដូចជាមួយកិរិយាស័ព្ទ ដែរ :
  - "ខ្ញុំមិនខ្ពស់" ( ខ្ពស់ = គុណនាម) ដូច "ខ្ញុំមិនទៅ" ( ទៅ = កិរិយាស័ព្ទ) ;
  - "កុំខ្ពស់!" ដូច "កុំទៅ!" ( គុណនាមនិងកិរិយាស័ព្ទមានលក្ខណៈសម្ព័ន្ធដូចគ្នា) ។

ប៉ុន្តែ លោក ប៉ឺ សុខគង់ បានរកឃើញលក្ខណៈសម្ព័ន្ធមួយដែលអាចឱ្យយើងទុកគុណនាមខ្មែរជាប្រភេទពាក្យមួយដោយឡែកប្លែកពីកិរិយាស័ព្ទ ហើយ ប្រហែលជាគាត់នឹងអាចរកឃើញបន្ថែកខ្លះទៀតដើម្បីសង្គ្រោះអត្ថិភាពនៃគុណនាមខ្មែរកុំឱ្យច្រឡំនឹងកិរិយាស័ព្ទទាំងស្រុង ។ តាមគំហើញនេះ :

- គេអាចថា : "លំនៅដ៏ល្អ/ដ៏ស្កុកស្កម្ភ" ( ល្អ/ស្កុកស្កម្ភ = គុណនាម);
- តែ គេមិនអាចថា : "*លំនៅដ៏ស្រឡាញ់/ដ៏ពេញចិត្ត" ( "ស្រឡាញ់/ពេញចិត្ត" = កិរិយាស័ព្ទ), ( គេត្រូវថា : "លំនៅដែលជាទីស្រឡាញ់/ទីពេញចិត្ត" ) ។

**៤- លក្ខណៈវិនិច្ឆ័យរូបនិយម និង ចំណោះបញ្ហាបន្ថែក រវាង កន្សោមពាក្យសេរី និង ពាក្យសមាស :**

វេយ្យាករណ៍ទំនើបត្រូវប្រើលក្ខណៈវិនិច្ឆ័យរូបនិយមគ្រប់ទិសទី : ជាដំបូង ត្រង់កន្លែងណាដែលវេយ្យាករណ៍និយាមប្រើលក្ខណៈវិនិច្ឆ័យន័យនិយម ។ នៅប្រទេសបារាំង និង នៅប្រទេសនៃទ្វីបអាព្រិកដែលប្រើភាសាបារាំងជាភាសាជាតិ គេបានប្រើវិធីថ្មីនេះស្ទើរតែគ្រប់សៀវភៅវេយ្យាករណ៍ទៅហើយ សព្វថ្ងៃនេះ ។

បញ្ហាបន្ថែក រវាង កន្សោមពាក្យសេរី និង ពាក្យសមាស ជាបញ្ហាចម្បងនៃវចនាលេខនៈ[1] (lexicographie) ឬ កិច្ចការអ្នកធ្វើវចនានុក្រម ។ សព្វថ្ងៃ នៅប្រទេសខ្មែរ គេតែងតែផ្អែកលើអព្ភន្តរញាណ[2](intuition) ឬ លើអញ្ញថាភាព ដើម្បីសម្រេចថា កន្សោមពាក្យណាជាកន្សោមពាក្យសេរី ហើយ កន្សោមពាក្យណាជាពាក្យសមាស ។ ភាសាវិទ្យាត្រូវប្រើលក្ខណៈវិនិច្ឆ័យរូបនិយម តាមរយៈតេស្ត ដើម្បីដោះស្រាយបញ្ហានេះ ។ ចំពោះពាក្យសមាសបារាំង គេស្តផ្អែកលើលក្ខណៈវិនិច្ឆ័យរូបនិយមបានផ្តល់លទ្ធផលគួរឱ្យពេញ

---

[1] - ខ្ញុំខ្ចីធាតុ "លេខនៈ" នេះ ពីលោក កេង វ៉ាន់សាក់ ដើម្បីប្រែធាតុបារាំង "graphie" ( មូលភាពនៃការបង្កើតពាក្យថ្មី ឆ្នាំ១៩៦៤ ទំព័រ៣១២) ។

[2] - ពាក្យនេះមានក្នុងវចនានុក្រម បារាំង-ខ្មែរ របស់ លោក ពិប យក់ និង ថាវ គន្ធ ។

ចិត្ត។ ចំពោះពាក្យសមាសខ្មែរវិញ ការអនុវត្តមិនទាន់ផ្តល់លទ្ធផលគួរឱ្យពេញចិត្តនៅឡើយទេ ៖ ការស្វះស្វែងត្រូវប្រឹងប្រែងតទៅទៀត។

តទៅនេះ យើងពិនិត្យការអនុវត្តតេស្តលើពាក្យសមាសបារាំង និង ការអនុវត្តបណ្តោះអាសន្នលើពាក្យសមាសខ្មែរ ៖

**៤,១- ការអនុវត្ត លើ កន្សោមពាក្យបារាំង**[1] ឧ. "pomme de terre" ៖

**៤,១,១- តេស្តបំបែក** (test de séparabilité/d'insertion) ៖

ពាក្យសមាស ដែលកើតពីការផ្សំពាក្យច្រើន (ពីរ ឬ លើសពីពីរ) ត្រូវមានលក្ខណៈដូចពាក្យទោលដែរ គឺមិនអាចទទួលអង្គធាតុពីក្រៅណាមួយឱ្យជែកបំបែករូបសាស្ត្រខ្លួនជាពីរ/បីចំណែកឡើយ។ គេមិនអាចដាក់ពាក្យណាមួយចូលក្នុងពាក្យពហុព្យាង្គដូចពាក្យ "ជំនួញ" ជាដើម។ គេមិនអាចថា "*ជំនេះនួញ" ក្នុងន័យថា "ជំនួញនេះ" ទេ។ ឬ ក៏គេមិនអាចថា "*ក្រចាស់បី" ក្នុងន័យថា "ក្របីចាស់" ដូច្នេះដែរ។ ចំពោះពាក្យសមាសក៏ដូចគ្នានេះដែរ ពីព្រោះ ក្នុងពាក្យសមាស សមាសភាពនីមួយៗបានរំលាយចូលគ្នាទៅហើយ បើពុំនោះសោត កន្សោមពាក្យមិនមែនជាពាក្យសមាសទេ គឺជាកន្សោមសេរី។ ក្រោយពីបានរៀបរាប់ពីអត្ថន័យរបស់តេស្តជែក គប្បីយើងពិនិត្យមើលការអនុវត្តរបស់វា ដូចតទៅ ៖

- គេមិនអាចថា "*pomme nouvelle de terre" ទេ គេត្រូវថា " pomme de terre nouvelle";
- ផ្ទុយពីកន្សោម "permis d'exploitation" ជាដើម ដែលអាចទទួលគុណនាមនៅខាងក្នុង ៖ "permis français d'exploitation"

សេចក្តីសន្និដ្ឋាន ៖ តាមរយៈតេស្តជែក កន្សោម "pomme de terre" ជាពាក្យសមាស។

**៤,១,២- តេស្តតំណាក់កត្តារួម** (test de mise en facteur commun) ៖

តេស្តទាំងអស់មានអត្ថន័យដូចគ្នា ៖ បើតេស្តមិនអាចបំបែកបំបាក់សមាជិកក្នុងគ្រួសារកន្សោមពាក្យណាមួយទេ កន្សោមពាក្យនោះមិនមែនជាកន្សោមសេរីទេ គឺជាកន្សោមផ្សារភ្ជាប់ គឺជាពាក្យសមាស ៖

- គេត្រូវរកពីរ/បីកន្សោមដែលមានសមាសភាពមួយដូចគ្នា ដូចជា "pomme de terre; "pomme d'Adam" & "pomme de pin" ៖ គេមិនអាចថា "*pomme de pin, de terre et d'Adam" ទេ (ភាសាបារាំងមិនអនុញ្ញាតការប្រើប្រាស់បែបនេះ) ;
- តែ គេអាចថា "chefs d'Etat et de gouvernement"

សេចក្តីសន្និដ្ឋាន ៖ តាមរយៈតេស្តកត្តារួម កន្សោម "pomme de terre"ជាពាក្យសមាស។

[1] - សូមអាន Jean-Louis CHISS et alii *Initiation à la linguistique structurale*", tome 1, p.154, Hachette 1981.

៤,១,៣- <u>តេស្តកំណាត់</u> (test de répétition partielle) :

ក្នុងតេស្តកំណាត់ គេកាត់កន្សោមពាក្យចោលមួយភាគ ក្រោយពីបានប្រើកន្សោមនោះទាំងមូលម្តងមកហើយ ។ បើគេកាត់មិនបានទេ (ពីព្រោះ បើគេកាត់ គេបានន័យផ្សេងទៅវិញ) កន្សោមនោះជាពាក្យសមាស :

- Ma mère a acheté 5 kg de <u>pommes de terre</u>; ces <u>pommes</u> sont très bonnes : កន្សោម "ces pommes" កាត់ចេញពី "de terre" មិនមែន "pommes de terre" ទេ ;
- ផ្ទុយទៅវិញ គេអាចថា "La France a envoyé beaucoup de <u>soldats de métier</u> au Tchad; ces <u>soldats</u> sont très combattifs : កន្សោម "ces soldats" ពិតមែនតែគ្មាន "de métier"នៅជាមួយ សម្គាល់ "soldats de métier" ដដែល ។

<u>សេចក្តីសន្និដ្ឋាន</u> :តាមរយៈតេស្តកំណាត់ កន្សោមពាក្យ "pomme de terre"ជាពាក្យសមាស ។

៤,១,៤- <u>តេស្តតំណូរ</u> ( test de commutation) :

តេស្តតំណូរជាវិធីប្តូរចំណែក/សមាសភាពណាមួយនៃកន្សោមដែលយើងចង់ស្ទង់ជាមួយពាក្យណាមួយយកពីក្រៅរើសឱ្យសមស្របតាមស្ថានភាព : ចំពោះ "pomme de terre" យើងអាចប្តូរ "de terre" ជាមួយ "d'inter-saison" :

- បើគេប្តូរ "pomme de terre" ទៅជា "pomme d'inter-saison" បញ្ញត្តិសម្គាល់ "pomme" ក្នុង "pomme de terre" ត្រូវរលាយ ពីព្រោះ ពាក្យ "pomme" ក្នុង "pomme d'inter-saison" និង ក្នុង "pomme de terre" ឥតមានន័យដូចគ្នាទេ;
- ផ្ទុយទៅវិញ បើគេប្តូរ "fauteuil à roulettes" ទៅជា "fauteuil à pédale" បញ្ញត្តិសម្គាល់ "fauteuil" នៅដដែល ។

<u>សេចក្តីសន្និដ្ឋាន</u> : តាមរយៈតេស្តតំណូរ កន្សោម "pomme de terre"ជាពាក្យសមាស ។

<u>កំណត់សម្គាល់</u> : តេស្តតំណូរជាតេស្តពិបាកប្រើ : តែ ដើម្បីឱ្យដឹងថាកន្សោម ដែលយើងស្ទង់ ជាពាក្យសមាស ឬ ជាកន្សោមសេរី យើងអាចប្រើតេស្តតែបីក៏ជាការគ្រប់គ្រាន់ណាស់ទៅហើយ : យើងអាចសន្និដ្ឋានថា កន្សោមដែលយើងស្ទង់ជាពាក្យសមាស ១00% ឬ ជាពាក្យសមាសតែត្រឹមកម្រិតណាមួយ ទៅតាមលទ្ធផលនៃតេស្តទាំងប៉ុន្មាននោះ ។

**៤,២- ការអនុវត្ត លើ កន្សោមពាក្យខ្មែរ** ឧ. "ស្បែកជើង" :

៤,២,១- <u>**តេស្តថែត**</u> :

- គេមិនអាចថា "*ស្បែកថ្មីជើង"(ឬ *ស្បែកនៃជើង/ស្បែករបស់ជើង" ទេ គេត្រូវថា "ស្បែកជើងថ្មី";

- ផ្ទុយទៅវិញ កន្សោម "ស្បែកគោ/ស្បែកស្គរ" ជាដើម ដែលអាចទទួលគុណវិសេសន៍ (complétif) ឬ ពាក្យឈ្នាប់ណាមួយ ដូចជា "ស្បែករបស់គោ" ឬ "ស្បែកសម្រាប់ជាសស្គរ" ។

<u>សេចក្ដីសង្កេត និង សេចក្ដីសន្និដ្ឋាន</u> :

(១)- បើគេថា "ស្បែកចាស់ស្គរ"លទ្ធផល ដែលបានមក ជាកន្សោមមិនសមស្របតាមទម្លាប់នៃការនិយាយស្ដីរបស់ខ្មែរទេ ប៉ុន្តែបើគេថា "ស្បែកស្គរចាស់" គេច្រើនយល់ថា អ្វីដែលចាស់នោះ គឺស្គរ : ដូច្នេះ ដើម្បីចៀសវាងន័យពាំត្រណោត គេត្រូវថា "ស្បែកចាស់នៃ/របស់ស្គរ" ទោះកន្សោមបែបនេះមិនសូវស្រួលស្ដាប់ក៏ដោយ( ការប្រើពាក្យ "នៃ"សម្រាប់ភ្ជាប់គុណវិសេសន៍(complétif)ទៅរងវិសេសន៍(complété) ជាទម្លាប់ថ្មី ក្នុងភាសាខ្មែរ ហើយ ដែលជាហេតុនាំឱ្យទ្រគោះត្រចៀកក្នុងករណីខ្លះ ។ ប៉ុន្តែភាសាយើងកំពុងស្វែងរកតម្លាភាព : យើងមិនអាចទុកកន្សោមណាដែលមានន័យពាំត្រណោតឱ្យនៅដដែល តទៅទៀតទេ) ។

(២)- ទោះបីការប្រើតេស្តមិនបានផ្ដល់លទ្ធផលល្អប្រពៃ ដូចការប្រើជាមួយកន្សោមបារាំង "pomme de terre"ក៏ដោយ យើងក៏អាចសន្និដ្ឋានដោយសមហេតុផលថា : តាមរយៈតេស្តដែកនេះ កន្សោម "ស្បែកជើង"ជាពាក្យសមាស ។

**៤,២,២- <u>តេស្តតំណាក់កត្តារួម</u>** :

ក្នុងភាសាខ្មែរ ការដាក់កត្តារួមមិនមែនឥតមានទេ ឧ. "<u>ការទូទាត់បំណុល</u>ថ្លៃទិញ ឬ ថ្លៃឈ្នួល" [1] ដែលក្នុងនោះ កន្សោម"ការទូទាត់បំណុល"ត្រូវភ្ជាប់ទៅ "ថ្លៃទិញ"ផង និងទៅ "ថ្លៃឈ្នួល"ផង ឬ "លោក/អ្នកគ្រូ"/ "សេចក្ដីស្នេហា និង មោទនភាព<u>ជាតិ</u>"[2] ដែលនៅក្នុងនោះ ពាក្យ "គ្រូ"ជាកត្តារួមរបស់"លោក" និងរបស់"អ្នក" ហើយ ពាក្យ "ជាតិ"ជាកត្តារួមរបស់"សេចក្ដីស្នេហា" និង របស់"មោទនភាព" ។ ប៉ុន្តែ ក្នុងការភ្ជាប់រងវិសេសន៍(complété)ជាមួយគុណវិសេសន៍(complétif)គេមិនសូវប្រើ "នៃ"ទេ ឧ.ប្រមុខរដ្ឋ/ប្រមុខរដ្ឋាភិបាល : ដូច្នេះហើយ យើងពិបាកប្រើតេស្តកត្តារួមជាទូទៅ ដើម្បីរកបន្ទែក រវាង កន្សោមសេរី និងកន្សោមផ្សារជាប់ដែលជាពាក្យសមាសណាស់ ។ បើយើងដាក់កត្តារួម : ប្រមុខ (រដ្ឋនិងរដ្ឋាភិបាល) យើងត្រូវបាន "ប្រមុខរដ្ឋ និង រដ្ឋាភិបាល" ទៅវិញ ។ លុះណា យើងប្រើ "នៃ" ទើបយើងអាចភ្ជាប់ "ប្រមុខ" ទៅ "រដ្ឋ" ផង និង ទៅ "រដ្ឋាភិបាល"ផង :"ប្រមុខនៃរដ្ឋ និង នៃរដ្ឋាភិបាល" (ការនិយាយបែបនេះមិនស្របតាមទម្លាប់ខ្មែរទេ នៅបច្ចុប្បន្នកាលនេះ) ។

---

[1] - យោង : "សេចក្ដីជូនដំណឹង ស្ដីពីការទូទាត់...", <u>រស្មីកម្ពុជា</u> ទំព័រក១ ថ្ងៃពុធ ០៦ - ០២ - ០២ ។

[2] - យោង : *ភាសាខ្មែរ* ថ្នាក់ទី៧ ក្រសួងអប់រំ ឆ្នាំ២០០១ ក្នុងអារម្ភកថា និង នៅទំព័រ២ ។ ការប្រើកត្តារួមថា "លោក/អ្នកគ្រូ"ជាការរំលោភលើទម្លាប់ដែលខ្មែរតែងតែថា "លោកគ្រូ អ្នកគ្រូ" ។

ប៉ុន្តែ ចំពោះកន្សោម"ស្បែកជើង"វិញ យើងអាចប្រើតេស្តកត្តារួមបានដោយសុវត្ថិភាព : ស្បែក (* គោនិងជើង) = "* ស្បែកគោនិងជើង "។

សេចក្តីសន្និដ្ឋាន : តាមរយៈតេស្តនេះ កន្សោម"ស្បែកជើង"ជាពាក្យសមាស ពីព្រោះ កាលណាគេដាក់កត្តារួម លទ្ធផល ដែលបានមក មិនត្រឹមត្រូវតាមទម្លាប់នៃការនិយាយស្តី ក្នុងភាសាខ្មែរទេ។

៤,២,៣- តេស្តកំណាត់ :

- យើងមិនអាចថា : "ម្តាយខ្ញុំបានទិញស្បែកជើងពីរគូ ស្បែកនោះល្អណាស់" ពីព្រោះ ស្បែកមិនមែនស្បែកជើងទេ;
- ផ្ទុយពីនេះ គេអាចថា "ខ្ញុំបានទិញតុបាយពីរ កាលពីម្សិលមិញ។ តុនោះល្អណាស់" : "តុនោះ" គឺជា "តុបាយ"ទាំងពីរនោះឯង។

សេចក្តីសន្និដ្ឋាន : តាមរយៈតេស្តកំណាត់ កន្សោម "ស្បែកជើង"ជាពាក្យសមាស។

៤,២,៤- តេស្តតំណូរ :

ដូចយើងបានឃើញរួចមកហើយ( កាលយើងស្ទង់ពាក្យសមាសបារាំង) យើងអាចប្រើតេស្តតំណូរនេះ ដូចតទៅ:

- យើងអាចដូរ"ស្បែកជើង"ទៅជា "ស្បែកគោ" : តាមរយៈវិធីនេះ យើងបានបំបែកចេញពីកន្សោម "ស្បែកជើង" នូវពាក្យ"ស្បែក" និង "ជើង" ។ ប៉ុន្តែ ពាក្យ"ស្បែក"ម្នាក់ឯងមិនអាចសម្គាល់ "ស្បែកជើង"បានទេ : ការបំបែកកន្សោម"ស្បែកជើង"ជាចំណែកបានបំផ្លាញន័យរបស់ពាក្យ "ស្បែក" នៃអង្គភាព "ស្បែកជើង"។
- ផ្ទុយពីនេះ បើ យើងដូរកន្សោម "ស្បែកគោ" ទៅជា "ស្បែកក្របី" យើងសង្កេតឃើញថា ពាក្យ "ស្បែក" ដែលយើងបានបំបែកចេញពីកន្សោម "ស្បែកគោ" រក្សាន័យដើមនៅដដែល។

សេចក្តីសន្និដ្ឋាន : ដូចយើងបានដឹងរួចមកហើយ តេស្តតំណូរជាតេស្តពិបាកប្រើណាស់ : តែ ប្រើតេស្តតែពីរក៏ជាការគ្រប់គ្រាន់ហើយ ដើម្បីឱ្យដឹងថា កន្សោមពាក្យជាកន្សោមសេរី ឬ ជាពាក្យសមាស។ ម្យ៉ាងទៀត ពិតមែនតែមានការពិបាក យើងក៏អាចសន្និដ្ឋានតាមរយៈតេស្តតំណូរដែលយើងបានប្រើខាងលើនេះ ថា កន្សោម "ស្បែកជើង"ជាពាក្យសមាស គួរឱ្យទុកចិត្តបានដែរ។

កំណត់សម្គាល់ : ដូចគ្នានឹងករណីពាក្យសមាសបារាំងដែរ គេអាចសន្និដ្ឋានថា កន្សោមដែលគេស្ទង់ជាពាក្យសមាស ១០០% ឬ ជាពាក្យសមាសតែត្រឹមកម្រិតណាមួយ ទៅតាមលទ្ធផលនៃតេស្តទាំងប៉ុន្មាន ដែលគេបានប្រើ។

**សេចក្ដីសន្និដ្ឋាន លើ អត្ថបទ :**

ភាសាវិទូតូចធំតែងនិយមប្រើលក្ខណៈវិនិច្ឆ័យរូបនិយម ដើម្បីសិក្សាពីភាសា ទោះគាត់បានប្រកាសក្តែងៗក្តី ឬ ទោះគាត់មិនបានប្រកាសបញ្ជាក់ក្តី។ ប៉ុន្តែ យើងបានដឹងហើយថា អ្នកអក្សរសាស្ត្របានសិក្សាពីភាសាតាំងពីយូរយារណាស់មកហើយ ដោយយកទស្សនវិជ្ជាជាមូលដ្ឋាន។ ក្នុងអត្ថបទនេះ ខ្ញុំបានគន់មើលចំណុចមួយចំនួន ក្នុងវេយ្យាករណ៍ខ្មែរនិងក្នុងវេយ្យាករណ៍បារាំងមួយចំនួន ដើម្បីស្ទង់ឥទ្ធិពលនៃភាសាវិទ្យាក្នុងសៀវភៅទាំងនោះ។ ពិតមែនតែ ការពិនិត្យឥតបានធ្វើឡើងជាលំដាប់លំដោយគ្រប់ចំណុចទាំងអស់ក៏ដោយ យើងក៏អាចមើលឃើញថា វេយ្យារកណ៍ខ្មែរទាំងប៉ុន្មាន ដែលខ្ញុំបានពិនិត្យ នៅប្រើលក្ខណៈវិនិច្ឆ័យន័យនិយម នៅឡើយ។

តាមរយៈលក្ខណៈវិនិច្ឆ័យរូបនិយម គេពិបាកបញ្ចូលលក្ខណៈនៃភាសាបរទេសក្នុងភាសាខ្មែរណាស់។ ផ្ទុយទៅវិញ បើគេប្រើលក្ខណៈវិនិច្ឆ័យន័យនិយម គេអាចបញ្ចូលលក្ខណៈភាសាបរទេសក្នុងភាសាខ្មែរបានដោយងាយ ឧ. គេអាចថា ភាសាខ្មែរមានគុណនាមកម្មសិទ្ធិ ថាមានលិង្គ ថាមានអ្វីច្រើនទៀតដែលខុសពីការពិត ដែលជាហេតុនាំឱ្យមានការវិលវល់ក្នុងស្មារតី នាំឱ្យអ្នកខ្លះយល់ថា វេយ្យាករណ៍ខ្មែរឥតមានប្រយោជន៍។ យើងសង្ឃឹមលើលក្ខណៈវិនិច្ឆ័យរូបនិយម :

- ដើម្បីធ្វើការពិពណ៌នាពីភាសាខ្មែរឱ្យស្របតាមលក្ខណៈពិតប្រាកដរបស់ភាសានេះ (1) ;
- ដើម្បីឱ្យអ្វីៗទាំងប៉ុន្មាន ដែលមានក្នុងសៀវភៅវេយ្យាករណ៍ខ្មែរ សុទ្ធតែមានប្រយោជន៍ដល់ការបង្រៀន / ការរៀនភាសានេះឯង។

x x

x

(1) - គប្បី កុំច្រឡំភាសា និង អក្ខរាវិរុទ្ធរបស់ភាសា។

# គន្ថនិទ្ទេស

## ១- ស្នាដៃនៃចំណេះមូលដ្ឋាន :

- Benveniste (Émile), Problèmes de linguistique générale; Gallimard 1966;
- Bloomfield (Léonard), Le langage, Payot 1970;
- Chiss (Jean-Louis) et alii , "Initiation à la problèmatique structurale" , Tome 1, Hachette université, 1977;
- Chomsky (Noam), Structures syntaxiques, Seuil 1969;
- Chomsky (Noam), Aspects de la théorie syntaxique, Seuil 1971;
- Chomsky (Noam), Questions de sémantique, Seuil 1975;
- Gagnepain (Jean), Du vouloir dire – Traité d'épistémologie des sciences humaines – tome 1, Du signe & de l'outil, Éditions Livre & Communication , Paris 1990; tome 2, De la personne & de la norme, Éditions Livre & Communication Paris 1991; tome 3, Guérir l'homme, former l'homme, sauver l'homme, Éditions De Boeck & Larcier S.A, Bruxelles 1995;
- Gleason (H.A.), Introduction à la linguistique, Larousse 1969;
- Grammont (Maurice), Traité de phonétique, Delagrave 1960;
- Hjelmslev (Louis), Prolégomènes à une théorie du langage, Minuit 1968;
- Jakobson (Roman), Essai de linguistique générale, Minuit 1963;
- Lyons (John), Linguistique générale, Larousse 1970;
- Malmberg (Bertil), Les nouvelles tendances de la linguistique, PUF 1966;
- Malmberg (Bertil), La phonétique, PUF 1975;
- Martinet (André), Éléments de linguistique générale, A. Colin 1970;
- Martinet (André), La linguistique synchronique, PUF 1968;
- Martinet (André), Syntaxe générale, A. Colin 1985;
- Rey (Alain), La lexicologie, Klincksieck 1970;
- Saussure (Ferdinand de), Cours de linguistique générale, Payot 1960;
- Wartburg (Walther), Problèmes et méthodes de linguistique, PUF 1963;

## ២- ស្នាដៃជំនាញឯកទេស :

### ២,១- ជាភាសាខ្មែរ :

- កេង វ៉ាន់សាក់ , មូលភាពនៃការបង្កើតពាក្យថ្មី , មហាវិទ្យាល័យអក្សរសាស្ត្រភ្នំពេញ ឆ្នាំ ១៩៦៤;
- ក្រសួងអប់រំ, វេយ្យាករណ៍ថ្នាក់ទី៥ , រោងពុម្ពរណសិរ្ស , ១៩៨៣ ;
- ក្រសួងអប់រំ , វេយ្យាករណ៍ថ្នាក់ទី៦ , រោងពុម្ពរណសិរ្ស , ១៩៨៣ ;
- ក្រសួងអប់រំ ,វេយ្យាករណ៍ថ្នាក់ទី៧ , រោងពុម្ពរណសិរ្ស , ១៩៨៣ ;
- ក្រសួងអប់រំ , ភាសាខ្មែរថ្នាក់ទី៧ , ២០០១ ;
- ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរ, បណ្ណាគារ គីម សេង , ភ្នំពេញ ១៩៥៨;

- ព្រុំ ម៉ល់ , "លទ្ធភាពបង្កើតពាក្យនិងការបង្កើតពាក្យ ក្នុងភាសាខ្មែរ" , ទស្សនាវដ្ដីលេខ២ ខែមិថុនា ២០០១ នៃវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា ;
- ឡុង សៀម , ស្ថាននាមវិទ្យា , ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ , ១៩៩៧ ;
- ឡុង សៀម , បញ្ហាវចនស័ព្ទវិទ្យាខ្មែរ, ផ្សាយដោយអ្នកនិពន្ធ , ភ្នំពេញ ១៩៩៩ ;
- អ៊ុក វិបុល , វេយ្យាករណ៍ខ្មែរទំនើប ថ្នាក់ទី ១២ , ផ្សាយដោយអ្នកនិពន្ធ , ភ្នំពេញ ២០០១;
- អៀវ កើស , ភាសាខ្មែរ, បណ្ណាគារ មិត្តសើរី ភ្នំពេញ ឆ្នាំ ១៩៦៧ ;
- អ៊ុំ ឈុំ , ពាក្យ, រោងពុម្ពខ្មែរ ភ្នំពេញ ឆ្នាំ ១៩៥២ ។

## ២.២- ជាភាសាបរទេស :

- Gorgoniyev (Y.A.), The Khmer language (traduit du russe) Mouscou 1966;
- Grevisse (Maurice), "Précis de grammaire française", Duculot, Paris-Gumbloux 1969;
- Huffman (Franklin), Modern Spoken Cambodian, Yale University Press, New Haven & London 1970;
- Khuon (Sokhamphu) Le système phonétique de la langue khmère, Université Humbolt (RDA), 1969;
- Long (Seam), Les lexèmes primaires et leur champ sémantique en khmer, 29e congré des Orientalistes à Paris août 1973;
- Martini (Fraçois), La langue cambodgienne, École Nationale des Langues Orientales, Paris;
- Prum (Moal), "Notions de genre et de nombre en cambodgien", revue n° 3 de la Communauté Khmère d'Outre-Mer , Paris 1964;
- Prum (Moal/Marc), "Processus sociolinguistique de la transformation du système lexicologique du khmer", revue Tétralogiques n°7 mai 1989, UFR du Langage, Presse Universitaire Rennes II ;
- Prum (Moal/Marc), "Esquisse d'un cadre théorique pour une sociolinguistique systémique", CIRL n°32 décembre 1996, Institut de Linguistique Appliquée , Université d'Abidjan , (Côte d'Ivoire) ;
- Prum (Moal), "Analyse sommaire des structures du cambodgien", revue n°1 décembre 2000 de l'Institut de la Langue Nationale de l'Académie Royale du Cambodge, Phnom-Penh .

# មាតិការបស់អត្ថបទ


បុព្វយោគ ........................................ ទំព័រ៣៧

លក្ខណៈវិនិច្ឆ័យរូបនិយម ........................................ --៣៨

១- ប្រភេទនៃលក្ខណៈវិនិច្ឆ័យរូបនិយម ........................................ --៣៨

១.១- លក្ខណៈវិនិច្ឆ័យរូបនិយម ផ្អែកលើ លក្ខណៈរូបសាស្ត្រ/រូបពាក្យ ........................................ --៣៨

១.២- លក្ខណៈវិនិច្ឆ័យរូបនិយម ផ្អែកលើ សូររលកក្នុងល្បះ ........................................ --៣៨

១.៣- លក្ខណៈវិនិច្ឆ័យរូបនិយម ផ្អែកលើ សៀង/កម្ពស់សូរសំឡេង ........................................ --៣៩

១.៤- លក្ខណៈវិនិច្ឆ័យរូបនិយម ផ្អែកលើ លក្ខណៈសម្ព័ន្ធ ........................................ --៣៩

២- ចំណោលភ្នែកលើចំណុចខ្លះៗក្នុងសៀវភៅវេយ្យាករណ៍មួយចំនួន តាមរយៈលក្ខណៈវិនិច្ឆ័យរូបនិយម........................................ --៤០

៣- លក្ខណៈវិនិច្ឆ័យរូបនិយម និង បញ្ហាបច្ចុប្បន្នភាព : អត្ថិភាពគុណនាមក្នុងភាសាខ្មែរ ........................................ --៤៣

៤- លក្ខណៈវិនិច្ឆ័យរូបនិយម និង ដំណោះបញ្ហាបន្លែករវាងកន្សោមពាក្យសេរីនិងពាក្យសមាស --៤៤

៤.១- ការអនុវត្តលើកន្សោមពាក្យបារាំង ........................................ --៤៥

៤.១.១- តេស្តជែក ........................................ --៤៥

៤.១.២- តេស្តតំណាក់កត្តារួម ........................................ --៤៥

៤.១.៣- តេស្តកំណាត់ ........................................ --៤៦

៤.១.៤- តេស្តតំណូរ ........................................ --៤៦

៤.២- ការអនុវត្តលើកន្សោមពាក្យខ្មែរ ........................................ --៤៦

៤.២.១- តេស្តជែក ........................................ --៤៦

៤.២.២- តេស្តតំណាក់កត្តារួម ........................................ --៤៧

៤.២.៣- តេស្តកំណាត់ ........................................ --៤៨

៤.២.៤- តេស្តតំណូរ ........................................ --៤៨

សេចក្តីសន្និដ្ឋានលើអត្ថបទ ........................................ --៤៩

គន្ថនិទ្ទេស ........................................ --៥០

# អំពីការកែប្រែអក្ខរាវិរុទ្ធខ្មែរ

រៀបរៀង ដោយ អនុគណៈកម្មាធិការនៃវិជ្ជាស្ថានសង្គមវិទ្យា

## សេចក្តីផ្តើម

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ នៅសាធារណរដ្ឋប្រជាមានិតកម្ពុជា អនុគណៈកម្មធិការពិនិត្យ និង ស្រាវជ្រាវ ឃើញមានការប្រើប្រាស់អក្ខរាវិរុទ្ធខ្មែរយើងខុសប្រក្រតី ជាហេតុធ្វើឱ្យមានការច្របូកច្របល់យ៉ាងខ្លាំង។ នាឆ្នាំ១៩៨៣ យើងសង្កេតឃើញថា មានការប្រែប្រួលអក្ខរាវិរុទ្ធខ្លះៗនៅក្នុងទំព័រសារពត៌មាន និង អត្ថបទជាផ្លូវការខ្លះៗ។ នៅក្នុងឆមាសទី២ នាឆ្នាំ ១៩៨៣ យើងសង្កេតឃើញមានការប្តូរអក្ខរាវិរុទ្ធនេះ ជាខ្សែចង្វាក់តែម្តង។ ទន្ទឹមនឹងនេះ ពាក្យដែលចេញមកពីការកែប្រែអក្ខរាវិរុទ្ធជាច្រើន ដែលយើងពុំដែលឃើញមាននៅក្នុងវចនានុក្រមខ្មែរ ក៏លេចធ្លោឡើងដែរ ហើយនៅក្នុងនោះ មានពាក្យជាច្រើនដែលប្រាសចាកន័យរបស់ពាក្យ ដែលមាននៅក្នុងវចនានុក្រមខ្មែរថែមទៀត។

បន្ទាប់ពីបានធ្វើការពិនិត្យ និង ស្រាវជ្រាវយ៉ាងហ្មត់ចត់អំពីបញ្ហានេះ អនុគណៈកម្មាធិការពិនិត្យ និង ស្រាវជ្រាវ បានរកឃើញនូវមូលហេតុនៃបាតុភូតនេះ ដែលបណ្តាលមកពីឥទ្ធិពលនៃអ្នកប្រាជ្ញអក្សរ-សាស្ត្រខ្មែរយើងមួយចំនួន ដែលបាននាំគ្នាបំផុសចលនាអក្សរសាស្ត្រមួយឈានទៅរក "ខេមរនីយកម្ម" ទាំងស្រុងនៃភាសាខ្មែរ គឺមានន័យថា បំបាត់ចោលបន្តិចម្តងៗនូវពាក្យបាលី/សំស្ក្រឹត ទាំងឡាយ ដែលមាននៅក្នុងភាសាខ្មែរយើង។ ចលនានេះចាប់ផ្តើមកើតឡើង នៅមហាវិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រ កាលពីជំនាន់ សីហនុ លន់ នល់ ប៉ុន្តែ ត្រូវបាត់ឥទ្ធិពលវិញ ដោយគ្មានការគាំទ្រពីប្រជាជន ពីកវីនិពន្ធជាច្រើន។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏អតីតសិស្សមហាវិទ្យាល័យអក្សរសាស្ត្រមួយចំនួន ដែលចង់បានភាសាខ្មែរមួយមានលក្ខណៈខ្មែរសុទ្ធ បានខិតខំនាំគ្នាស្រាវជ្រាវរកពាក្យខ្មែរពីបុរាណកាលមកប្រើវិញ ហើយនាំគ្នាតាក់តែងជាវេយ្យាករណ៍ និង វិធានផ្សេងៗ ដើម្បីធ្វើឱ្យក្លាយពាក្យខ្មែរបុរាណទាំងនោះ ទៅជាពាក្យថ្មីៗមួយចំនួន ដើម្បីយកទៅជំនួសពាក្យខ្មែរ ដែលខ្ចីមកពីបាលី និង សំស្ក្រឹត ទោះជាពាក្យទាំងនេះបានត្រូវគេប្រើប្រាស់រត់មាត់ទៅហើយក្តី។ ប៉ុន្តែ ការខំប្រឹងប្រែង ដែលប្រកបទៅដោយឧត្តមគតិដ៏ខ្ពង់ខ្ពស់នេះ ប្រែទៅជាបង្កើតភាពច្របូកច្របល់ និង អនាធិបតេយ្យ ដែលនឹងធ្វើឱ្យភាសាខ្មែរទាំងមូលរលាយសាបសូន្យទៅវិញ។ អភិក្រមនៃមហន្តរាយនេះបណ្តាលមកពីការយកពាក្យខ្មែរពីបុរាណ ដែលខ្មែរយើងបច្ចុប្បន្ននេះ ស្តាប់ពុំបាន និង ពុំយល់ទាល់តែសោះនោះ មកប្រើជំនួសពាក្យខ្មែរថ្មី ដែលមានឫសគល់ពីបាលី/សំស្ក្រឹតនោះ ហើយ នឹងបង្កើតផលវិបាកដ៏ធ្ងន់ធ្ងរ ដល់ការរីកចម្រើននៃភាសាខ្មែរយើងនាពេលបច្ចុប្បន្ន និង ទៅអនាគតកាលថែមទៀត។ មួយចំណែកទៀត វេយ្យាករណ៍ និង វិធានទាំងឡាយ ដែលអ្នកប្រាជ្ញទាំងនោះបានបង្កើត

ឡើង គ្មានលក្ខណៈរឹងមាំទេ ហើយ ថែមទាំងគ្មានឯកភាពគ្រប់គ្រាន់ទៀត ពីព្រោះ ចលនានេះបែកចេញជានិន្នាការផ្សេងៗទៀត ដែលគ្មានអ្វីអាចទប់ទល់ ឬ ផ្សះផ្សារបានឡើយ។ វិធានខ្លះ ដែលគេបង្កើតសម្រាប់ពន្យល់ចលនានៃការក្លាយពាក្យពីកិរិយាស័ព្ទទៅជានាមនៅក្នុងភាសាខ្មែរ បានត្រូវអ្នកប្រាជ្ញទាំងនោះយកទៅអនុវត្ត ដើម្បីបង្កើតពាក្យខ្មែរមួយដ៏ចម្លែកទៅវិញ ជាហេតុនាំឱ្យកើតឡើងនូវពាក្យជាច្រើន ដែលខ្មែរយើងពុំដែលប្រើទាល់តែសោះ ឬ មួយដែលខ្មែរយើងធ្លាប់ប្រើដែរ ប៉ុន្តែ ជាពាក្យដែលគេប្រើនៅក្នុងន័យផ្សេងពីន័យដែលកំណត់ដោយវិធានថ្មីនេះ។ ហេតុដូច្នេះហើយ បានជាយើងសង្កេតឃើញថា ពាក្យដែលចេញមកពីការកែប្រែអក្ខរាវិរុទ្ធថ្មីៗ ដ៏ចម្លែកទាំងនេះ បានទៅជាន់ន័យរបស់ពាក្យខ្មែរយើង ដែលយើងធ្លាប់ប្រើជាយូរយារណាស់មកហើយ។ ផលវិបាកក្នុងការយកពាក្យខ្មែរ ដែលគ្មានឫសគល់ចេញពីបាលី និង សំស្ក្រឹត ឬ ខ្មែរបុរាណមកប្រើជំនួសពាក្យបាលី និង សំស្ក្រឹត គឺធ្វើឱ្យន័យរបស់ពាក្យវិលវល់រកយល់ពុំបានសោះ បើគេមិនរៀន"ភាសាខ្មែរថ្មី"នេះឡើងវិញទាំងអស់ ឬ បើគ្មានវចនានុក្រមនៃ"ភាសាខ្មែរថ្មី"មួយជាកំហិតទេនោះ។ ម្យ៉ាងទៀត ការបំបែកពាក្យ ដែលផ្អែកតែទៅលើវិធានទាំងប៉ុន្មាននោះ ក៏មិនអាចឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃភាសាវិទ្យាសាស្ត្រ ដែលបែកជាកូនចៅ ហើយដែលទាមទារនូវបច្ឆិមបទ( suffixe) សមស្របទៅតាមបញ្ញត្តិរបស់វិទ្យាសាស្ត្រថែមទៀត។ មិនតែប៉ុណ្ណោះ វិធី ឬ វិធាន ដែលគេយកទៅប្រើ ដើម្បីធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទនោះសោត ធ្វើឱ្យបាត់លក្ខណៈច្បាស់លាស់នៃន័យរបស់ពាក្យក្លាយតាមសូរស័ព្ទទាំងនោះទៀត គឺធ្វើឱ្យបាត់លក្ខណៈសម្គាល់ ករណនាម និង សភាវនាម ទៀត។ ឧ. ទិញ > ទំនិញ ( ការទិញ ឬ របស់ដែលគេទិញ ឬ លក់ ?) ដាំ > ដំណាំ ។ ពាក្យក្លាយតាមសូរស័ព្ទខ្លះធ្វើឱ្យច្រឡំន័យ ឬ ប្រាសចាកន័យ ឬ ជាន់ន័យតែម្ដង។ ឧ. ចេញ > ចំណេញ ( ការចេញ ឬ ប្រាក់ចំណេញ?) ព្រាង > ពង្រាង (ជាន់នឹង កិ. ពង្រាង) ប្រើ > បម្រើ ( ជាន់នឹង កិ.បម្រើ) នាំ > លំនាំ ....។ ម្យ៉ាងទៀត បើយកវិធានសម្រាប់ពន្យល់ការធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទដែលអ្នកប្រាជ្ញ ឬ ប្រជាជនបានធ្វើរួចមកហើយនោះទៅធ្វើជាវិធានសម្រាប់បង្កើតពាក្យថ្មីនោះ គឺយើងនឹងត្រូវដូរភាសាខ្មែរទាំងមូលជាចាំបាច់ ពីព្រោះ មកទល់នឹងបច្ចុប្បន្ននេះ យើងមានពាក្យបាលី និង សំស្ក្រឹត ដែលយើងបានប្រើហូរហែរតមាត់ ចាំស្ទាត់រួចស្រេចអស់ទៅហើយ ។ វិធានទាំងនេះក៏មិនមែនបានត្រូវប្រជាជនយកទៅប្រើជាកំហិតនោះដែរទេ ពីព្រោះ យើងសង្កេតឃើញថា ពាក្យខ្មែរខ្លះមិនមែនសុទ្ធតែចេញមកពីវិធានទាំងនោះឡើយ។ ឧ. ធ្វើ មិនមែនទាញទៅទង្វើ ទេ ពីព្រោះ ខ្មែរយើងកំណត់យកពាក្យអំពើ (អំពី)ទៅវិញទេ។ ឈឺ មិនមែន ទាញទៅ ជំងឺ ទេ ព្រោះខ្មែរយើងកំណត់យកពាក្យ ជំងឺ ទៅវិញទេ។ ឆី មិនមែនទាញទៅ ចំហី ទេ គឺខ្មែរគេកំណត់យក ចំណី ទៅវិញ។ ប្រសិនបើយើងយកវិធាននោះទៅបង្កើតពាក្យថ្មីដោយមិនកំណត់ ករណនាម (ការ ឬ សេចក្ដីភាព) ឱ្យច្បាស់លាស់ទេនោះ យើងនឹងឈានទៅបង្កើតភាសាខ្មែរមួយថ្មីទៀត ជាចាំបាច់ :

១- រីក > របីក , រួម > របួម .......

ឧទាហរណ៍ : របីកដំបៅ , របួមចំណែក

២- ចូលរួម > ចំណូលរួម (ការចូលរួម ឬ ប្រាក់ចំណូលសរុប?)

ចំពោះការលុបចោលពាក្យបាលី ឬ សំស្ក្រឹតដោយឆន្ទៈនិយមបែបនេះ ផលវិបាកមានច្រើនណាស់ ដែលនាំទៅរកអនាធិបតេយ្យ។ ក្នុងចំណោមផលវិបាកទាំងនោះ មានផលវិបាកមួយដែលគួរឱ្យអស្ចារ្យ ណាស់ គឺការនាំប្រែក្លាយភាសាខ្មែរឱ្យទៅជាភាសាបារាំងតែម្តង ព្រោះចង់លុបបំបាត់ពាក្យបាលី និង សំស្ក្រឹត។ និន្នាការនេះកំពុងតែចាប់ផ្តើមដែរហើយ។

ឧទាហរណ៍ : បច្ចេកទេស > តិចនិច , វិទ្យាសាស្ត្រ > ស្យង់ , បច្ចេកវិជ្ជា > តិចណូឡូស៊ី.....

បើគោរពតាមគោលការណ៍នេះ បន្តិចទៀត ពាក្យនយោបាយនឹងត្រូវជំនួសដោយពាក្យ ប៉ូលីទិច សេដ្ឋកិច្ច ក្លាយទៅជា អេកូណូមិច ។ល។ និង ។ល។........

ចំពោះពាក្យបាលី និង សំស្ក្រឹត ដែលគេមានគោលបំណងលុបចោលដោយយកពាក្យខ្មែរបុរាណ ឬ ខ្មែរយើងសុទ្ធមកជំនួសវិញនោះ ផលវិបាកធំ គឺយើងស្តាប់មិនបានផង ឆ្គងផង ហើយ បាត់បញ្ញត្តិវិទ្យាសាស្ត្រ ថែមទៀត ជាហេតុនាំឱ្យការបង្កើតពាក្យវិទ្យាសាស្ត្រ និង ឧព្ភតកម្ម ធ្វើទៅមិនបានគ្រប់ជ្រុងជ្រោយតាមការ វិវត្តន៍របស់វិទ្យាសាស្ត្រ និង បាតុភូតរបស់វានីមួយៗ។

១- យកពាក្យខ្មែរបុរាណ ឬ ពាក្យខ្មែរសុទ្ធមកប្រើជំនួសបាលី សំស្ក្រឹត វិញ ជាហេតុធ្វើឱ្យពិបាក បង្កើតពាក្យថ្មី។

ឧទាហរណ៍ : <u>វប្បធម៌</u> ក្លាយទៅជា <u>អំបូន</u> <u>វប្បធម៌ខ្មែរ</u> ក្លាយទៅជា <u>អំបូនក្មែរ</u>

ប្រសិនបើយើងរក្សាពាក្យ បាលី ឬ សំស្ក្រឹតវិញ យើងមានលទ្ធភាពច្រើន ហើយស្រួលថែមទៀត ក្នុងការបង្កើតពាក្យថ្មី :

| | | |
|---|---|---|
| ឧទា. វប្បធម៌ | វប្បធម៌វិទ្យា | (culturologie) |
| | អត្តវប្បធម៌ | (subculture) |
| | ទ្វិកវប្បធម៌ | (biculturalisme) |
| | ។ល។ ..... | |
| វប្បកម្ម | ឯកវប្បកម្ម | (monoculture) |
| | ពហុវប្បកម្ម | (polyculture) |
| | ប្រពលវប្បកម្ម | (culture intensive) |
| | កាយវប្បកម្ម | (culturisme) |

។ល។ ....

២- ពាក្យបាលី ឬ សំស្រ្កឹត ដែលពាក្យខ្មែរបុរាណ ឬ ពាក្យខ្មែរ ដែលគ្មានប្រភពចេញពីពាក្យបាលី និង សំស្រ្កឹត មិនអាចយកទៅជំនួសបាន។

ឧទា. វប្បធម៌ខ្មែរ បើប្រើជាពាក្យខ្មែរបុរាណ គឺអំបូនក្មែរ (ស្តាប់ពុំបាន) ហើយ បើយើងប្រើជាពាក្យខ្មែរដែលគ្មានប្រភពពីបាលី និង សំស្រ្កឹតនោះ គឺពុំមានពាក្យសម្រាប់ជំនួសទេ នឹងទៅជាឃ្លាប្រយោគមួយ ហើយក្នុងឃ្លាប្រយោគនោះក៏មានពាក្យដែលមានប្រភពពីបាលី/សំស្រ្កឹតនោះទៀត។ វប្បធម៌ខ្មែរនឹងទៅជាការផ្សាំបណ្តុះចំណេះវិជ្ជា និង ប្រាជ្ញស្មារតីខ្មែរ។

## I
## អំពីពាក្យក្លាយតាមសូរស័ព្ទ

ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាបន្ទាន់ ជាពិសេសនៅក្នុងករណីដែលខ្វះនាម គេអាចទាញកិរិយាស័ព្ទឱ្យក្លាយទៅជានាម។ ប៉ុន្តែ យើងសង្កេតឃើញថា វិធីធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទនេះនាំទៅរកផលវិបាកដ៏ធ្ងន់ធ្ងរមួយបែប ដែលអាចធ្វើឱ្យភាសាខ្មែរយើងទាំងមូល ច្របូកច្របល់ វិលវល់ និង ប្រើមិនកើតតែម្តង។ យើងសូមលើកឡើងអំពីផលវិបាកសំខាន់ៗ ដូចខាងក្រោមនេះ :

### ១- ការច្របូកច្របល់បែលបណ្តាលឱ្យខ្មែរយើងស្តាប់ភាសាខ្លួនមិនបាន :

ពាក្យទាំងឡាយ ដែលត្រូវបានទាញចេញតាមក្បួននេះ ជាពាក្យដែលយើងស្តាប់មិនបាន ឬ មិនយល់ទាល់តែសោះ ពីព្រោះ ពាក្យក្លាយ តាមសូរស័ព្ទនេះ ពុំមែនត្រូវបង្កើតឡើងដោយអ្នកប្រើប្រាស់ទេ។ ពាក្យថ្មីៗដ៏ចម្លែកទាំងឡាយ ដែលយើងបានឃើញថ្មីៗនេះ ជាផលិតផលនៃក្បួនមួយ ដែលធ្វើឧភាសកម្ម (systématisation) ទាំងកម្រោល។ តាមធម្មតា ពាក្យនីមួយៗតែងតែកើតឡើងទៅតាមទម្លាប់ប្រើរបស់ប្រជាជន និង ក្នុងរយៈវេលាមួយដ៏សមស្របក្នុងប្រវត្តិសាស្ត្ររបស់ភាសានីមួយៗ។ ប៉ុន្តែ យើងមិនអាចធ្វើឧភាសកម្មទៅតាមក្បួនធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទ តាមតែការនឹកឃើញរបស់អ្នកប្រាជ្ញម្នាក់ ឬ ពីរនាក់ ដោយបង្ខំ និង ទាំងកម្រោលក្នុងរយៈពេលដ៏ខ្លីមួយឡើយ ពីព្រោះ នៅក្នុងករណីនេះ គេត្រូវកេណ្ឌប្រជាជនទូទាំងប្រទេសកម្ពុជា និង អាណិកជនខ្មែរទាំងអស់នៅបរទេស និង ជនបរទេសចេះភាសាខ្មែរមួយចំនួនទៀត ដែលបានសិក្សាភាសាខ្មែរតាមក្បួនដូនតាយើង។ ម្យ៉ាងទៀត បើធ្វើដូច្នេះមែន ក្បួនខ្មែរពីបុរាណក៏នឹងរលាយបាត់សាបសូន្យថែមទៀត ពីព្រោះ គេនឹងអានលែងដាច់ លែងយល់តែម្តង។

បើធ្វើទៅតាមក្បួនដែលធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទ ពាក្យនេះ យើងនឹងឃើញ( តាមការពិតយើងបានឃើញខ្លះរួចទៅហើយ) មានពាក្យមួយចំនួនធំកើតឡើងព្រោងព្រាត ប៉ុន្តែ ជាពាក្យចម្លែកៗដែលយើងមិនអាចទទួលយកបានឡើយ ។ យើងសូមជូនជាឧទាហរណ៍ ដូចខាងក្រោមនេះ :

| | | |
|---|---|---|
| ការយឹតយោង | នឹងក្លាយទៅជា | យោបឹតយោបោង ឬ យោបឹតយោង |
| ការសរសើរ | នឹងក្លាយទៅជា | សំនរសំនើរ ឬ សំនរសើរ( តាមរបៀបសរសេរនៃការទាញសូរ) |
| ការទទួច | នឹងក្លាយទៅជា | ទំនទំនួច ឬ ទំនទួច |
| ការទទូរ | នឹងក្លាយទៅជា | ទំនទំនូរ ឬ ទំនទូរ |
| ការរាលដាល | នឹងក្លាយទៅជា | របាលដាល ឬ របាលដំនាល |
| ការរារែក | នឹងក្លាយទៅជា | របារបែក ឬ របារែក |
| ការរង់ចាំ | នឹងក្លាយទៅជា | របង់ចាំ ឬ របង់ចំនាំ |
| ការចេញទៅ | នឹងក្លាយទៅជា | ចំនេញទៅ ឬ ចំនេញទំនៅ |
| ការរស់នៅ | នឹងក្លាយទៅជា | របស់នៅ ឬ របស់លំនៅ |
| ការថែទាំ | នឹងក្លាយទៅជា | តំហែទាំ ឬ តំហែទំនាំ |
| ការនាំចូល | នឹងក្លាយទៅជា | លំនាំចូល ឬ លំនាំចំនូល ។ល។ .... |

**២- ការជាន់ពាក្យ និង ជាន់ន័យរបស់វា :**

វិធីធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទនេះ បណ្តាលឱ្យជាន់ទៅលើពាក្យដែលមានរួចហើយ និង ធ្វើឱ្យន័យរបស់ពាក្យដែលបង្កើតថ្មីច្របូកច្របល់ជាមួយនឹងន័យរបស់ពាក្យដែលមានរួចហើយ ។ ការធ្វើឱ្យក្លាយពាក្យ តាមសូរស័ព្ទនេះ មានទិសដៅមួយ គឺលុបបំបាត់បុព្វបទ <u>ការ</u> ពីករណនាម ។

ឧទាហរណ៍ : ការនាំចេញ នឹងក្លាយទៅជា លំនាំចេញ ឬ លំនាំចំនេញ , លំនាំចេញទំនិញទាំងនេះត្រូវហាមឃាត់( ការនាំចេញទំនិញទាំងនេះត្រូវហាមឃាត់...) ត្រង់កន្លែងនេះ យើងសង្កេតយ៉ាងច្បាស់ថា ពាក្យលំនាំនេះមានន័យខុសស្រឡះពីការនាំទាំងស្រុង ហើយធ្វើឱ្យយើងមានការច្របូកច្របល់យ៉ាងខ្លាំង អំពីន័យនៃពាក្យនេះ។ បើយើងចង់និយាយថា លំនាំចេញ ឬ លំនាំចំនេញនេះ យើងអាចច្រឡំនឹងពាក្យលំនាំដែលមានន័យថា បែបបទ ឬ ទំនងចេញ ទៅវិញ។ ករណីបែបនេះមានច្រើនណាស់ ដូចមានខាងក្រោមនេះ :

<u>រត់</u> ក្លាយទៅជា <u>របត់</u> ។ ពាក្យ <u>របត់</u> តាមន័យពិតប្រាកដរបស់វានៅក្នុងភាសាខ្មែរយើងគ្មានន័យថា <u>ការរត់</u> ទាល់តែសោះ។ តាមយើងធ្លាប់ប្រើ ពាក្យរបត់នេះមានន័យថា ផ្លូវ ឬ ទីដែលបត់វៀចទៅវិញទេ។

| | | |
|---|---|---|
| ស្មើ | ក្លាយទៅជា | សំណើ(សំនើ) ។ តាមការពិត តាមដែលយើងធ្លាប់ប្រើ ពាក្យសំណើ (សំនើ) នេះមានន័យថា : ពេលវេលាដ៏ខ្លីទៅវិញទេ។ ឧ. ប្រើវាមួយសំណើ .... |
| ទេរ | ក្លាយទៅជា | ទំនេរ ។ ពាក្យ ទំនេរ នេះគ្មានន័យអ្វីទាក់ទងនឹងពាក្យទេរ នេះសោះ ។ |
| រៀន | ក្លាយទៅជា | របៀន ។ ដូចយើងដឹងស្រាប់ហើយ ខ្មែរយើងមិនដែលប្រើពាក្យរបៀន នេះសម្រាប់សម្គាល់ការរៀន ឡើយ ។ ពាក្យរបៀននេះមាន ន័យថា ចំណេះដែលបានមកពីរៀនសិល្បិ៍សាស្ត្រ អាគម ទៅវិញទេ ។ ឧ. របៀននយោបាយនាំមកនូវចំនែក( បំណែក > បែក) ប្រាជ្ញ ( ការរៀននយោបាយនាំមកនូវការបែកប្រាជ្ញា...) |
| កប់ | ក្លាយទៅជា | កំណប់ ( កំនប់) ។ ខ្មែរយើងមិនដែលប្រើពាក្យ កំណប់ នេះថា ជាការកប់ឡើយ ។ ឧ. កំណប់ខ្មោច ( ការកប់ខ្មោច) ។ តាមន័យដែលយើងធ្លាប់ប្រើ កំណប់មានន័យថា របស់ដែលគេកប់ ហើយនៅក្នុងការវិត្តន៍របស់ន័យវា ពាក្យកំណប់នេះមានន័យថា វត្ថុមានតម្លៃដែលគេកប់ទុកថែមទៀត ។ |
| រស់ | ក្លាយទៅជា | របស់ ។ នៅក្នុងភាសាខ្មែរយើង ពាក្យ របស់ មិនដែលមានន័យថា ការរស់ សោះឡើយ ។ ឧ. របស់ឡើងវិញនៃប្រជាជនកម្ពុជា? ( ការរស់ឡើងវិញនៃប្រជាជនកម្ពុជា) ។ |
| ចេញ | ក្លាយទៅជា | ចំណេញ ( ចំនេញ) ។ ដូចយើងធ្លាប់ដឹងស្រាប់ហើយ ពាក្យចំណេញនេះមិនដែលមានន័យថា ការចេញនោះទេ ។<br>ឧ. ចំណេញសៀវភៅក្នុងឆ្នាំនេះច្រើនណាស់ ( ការចេញសៀវភៅក្នុងឆ្នាំនេះច្រើនណាស់) ។ ម្យ៉ាងទៀត ពាក្យចំណេញនេះអាចធ្វើឱ្យយើងច្រឡំនឹងប្រាក់ចំណេញ ថែមទៀត ។ |

។ ល ។ ....

**៣- ការប្រើពាក្យក្លាយតាមសូរស័ព្ទទាំងនេះបណ្ដាលឱ្យមានការចុះរមនាសត្ថ័ន្ធនៃភាសាខ្មែរទាំងមូល**

ប្រសិនបើយើងយកពាក្យក្លាយតាមសូរស័ព្ទ ដែលអ្នកប្រាជ្ញសម័យថ្មីបាន និង កំពុងបង្កើតឡើង ដោយប្រើវិធីទាញសូរស័ព្ទនេះ មកប្រើក្នុងឃ្លាប្រយោគ យើងនឹងឃើញភាសាខ្មែរយើងប្រែក្លាយទៅជា

ភាសាមួយទៀត ដែលយើងពុំអាចយល់ ឬ ស្តាប់បានឡើយ ។ ឧទាហរណ៍ :

- ការចាកចេញ ឬ ការបោះបង់ចោល ការរៀនសូត្រ ជាការគេចវេះ ពីការរិះរករូបមន្ត នៃ ការកសាងប្រទេស

នឹងក្លាយទៅជាឃ្លា ដូចខាងក្រោមនេះ :

ចំណាកចំណេញ រឺ បំណោះបំណង់ចោល របៀនសូត្រ ជាគំនេចវេះ ពីរបិះរបករូបមន្ត នៃ កំណសាងប្រទេស

ប្រសិនបើ ប្រើអក្សរ ន ជំនួសអក្សរ ណ តាមវិធីទាញសូរស័ព្ទទៀតនោះ ឃ្លានេះនឹងត្រូវសរសេរ ដូចខាងក្រោមនេះ :

ចំនាកចំនេញ រឺ បំនោះបំនង់ចោល របៀនសូត្រ ជាគំនេចវេះពី របិះរបករូបមន្តនៃកំនសាងប្រទេស ។

- តើអ្នកមានការជ្រួតជ្រាបខ្លះ អំពី ការចុះផ្សាយដំណឹងដែលទាក់ទងទៅនឹង ការសងសឹកគ្នានេះ ឬទេ?

ឃ្លានេះនឹងក្លាយទៅជា :

តើអ្នកមានជំរួតជំរាបខ្លះ អំពីចំនុះផ្សាយដំនឹងដែលទាក់ទងទៅនឹងសំនងសំនឹកគ្នានេះ ឬ ទេ?

- ការរៀបរាប់អំពីការរុករក និង ការរកឃើញ នៃការស្រាវជ្រាវមួយ របស់អ្នកនិពន្ធរូបនេះ ពោរពេញទៅដោយការខុសឆ្គង ....

ឃ្លានេះនឹងក្លាយេទៅជា :

របៀបរបាប់ អំពី របុករបក និង របកគំហើញ នៃសំរាវជ្រាវមួយរបស់ស្នេរូបនេះ ពោរពេញទៅដោយកំហុសឆ្គង ...

។ល។ និង ។ល។

ដូចមានជាឧទាហរណ៍ខាងលើនេះស្រាប់ ឃ្លាប្រយោគរបស់ភាសាខ្មែរយើងនឹងក្លាយទៅជាភាសាមួយទៀត ដែលពុំអាចមានអ្នកណាស្តាប់បាន ឬ យល់បានឡើយ ។ បើយើងអនុវត្តនីវិធីទាញសូរស័ព្ទនេះ យើងនឹងបង្កើតភាសាខ្មែរថ្មីមួយទៀត យកទៅឱ្យជនជាតិខ្មែរយើងរៀនជាពុំខាន ។ តើធ្វើដូច្នេះបានប្រយោជន៍អ្វីខ្លះចំពោះប្រទេសជាតិ?

## ៤- វិធាននៃការធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទនេះគ្មានលក្ខណៈទូទៅ ដូចការអះអាងរបស់អ្នកប្រាជ្ញទាំងឡាយនោះទេ :

តាមការពិត វិធានដែលគេបានលើកឡើងសម្រាប់ពន្យល់អំពីនិន្នាការទូទៅនៃការទាញសូរស័ព្ទ នេះ

នៅក្នុងភាសាខ្មែរយើង មិនមែនត្រឹមត្រូវដាច់ខាតអាចយកវាទៅធ្វើជាវិធានសម្រាប់បង្កើតពាក្យខ្មែរថ្មីនោះបានទេ។ ម្យ៉ាងទៀត គេមិនដែលយកវិធានដែលសម្រាប់ពន្យល់និន្នាការដែលមានរួចមកហើយ ទៅធ្វើជាវិធានសម្រាប់បង្កើតពាក្យថ្មីនោះទេ។ ដូចយើងបានសង្កេតឃើញរួចមកហើយ នៅក្នុងភាសាខ្មែរយើង អ្នកប្រាជ្ញពីបុរាណមិនដែលកំណត់យកការទាញសូរស័ព្ទនេះទៅធ្វើជាវិធានសម្រាប់បង្កើតពាក្យក្លាយឡើយ។ ពាក្យខ្លះមិនបានក្លាយទៅតាមនិន្នាការនេះទាំងអស់ទេ។ ឧទាហរណ៍ :

- ទិច មិនក្លាយទៅជា ទំនិច គឺទៅជា ទ្រនិច ទៅវិញ។ រីឯ ពាក្យ ទ្រនិច នេះវិញក៏លែងមានន័យថា ការទិច ទៀតដែរ ( ទ្រនិចឃ្នុំ ទ្រនិចនាឡិកា .....)
- ទំ មិនក្លាយទៅជា ទំនំ ទេ គឺក្លាយទៅជា ទ្រនំ ទៅវិញ ហើយពាក្យទ្រនំក៏លែងមានន័យ ឬ មិនអាចមានន័យថា ការទំ ទេ គឺមានន័យថា ទីដែលសត្វស្លាបតែងតែទៅទំ ឬស្នាក់នៅ ប៉ុណ្ណោះ។
- ធ្វើ មិនក្លាយទៅជា ទង្វើ ទេ គឺខ្មែរយើងមានពាក្យ អំពើ រួចហើយ សម្រាប់សម្គាល់ពាក្យ ការធ្វើ ....

ករណីចម្លែកមួយទៀតគួរឱ្យយើងកត់សម្គាល់ក្នុងការអនុវត្តន៍វិធាន នៃការទាញសូរស័ព្ទតែមួយនេះ :

ឧទាហរណ៍ : សរសេរ ក្លាយទៅជា សំណេរ (សំនេរ) ចុះសរសើរ ម្តេចក៏មិនទាញទៅជា សំណើរ(សំនើរ) ផង។

បើអនុវត្តន៍តាមវិធានរបស់អ្នកប្រាជ្ញទាំងនោះវិញ ពាក្យសរសេរមិនអាចក្លាយទៅជា សំណេរ (សំនេរ) បានទេ គឺក្លាយទៅជា សំណរសំណេរ (សំនរសំនេរ) ទៅវិញ ទើបត្រឹមត្រូវទៅតាមក្បួនធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទ ។ល។ និង។ល ។...

### ៥- វិធីធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទ កិរិយាស័ព្ទ ឱ្យទៅជានាមនេះ ធ្វើឱ្យបាត់នូវលក្ខណៈសម្គាល់រវាង ករណនាម និង សភាវនាម :

នៅក្នុងភាសាខ្មែរយើង ការប្រើបុព្វបទ ការ ដើម្បីសម្គាល់ករណនាម និង បច្ឆិមបទ ភាព សម្រាប់សម្គាល់សភាវនាម ជាមូលដ្ឋានល្អណាស់ សម្រាប់ប្រើក្នុងវិស័យវិទ្យាសាស្ត្រ។ ប៉ុន្តែ មិនដឹងមកពីហេតុអ្វីស្រាប់តែគេយកវិធាននៃការបំបែកពាក្យតាមសូរស័ព្ទនេះ ទៅលុបបំបាត់ចោលអស់ ហើយធ្វើឱ្យមានការច្របូកច្របល់ពាសពេញតែក្នុងភាសាខ្មែរយើង។ មិនត្រឹមតែបុព្វបទ ការ និង បច្ឆិមបទ ភាព នេះទេ ខ្មែរយើងធ្លាប់ប្រើបុព្វបទ សេចក្តី និង ដំណើរ ថែមទៀត ដើម្បីពង្រឹងនូវសេចក្តីត្រូវការជាចាំបាច់ នៃការពិពណ៌នាតាមបែបវិទ្យាសាស្ត្រទៀត : សេចក្តី សម្រាប់សម្គាល់ខ្លឹមសារ ដំណើរ សម្រាប់សម្គាល់ចលនាធម្មជាតិ

ការ សម្រាប់សម្គាល់អំពើ ភាព សម្រាប់សម្គាល់ សភាព ឬ ជីវិត ។ ល ។...ក្នុងការប្រើបុព្វបទ និង បច្ឆិមបទទាំងឡាយនេះ ខ្មែរយើងបាននាំគ្នាប្រើតាំងតែពីដើមរហូតមក លើកលែងតែនៅក្នុងករណីនៃពាក្យខ្លះដែលមាននិយមន័យច្បាស់លាស់របស់គេស្រេចទៅហើយនោះ។ ដូច្នេះ ការលុបចោលនូវបុព្វបទ និង បច្ឆិមបទទាំងនេះធ្វើឱ្យយើងមានការពិបាកខ្លាំង ក្នុងការសម្គាល់ ករណនាម និង សភាវនាម ។

ឧទាហរណ៍ :

១- អត់អោន (អត់ឱន)
→ អំណត់អំណោន ( ឬ អំនត់អំនោន) = សេចក្ដីអត់ឱន
ឬ
→ អំណត់អំណោន ( ឬ អំនត់អំនោន) = ការអត់ឱន ?

២- ឃើញ ក្លាយទៅជា គំហើញ (តើពាក្យគំហើញនេះមានន័យថា ការឃើញ ឬ របស់ដែលគេឃើញ?)

- ទិញ ក្លាយទៅជា ទំនិញ (ខ្មែរយើងប្រើពាក្យទំនិញនេះសម្រាប់តែសម្គាល់របស់ដែលគេទិញ ឬ លក់ប៉ុណ្ណោះ)
- កប់ ក្លាយទៅជា កំណប់ (កំនប់) (ខ្មែរយើងប្រើពាក្យកំណប់សម្រាប់សម្គាល់របស់ដែលគេកប់ប៉ុណ្ណោះ)
- កាត់ ក្លាយទៅជា កំណាត់ (កំនាត់) (ខ្មែរយើងប្រើពាក្យកំណាត់សម្រាប់សម្គាល់របស់ ឬ វត្ថុ ដែលគេកាត់រួចទៅហើយ ប៉ុណ្ណោះ)

ឧ. កំណាត់ឧស ....

បើយើងចង់និយាយ ឬ សរសេរថា :

- ការកាត់កំណាត់សំពត់ជាកំណាត់ៗបែបនេះ ធ្វើឱ្យយើងមានការខាតបង់ច្រើន ។

ហើយ បើយើងប្រើតាមភាសាដែលគេកំពុងតែប្តូរថ្មីនោះ យើងត្រូវសរសេរ ដូច្នេះវិញ :

- កំណាត់កំណាត់សំពត់ ជាកំណាត់ៗបែបនេះ ធ្វើឱ្យយើងមានកំហាតបង់ច្រើន( ពិបាកស្ដាប់ណាស់) ។

ឧទាហរណ៍បែបនេះមានច្រើនតទៅទៀត ប៉ុន្តែ យើងសូមលើកតែឧទាហរណ៍ខ្លះៗប៉ុណ្ណោះ ។

## ៦ - វិធីធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទនេះគ្មានវិធានជាឯកភាពរបស់វាទេ :

ចំពោះការអនុវត្តនីវិធាននៃការធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទនេះ យើងសង្កេតឃើញថា គ្មានឯកភាពគ្នាទាល់តែសោះ។ អ្នកធ្វើឧភាសកម្មវិធាននៃការធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទទាំងនេះ បកស្រាយនិងអនុវត្តនីវិធាននោះខុសៗពីគ្នា ។ ឧទាហរណ៍ :

ចំពោះពាក្យដែលមានពីរព្យាង្គ អ្នកប្រាជ្ញខ្លះកំណត់ឱ្យធ្វើការក្លាយពាក្យតាមសូរស័ព្ទតែព្យាង្គទី១ ប៉ុណ្ណោះ ប៉ុន្តែ អ្នកប្រាជ្ញខ្លះទៀតកំណត់ឱ្យធ្វើការក្លាយពាក្យតាមសូរស័ព្ទទាំងពីរព្យាង្គតែម្តង ទោះបីព្យាង្គទាំងពីរនេះគ្មានសូរដូចគ្នាក្តី។ ឧ. បើតាមវិធានខុសៗគ្នានេះ :

| | | |
|---|---|---|
| រកឃើញ | ខ្លះឱ្យក្លាយទៅជា <u>របកឃើញ</u> |
| | ខ្លះទៀតឱ្យក្លាយទៅជា <u>របកគំហើញ</u> |
| រាលដាល | ខ្លះឱ្យក្លាយទៅជា <u>របាលដាល</u> |
| | ខ្លះទៀតឱ្យក្លាយទៅជា <u>របាលដំណាល</u> |
| ជឿជាក់ | ខ្លះឱ្យក្លាយទៅជា <u>ជំនឿជាក់</u> |
| | ខ្លះទៀតឱ្យក្លាយទៅជា <u>ជំនឿជំនាក់</u> |
| ចេះដឹង | ខ្លះឱ្យក្លាយទៅជា <u>ចំណេះដឹង</u> |
| | ខ្លះឱ្យក្លាយទៅជា <u>ចំណេះដំណឹង</u> |
| ជួបជុំ | ខ្លះឱ្យក្លាយទៅជា <u>ជំនួបជុំ</u> |
| | ខ្លះទៀតឱ្យក្លាយទៅជា <u>ជំនួបជំនុំ</u> |

។ល។ និង ។ល។ ...

## II
## <u>អំពីការទាញសូរស័ព្ទ</u>

ការយកអក្សរ <u>ល</u> ទៅជំនួសអក្សរ <u>ឡ</u> យកអក្សរ <u>ន</u> ទៅជំនួសអក្សរ <u>ណ</u>

នៅក្នុងអត្ថបទដែលបោះពុម្ពផ្សាយ គេសង្កេតឃើញមានការកែអក្ខរាវិរុទ្ធអក្សរ ណ។ អ្នកដែលផ្តើមគំនិតកែប្រែអក្ខរាវិរុទ្ធ តាមរបៀបនោះ សំអាងទៅលើវិធានលំឱនសូរស័ព្ទផង ហើយអះអាងថា អក្សរ ណ និង អក្សរ ឡ នេះគេអាចប្រើតែក្នុងករណីពិសេសប៉ុណ្ណោះ គឺអាចសរសេរ ណ បាន កាលណាគ្មានការលំឱនសូរស័ព្ទ (ឧ. ណែងណង នាយ ។ល។...)។ ចំពោះអក្សរ ឡ វិញ គេសំគាល់ថា អាចប្រើបានតែក្នុងករណីនៃពាក្យខ្ចីពីភាសាបរទេស (ឧ. សាឡាង សាឡាត ។ល។ ...) និង ពាក្យខ្មែរដែលគ្មានលំអៀងសូរស័ព្ទ។ ឧ. ឡូឡា

ការលើកវិធានបែបនេះជាការផ្តាំផ្តងណាស់ ពីព្រោះ :

១- ធ្វើឱ្យប៉ះពាល់ដល់អក្ខរាវិរុទ្ធខ្មែរយើង ដែលមានពីយូរយារណាស់មកហើយ គឺមានតាំងពីមុនកំណើតនៃអ្នកប្រាជ្ញសម័យថ្មីទាំងនេះទៅទៀត។ ឯកសារជាច្រើនណាស់ដែលបញ្ជាក់ថា អ្នកប្រាជ្ញខ្មែរយើង

តាំងពីដើមមកទល់នឹងបច្ចុប្បន្ននេះ បានកំណត់យកអក្ខរាវិរុទ្ធដែលយើងធ្លាប់ប្រើជាហូរហែររហូតមកនេះ។ ជាភស្តុតាងជាក់ស្តែង សម្តេចសង្ឃរាជ ជួន ណាត ក៏បានកំណត់យកអក្ខរាវិរុទ្ធនេះដែរ។ម្យ៉ាងទៀត ពាក្យ អក្ខរាវិរុទ្ធមានន័យថា អក្សរដែលគេមិនអាចកែបាន គឺត្រូវទុកដដែលដោយមិនបាច់ពន្យល់រកមូលហេតុអ្វីទេ។ តាមធម្មតាពាក្យនីមួយ១សុទ្ធតែមានឫសគល់ មានប្រភព មានប្រវត្តិរបស់វា ដែលគ្មានវិធានណាមួយអាចកែប្រែបានឡើយ ជាពិសេសកាលណាវិធាននោះធាក់ថយក្រោយ (តាមការពិតគ្មានវិធានណាអាចធាក់ថយក្រោយបានទេ (aucune règle ne peut être rétroactive))។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏អ្នកប្រាជ្ញជំនាន់ក្រោយទាំងនេះហ៊ានបង្កើតវិធានដែលប្តូរអក្ខរាវិរុទ្ធដែលមានរួចទៅហើយនោះធ្វើព្រងើយ។ គឺគំនិតឆន្ទនិយមនេះហើយ ដែលកំពុងតែធ្វើឱ្យភាសាខ្មែរយើងច្របូកច្របល់យ៉ាងខ្លាំង។ មិនតែប៉ុណ្ណោះ អ្នកប្រាជ្ញទាំងនោះបានអះអាងថែមទៀតថា គេធ្វើដូច្នេះ ពីព្រោះ "គេចង់ឱ្យអក្សរខ្មែរមានអារ្យធម៌"។ តាមការពិតអ្នកណាក៏ដឹងដែរថា អារ្យធម៌ខ្មែរយើងបានកកើតឡើងមុនអ្នកប្រាជ្ញទាំងឡាយនេះ ទៅទៀត។

២- នៅក្នុងវិស័យភាសាសាស្ត្រ គេលើកជាក្បួនវេយ្យាករណ៍ ឬ វិធានផ្សេង១ ដើម្បីរក្សាទុកនូវក្រឹតក្រម ឬ កេរមតិក ដែលគេតែងតែគោរពជាកំហិត គឺត្រង់នេះឯងហើយ ដែលគេហៅថា វប្បធម៌នោះ។ ប៉ុន្តែ ជាទូទៅ ភាសាវិទូច្រើនលើកវិធានទាំងនោះ ដើម្បីពន្យល់អំពីលក្ខណៈវេយ្យាករណ៍នៃភាសានីមួយ១តែប៉ុណ្ណោះ។ រីឯ អ្នកវេយ្យាករណ៍ខ្មែរបុរាណយើងមានគោលដៅទាំងពីរនេះរួមគ្នាតែម្តង (រក្សា និង ពន្យល់)។

៣- ពាក្យព្រមទាំងអក្ខរាវិរុទ្ធដែលកកើតឡើង គឺអាស្រ័យដោយអ្នកប្រើបង្កើត គឺជួនកាលគ្មានវិធានអ្វីជាមូលដ្ឋានផងទេ ប៉ុន្តែក្រោយ១មកគេនាំគ្នាប្រើជាហូរហែតែម្តង។ ហេតុដូច្នេះហើយ បានជាវិធានដែលបានលើកឡើងក្រោយ១នេះ ពន្យល់ទម្លាប់ទាំងនេះមិនបានជាទូទៅទេ។ ដូច្នេះ ការធ្វើឧភាសកម្មខ្លាំងជ្រុលពេកនាំមកនូវករណីពិសេសក៏ច្រើនរាប់មិនអស់ដែរ។

ឧ. ប្រលែង : លេងទៅលេងមក

ចុះ ប្រគេន : គេនទៅគេនមក ឬ យ៉ាងណា ?

ប្រហែស : ហែសទៅហែសមក ឬ យ៉ាងណា ?

ប្រណី : ណីទៅណីមក ឬ យ៉ាងណា ?

។ល។ និង ។ល។

ចំពោះការលុបបំបាត់ស្រះពេញតួ ដូចជា ឫ ទៅ រឺ , ឭ ទៅជា លឺ , នឹងនាំឱ្យ ឪពុក ទៅជា អូវពុក, ឯណា ទៅជា អែណា , ឧទាហរណ៍ ទៅជា អ៊ុទាហរណ៍ ។ល។ និង ។ល។ ក៏ជាការឆ្គាំឆ្គងណាស់ដែរ។ ការធ្វើបែបនេះ គឺជាការបង្រួមភាពសម្បូរណ៍បែបមកភាពក្រីក្រយ៉ាងជាក់ស្តែង ដោយសំអាង

ទៅលើអ្វីដែលគេហៅថា វិចារណនីយកម្ម (rationalisation)នោះ។ ធម្មតាគេមិនដែលកែវប្បធម៌ទេ យ៉ាងណាមិញ នៅអារ្យប្រទេសនានាក្នុងសកលលោកយើងនេះ គេមិនដែលកែអត្ថបទរបស់អ្នកនិពន្ធទេ ទោះខុសជាក់ស្តែងក៏ដោយ ឬ មានការភាន់ច្រឡំមែនក៏ដោយ ក៏អ្នកប្រាជ្ញក្រោយៗរក្សាទុកជានិច្ច។ ជាការពិតណាស់ដែលថា វប្បធម៌វិវត្តជានិច្ច ប៉ុន្តែ ការវិវត្តន៍មិនមែនជាការកែដោយកម្រោល ឬ តាមឆន្ទនិយម របស់អ្នកណាម្នាក់បានឡើយ។ ការធ្វើដូច្នេះនាំមកនូវការខាតច្រើនណាស់ គឺជាការកាត់វប្បធម៌ចាស់បោះចោលទាំងស្រុង ពីព្រោះ អ្នកជំនាន់ក្រោយនឹងអានក្បួនបុរាណមិនដាច់ឡើយ(ខ្មែរបាត់ក្បួន ឬ ខ្មែរបំបាត់ក្បួនរបស់ខ្លួនដោយខ្លួនឯង ពីព្រោះគ្មានជនបរទេសណាគេបង្ខំឱ្យយើងធ្វើដូច្នេះទេ)។

នៅក្នុងដំណើរប្រវត្តិសាស្ត្រ ពាក្យបានត្រូវគេបង្កើតឡើងដោយចៃដន្យ ទៅតាមសេចក្តីត្រូវការ និងឥទ្ធិពលពីអារ្យធម៌នានា។ ហេតុដូច្នេះ យើងគប្បីយល់ថា គេមិនដែលបង្កើតពាក្យទៅតាមវិធានដែលកំណត់ទុកជាមុនទេ លើកលែងតែពាក្យវិទ្យាសាស្ត្រមួយចំនួនចេញ ដែលឃ្លាតឆ្ងាយច្រើនពីភាសាដែលយើងនិយាយ ឬ សរសេរ ក្នុងជីវិតធម្មតា។ នៅក្នុងការវិវត្តន៍ និង ការរីកចម្រើនរបស់វា ភាសាខ្មែរយើងបានទទួលឥទ្ធិពលពីបាលី សំស្ក្រឹត ច្រើន ហើយ ពាក្យខ្ចីទាំងឡាយនេះបានត្រូវប្រជាជន និង អ្នកប្រាជ្ញប្រើប្រាស់ទន្ទឹមនឹងនិជភាសា(vernaculaire) ដែរ។ ប៉ុន្តែ និជភាសាពុំសូវមានពាក្យទស្សនវិជ្ជា និង វិទ្យាសាស្ត្រផ្សេងៗគ្រប់គ្រាន់ទេ ជាហេតុធ្វើឱ្យពាក្យខ្ចីពីបាលី សំស្ក្រឹត ត្រូវបញ្ចូលទៅក្នុងភាសាខ្មែរយើងតែម្តង ជាពិសេសក្នុងវាក្យស័ព្ទទស្សនវិជ្ជា។ អ្នកប្រាជ្ញខ្មែរបុរាណបានរក្សាទុករហូតមកទល់សព្វថ្ងៃ នូវឫសគល់ បាលី សំស្ក្រឹត នៃពាក្យទាំងនោះ ដែលបានក្លាយទៅជាអក្ខរាវិរុទ្ធតែមួយគត់ ដែលគ្មានអ្នកណាហ៊ានប៉ះពាល់ឡើយ។ ប៉ុន្តែ អ្នកប្រើប្រាស់ពាក្យខ្ចីទាំងនោះក៏គោរពអក្ខរាវិរុទ្ធទាំងនោះមិនបានទាំងស្រុងដែរ ទោះជាពាក្យនិជភាសាក៏ដូច្នេះដែរ ជាហេតុធ្វើឱ្យមានអនាធិបតេយ្យរកកំណត់មិនត្រូវ ។ ដើម្បីរក្សាឱ្យបាននូវឯកភាពនៃអក្ខរាវិរុទ្ធនេះ សម្តេចសង្ឃរាជ ជួន ណាត បានបង្កើតវចនានុក្រមមួយដែលត្រូវបានអ្នកប្រាជ្ញទាំងឡាយគាំទ្រ រក្សាទុកតៗគ្នា រហូតមក។ ដោយហេតុដូច្នេះហើយ បានជាគ្មានអ្នកណាហ៊ានកែអក្ខរាវិរុទ្ធដែលកំណត់ដោយសង្ឃរាជ ជួន ណាត ឡើយ ពីព្រោះសមិទ្ធផលដ៏កម្រនេះអាចពង្រឹងអក្សរសាស្ត្រខ្មែរផង ហើយ អាចចៀសវាងកុំឱ្យកើតមានសង្គ្រាមអក្សរសាស្ត្រនៅក្នុងប្រទេសទៀត។ នៅក្នុងស្ថានភាពប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ អ្នកប្រាជ្ញអក្សរសាស្ត្រកើតឡើងច្រើនណាស់ ហើយ មាននិន្នាការខុសៗគ្នាថែមទៀត។ ប្រសិនបើមានអ្នកប្រាជ្ញណាហ៊ានកែអក្ខរាវិរុទ្ធដែលមានជាធរមានមកហើយនេះ អ្នកប្រាជ្ញឯទៀតក៏នឹងនាំគ្នាកែជាបន្តបន្ទាប់តាមនិន្នាការរបស់គេរៀងៗខ្លួនដែរ។ គឺនៅពេលនោះឯងហើយ ដែលអក្សរសាស្ត្រខ្មែរនឹងរលាយសាបសូន្យតែម្តង។ ហេតុដូច្នេះហើយ បានជាគ្មានអ្នកប្រាជ្ញខ្មែរណាម្នាក់ ដែលយល់អំពីបញ្ហានេះ ហ៊ានកែអក្ខរាវិរុទ្ធដែលបានត្រូវខ្មែរទាំងអស់ទទួលស្គាល់រាល់ៗគ្នាហើយនោះឡើយ។

ប៉ុន្តែ អ្នកប្រាជ្ញខ្មែរយើង នាបច្ចុប្បន្នកាលនេះ នៅតែស្រមៃចង់បានភាសាខ្មែរមួយ ដែលគ្មានពាក្យខ្ចីពីបាលី/សំស្ក្រឹត ទៀត ទោះបីនៅអនាគតកាល គេត្រូវខ្ចីពាក្យពីបារាំង អង់គ្លេស និង ភាសាបរទេសផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការដ៏ធំធេងនៅថ្ងៃមុខ ដោយចៀសពុំផុតក៏ដោយក្តី។ ជាកិច្ចចាប់ផ្តើម អ្នកប្រាជ្ញទាំងឡាយនេះបាននាំគ្នាយកអក្សរ ល ទៅជំនួសអក្សរ ឡ យកអក្សរ ឌ ទៅជំនួសអក្សរ ណ ដោយបង្កើតឡើងនូវវិធានផ្សេងៗដោយបកស្រាយសិលាចារឹកតាមទស្សនៈផ្ទាល់រៀងៗខ្លួន។ តាមការពិត អក្សរ ណ នេះបានត្រូវអ្នកប្រាជ្ញពីបុរាណប្រើដោយគ្មានគិតអំពីវិធានទាំងឡាយនេះទេ។ នៅក្នុងសិលាចារឹក អក្សរ ណ មានគ្រប់គ្រាន់ទាំងអស់។ ប៉ុន្តែ ចំពោះអក្សរ ឡ វិញ បើគេសិក្សាសិលាចារឹកឱ្យច្បាស់ គេនឹងឃើញថា អក្សរ ឡ នេះមាននៅពេលដែលអក្សរខ្មែរកើតឡើង ប៉ុន្តែមានរូបរាងផ្សេង គឺ  ។ បន្ទាប់មកក៏បាត់ទៅវិញ។ លុះមកដល់ពេលចុងក្រោយ ដែលគេចារអក្សរនៅលើសិលាចារឹក អក្សរ ឡ នេះ ក៏លេចមកវិញ ហើយបានត្រូវអ្នកប្រាជ្ញក្រោយៗប្រើជាហូរហែររហូតមក ដូចយើងឃើញភស្តុតាងនៅក្នុងសាស្ត្រានានា និង ក្នុងវចនានុក្រម ជួន ណាត ស្រាប់។ ដោយការវិវត្តន៍ក្នុងការប្រើអក្សរខ្មែរបាននាំអក្សរ ឡ មកវិញទៅហើយនោះ តើបានប្រយោជន៍អ្វីនឹងត្រូវកម្រិតព្រំដែននៃការប្រើប្រាស់អក្សរ ឡ និងអក្សរ ណ នេះ ជាពិសេសបើអ្នកប្រាជ្ញខ្មែរបាននាំគ្នាឯកភាពរក្សាទុកការប្រើអក្សរ ឡ និង ណ នេះ តាមការកំណត់របស់អក្ខរាវិរុទ្ធជាធរមានទៅហើយនោះ។ ម្យ៉ាងទៀត ដូចយើងឃើញស្រាប់ហើយការកំណត់វិធាននេះនាំឱ្យមានអនាធិបតេយ្យគួរឱ្យបារម្ភនាបច្ចុប្បន្ននេះ។ នៅក្នុងចំណោមអ្នកប្រាជ្ញសម័យថ្មីទាំងនេះ មាននិន្នាការខុសៗគ្នាអំពីការប្តូរអក្សរ ឡ ចេញ។ ក្រៅពីនិន្នាការដែលយក ល ទៅជំនួស ឡ ដោយប្រើវិធីទាញសូរស័ព្ទនេះ យើងសង្កេតឃើញមាននិន្នាការមួយទៀតដែលបានលើកវិធានមួយឱ្យប្រើ ល្ម (ល បុកជើង) ជំនួស ឡ សម្រាប់សរសេរពាក្យមួយម៉ាត់។

ឧ. ល៉ើយ , ល៉ើង ។ល។ .... និន្នាការមួយទៀតបានកំណត់ថា ចំពោះពាក្យមួយម៉ាត់តែងដូច្នេះត្រូវប្រើអក្សរ ឡ វិញ។ រួមសេចក្តីមក អ្នកប្រាជ្ញទាំងឡាយនេះមិនឯកភាពគ្នាទេចំពោះការប្តូរអក្សរ ឡ ចេញនេះ ហើយយើងអាចប៉ាន់ស្មានយ៉ាងច្បាស់បានថា គេនឹងមិនអាចឈានទៅរកឯកភាពគ្នាបានជាដាច់ខាត។

ប្រការដែលយើងគួរចាប់អារម្មណ៍ក្នុងបញ្ហានេះ គឺការដែលយកក្បួន ឬ វិធានទាំងឡាយខាងលើនេះ មកអនុវត្ត នៅក្នុងការប្រើប្រាស់ភាសាខ្មែរយើង ទាំងកម្រោលបំផុត គឺឈានទៅកែពាក្យខ្មែរយើងដែលមានរាប់សតវត្សរ៍រួចមកហើយ។ ផលវិបាកមួយដែលកើតឡើងជាចំបាច់ក្នុងការយកវិធាន ដែលពន្យល់អំពីនិន្នាការនៃការកកើតពាក្យខ្មែរយើងពីបុរាណ ទៅអនុវត្ត ការធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទ តាមការនឹកឃើញនោះ គឺនាំទៅរកការដួរអក្ខរាវិរុទ្ធខ្មែរទាំងស្រុង។ ជាឧទាហរណ៍ យើងកំពុងតែសង្កេតឃើញមានការ

ដូវពាក្យខ្មែរ ដែលគេកំណត់សរសេរជាព្យាង្គតម្រួតឱ្យទៅជាព្យាង្គរាយទាំងអស់។ យើងនឹងលើកឡើងអំពីបញ្ហានេះនៅចំពូក III ។

ក- ការប្ដូរអក្សរ ណ ទៅ ន :

- ចំណេះ ទៅជា ចំនេះ អាចអានច្រឡំថា ចំ នេះ
- សំណេះ ទៅជា សំនេះ អាចអានច្រឡំថា សំនេះជាក្មេងល្អ
- សំណៅ ទៅជា សំនៅ អាចអានច្រឡំថា សំនៅផ្ទះ
- ចំណោម ទៅជា ចំនោម អាចអានច្រឡំថា ជាន់ចំនោមគេ
- ដំណឹង ទៅជា ដំនឹង អាចអានច្រឡំថា ដំនឹងមិនល្អទេ នាំឱ្យច្រឡំ ដំនឹងមិនល្អ ឬ ពតិមានមិនល្អ ?
- ដំណាំ ទៅជា ដំនាំ អាចអានច្រឡំថា ដំនាំ (កម្ទេចចោល)
- ចំណុះ ទៅជា ចំនុះ អាចអានច្រឡំថា ដើរចំនុះ
- ចំណាយ ទៅជា ចំនាយ អាចអានច្រឡំថា ចំ នាយ នេះ

ខ- ការប្ដូរអក្សរ ឡ ទៅ ល

- ក្រឡ ទៅជា ក្រល អាចអានច្រឡំថា ក្រល
- ក្រឡា ទៅជា ក្រលា អាចអានច្រឡំថា ក្រលាទៅផ្ទះម្ល៉េះ
- ក្រឡាស់ ទៅជា ក្រលាស់ អាចអានច្រឡំថា ដើមឈើ ក្រ លាស់ ម្ល៉េះ
- សំឡាប់ ទៅជា សំលាប់ អាចអានច្រឡំថា សំ លាប់កញ្ចើល
- សំឡក់ ទៅជា សំលក់ អាចអានច្រឡំថា សំ លក់ ទំ ធ្វើឱ្យច្រឡំ សំឡក់ទំ ឬ សំ លក់ទំ ?
- សំឡី ទៅជា សំលី អាចអានច្រឡំថា សំ លីគ ធ្វើឱ្យច្រឡំ សំឡីគ ឬ សំ លីគ ?
- សំឡុត ទៅជា សំលុត អាចអានច្រឡំថា សំ លុត (ជង្គង់)
- សំឡប ទៅជា សំលប អាចអានច្រឡំថា សំ លប (ចាប់សត្វ)
- ដំឡោក ទៅជា ដំលោក អាចអានច្រឡំថា ដំ លោក (មួយញញួរ)

## III
## ការសរសេរព្យាង្គរាយ និង ព្យាង្គតម្រួត

នៅក្នុងវចនានុក្រមសម្ដេច ជួន ណាត យើងសង្កេតឃើញថា គេអាចសរសេរបានពីរបែប (គឺព្យាង្គរាយផង ព្យាង្គតម្រួតផង) ចំពោះតែពាក្យមួយចំនួនប៉ុណ្ណោះ។ មានពាក្យខ្លះដែលមិនត្រូវសរសេរជាព្យាង្គរាយទាល់តែសោះ ក៏សម្ដេច ជួន ណាត អនុគ្រោះសិនដែរ ដោយហេតុថា ការសរសេរខុសជាទូទៅនេះមានចំពោះតែពាក្យមួយចំនួនតូចបំផុត ប៉ុណ្ណោះ។ ប៉ុន្តែ បច្ចុប្បន្ននេះ "អ្នកប្រាជ្ញទំនាញសូរ" យកការអនុគ្រោះនេះទៅធ្វើជាវិធានទូទៅតែម្ដង ធ្វើឱ្យអក្ខរាវិរុទ្ធខ្មែរយើងក្រឡាប់ចាក់បង្កើតឡើងនូវអនាធិបតេយ្យក្នុងការសរសេរនេះស្ទើរតែគ្រប់ពាក្យទាំងអស់។ តាមការពិត អ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរយើងបច្ចុប្បន្ននេះពុំបានគិតថា ការនាំសរសេរជាព្យាង្គរាយទាំងអស់ដូច្នេះបណ្ដាលឱ្យមានការច្រឡូកច្រឡំពាក្យឡើយ គឺគេពុំបានយល់ថា ការសរសេរជាព្យាង្គតម្រួតចំពោះពាក្យមួយចំនួននោះមានលក្ខណៈសំខាន់នោះទេ។ ម្យ៉ាងទៀត គេគិតតែពីនាំគ្នាធ្វើយ៉ាងណាយកវិធានរបស់គេទៅអនុវត្តឱ្យបានដាច់ខាតតែប៉ុណ្ណោះ។ ទោះជាយ៉ាងដូច្នេះក៏ដោយក៏គេនៅតែអះអាងថា គេចង់ឱ្យភាសាខ្មែរយើងមានក្បួនខ្នាតដែរ។ យើងឆ្ងល់ណាស់ថា ហេតុដូចម្ដេចបានជាគេចោទថា ភាសាខ្មែរយើងគ្មានក្បួនខ្នាត ពីព្រោះ ត្រង់ចំណុចនេះតែម្ដង ដែលយើងសង្កេតឃើញថា ក្បួនយើងមានច្បាស់លាស់ត្រឹមត្រូវណាស់ ប៉ុន្តែតើអ្នកណាជាអ្នកបំផ្លាញក្បួនខ្នាតដែលមានរួចមកហើយអស់នោះ? ជាឧទាហរណ៍យើងសូមបញ្ជាក់ថា ចំពោះការសរសេរជាព្យាង្គរាយ ឬ ជាព្យាង្គតម្រួតនោះ តាមក្បួនដែលយើងមាន[1] កាលណាពាក្យដើមសរសេរតម្រួត ពាក្យក្លាយក៏ត្រូវសរសេរព្យាង្គតម្រួតដែរ។ ប៉ុន្តែ កាលណាពាក្យដើមសរសេរជាព្យាង្គរាយ ទើបគេអាចសរសេរពាក្យក្លាយជាព្យាង្គរាយបាន។ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់អំពីបញ្ហានេះ យើងសូមលើកឧទាហរណ៍មួយចំនួន ដូចខាងក្រោមនេះ :

<u>តម្រូវ</u> ត្រូវសរសេរជាព្យាង្គតម្រួត ពីព្រោះមកពីពាក្យ <u>ត្រូវ</u> ជាព្យាង្គតម្រួត។ ពាក្យឯទៀតៗ ក៏ត្រូវអនុវត្តតាមវិធាននេះដែរ ដូចជា ត្រួត ⇒ តម្រួត ស្រេច ⇒ សម្រេច ក្រ ⇒ កម្រ ក្រិត ⇒ កម្រិត ។ល។...

ប៉ុន្តែ អាចសរសេរជាព្យាង្គរាយបានចំពោះពាក្យដែលក្លាយពីពាក្យដើមសរសេរជាព្យាង្គរាយប៉ុណ្ណោះ ដូចជា : ឈឺ ⇒ ជំងឺ, គិត ⇒ គំនិត ។ល។...

ចំពោះពាក្យខ្លះទៀត ដែលបានសរសេរខុសជាទូទៅរួចហើយ ប៉ុន្តែដែលមានចំនួនតិចបំផុត សម្ដេចសង្ឃក៏បានអនុគ្រោះសិនដែរ ទម្រាំវិលមករកត្រូវវិញនៅថ្ងៃមុខ។

---

(1) - វចនានុក្រមខ្មែរ របស់ ជួន ណាត, ទំព័រ គ។

ឧ. ស្គាល់ ⇒ សំគាល់, សម្គាត់ ⇒ សំងាត់, សម្គម ⇒ សំគម

សម្អាក ⇒ សំកាក, សម្គក ⇒ សំកក, សម្ដី ⇒ សំដី ។ល។...

ខាងក្រោមនេះ យើងសូមលើកឡើងនូវពាក្យមួយចំនួនដែលបណ្ដាលឱ្យមានផលវិបាកធ្ងន់ កាលណាគេសរសេរវាជាព្យាង្គរាយ កាលណា គេមិនគោរពអក្ខរាវិរុទ្ធពិតប្រាកដនៃពាក្យខ្មែរ ដែលកំណត់ដោយវចនានុក្រម ជួន ណាត នោះ :

ចង្កៀង បើសរសេរជាព្យាង្គរាយនឹងក្លាយទៅជា ចង់កៀង
ធ្វើឱ្យច្រឡំនឹងពាក្យ ចង់ កៀង , ឧ. ចង់កៀងគោក្របី ...

ចង្កា បើសរសេរជាព្យាង្គរាយ នឹងក្លាយទៅជា ចង់កា
ធ្វើឱ្យច្រឡំនឹងពាក្យ ចង់ កា , ឧ. ចង់កាខ្នងសំបុត្រ ...

បន្ទាយ បើសរសេរជាព្យាង្គរាយ នឹងក្លាយទៅជា បន់ទាយ
ធ្វើឱ្យច្រឡំនឹងពាក្យ បន់ ទាយ : បន់ គឺ បន់ស្រន់ , ទាយ គឺ ទស្សន៍ទាយ ....

ចង្កេះ បើសរសេរជាព្យាង្គរាយ នឹងក្លាយទៅជា ចង់កេះ
ធ្វើឱ្យច្រឡំនឹងពាក្យ ចង់ កេះ , ឧ. ចង់កេះគាត់ប្រាប់បន្តិច ...

កង្កែប បើសរសេរជាព្យាង្គរាយ នឹងក្លាយទៅជា កង់កែប
ធ្វើឱ្យច្រឡំនឹងពាក្យ កង់ កែប

បង្រៀន បើសរសេរជាព្យាង្គរាយ នឹងក្លាយទៅជា បង់រៀន
ធ្វើឱ្យច្រឡំនឹងពាក្យ បង់ រៀន

ចង្កូត បើសរសេរជាព្យាង្គរាយ នឹងក្លាយទៅជា ចង់កូត
ធ្វើឱ្យច្រឡំនឹងពាក្យ ចង់ កូត , ឧ. ចង់កូតទ្រ.....

ការសរសេរជាព្យាង្គរាយនេះមិនត្រឹមតែយកទៅអនុវត្តន៍ចំពោះពាក្យខ្មែរសុទ្ធប៉ុណ្ណោះទេ ប៉ុន្តែ បានត្រូវយកទៅអនុវត្តន៍ចំពោះពាក្យដែលមានប្រភពពីបាលី សំស្ក្រឹត ថែមទៀត។ ការយកពាក្យខ្មែរ ដែលមានឫសគល់ជាបាលី សំស្ក្រឹត ទៅសរសេរតាមការប្រកបសូរស័ព្ទ (transcription phonétique) តាមបែបបទខ្មែរដូច្នេះ ជាការកែអក្ខរាវិរុទ្ធយ៉ាងជាក់ស្ដែងដែលមិនអាចប្រកែកបាន។ ផលវិបាកនៃវិធី "ខេមរនីយកម្មសូរស័ព្ទនិយម" របៀបនេះ មានយ៉ាងហោចណាស់ក៏ពីរដែរ គឺ : ១- បាត់ប្រភពនៃពាក្យដើម និងដំណើរវិវត្តរបស់វាទៅក្នុងប្រវត្តិរបស់ពាក្យទាំងនោះ។ ២- ពិបាករាវរកន័យ និង បញ្ញត្តិ (concept) នៃពាក្យនីមួយៗដែលជាការចាំបាច់ណាស់សម្រាប់ធ្វើការពិចារណាផ្សេងៗ ដូចជា សង្គមវិទ្យាដែលពឹងផ្អែកមួយចំណែកទៅលើមូលដ្ឋាននិរុត្តិវិជ្ជា ដើម្បីធ្វើការសិក្សាន័យសាស្ត្រ (étude sémantique)។ ដូច្នេះ ដើម្បី

ធ្វើការសិក្សាទាំងនេះ អនាគតសិក្ខាកាមខ្មែរយើងត្រូវរៀនភាសាខ្មែរ២បែបជាចាំបាច់ មួយ គឺខ្មែរបុរាណមួយទៀត គឺភាសាខ្មែរមួយទៀត ដែលអ្នកប្រាជ្ញថ្មីកំពុងបង្កើតនេះ។ ម្យ៉ាងទៀត ការយកពាក្យបាលីទៅសរសេរជាព្យាង្គរាយដូច្នេះ គឺធ្វើឱ្យប្រាសចាកន័យដើមរបស់វា គឺមានលក្ខណៈប្រឡាយកាត់ខ្លាំងហួសហេតុបណ្ដាលឱ្យពាក្យទាំងនោះ មិនដឹងជាត្រូវយោងទៅតាមវិធាន ឬ វេយ្យាករណ៍ណា (បាលី ? សំស្ក្រឹត ឬខ្មែរ?)។ គឺត្រង់ចំណុចនេះហើយ ដែលអនាធិបតេយ្យក្នុងការសរសេរ (ប្រកប) ស្ដែងចេញឡើង។ ឧ. សម្ព័ន្ធ ប្រែជាសរសេរ សំព័ន្ធ ទៅវិញ (ខ្មែរក៏មិនខ្មែរ បាលីក៏មិនបាលី) ពីព្រោះ បើសរសេរតាមខ្មែរសុទ្ធ គឺសរសេរ សំពាន់ តែម្ដង។ ចំពោះពាក្យ សម្ភារៈ ដែលគេសរសេរថា សំភារៈ វិញក៏ដូច្នេះដែរ គឺបើប្រកបតាមបែបខ្មែរ គេសរសេរ សំភារាក់ តែម្ដងទើបត្រូវស្ទួរស័ព្ទ។ បើសរសេរជាបាលី យោងទៅតាមវេយ្យាករណ៍បាលី គឺខុសទាំងស្រុង ពីព្រោះ :

តាមក្បួនផ្ដុំពាក្យដែលមានប្រភពពីបាលី កាលណា និគ្គហិត(ំ)បូកនឹងព្យញ្ជនៈនិគ្គហិតផ្លាស់ទៅជា វគ្គន្ត គឺ ង ញ ណ ន ម មិនអាចសរសេរជាព្យាង្គរាយបានទេ គឺត្រូវសរសេរជាព្យាង្គតម្រួត។

ំ ⟹
- ង ឧ. សង្ខារ សង្គម សង្កថា សង្គហៈ ។ល។
- ញ សញ្ញាណ សញ្ជាតិ សញ្ញា
- ណ សណ្ឋាន សណ្ឋិត សណ្ឋាគារ
- ន សន្ទាន សន្ធិ សន្ដោស
- ម សម្ព័ន្ធ សម្បត្តិ សម្ភារៈ

នៅក្នុងដំណើរការបច្ចុប្បន្ននេះ គេសង្កេតឃើញថា និន្នាការសរសេរជាព្យាង្គរាយនេះមានល្បឿនលឿនហួសហេតុ គឺជ្រុលរហូតដល់ទៅលែងគោរពក្បួនខ្នាតអ្វីទាំងអស់ ហើយ ទៅអនាគតដ៏ខ្លី ពាក្យមួយចំនួនទៀតនឹងក្លាយទៅជាព្យាង្គរាយទាំងអស់ ដូចឧទាហរណ៍ខ្លះ១ នៅខាងក្រោមនេះ :

| | | |
|---|---|---|
| សម្បត្តិ | នឹងក្លាយទៅជា | សំបាត់ |
| សម្មស្ស | នឹងក្លាយទៅជា | សំភាស់ |
| សម្បទាន | នឹងក្លាយទៅជា | សំប៉ាក់ទាន |
| សម្បទា | នឹងក្លាយទៅជា | សំប៉ាក់ទា |
| សម្ភព | នឹងក្លាយទៅជា | សំភព ឬ សំភប់ |
| សម្បជញ្ញៈ | នឹងក្លាយទៅជា | សាំប៉ាក់ជាញញាក់ |
| សង្ខារ | នឹងក្លាយទៅជា | សាំងខារ |

| | | |
|---|---|---|
| សញ្ញាណ | នឹងក្លាយទៅជា | សាញ់ញ៉ាណ |
| សង្គ្រោះ | នឹងក្លាយទៅជា | សង់គ្រោះ |
| សណ្ឋាន | នឹងក្លាយទៅជា | សន់ឋាន |
| សណ្ឋាគារ | នឹងក្លាយទៅជា | សន់ឋាគារ |
| សន្ធិ | នឹងក្លាយទៅជា | សន់ធិ |
| សន្ដោស | នឹងក្លាយទៅជា | សន់ដោស ។ល។.... |

"ខេមរនីយកម្ម" មហាលោតផ្លោះបែបនេះ គឺជាទិន្នាការមួយដែលនឹងធ្វើឱ្យភាសាខ្មែរយើងរលាយសាបសូន្យ បាត់អស់លក្ខណៈជាភាសាខ្មែរយើង ដែលមានប្រភពវិទ្យាសាស្ត្រ និង ការរីកចម្រើនតាមក្រឹតក្រមត្រឹមត្រូវរបស់វា។ អក្សរសាស្ត្រក៏ដូចជាផ្ទះដែរ គឺកាលវាគ្មានគ្រឹះ ឬ ឫសគល់របស់វាមាំទាំទេនោះ ផ្ទះនឹងត្រូវរលំ នៅពេលដែលមានខ្យល់បក់ខ្លាំង។ យើងនៅចាំមិនទាន់ភ្លេចទេថា ការផ្សងព្រេងរបស់ប៉ុល ពត មានមូលហេតុរបស់វា នៅក្នុងការលោតផ្លោះដ៏អស្ចារ្យបែបនេះ គឺការលប់បំបាត់វប្បធម៌បរទេស និង ឥទ្ធិពលរបស់វាដោយកម្រោល។ លទ្ធផល គឺការកម្ទេចចោលទាំងស្រុងនូវសង្គមទាំងមូល រួមបញ្ចូលទាំងវប្បធម៌ខ្មែរឯងថែមទៀត។

## IV

## ការបំបាត់ស្រះពេញតួ

បើយើងពិនិត្យមើលឱ្យបានហ្មត់ចត់ យើងនឹងឃើញថា ក្រៅពីគោលដៅឯទៀត១ អ្នកប្រាជ្ញ"ទំនាញសូរ"មានគោលដៅមួយទៀត ដោយមិនអាចប្រកែកបាន គឺការបំបាត់ចោលស្រះពេញតួទាំងស្រុងទៀត។ ហេតុដូច្នេះហើយ បានជាគេឃើញមានការប្តូរស្រះពេញតួចេញអស់ពីពាក្យដែលយើងធ្លាប់សរសេរដោយប្រកបនឹងស្រះពេញតួ ដែលវចនានុក្រម ជួន ណាត បានបញ្ចូលមកក្នុងអក្ខរានុក្រមខ្មែរយើង។ ឧទាហរណ៍ :

| | | |
|---|---|---|
| ឫ | ប្តូរទៅជា | រឺ |
| ឭ | ប្តូរទៅជា | លឺ |
| ឪពុក | ប្តូរទៅជា | អូវពុក |
| ឫកពា | ប្តូរទៅជា | រឹកពា |
| ឥត | ប្តូរទៅជា | អិត |
| ឥឡូវ | ប្តូរទៅជា | អីលូវ |
| ឮង៉ី | ប្តូរទៅជា | អែង |

| | | |
|---|---|---|
| ឯណា | ប្តូរទៅជា | អែណា |
| ឪឡឹក | ប្តូរទៅជា | អូវលឹក |
| ឪឡ | ប្តូរទៅជា | អូវល |
| ឯង | ប្តូរទៅជា | អែង |
| ឱហាត | ប្តូរទៅជា | អោហាត |

ការបំបាត់ស្រៈពេញតួនេះបណ្តាលមកពីការចង់លុបឥទ្ធិពលបាលី និង សំស្ក្រឹតឱ្យផុតពូជតែម្តង។

ចំពោះគោលដៅនេះ យើងសូមលើកឡើងនូវផលវិបាក និង លក្ខណៈអចិន្តភាពរបស់វា នៅក្នុងជំពូក V។

## V
## អំពីការលុបបំបាត់ពាក្យបាលីនិងសំស្ក្រឹត ដោយយកពាក្យខ្មែរបុរាណ ពាក្យដែលធ្វើឱ្យក្លាយតាមស្វរស័ព្ទ និង ពាក្យខ្មែរដែលយើងប្រើ នៅក្នុងនិច្ចភាព មកជំនួសវិញ

គោលដៅនេះមានលក្ខណៈអចិន្តភាព( utopique )យ៉ាងជាក់ស្តែង។ ដើម្បីឱ្យយើងអាចមើលឃើញយ៉ាងច្បាស់ថា តើយើងធ្វើទៅបាន ឬ មិនបាននោះ យើងសូមលើកនូវតារាងពាក្យមួយចំនួន ដែលយើងប្រើជារៀងរាល់ថ្ងៃ ដោយមិនបានគិតថា តាមការពិត ពាក្យទាំងឡាយនោះជាពាក្យបាលី ឬ សំស្ក្រឹតសុទ្ធតែម្តង។

តារាងពាក្យបាលី និង សំស្ក្រឹតដែលខ្មែរយើងនិយាយ

សរសេររត់មាត់រាល់ថ្ងៃ ដោយមិនដឹងខ្លួន

| | | |
|---|---|---|
| ១- ចិត្ត សំ.បា | ៤៣- វិហារ សំ.បា. | ៨៥- អន្តរាយ សំ.បា. |
| ២- អម្ពិល បា. | ៤៤- គ្រឹះ សំ. | ៨៦- អន្តរធាន សំ.បា. |
| ៣- អារ៌ បា. | ៤៥- គ្រុឌ សំ. | ៨៧- អាចម៍ សំ.បា. |
| ៤- ចោរ បា. | ៤៦- ឃោសនា បា. | ៨៨- អនេក សំ.បា. |
| ៥- បាសក សំ.បា. | ៤៧- រោងចក្រ សំ. | ៨៩- ទូត សំ.បា. |
| ៦- សាលា បា. | .៤៨- រាសី បា. | ៩០- វស្សា បា. |
| ៧- សាល បា. | ៤៩- ប្រពន្ធ សំ. | ៩១- អស្ចារ្យ សំ.បា. |
| ៨- ស្រី សំ. | ៥០- ប្តី បា.សំ. | ៩២- អកុសល បា. |
| ៩- ចោទ បា. | ៥១- សាសនា បា. | ៩៣- អគ្រាត្រ សំ. |

១០- គភ៌ សំ.
១១- ស្រូវ សំ.
១២- គ្រូ បា.
១៣- ក្បាល សំ.បា.
១៤- រូបកាយ សំ.បា.
១៥- ទុក្ខ បា.
១៦- សុខ សំ.បា.
១៧- មេឃ សំ.បា.
១៨- ភ័យ សំ.បា.
១៩- ជាតិ សំ.បា.
២០- រសជាតិ បា.សំ
២១- ពេលវេលា បា.សំ.
២២- វត្ត បា.
២៣- លោក សំ. បា
២៤- សមុទ្រ
២៥- គាថា សំ.
២៦- គោរព សំ.
២៧- សិស្ស បា.
២៨- គុណ សំ.បា.
២៩- ទោស បា.
៣០- គូថ បា.
៣១- គូទ បា.សំ.
៣២- គេហ៍ សំ.បា.
៣៣- ប្រយោជន៏ សំ.
៣៤- គោ សំ.បា.
៣៥- កម្ម បា.
៣៦- សប្បាយ បា.

៥២- ទ្វីប សំ.
៥៣- ចតុរង្គ សំ.
៥៤- ពាក្យសង្ឃ បា.
៥៥- ពាក្យស័ត្យ សំ.
៥៦- លេខ សំ.បា.
៥៧- ជន សំ.បា.
៥៨- រាស្ត្រ សំ.
៥៩- ចលាចល សំ.បា.
៦០- ចារ៉ុ បា.សំ
៦១- ទេព្តា, ទេវតា សំ.បា.
៦២- សករាជ សំ.បា.
៦៣- បុណ្យសក្តិ សំ.
៦៤- ចៃដន្យ សំ.
៦៥- ទេសកាល បា.
៦៦- ចេតិយ បា.
៦៧- ទេពច្យុតិ សំ.
៦៨- ឆត្រ សំ.
៦៩- ឆទាន , សាលាឆទាន សំ.
៧០- ទ្វារ សំ.បា.
៧១- រោគ សំ.បា.
៧២- ជោគជតារាសី បា
៧៣- ជនបទ សំ.បា.
៧៤- អាចារ្យ សំ.
៧៥- អនុគ្រោះ សំ.
៧៦- ទង់ជ័យ បា.
៧៧- ជាតិ សំ.បា.
៧៨- ភូមិ សំ.បា.

៩៤- អាស្រ័យ សំ.
៩៥- ប្រាជ្ញា សំ.
៩៦- អធិកអធម សំ.បា.
៩៧- មិត្តភក្តិ បា. សំ.
៩៨- នគរ សំ.បា.
៩៩- អក្សរ សំ.
១០០- ធូប សំ.បា.
១០១- កុដិ សំ.បា.
១០២- នាយ នាយសំពៅ សំ.បា.
១០៣- សីលទាន បា.សំ.
១០៤- វីធ ក្របីវីធ បា.
១០៥- ព័ទ្ធ ហ៊ុំព័ទ្ធ សំ.បា.
១០៦- និត្យ និត្យនៅ សំ.
១០៧- បុណ្យ សំ.
១០៨- កំសាន្ត សំ.
១០៩- បវរកញ្ញា បា.
១១០- កប៉ាល់ សំ.បា.
១១១- ឧបាយកល សំ.
១១២- កសិករ បា.
១១៣- កសិណ បា.
១១៤- ពាក្យកាព្យ បា.សំ.
១១៥- ការ បា.
១១៦- កិត្តិយស បា.
១១៧- កីឡា បា.
១១៨- កុមារ បា.
១៩៩- កុហក បា.
១២០- កេណ្ឌ បា.

៣៧- គ្រហស្ថ សំ.ភ្លា.
៣៨- ភាសា បា.
៣៩- មុខ សំ.បា.
៤០- គ្រាហ៍ សំ.
៤១- ឋានៈ បា.
៤២- ព្រះ សំ.បា.

៧៩- ជីវិត សំ.បា.
៨០- ក្ស័យ សំ.
៨១- ជីពចរ សំ.បា.
៨២- ពន្ធ សំ.បា.
៨៣- ភិក្ខុ បា.
៨៤- សាមណេរ បា.

១២១- កេរ្តិ៍ សំ.
១២២- ខេត្ត បា.
១២៣- ខ្មែរ បា.
១២៤- មនុស្ស បា.
។ល។ និង ។ល។

ការលុបពាក្យបាលី ឬ សំស្ក្រឹត ដោយយកពាក្យខ្មែរមកជំនួសវិញ

ដើម្បីឃើញលក្ខណៈអចិន្តភាព នៃការយកពាក្យខ្មែរមកជំនួសពាក្យបាលី ឬ សំស្ក្រឹតទាំងស្រុង យើងសូមសាកល្បងធ្វើការទិទស្សន៍ តាមរយៈឃ្លាជាឧទាហរណ៍ដូចខាងក្រោមនេះ :

-កាកបាទក្រហមនឹងក្លាយទៅជាជើងក្អែកក្រហម
- ការិយាល័យវប្បធម៌មហាជន នឹងក្លាយទៅជា កន្លែងធ្វើការបណ្ដុះបណ្ដាលមនុស្សម្នា
- អនាម័យរដ្ឋធានី នឹងក្លាយទៅជា ដំណើរមិនឈឺក្រុង
- មន្ទីរពេទ្យកុមារមជ្ឈិម នឹងក្លាយទៅជា កន្លែងគ្រូហ្មក្មេងៗកណ្ដាល
- នគរបាលចរាចរ នឹងក្លាយទៅជា អ្នកមើលស្រុកដំណើរទៅមក
- សាលាបំពេញវិជ្ជាមជ្ឈិម នឹងក្លាយទៅជា រោងរៀនចំណេះកណ្ដាល
- វិជ្ជាស្ថានគរុកោសល្យ នឹងក្លាយទៅជា ទីចំណេះអ្នកបង្រៀនក្បួនចំណេះ
- សាលាឆទាន នឹងក្លាយទៅជា រោងឱ្យប្រាំមួយ
- ប្រាជ្ញាបុណ្យផងកើតដោយប្រណិបត្តិ នឹងក្លាយទៅជា ការយល់ដឹងស្អាតផងកើតដោយស្ដាប់បាន
- អង្គការពតិមានមជ្ឈិមរណសិរ្ស នឹងក្លាយទៅជា ក្រុមចាត់ចែង ឬ ចាត់ការដំណឹង នៃក្រុមក្បាលទ័ពកណ្ដាល
- រណសិរ្សសាមគ្គី ការពារ កសាង មាតុភូមិកម្ពុជា នឹងក្លាយទៅជា ក្បាលទ័ពរួបរួម ការពារកសាងដីម្ដាយកម្ពុជា
- មជ្ឈិមសមាគម យុវជនបដិវត្តកម្ពុជា នឹងក្លាយទៅជា ក្រុមហ៊ុនកណ្ដាលមនុស្សជំទង់ បំរះប៉ៃរបំរួល ឬ ការបម្រះប្រែប្រួលកម្ពុជា ។ល ។...

## ១- ផលវិបាកនៃការលុបពាក្យបាលី និង សំស្ក្រឹត នាំទៅរក "បារាំងនិយកម្ម" ឬ "អង់គ្លេសនិយកម្ម" នៃភាសាខ្មែរ

នៅក្នុងអត្ថបទផ្សេងៗ ដែលចុះផ្សាយនៅក្នុងទំព័រសារពត៌មាន ឬ ទស្សនាវដ្ដីខ្មែរយើង យើងសង្កេតឃើញមាននិន្នាការមួយ ដែលធ្វើឱ្យយើងមានការបារម្ភខ្លាំង គឺនិន្នាការយកពាក្យបារាំងមកប្រើជំនួសពាក្យខ្មែរតែម្ដង ។ ប្រសិនបើជាពាក្យវិទ្យាសាស្ត្រពិបាកៗ ដូចជា វាក្យស័ព្ទ ផ្នែកគីមីវិទ្យាជាដើម យើងមិនសូវជាមានការភ្ញាក់ផ្អើលអ្វីប៉ុន្មានទេ ពីព្រោះ យើងគ្មានសមមូលធាតុ (équivalents) គ្រប់គ្រាន់ចំពោះផ្នែកនេះក្នុងភាសាខ្មែរយើង ។ ប៉ុន្តែ គួរឱ្យឆ្ងល់ណាស់ពាក្យដែលគេប្ដូរមកជាភាសាបារាំង (តាមការប្រកបសូរស័ព្ទ) ទាំងនោះ សុទ្ធតែជាពាក្យ ដែលខ្មែរធ្លាប់ប្រើយូរយារណាស់មកហើយ ។ តើគេធ្វើដូច្នេះ ដើម្បីបំបាត់ពាក្យបាលី ឬ សំស្ក្រឹតចេញ ឬក៏ជាការបំផុសចលនាសម័យនិយមអ្វីមួយបែបទៀតទៅហើយ ?

ឧទាហរណ៍:

| | | |
|---|---|---|
| វិទ្យាសាស្ត្រ | ក្លាយទៅជា | ស្យង់ |
| បច្ចេកទេស | ក្លាយទៅជា | តិចនិច |
| បច្ចេកវិជ្ជា | ក្លាយទៅជា | តិចណូឡូស៊ី |

តាមការសន្និដ្ឋានរបស់យើង ប្រហែលមកពីអ្នកធ្វើការផ្លាស់ប្ដូររបៀបនេះ គេយល់ថា បើលុបពាក្យបាលី ឬ សំស្ក្រឹតចោលចេញ ហើយបើគ្មានពាក្យខ្មែរមកជំនួសវិញបានមានតែច្រកមួយទេ គឺយកភាសាបារាំងមកជំនួសតែម្ដង (ទំរាំដល់វេនភាសាផ្សេងៗទៀត ដែលខ្មែរយើងអាចមានលទ្ធភាព និង ចេះស្ទាត់) ។ ការសន្និដ្ឋាននេះក៏ប្រហែលជាពុំខុសប៉ុន្មានដែរ ពីព្រោះថា បន្តិចទៀតនេះ ខ្មែរយើងភាគច្រើនបោះបង់ចោលភាសាបារាំងជាចាំបាច់ ។ នៅក្នុងចន្លោះពេលនៃការប្រែប្រួលនេះ ការយកភាសាបារាំង ឬ អង់គ្លេសមកជំនួសមិនអាចឱ្យយើងយកបុព្វបទ និង បច្ឆិមបទមកផ្គុំ ឬ កំណត់គុណនាមបានទេ ។ នៅក្នុងករណីនេះតើយកវេយ្យាករណ៍បារាំងមកកំណត់ ឬ វេយ្យាករណ៍ខ្មែរមកកំណត់វិញ ។ ឧ. អ្នកស្យង់ ឬ អ្នកស្យង់ទីហ្វិច ឬ ស្យង់ទីភិច ? អ្នកតិចនិច ឬ អ្នកតិចនិចស្យាំង ? ឃើញថា ពិបាករកឯកភាពណាស់ក្នុងការកំណត់វិធាន ។

ប្រសិនបើ គេមិនអាចទប់និន្នាការនេះបានទេ បន្តិចទៀតពាក្យមួយចំនួនធំដូចខាងក្រោមនេះ នឹងត្រូវយកពាក្យបារាំងមកជំនួសជាបន្តបន្ទាប់ :

| | | |
|---|---|---|
| វេជ្ជបណ្ឌិត | នឹងក្លាយទៅជា | ដុកទ័រ |
| វិស្វករ | នឹងក្លាយទៅជា | អាំងសេនញ៉េរ |
| នយោបាយ | នឹងក្លាយទៅជា | ប៉ូលីតិច |
| សេដ្ឋកិច្ច | នឹងក្លាយទៅជា | អេកូណូមិច |
| ទោចក្រយាន | នឹងក្លាយទៅជា | ប៊ីស៊ីក្លែត |
| ឱសថសាស្ត្រ | នឹងក្លាយទៅជា | ហ្វាម៉ាស៊ី ឬ ផាម៉ាស៊ី |

| | | |
|---|---|---|
| វេជ្ជសាស្ត្រ | នឹងក្លាយទៅជា | ម៉េដឺស៊ីន |
| នីតិសាស្ត្រ | នឹងក្លាយទៅជា | ស្យង់សៀវឡើឌិច |
| មនោសញ្ចេតនា | នឹងក្លាយទៅជា | សង់ទីម៉ង់ ។ល។... |

**២ – ការប្រើពាក្យខ្មែរជាពាក្យវិទ្យាសាស្ត្រ និងធ្វើឱ្យខូចបល់ដំណើរការនៃខេមរយានកម្ម**

ទោះបីយើងខិតខំធ្វើពាក្យខ្មែរឱ្យក្លាយតាមសូរស័ព្ទ ឱ្យអស់លទ្ធភាពយ៉ាងណាក្តី ក៏យើងមិនអាចបង្កើតពាក្យវិទ្យាសាស្ត្រឱ្យបានសមស្របដែរ ។ ការយកតែពាក្យខ្មែរ និជភាសា (vernaculaire) ទៅប្រើក្នុងវិទ្យាសាស្ត្រ ជាការមួយដែលគេពុំអាចធ្វើទៅរួចឡើយ។ ដូច្នេះ ចលនាខេមរយានកម្មនឹងត្រូវស្ទះចោលនៅកណ្តាលផ្លូវ ។ ចំពោះបញ្ហានេះ យើងសង្កេតឃើញមានការប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីយកពាក្យខ្មែរដែលគេបង្កើតតាមវិធីទាញសូរ ឬ បូកផ្សំជាបរិប្រយោគ ( périphrase) ទៅប្រើជាពាក្យវិទ្យាសាស្ត្រ ។ ទោះបីយើងខិតខំយ៉ាងណាក្តី ក៏យើងរកយល់មិនកើតឡើយ គឺទាល់តែស្មានកាត់យកន័យពីឃ្លាបារាំងវិញទើបអាចយល់ខ្លះ។ នៅចំពោះមុខសភាពការណ៍នេះ យើងយល់ឃើញថា បើពាក្យបាលី ឬ សំស្ក្រឹតវិញ យើងអាចមានលទ្ធភាពសមស្របល្អជាងឆ្ងាយណាស់ ពីព្រោះ យើងអាចបង្វិលបំបែកពាក្យបាលី ឬ សំស្ក្រឹតទាំងនោះទៅតាមអនុក្រម (série) ផ្សេងៗ ជាខ្សែចង្វាក់នៃធាតុភូតនីមួយៗ។ ជាការពិតណាស់ ដែលយើងត្រូវចេះភាសាបាលី ឬ សំស្ក្រឹតទាំងនោះខ្លះៗដែរ ប៉ុន្តែ ប្រការនេះមិនពិបាកដល់ការសិក្សាភាសាបរទេសមួយទៀតទាំងមូលនោះទេ។ម្យ៉ាងទៀត ភាសាបាលី និង សំស្ក្រឹតនេះ មិនមែនជាអ្វីដែលខុសឆ្គងនោះទេ ពីព្រោះ សូម្បីតែភាសាបារាំង អង់គ្លេស ក៏គេយកភាសាក្រិក និង ឡាតាំង ទៅធ្វើជាមូលដ្ឋាននៃការវិវត្តន៍ និង ការរីកចម្រើនលូតលាស់របស់ភាសាវិទ្យាសាស្ត្ររបស់គេដែរ ។

ដើម្បីគូសបញ្ជាក់ថា ការយកភាសាបាលី និង សំស្ក្រឹត ទៅធ្វើជាមូលដ្ឋាននៃការបង្កើតពាក្យវិទ្យាសាស្ត្រមានការងាយស្រួលជាង ហើយអាចធ្វើឱ្យខេមរយានកម្មអាចទៅដល់គោលដៅដោយសុវត្ថិភាព យើងសូមលើកឧទាហរណ៍មួយចំនួន ដូចខាងក្រោមនេះ :

- ពាក្យ " ផ្តាច់មុខ " ត្រូវនឹងពាក្យបារាំង monopole។ ប៉ុន្តែ បើយើងប្រើពាក្យ "ផ្តាច់មុខ" នេះចូលជ្រៅទៅក្នុងពាក្យបច្ចេកទេសខាងសេដ្ឋវិទ្យានោះ គឺយើងទៅពុំរួចទេ ពីព្រោះ មានធាតុភូតប្រហាក់ប្រហែលគ្នាជាច្រើនទៀត ដែលត្រូវចេញជាដាច់ខាត គេត្រូវធ្វើជាឃ្លាមួយមានពាក្យច្រើន ដើម្បីពន្យល់តែម្តង (périphrase) ឧទាហរណ៍ :

. ពាក្យ monopole បើប្រើជាភាសាខ្មែរ គេត្រូវសរសេរ ឬ ត្រូវនិយាយថា : " ផ្តាច់មុខមានអ្នកលក់តែម្នាក់ និង អ្នកទិញច្រើន" ទើបគ្រប់ន័យរបស់វា ។

. ពាក្យ duopole បើប្រើជាភាសាខ្មែរ គេត្រូវសរសេរ ឬ និយាយថា " ផ្ដាច់មុខមានអ្នកលក់ពីរនាក់ និង អ្នកទិញច្រើន " ទើបគ្រប់ន័យរបស់វា ។

. ពាក្យ oligopole បើប្រើជាភាសាខ្មែរ គេត្រូវសរសេរ ឬ និយាយថា : " ផ្ដាច់មុខមានអ្នកលក់មួយចំនួនតិច បីបួននាក់ និង អ្នកទិញច្រើន " ទើបគ្រប់ន័យរបស់វា ។

. ពាក្យ monopsone បើប្រើជាភាសាខ្មែរ គេត្រូវសរសេរ ឬ និយាយថា : " ផ្ដាច់មុខមានអ្នកទិញម្នាក់ និង អ្នកលក់ច្រើន " ទើបគ្រប់ន័យរបស់វា ។

. ពាក្យ duopsone បើប្រើជាភាសាខ្មែរ គេត្រូវសរសេរ ឬ និយាយថា : " ផ្ដាច់មុខមានអ្នកទិញពីរនាក់ និង អ្នកលក់មានចំនួនច្រើន " ទើបគ្រប់ន័យរបស់វា ។

. ពាក្យ oligopsone បើប្រើជាភាសាខ្មែរ គេត្រូវសរសេរ ឬ និយាយថា : " ផ្ដាច់មុខមានអ្នកទិញមួយចំនួនតិច ( បី បួន ប្រាំនាក់) និង អ្នកលក់មានចំនួនច្រើន " ទើបគ្រប់ន័យរបស់វា ។

ដូច្នេះយើងឃើញថា ពាក្យ " ផ្ដាច់មុខ " អាចប្រើបានសម្រាប់តែសម្គាល់ន័យទូទៅប៉ុណ្ណោះ ។ ប៉ុន្តែបើចូលជ្រៅទៅក្នុងការកំណត់បាតុភូតវាឱ្យបានល្អិត ពាក្យនេះលែងប្រើបានទៀត ហើយបើគេចង់ចៀសវាងធ្វើឃ្លាវែង ដែលជាហេតុនាំឱ្យអត្ថបទនីមួយៗមានទំហំធំលើសជាង ១០ដង នៃទំហំអត្ថបទដដែល និពន្ធជាភាសាផ្សេងៗ។ ដូច្នេះ គេត្រូវវិលទៅរកការបំបែកពាក្យពីភាសាបរទេសមួយ ដែលអាចយកធ្វើជាបង្អែកបាន ។ ប៉ុន្តែយើងក៏មិនទាន់ធ្លាក់ទៅក្នុងភាពទាល់ច្រកយកសូរស័ព្ទនៃពាក្យបារាំង ឬ អង់គ្លេស ទៅប្រកបជាអក្សរខ្មែរដែរ ។ ការធ្វើបែបនេះមានផលពិបាកច្រើនណាស់ គឺមានតាំងពីបញ្ហាប្រកបសូរស័ព្ទ រហូតទៅដល់បញ្ហាសណ្ឋានសាស្ត្រ ដោយមិនគិតពីបញ្ហាវេយ្យាករណ៍ ដែលកំណត់ការប្រែប្រួលសណ្ឋាននៃពាក្យទៀតផង។ នៅចំពោះបញ្ហានេះ មធ្យោបាយមួយដែលស្រួលងាយបំផុត គឺការរក្សាទុកភាសាបាលី និងសំស្ក្រឹត ដោយយកវាទៅបំបែកទៅតាមសេចក្ដីត្រូវការ។ តាមការពិត បើប្រៀបធៀបជាមួយនឹងភាសាបារាំង ឬ អង់គ្លេស ឬ រុស្ស៊ី ឬ វៀតណាម សូរស័ព្ទបាលី ឬ សំស្ក្រឹត មានលក្ខណៈស្រួលងាយជាង ហើយម្យ៉ាងទៀត ជាភាសាដែលជនជាតិខ្មែរយើងធ្លាប់ស្គាល់ ធ្លាប់រៀនរួចខ្លះទៅហើយទៀតផង។ ឧទាហរណ៍ :

ចំពោះពាក្យ monopole យើងអាចប្រើពាក្យ ឯកាធិការ ( ឯក + អធិការ)

ចំពោះពាក្យ duopole យើងអាចប្រើពាក្យ ទ្វីកាធិការ ( ទ្វិក + អធិការ)

ចំពោះពាក្យ oligopole យើងអាចប្រើពាក្យ អប្បាធិការ ( អប្ប + អធិការ)

ចំពោះពាក្យ monopsone យើងអាចប្រើពាក្យ ឯកយាធិការ ( ឯក +កយ+ អធិការ)

ចំពោះពាក្យ duopsoneយើងអាចប្រើពាក្យ ទ្វិកាយាធិការ ( ទ្វិក +កយ+ អធិការ)

ចំពោះពាក្យ oligopsoneយើងអាចប្រើពាក្យ អប្បក យាធិការ ( អប្ប +កយ+ អធិការ)

## VI

## អំពី ព្រឹត្តិភាសា ( idiome )

មិនថាតែភាសាខ្មែរយើងទេ ទោះជាភាសាទាំងអស់នៅលើសកលលោក ក៏មានលក្ខណៈពិសេសដោយឡែករបស់ខ្លួនដែរ ។ អាស្រ័យហេតុនេះ ការបកប្រែពីភាសាមួយទៅភាសាមួយទៀត គប្បីរក្សានូវលក្ខណៈពិសេសនេះជាដាច់ខាត ។ បើពុំនោះសោតទេ នឹងបណ្តាលឱ្យច្រឡំន័យ ពិបាកយល់ ពិបាកស្តាប់ អាចជះឥទ្ធិពលមិនល្អទៅដល់ការអនុវត្តន៏។ ឧទាហរណ៍ : défense d'entrer ប្រយោគប៉ុណ្ណេះ សម្រាប់ភាសាបារាំង សម្រាប់ជនជាតិបារាំង គឺមានន័យគ្រប់គ្រាន់ល្មមឱ្យគេយល់បាន ស្តាប់បានហើយ។ តែបើប្រែជាភាសាខ្មែរថា "ហាមចូល" យើងពិនិត្យឃើញថា ការបកប្រែនេះដូចទាំងស្រុងទៅតាមភាសាបារាំងពេក ចំពោះជនជាតិខ្មែរយើង (មិនសំដៅយកខ្មែរអ្នកចេះដឹងភាសាបារាំងទេ គឺចង់និយាយចំពោះបងប្អូនប្រជាជនទូទៅ) ច្បាស់ជាពិបាកកាត់យល់ពីពាក្យនេះណាស់ ពីព្រោះ គេនៅស្ទាក់ស្ទើរសង្ស័យនឹងពាក្យ "ហាម" ប្ញកនឹងពាក្យ "ចូល" គឺហាមផង ចូលផង។ ប៉ុន្តែ បើប្រែថា "ហាមមិនឱ្យចូល" "ហាមផ្តាច់មិនឱ្យចូល" ឬ "សូមកុំចូល" នោះ សូម្បីតែកុមារទើបតែចេះអានអក្សរខ្មែរក៏អាចយល់បានយ៉ាងងាយដែរ ព្រោះន័យរបស់ប្រយោគនេះមានលក្ខណៈជាខ្មែរ គឺជាព្រឹត្តិភាសា(idiome) ខ្មែរតែម្តង។

យើងសូមលើកឧទាហរណ៍ខ្លះៗទាក់ទងនឹងការបកប្រែពីភាសាបរទេសមកជាភាសាខ្មែរតាមរបៀបផ្ចិតចម្លងទាំងស្រុង ហើយដែលមានន័យស្ទាក់ស្ទើរ មិនច្បាស់លាស់ ... គួរគប្បីសម្រួលតាមលក្ខណៈខ្មែរយើងវិញ :

ហាមចូល → ហាមមិនឱ្យចូល

ហាមចត → ហាមមិនឱ្យចត

ហាមនោម → ហាមមិនឱ្យនោម

ហាមចាក់សំរាម → ហាមមិនឱ្យចាក់សំរាម

មានមិត្តខ្លះ គេរិះគន់ញែកថា ក្នុងប្រយោគនេះមានពាក្យអវិជ្ជមានកម្មដល់ទៅពីរ គឺ "ហាម" ជាតួអវិជ្ជមានកម្ម (négation) មួយ "មិនឱ្យ" ជាតួអវិជ្ជមានកម្មមួយទៀត។ គេថា កាលណា ក្នុងប្រយោគមួយមានអវិជ្ជមានកម្មជាប់គ្នាដល់ទៅពីរ គឺមានន័យ "ស្រប" (affirmation)ទៅវិញ ការយល់បែបនេះពិតជាត្រឹមត្រូវណាស់សម្រាប់ភាសាបារាំង យើងខ្ញុំក៏ឯកភាពផងដែរ ប៉ុន្តែ ចំពោះភាសាខ្មែរវិញ យោលទៅតាម

លក្ខណៈពិសេសនៃព្រឹត្តិភាសា(idiome) យើងមិនបានគិតអំពីអវិជ្ជមានកម្មពីរជាប់គ្នា ឬ យ៉ាងណាៗនោះទេ សំខាន់ គឺសរសេរយ៉ាងណាឱ្យស្របទៅតាមលក្ខណៈភាសាយើង ឱ្យជនជាតិយើងយល់បានជាការស្រេចទៅហើយ ។ ក្នុងគ្រួសារខ្មែរយើង យើងធ្លាប់ឮឪពុកម្ដាយនិយាយប្រដៅទូន្មានកូនចៅថា : អញហាម ហាមហើយហាមទៀត ហាមកុំឱ្យទៅលេងមាត់ត្រពាំង ក្រែងវាលង់ទឹក! តើមិត្តយល់ថា ឃ្លានេះវាស្ទួនន័យ (pléonasme) ឬ យ៉ាងណា? ។ ចំពោះយើង យើងយល់ថា នេះជារូបភាពនៃការពង្រឹងសង្កត់ន័យឱ្យមានលក្ខណៈខ្លាំងក្លាឡើង តែប៉ុណ្ណោះ ។ ទោះបីជាមានអ្នកខ្លះចង់បង្វែរន័យនៃឃ្លាខាងលើនេះថា "ឱ្យទៅលេងក្បែរមាត់ត្រពាំងចុះ" នោះក៏ពុំកើតដែរ ព្រោះវាផ្ទុយនឹងទម្លាប់ក្នុងការនិយាយស្ដីរបស់ខ្មែរ រីឯ បារាំង ឬ ភាសាណាទៀត ស្រេចនឹងជាតិគេចុះ ។ រួមសេចក្ដីមក យើងគប្បីយល់ថា ជាតិសាសន៍មួយៗរមែងមានលក្ខណៈពិសេស តាំងពីអរិយធម៌ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ ហើយជាពិសេសបញ្ញត្តិ(concept) នៅក្នុងភាសារបស់គេនីមួយៗ ។

អំពី ភាក្យសម្ព័ន្ធ : មានឃ្លាជាច្រើន ដែលយើងបកប្រែត្រង់ៗពេកពីភាសាគេ ។ ដើម្បីរក្សាសម្ផស្ស និង សណ្ដាប់ធ្នាប់នៃភាសាយើងឱ្យបានគង់វង់ យើងគប្បីគោរពបែបបទដែលយើងធ្លាប់សរសេរតាំងពីដើមមកវិញ ។ ឧទាហរណ៍ :

តំណាងឱ្យ គប្បីប្រើតែពាក្យ តំណាង វិញ

- យុវជនបីរូបតំណាងឱ្យសមាគមនិស្សិត គប្បីសរសេរ និង និយាយថា យុវជនបីរូបតំណាងសមាគមនិស្សិតវិញ ។

## VII
## អំពីការប្រើ បកតិសំខ្យា

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ យើងសង្កេតឃើញមិត្តមួយចំនួនប្រើបកតិសំខ្យា (ទាំងការនិយាយក៏ដូចជាសរសេរ) មានការឆ្គាំឆ្គងដោយមិនគោរពតាមទម្លាប់ និង សម្ផស្សរបស់ភាសាខ្មែរយើង ដែលបុព្វបុរសយើងធ្លាប់និយាយ ធ្លាប់សរសេរ ជារៀងដរាបមក ។

ឧ. ខ្ញុំសូមចាត់តាំងបួនសមមិត្តចុះមូលដ្ឋាន
មួយចំនួនសមមិត្តអនុវត្តបានល្អតាមស្មារតីសារាចរ.........

អ្នកប្រាជ្ញខាងអក្សរសាស្ត្រយើង ក៏លោកមិនបានកំណត់ដាច់ខាតថា ឱ្យដាក់ បកតិសំខ្យា នៅពីមុខនាមទាំងអស់ ឬ ក៏ឱ្យដាក់ពីក្រោយនាមទាំងអស់នោះ ក៏ទេដែរ ។ តែលោកគ្រាន់តែណែនាំឱ្យយើងប្រើវាឱ្យ

បានសមរម្យទៅតាមការគួរបានន័យថា ពាក្យណាគួរដាក់ បកតិសំខ្យានៅមុខ ពាក្យណាគួរដាក់ខាងក្រោយ អាចស្ដាប់បាន មិនឆ្គង មិនទាស់ដល់ការស្ដាប់ នោះគួរប្រើយ៉ាងនោះទៅ។

<u>បកតិសំខ្យា នៅពីក្រោយនាម</u> :

ឧ. ឆ្កែពីរ ស៊ីកូនមាន់អស់ដប់ ...។ និយាយ សរសេរយ៉ាងនេះ ងាយស្រួលស្ដាប់ជាង គឺមិនគប្បីសរសេរ ឬ និយាយថា : "ពីរឆ្កែស៊ីអស់ដប់កូនមាន់" ទេ។

<u>បកតិសំខ្យា នៅពីមុខនាម</u> :

ឧ. ចូរឯងយកស្វាយទុំដប់នេះទៅជូនលោកតា លោកយាយ ហើយត្រឡប់មកវិញ សុំស្រូវគាត់ពីរត្រឡោកមកឱ្យមាន់ស៊ីផង។ ប៉ុន្តែ បើនិយាយថា "ចូរឯងយកដប់ស្វាយទុំទៅជូនលោកតា លោកយាយ ហើយត្រឡប់មកវិញសុំស្រូវគាត់ត្រឡោកពីរមកឱ្យមាន់ស៊ីផង" នោះពិតជាឆ្គង ហើយពិបាកស្ដាប់ណាស់។

រួមមកវិញ យើងខ្ញុំយល់ថា មិត្តទាំងអស់បានចេះ បានដឹងអំពីបញ្ហានេះរួចរាល់អស់ហើយ សំខាន់គឺគួរអនុវត្តឱ្យបានល្អនូវការចេះដឹងរបស់យើង ទៅតាមលំអានអ្នកប្រាជ្ញបុរាណ និង តាមទម្លាប់ភាសាយើង ដែលតែងតែមានវិធាន ក្បួនខ្នាត ចង្អុលបង្ហាញ និង បំភ្លឺយើង អំពីរបៀបនិយាយ របៀបសរសេរឱ្យបានត្រឹមត្រូវ គឺធ្វើយ៉ាងណាចៀសវាងនូវអ្វីៗដែលលឿនពេក ទំនើបពេករហូតដល់លោតផ្លោះចេញឆ្ងាយពីភាសាជាតិ ហើយ ភ្លេចខ្លួនចូលទៅស្រូបយកចំហាយពីភាសាដទៃយកមកជំនួសមាតុភាសារបស់ខ្លួន ហើយតាំងមានមោទនភាពថា ខ្លួនជឿនលឿន ខ្លួនទំនើបជាងគេ ខ្លួនស្ថិតនៅជួរមុខខាងទំនើបភាវូបនីយកម្មអក្សរ-សាស្ត្រ។ គួរជម្រាបផងដែរថា ប៉ុល ពត ហេតុតែចង់ធ្វើទំនើបភាវូបនីយកម្មលទ្ធិសង្គមនិយមនេះឯង ទើបនាំមកនូវគ្រោះមហន្តរាយដ៏ជូរចត់បំផុត ដល់ប្រទេសកម្ពុជាយើង។

ឧទាហរណ៍ខ្លះៗនៃការប្រើបកតិសំខ្យា មិនសមស្របទៅតាមកន្លែងរបស់វា ដែលគប្បីអ្នកប្រើភាសាខ្មែរចៀសវាង :

ឧ. ដាំដើមដូង ៤ ដើម មិនមែនសរសេរថា ដាំ ៤ ដើមដូងនោះទេ គឺវាឆ្គង។

ហូបដូងអស់ ៤ ផ្លែ<br>ឬ<br>ហូបផ្លែដូងអស់ ៤ } មិនមែនសរសេរ ឬ និយាយថា ហូប៤ផ្លែដូងនោះទេ

ហូបគុយទាវអស់បីចាន មិនមែនសរសេរថា ហូបអស់បីចានគុយទាវទេ។

និស្សិតបួននាក់ទៅចូលរៀនមហាវិទ្យាល័យពីរ មិនមែនថា "បួននិស្សិតទៅចូលរៀនពីរមហាវិទ្យាល័យនោះទេ។

## VIII
## អំពីភាសាសាស្ត្រ និង ប្រវត្តិនៃវចនានុក្រមខ្មែរ

### ១ - តើភាសាសាស្ត្រសិក្សាអំពីអ្វី?

ភាសាសាស្ត្រជាការសិក្សាតាមបែបវិទ្យាសាស្ត្រ នូវសន្ទសញ្ញា(langage)ដែលមនុស្សប្រើ ដើម្បីធ្វើការទាក់ទងគ្នា។ ពាក្យថា "តាមបែបវិទ្យាសាស្ត្រ" មានន័យថា ការសង្កេត និង ពិពណ៌នាអំពីបាតុភូត។ ចំពោះភាសាសាស្ត្រ គឺការសង្កេត និង ពិពណ៌នាអំពីបាតុភូតទាំងឡាយ ដែលលេចចេញឡើងនៅក្នុងសន្ទសញ្ញានេះ។ ប៉ុន្តែប្រការមួយដែលគួរឱ្យសោកស្ដាយជាទីបំផុត គឺការយល់ថា ភាសាសាស្ត្រជាការសិក្សាដែលកំណត់វិធានផ្សេងៗ ដើម្បីយកទៅឱ្យគេអនុវត្តន៍តាម នៅក្នុងការប្រើភាសានីមួយៗទៅវិញ។ តាមនិយមន័យពិតប្រាកដរបស់វិទ្យាសាស្ត្រនេះ ភាសាសាស្ត្រ(la linguistique) គឺជាវិទ្យាសាស្ត្រមួយបែប ដែលសិក្សាអំពីសន្ទសញ្ញា តាមរយៈទិដ្ឋភាពផ្សេងៗនៃសូរស័ព្ទ និង វាក្យសម្ព័ន្ធ ព្រមទាំងទិដ្ឋភាពន័យសាស្ត្រ ទិដ្ឋភាពសង្គម រួមបញ្ចូលទាំងការសិក្សាអំពីរចនាសម្ព័ន្ធ ការរីកចម្រើន ការវិវត្តន៍ ការបែងចែកជាភាសាផ្សេងៗ និង ទំនាក់ទំនងរវាងភាសាទាំងឡាយនេះ។ ដូច្នេះ ភាសាសាស្ត្រមិនមែនជាការសិក្សាអំពីការកំណត់វិធានយកទៅឱ្យគេប្រើនោះទេ។ ការសិក្សាអំពីការកំណត់វិធាននេះ ជាវិស័យរបស់វេយ្យាករណ៍។ ប៉ុន្តែចំពោះការសិក្សាអំពីវេយ្យាករណ៍នេះទៀតសោត ក៏ចែកជាច្រើនផ្នែកទៅទៀត មានជាអាទិ វេយ្យាករណ៍ពិពណ៌នា(grammaire descriptive) វេយ្យាករណ៍បទដ្ឋាន(grammaire normative) វេយ្យាករណ៍ប្រវត្តិសាស្ត្រ (grammaire historique) វេយ្យាករណ៍ប្រៀបធៀប(grammaire comparée) វេយ្យាករណ៍ទូទៅ (grammaire générale) វេយ្យាករណ៍កំណត់វិធាន (grammaire générative) ។ល។ បញ្ហាដែលចោទឡើង គឺការភាន់ច្រឡំរវាងមុខវិជ្ជាទាំងពីរនេះ ដែលមានប្រភេទបញ្ញត្តិ(catégorie) ខុសគ្នា។ ដើម្បីស្វែងយល់អំពីភាពខុសគ្នានេះ គេអាចធ្វើការប្រៀបធៀបវេយ្យាករណ៍បទដ្ឋានទៅនឹងសីលធម៌មួយ ដែលគេកំណត់យកទៅគ្រប់គ្រងសង្គមមួយ ហើយប្រៀបធៀបភាសាសាស្ត្រទៅនឹងវិទ្យាសាស្ត្រមួយបែប ដែលសិក្សារកធម្មភាព (lois) នៃសកម្មភាពទាំងឡាយរបស់មនុស្សនៅក្នុងសង្គម។ ដូច្នេះ យើងអាចយល់បានថា សីលធម៌ជាការតាក់តែងក្បួន និង វិធានផ្សេងៗសម្រាប់បញ្ជាសកម្មភាព និង កំណត់ចរិយារបស់មនុស្សនៅក្នុងសង្គម ទៅតាមការយល់ឃើញ ឬ ឆន្ទៈរបស់មនុស្សមួយក្រុមតូច។ ប៉ុន្តែ ច្បាប់ក្បួន ឬ វិធានទាំងនោះនឹងក្លាយទៅជាឥតប្រសិទ្ធភាព កាលណាវាមិនឆ្លើយតបទៅនឹងធម្មភាពរបស់វិទ្យាសាស្ត្រ។

### ២ - អំពីតួនាទីរបស់ភាសា:

តើភាសាជាអ្វី ?

ភាសាគឺជាឧបករណ៍មួយប្រភេទមានលក្ខណៈជាសញ្ញា ដែលមនុស្សប្រើសម្រាប់ទាក់ទងគ្នា។ ប៉ុន្តែចំពោះភាសាវិទូ ភាសាក៏ជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងនូវសកម្មភាពរបស់មនុស្សនៅក្នុងសហគមន៍នីមួយៗដែរ តាមរយៈន័យរបស់វា(contenu sémantique) ក៏ដូចជាតាមរយៈស័ព្ទរបស់វា (expression phonique) ដែរ។ ដូច្នេះភាសាជាសញ្ញា ឬ និមិត្តរូបទាំងឡាយដែលប្រជាជនទាំងអស់បានកំណត់ឡើងរួមគ្នា ហើយទទួលស្គាល់គ្រប់ៗគ្នា និង ហាត់រៀនតៗគ្នា។ ប៉ុន្តែ នៅពេលដែលសញ្ញា ឬ និមិត្តរូបទាំងនោះ បានត្រូវមនុស្សមួយចំនួនតូចនាំគ្នាកែប្រែវា ហើយយកទៅឱ្យប្រជាជនរៀនតាមវិញនោះ ភាសានោះក៏ត្រូវច្របូកច្របល់ ហើយនឹងគ្មានអ្នកណាអាចប្រើវាកើតទៀតឡើយ។ គឺនៅពេលនោះហើយ ដែលភាសានោះត្រូវគេបោះបង់ចោលបន្តិចម្តងៗ។ ភាសាមួយអាចត្រូវគេវិនិច្ឆ័យថា មានការរីកចម្រើន កាលណាវាឆ្លើយតបជានិច្ចទៅនឹងការរីកចម្រើននៃសេចក្តីត្រូវការរបស់មនុស្ស នៅក្នុងសហគមន៍មួយ ពោល គឺមានការបញ្ចូលនូវពាក្យថ្មីៗទៀត ដែលមិនធ្វើឱ្យប៉ះពាល់ដល់ពាក្យដែលមានរួចហើយ។ អ្នកប្រាជ្ញអក្សរសាស្ត្រខ្លះ ច្រឡំការវិវត្តន៍របស់ភាសា និង ការប្តូរភាសា។ ធម្មតា កាលណាភាសាមួយវិវត្ត អ្នកប្រើប្រាស់មិនសូវចាប់អារម្មណ៍ទេ គឺគេប្រើតាមសម្រួល។

## ៣- គុណូបការៈរបស់សម្តេចសង្ឃរាជ ជួន ណាត

ផ្ទុយស្រឡះពីការអះអាងរបស់អ្នកប្រាជ្ញ ដែលយកការទាញសូរស័ព្ទធ្វើជាមូលដ្ឋាននៃការបង្កើតពាក្យថ្មី សម្តេចសង្ឃរាជ ជួន ណាត បានធ្វើឱ្យភាសាខ្មែរយើងមានឯកភាពផង មានលក្ខណៈសម័យទំនើបផង។ កាលពីដើម អក្ខរាវិរុទ្ធភាសាខ្មែរមានបញ្ហាខ្លះខាងឯកភាព ប៉ុន្តែ បន្ទាប់ពីពេលដែលអ្នកប្រាជ្ញខ្មែរយើងនេះបានចងក្រងជាវចនានុក្រមខ្មែរមួយបានសម្រេចមក អក្ខរាវិរុទ្ធខ្មែរយើងក៏បានរកឯកភាពឃើញវិញ ទាំងពាក្យខ្មែរដែលមានឫសគល់ពីបាលី/សំស្ក្រឹត ទាំងពាក្យខ្មែរដែលប្រើក្នុងភាសាប្រជាប្រិយ ទាំងវេយ្យាករណ៍។ លក្ខណៈទំនើបនៃវចនានុក្រមនោះ គឺការបញ្ចូលនូវពាក្យជាច្រើនបន្ថែមលើសពីនិជភាសា (vernaculaire) របស់ខ្មែរយើងពីបុរាណ។ ពាក្យថ្មីៗទាំងនេះ ទោះបីមានប្រភពពីបាលី ឬ សំស្ក្រឹតក្តី ជាពាក្យដែលចាំបាច់ណាស់ សម្រាប់ប្រើប្រាស់ក្នុងសម័យយើងនេះ ពីព្រោះ វាជាមូលដ្ឋាននៃពាក្យវិទ្យាសាស្ត្រ។ គឺតាមរយៈពាក្យដែលបានត្រូវកំណត់យកនោះហើយ ដែលគេអាចបង្កើតនូវឧត្បត្តស័ព្ទ (mots dérivés) បានច្រើនទៀត។ លក្ខណៈសម័យទំនើបមួយទៀត ដែលគេមិនសូវជាចាប់អារម្មណ៍ គឺការរក្សាយ៉ាងខ្ជាប់ខ្ជួននូវក្បួនវេយ្យាករណ៍មួយដែលខ្មែរយើងទទួលបានដោយពេញចិត្ត។ ទន្ទឹមនឹងពាក្យដែលមានឫសគល់ពីបាលី ឬ សំស្ក្រឹត ដែលគេអាចកំណត់បានថាជាភាសាមួយដែលមានលក្ខណៈវិទ្យាសាស្ត្រនោះ វចនានុក្រមនោះបានបញ្ចូលនូវពាក្យប្រជាប្រិយ និង និជភាសា មួយចំនួនធំ ដើម្បីរក្សានូវមូលដ្ឋាននៃវប្បធម៌ខ្មែរយើង។

ប្រការដែលយើងគួរកត់សម្គាល់ គឺទស្សនៈប្រាកដនិយមផ្នែកសទ្ទានុក្រមនៃវចនានុក្រមនោះ : យើងសង្កេតឃើញថា គណៈកម្មការវប្បធម៌ដែលដឹកនាំដោយសង្ឃរាជ ជួន ណាត កាលជំនាន់នោះ គ្មានទស្សនៈរើរវាយថា គេអាចទាត់ចោលពាក្យខ្មែរដែលមានឫសគល់ពីបាលី ឬ សំស្រ្កឹត ឱ្យផុតអស់ពីពីភាសាខ្មែរឡើយ ហើយនៅលើមូលដ្ឋាននេះ បានបើកផ្លូវយ៉ាងទូលាយ ហើយសមរម្យបំផុត ដើម្បីឱ្យភាសាខ្មែរយើងរីកចម្រើនជានិច្ចទៅអនាគតកាល។ ម្យ៉ាងទៀត វចនានុក្រមខ្មែរនោះក៏បានកំណត់យ៉ាងច្បាស់ថា គេមិនគប្បីយកពាក្យដែលមានឫសគល់ពីបាលី ឬ សំស្រ្កឹតទាំងឡាយនោះ ទៅសរសេរ ឬ ប្រកបតាមបែបខ្មែរទាំងស្រុងនោះទេ។ ប៉ុន្តែ នៅក្នុងវិធីប្រកបនេះសោតទៀត ជាពិសេស ការសរសេរជាព្យាង្គតម្រួត ឬ ជាព្យាង្គរាយ វចនានុក្រមរបស់ ស.ស. ជួន ណាត បានរក្សាទុកយ៉ាងខ្ជាប់ខ្ជួននូវលក្ខណៈនិរុត្តិសាស្ត្រ ពោលគឺការក្សានូវលក្ខណៈប្រវត្តិសាស្ត្រនៃពាក្យនីមួយៗ បើជាពាក្យបាលី ឬ សំស្រ្កឹត លោករក្សាជានិច្ចនូវមូលស័ព្ទ(radical) ពីកំណើតរបស់វា។ ក្នុងករណីនេះ លោកបានជួយឱ្យអ្នកសិក្សាភាសាខ្មែរយើងអាចចៀសផុតពីការភ័ន្តច្រឡំផ្នែកសទិសស័ព្ទថែមទៀត។

ប៉ុន្តែ វចនានុក្រមនោះ ក៏មានការខ្វះខាតមួយចំនួនដែរ គឺបានអនុញ្ញាតឱ្យអ្នកប្រាជ្ញជាន់ក្រោយមានលទ្ធភាពក្នុងការកម្ចេចវចនានុក្រមរបស់លោកនៅថ្ងៃក្រោយ ដោយលោកបានអនុគ្រោះឱ្យប្រកបពាក្យមួយចំនួនខុសពីវិធានដែលលោកបានកំណត់ ពីព្រោះ លោកយល់ឃើញថា ពាក្យទាំងនេះមានចំនួនតិចណាស់ហើយ ម្យ៉ាងទៀត លោកជឿថា ថ្ងៃក្រោយ អ្នកចេះស្ទាត់ខាងអក្ខរាវិរុទ្ធខ្មែរមុខតែនឹងនាំឱ្យគេវិលមករកផ្លូវត្រូវវិញជាពុំខាន។ ការប៉ាន់ស្មាននេះខុសទាំងស្រុង ពីព្រោះ អ្នកប្រាជ្ញជាន់ក្រោយបានយកសេចក្ដីអនុគ្រោះដ៏ពោរពេញទៅដោយការទុកចិត្តនោះទៅបង្កើតជាវិធាន ដើម្បីវាយរំលំមូលដ្ឋានរបស់ស.ស. ជួន ណាត ទៅវិញ។ ប៉ុន្តែ ប្រជាជនគ្រប់មជ្ឈដ្ឋានគេពុំគាំទ្រការវាយរំលំក្បួនអក្សរសាស្ត្រខ្មែរដ៏កម្រនេះទេ។ ជាភស្តុតាងតាំងពីសម័យមុនមកទល់នឹងបច្ចុប្បន្នកាលនេះ យើងនៅតែប្រើវចនានុក្រមនេះរហូត គឺយើងនៅតែប្រើពាក្យបដិវត្តន៍ ប្រជាជន មជ្ឈិម កម្មករ ចិត្ត កញ្ញា កប្បាស កសិកម្ម គង្គា ការឃើញ (ពុំមែនគំហើញទេ) ការឃុំ (ពុំមែនគំហុំទេ) ការបៀតបៀន(ពុំមែនរបៀតរបៀនទេ) ការរីក(ពុំមែនរបីកទេ) ការដេញដោល (ពុំមែនដំណេញដំណោលទេ) សេចក្ដីរីករាយ(ពុំមែនរបីករបាយទេ) ភាពតានតឹង(ពុំមែនតំណានតំណឹងទេ)។ល។

**៩- ប្រវត្តិនៃវចនានុក្រមខ្មែរ**

នាឆ្នាំ១៩២១ សាលាបាលីជាន់ខ្ពស់បានចាប់កំណើតឡើង។ នៅឆ្នាំ១៩៣០ សាលាបាលីជាន់ខ្ពស់នេះបានត្រូវដាក់ឱ្យនៅក្រោមការគ្រប់គ្រងរបស់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យជាមួយនឹងរាជបណ្ណាល័យ។ បន្ទាប់មកទៀត ពុទ្ធិកវិទ្យាល័យ និង ពុទ្ធិកមហាវិទ្យាល័យក៏បានចូលរួមចំណែកជាមួយវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

នេះដែរ។ កាលជំនាន់នោះ មានតែស្ថាប័នទាំងឡាយនេះទេដែលមានបង្រៀនវិជ្ជាផ្សេងៗ តាមរយៈភាសាខ្មែរទាំងស្រុង។ វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យជាស្ថាប័នមួយដែលអ្នកប្រាជ្ញខ្មែរនាំគ្នាធ្វើការសិក្សា និង បោះពុម្ពផ្សាយសៀវភៅសិក្សាជាភាសាខ្មែរយ៉ាងសកម្មបំផុត ហើយការសិក្សាស្រាវជ្រាវទាំងនោះមានឈ្មោះល្បីល្បាញមិនត្រឹមតែក្នុងប្រទេសកម្ពុជាទាំងមូលនោះទេ នៅឯបរទេសក៏គេនាំគ្នាយកសៀវភៅបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យនេះ ទៅធ្វើជាមូលដ្ឋាននៃការសិក្សាស្រាវជ្រាវអំពីវប្បធម៌ខ្មែរដែរ។ ប៉ុន្តែសកម្មភាពនេះបានចុះថយជាលំដាប់ ចាប់តាំងពីឆ្នាំ១៩៧០មក។ គឺវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យនេះហើយដែលបានបោះពុម្ពផ្សាយទស្សនាវដ្ដី "កម្ពុជ-សុរិយា" ដែលបានកើតឡើងនៅឆ្នាំ១៩៤៧។ គឺនៅក្នុងរយៈកាលនោះហើយ ដែលវចនានុក្រមខ្មែរលើកដំបូងបង្អស់បានត្រូវបោះពុម្ពផ្សាយចំនួនប្រាំលើក។ មុនការបោះពុម្ពផ្សាយនៃវចនានុក្រមនេះ ប្រទេសកម្ពុជាយើងកាលជំនាន់នោះមានតែវចនានុក្រមខ្មែរ-បារាំងប៉ុណ្ណោះ[1] ។ ការបោះពុម្ពផ្សាយនូវវចនានុក្រមខ្មែរសុទ្ធមួយជាលើកដំបូងនេះ ជាព្រឹត្តិការណ៍មួយយ៉ាងសំខាន់ ចំពោះប្រវត្តិនៃអក្សរសាស្ត្រខ្មែរយើង ទោះជាយ៉ាងនេះក្ដី ក៏មានមតិខ្លះរិះគន់ថា ពាក្យខ្លះមានលក្ខណៈបាលីពេក។ ប៉ុន្តែ អ្នកដែលរិះគន់នោះ ក៏ចៀសពីពាក្យដែលមានឫសគល់បាលីនោះពុំផុតដែរ ហើយក៏នាំគ្នាប្រើជារៀងរហូតមកទល់នឹងបច្ចុប្បន្នកាលនេះ។

វចនានុក្រមខ្មែរនេះជាស្នាដៃនៃភាសាវិទូ និង ពុទ្ធសាសនសង្ឃមួយក្រុមដឹកនាំដោយសម្ដេចសង្ឃរាជ ជួន ណាត (មហានិកាយ)។ ដោយសារការស្រាវជ្រាវរបស់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ពាក្យទាំងឡាយដែលត្រូវបញ្ចូលទៅក្នុងវចនានុក្រមខ្មែរនោះមានលក្ខណៈរូបី ហើយឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សនូវមូលដ្ឋានវប្បធម៌ខ្មែរយើង។ កាលជំនាន់នោះ ការគាបសង្កត់នៃវប្បធម៌បារាំងមកលើវប្បធម៌ខ្មែរមានសភាពខ្លាំងក្លាណាស់ : និសិត្សខ្មែរដែលបានទៅបំពេញវិជ្ជានៅប្រទេសបារាំង លុះដល់ត្រឡប់មកមាតុប្រទេសវិញបានត្រូវជ្រើសរើសឱ្យកាន់កាប់កន្លែងសំខាន់ៗខាងផ្នែករដ្ឋបាល និង ខាងវិស័យវិស្វកម្ម។ គឺនៅពេលនោះហើយ ដែលបញ្ហានៃការប្រើប្រាស់ពាក្យខ្មែរឱ្យបានទៅតាមសេចក្ដីត្រូវការជាចាំបាច់បានចោទឡើង។ នៅចំពោះមុខការខ្វះខាតនេះ គេនាំគ្នានិយាយបារាំងតែម្ដង ដោយគេគិតថា គ្មានអ្នកណាអាចបកពាក្យបារាំងនោះមកជាភាសាខ្មែរឱ្យបានត្រឹមត្រូវឡើយ ហើយដោយខ្ជិលដោះស្រាយអំពីបញ្ហានេះ គេក៏នាំគ្នាអះអាងថាពាក្យបារាំងនោះជាពាក្យវិទ្យាសាស្ត្រទៅហើយ មិនគប្បីបកប្រែវាទេ។ ប៉ុន្តែ ការប្រើភាសាបារាំងពាសពេញ

[1] - វចនានុក្រមខ្មែរ-បារាំង របស់ B. Bernard, ហុងកុងឆ្នាំ១៩០២, ៣៨៦ទំព័រ។ នៅខាងដើមនៃវចនានុក្រមនោះ អ្នកនិពន្ធបានលើកឡើងអំពីវេយ្យាករណ៍ខ្មែរ(៤៨ ទំព័រ)

- វចនានុក្រមខ្មែរ-បារាំង របស់ Joseph Guesdon (១៩៨២ ទំព័រ, ២៥.០០០ ពាក្យ)Plon.

- វចនានុក្រមខ្មែរ-បារាំង របស់ Joseph Tandart (១៩៣៥ ទំព័រ, Albert Portail ២៤៦៨ ទំព័រ)។

ក្នុងភាសាខ្មែរដូច្នេះ ក៏បង្កើតឡើងនូវប្រតិកម្មមួយដែលគេមិនអាចចៀសវាងបាន។ ប្រតិកម្មនោះបានផ្ទុះឡើងនៅឆ្នាំ១៩៦៦ ហើយបានជម្រុញឱ្យរាជរដ្ឋាភិបាលចាត់ចែងដោះស្រាយបញ្ហានេះជាបន្ទាន់។ គឺចាប់ពីពេលនោះមកហើយ ដែលគណៈកម្មការខេមរយានកម្មបានត្រូវកើតឡើង ហើយទទួលភារកិច្ចបង្កើតពាក្យថ្មីទៅតាមសេចក្តីត្រូវការរបស់ប្រជាជនខ្មែរយើង។ ប៉ុន្តែ ទន្ទឹមនឹងនោះ ក៏មានការប្រេះឆាមួយគួរឱ្យសោកស្តាយជាទីបំផុត ដែលបណ្តាលមកពីនិន្នាការពីរ។ និន្នាការមួយយោលទៅតាមទស្សនៈរបស់សង្ឃរាជ ជួន ណាត ដែលឱ្យយកឫសនៃពាក្យ បាលី ឬ សំស្ក្រឹត ទៅបង្កើតពាក្យថ្មីៗទាំងនោះ។ និន្នាការមួយទៀតរបស់លោកសាស្ត្រាចារ្យ កេង វ៉ានសាក់ ប្រឆាំងនឹងការយកឫសពាក្យបាលី ឬ សំស្ក្រឹតមកធ្វើជាពាក្យថ្មី។ និន្នាការនេះ ទាមទារឱ្យយកវិធីធ្វើអក្ខាសពាក្យខ្មែរបុរាណទៅធ្វើ ឧព្ភតកម្ម(dérivation traditionnelle par affixation)។ យើងសូមបញ្ជាក់ថា នៅក្នុងគោលគំនិតរបស់លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ការបង្កើតពាក្យថ្មីនេះមានល័ក្ខខ័ណ្ឌរបស់វាច្បាស់លាស់ណាស់[1]។ លោកបានបញ្ជាក់ជាអាទិថា គេត្រូវបង្កើតតែពាក្យណាដែលភាសាខ្មែរយើងពុំទាន់មាននៅឡើយប៉ុណ្ណោះ[2]។ ប៉ុន្តែ សិស្សរបស់លោកមិនត្រឹមតែមិនស្តាប់ពាក្យបណ្តាំតែប៉ុណ្ណោះទេ គឺថែមទាំងនាំគ្នាធ្វើឧភាសកម្មទាំងកម្រោលថែមទៀត ធ្វើឱ្យវាក្យស័ព្ទខ្មែរប្តូរទាំងឫសគល់ ទាំងសណ្ឋាន ស្តាប់លែងយល់អ្វីទាំងអស់ ហើយបណ្តាលឱ្យអ្នកប្រើប្រាស់មិនដឹងថា ត្រូវប្រើពាក្យអ្វីឡើយ។ តាមការពិត មានពាក្យខ្មែរខ្លះត្រូវយកមកប្រើវិញដែរ ប៉ុន្តែពាក្យទាំងនោះពុំអាចបែកទៅតាមបាតុភូតល្អិតៗនៃវិទ្យាសាស្ត្របានទេ ជាហេតុដែលធ្វើឱ្យខេមរយានកម្មត្រូវស្ទះដំណើរ។ ត្រង់កន្លែងនេះលោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ក៏បានហាមឃាត់នៅក្នុងសៀវភៅ "មូលភាព" របស់លោកដែរ។ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ លោក ឃួន សុខុម្ភ ដែលជាសិស្សរបស់លោក កេង វ៉ាន់សាក់ នៅពេលដែលត្រឡប់មកពីបំពេញវិជ្ជាពីក្រុងប៉ែឡាំងវិញ បានបំផុសចលនាទំនាញសូរស័ព្ទ("ទំនាញសូរ") យ៉ាងខ្លាំងនៅមហាវិទ្យាល័យអក្សរសាស្ត្រភ្នំពេញ បណ្តាលឱ្យមានការច្របូកច្របល់យ៉ាងខ្លាំង។ ប៉ុន្តែ ដោយគ្មានការគាំទ្រពីប្រជាជនពីមជ្ឈដ្ឋានកវីនិពន្ធនិ៍ អ្នកសារពតិមាននោះ ចលនានោះក៏បាត់ឥទ្ធិពលទៅវិញ ហើយបន្សល់ទុកនូវពាក្យមួយចំនួន ដែលយើងនាំគ្នាប្រើខុសរហូតមកទល់នឹងសព្វថ្ងៃនេះ។ ទោះជាយ៉ាងនេះក្តី អ្នកដែលគេស្រឡាញ់អក្សរសាស្ត្រខ្មែរយ៉ាងមាំមួន គេមិនបណ្តោយទៅតាមការធ្វេសប្រហែសបែបនេះទេ គឺបើគេមិនទាន់ច្បាស់ គេបើកវចនានុក្រមខ្មែរមើលជាបន្ទាន់មុននឹងសរសេរ។ នៅក្នុងពេលដែលមានការខ្វែងគំនិតគ្នានេះ លោក លាង ហាប់អាន ដែលជាសិស្សរបស់លោក កេង វ៉ាន់សាក់ ផង ជាសិស្សរបស់សម្តេចសង្ឃរាជ ជួន ណាត ផង

---

[1] - "មូលភាពនៃការបង្កើតពាក្យថ្មី" កេង វ៉ាន់សាក់ មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ - ភ្នំពេញ ១៩៦៤។

[2] - "មូលភាពនៃការបង្កើតពាក្យថ្មី" ទំព័រ ៤។

បានសូមអនុញ្ញាតពីសម្តេចសង្ឃរាជឱ្យប្រើពាក្យខ្លះ ដែលបង្កើតឡើងថ្មីៗតាមវិធីអក្ខរាសនេះ។ សម្តេច ជួន ណាត ក៏បានយល់ព្រមដែរនៅក្នុងករណីចាំបាច់ ហើយត្រឹមត្រូវ គឺមិនឱ្យធ្វើជាទូទៅតាមទំនើងចិត្តទេ។ ប៉ុន្តែ បច្ចុប្បន្ននេះ ពាក្យបណ្តាំនេះក៏រលាយបាត់សាបសូន្យទៅទៀត ជាហេតុធ្វើឱ្យមានអនាធិបតេយ្យដូចយើង បានឃើញស្រាប់ ។ ចំពោះការបញ្ចូលពាក្យថ្មីតាមវិធីអក្ខរាសនេះ មកក្នុងវចនានុក្រមខ្មែរ ដែលបោះពុម្ពចុង ក្រោយបង្អស់នេះ យើងមានការសង្ស័យថា មានពាក្យខ្លះត្រូវបន្ថែមជាក្រោយៗបន្តបន្ទាប់មកទៀត ដោយ គ្មានការយល់ព្រមពីសង្ឃរាជ ជួន ណាត ទេ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏យើងឃើញថា មិនទាន់ប៉ះពាល់ អ្វីធ្ងន់ធ្ងរដល់ភាសាខ្មែរយើងនៅឡើយទេ ពីព្រោះ ពុំទាន់មានប្តូរអក្សរ ឡ និង អក្សរ ណ នៅឡើយទេ ។ រីឯស្រះពេញតួក៏ត្រូវបានទទួលស្គាល់ និង ប្រើប្រាស់ជាធម្មតាទៅតាមអក្ខរាវិរុទ្ធជាធរមាន។ ចំពោះ សៀវភៅខេមរយានកម្ម ដែលបោះពុម្ពចុងក្រោយបង្អស់នេះ ក៏មិនទាន់ហ៊ានកែអ្វីជាដុំកំភួនដែរ ។

## គន្ថនិទ្ទេស


ស្នាដៃជាភាសាខ្មែរ :

- កេង វ៉ាន់សាក់ , មូលភាពនៃការបង្កើតពាក្យថ្មី, បណ្ណាគាររស្មីកម្ពុជា, ភ្នំពេញ ១៩៦៤
- ឃួន សុខម្ភូ, ទម្រង់សូរវិទ្យាខ្មែរ, មជ្ឈមណ្ឌលរកឯកសារនិងស្រាវជ្រាវ ផ្នែកភាសាវិទ្យាអនុវត្តិនៃ មហាវិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រ នាសកលវិទ្យាល័យភ្នំពេញ, ១៩៧០-១៩៧១
- ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរ, បណ្ណាគារគីម សេង, ភ្នំពេញ ១៩៦៨
- វចនានុក្រមខ្មែរ, បោះពុម្ពគ្រាទី៥, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស ២៥១២ គ.ស ១៩៦៧-៦៨
- អៀវ កើស, ភាសាខ្មែរ ( ការសាកល្បងពិនិត្យដោយហេតុផល) រោងពុម្ព ព្រះរាជទ្រព្យ, ភ្នំពេញ ១៩៦៧

ស្នាដៃជាភាសាបរទេស :

- Bloomfield (Leonard), Language, New York, 1933.
- Cambefort (G.), Introduction au cambodgien, Paris, 1950;
- Cambodian-English dictionary, 2 vol., 1977 (Robert K. Headley, Jr., Kylinchhor, Lam Kheng Lim, Lim Hak Kheang, Chem Chun).
- Chomsky (Noam), Syntactic Structures, La Haye, 1957.
- coedès (G.) , Inscriptions du Cambodge, 8 vol. (1937-1966);
  , Les langues de l'Indochine, Conférences de l'Institut de linguistique de l'Université de Paris, t. VII, 1940-1948;
- Dictionnaire cambodgien-français, Paris, 1930 (J. GUESDON)
- Dictionnaire khmer-français, Saïgon, 1878 (E. AYMONIER)
- Fabricius, (P.), L'Evolution de la langue khmère, in Cambodge d'aujourd'hui, n° 7,

Juillet 98, Phnom Penh.

- Godel ( Robert), Les sources manuscrites du cours de linguistique générale, F. de Saussure, 1957.
- Gorgoniev (J.U.A), Grammaire de la langue khmère, Ed. Naouka, rédaction. Gle de Littérature Orientale, Moscou, 1966;
- Halle (M.) et Jakobson (R.), Fundamentals of Language, La Haye, 1956.
- Harris (Zellig S.), Introduction to Descriptive Linguistics, 2e éd., N.Y., 1961.
- Henderson (E.), the Main Features of Cambodian Pronunciation, in Bulletin of the scool of oriental studies, vol.XIV, Londre, 1952.
- Hjemslev (L.), Prolégomènes à une théorie de langage (tra. du danois), Paris, 1968.
- Hoekett )Challes F.), A Course in Modern Linguistics, New York, 1958.
- Huffman (Franolin E.) An Outline of Cambodian Grammar, Unpublished Ph D. disnertation, cornell University, 1967.
- Jacob (Judith M.), The Structure of the Word in old Khmer, in BSOAS 23 (1960).
  , Prefixation and Infixation in old Mon, old Khmer and Modern Khmer, in Linguistic Comparison in Southeast Asia and Asia Pacific, School of Oriental and African Studies, University of London, 1963.
- Jackobson (Roman), Essais de liguistique générale, Paris, s.d.
- Jacques (C.) , Les Inscriptions du Cambodge, in Nokor Khmer, 1er trimestre, 1970, n°2
- Janneau (G.), Manuel pratique de la langue cambodgienne, Saïgon, 1870;
  , Etude de l'alphabet cambodgien, Saïgon, 1869;
- Jespersen (Otto), Language, Longres, 1922.
- Lepschy (G.), La Linguistique structurale ( tra. de l'italien), Paris, 1968.
- Lexique franco-khmère, Ministère de l'Education Nationale et de la Jeunesse, Phnom Penh, 1954
- Lewitz (S.), Note sur la translittération du Cambodgien BEFEO, t.LV, 1969.
  , Textes en Khmer moyen Inscriptions modernes d'Angkor, BEFEO, t.LVII, LVIII, LIX, LX ( 1970; 71-72; 1973).
  , Recherche sur le vocabulaire cambodgien, J.A, 1967, 1968, 1969, 1970, 1971, 1974.
  , Lectures cambodgiennes, Paris, Maisonneuve, 1969.
- Lewiz (S.) et Rollet (B.), Lexique des ........................ du Cambodge, BEFEO, t.LX, 1973.
- Malmberg (Bertil), Les nouvelles tendances de la Linguistique (tra. de suédois), Paris, 1966.
  , La phonétique, Paris, 1954.
- Manipoud (I.), Cours de langue cambodgienne, Phnom Penh, S.D;
- Marouzeau (J.), Terminologie linguistique , Paris, 1961.
- Martinet (A.) , Eléments de linguistique générale, Armand Colin, Paris, 1973;
  , Linguistique synchronique, PUF, Paris, 1968;
  , La description phonologique, Paris, 1956;
  , Economie des changements phonétiques, Berne, 1955;
  , Le langage, in Encyclopédie de la Pleiade, Paris, 1968;
- Martini (F.) , De la réduction des mots sanscrits passés en cambodgien, BSLP, t.50,

fasc. 1, Paris, 1954;
, Méthode de lecture cambodgienne, Paris, 1ère et 2e partie, 1952 et 1954;
, Aperçu phonologique du cambodgien, BSLP, t.42, Paris, 1942-1946;
, La langue cambodgienne, in France-Asie nov. Décem, 1955, n°114-115;
, De la signification de BA et ME affixes aux noms des Monuments khmers, BEFEO, t. XLIV, fasc. 1, Hanoï, 1951;
, Notes d'étymologie khmère, BSEI, nlle série, t. XXVI , Saïgon, 1951;
, La distinction de prédicat de qualité et de l'épithète en cambodgien et en siamois;
, Le cambodgien (khmer), in Encyclopédie de la Pleiade, p.1050 à 1067;
, De la création actuelle des mots en cambodgien, in BSLP,t. LVII, 1962;
, L'Etude structurale du cambodgien, in BCKOM,n°2, 1962;

- Maspéro (G), Grammaire de la langue khmère, Paris, 1915;
, Les Langues Mon-Khmer, in Les langues du monde, édit., Paris, 1952;
- Meillet A.), Linguistique historique et Liguistique générale, 2 Vol. (1921 et 1938), Paris.
- Menétrier (E), Le vocabulaire Cambodgien dans ses rapports avec le Sanscrit et le pali, Phnom Penh, 1933.
- Menétrier (E), et Pannetier (C.), Eléments de grammaire Cambodgienne applliquée, Phnom Penh, 1925.
- Midoux (M.), La dérivation de la langue cambodgienne modernne, Paris, 1973-74. (thèse de 3 ème cycle).
- Moura (J.), Vocabulaire français-cambodgien et cambodgien-français, Challamel Ainé, Paris, 1878.
- Perrot (Jean), La Linguistique, Paris, 2 édition, 1957.
- Pike ( Kennet L.), Language in Relation to a Unified theory of the Structure of Human Bchavior, 3e vol., Glandale, 1954-1960.
- Ruwet (N.), La grammaire générative, Langages 4, 1966.
- Sapir (Edward), Language, New York, 1921, tra.frse, Le Langage, Paris, ....
- Saussure (F.de), Cours de linguistique générale, Paris, 1949.
- Schmidt (W.), Die Mon-Khmer volker, ein Bindeglied zwischen wolkern Zentralasiens und Austronesiens, Braunschweig, 1906. (traduction française par Mme J.Marouzeau, in Bulletin de l'EFEO, VI, 1907)
- Seabok (T.A), A Bibliography of Mon-Khmer Linguistics, in Studies in Linguistics, I.II, oklahoma, 1942.
- Tonkin (Derek), Modern Cambodian writing, Phnom Penh, 1962.
- Troubetzkoy, Principes de phonologie, trad.frese, Paris, 1949.
- Vendryes (J.), Le Langage, Paris, 1923.
- Waturg (W.von), Méthodes de la linguistique, trad.frse, nouv.édit.revue, Paris1969.

## មាតិការបស់អត្ថបទ

លំនាំដើម ........................................ ទំព័រ៥៣
I- អំពីពាក្យក្លាយតាមសូរស័ព្ទ ........................................ -- ៥៦
១- ការច្របូកច្របល់ដែលបណ្ដាលឱ្យខ្មែរយើងស្ដាប់ភាសាខ្លួនមិនបាន ........................................ -- ៥៦
២- ការជាន់ពាក្យ និង ជាន់ន័យរបស់វា ........................................ -- ៥៧
៣- ការប្រើពាក្យក្លាយតាមសូរស័ព្ទទាំងនេះបណ្ដាលឱ្យមានការប្ដូររចនាសម្ព័ន្ធ នៃភាសាខ្មែរទាំងមូល........................................ -- ៥៨
៤- វិធាននៃការធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទនេះគ្មានលក្ខណៈទូទៅដូចការអះអាងរបស់អ្នកប្រាជ្ញទាំងឡាយនោះទេ ........................................ -- ៥៩
៥- វិធីធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទកិរិយាស័ព្ទឱ្យទៅជានាមនេះ ធ្វើឱ្យបាត់នូវលក្ខណៈសម្គាល់រវាង ករណនាម និង សភាវនាម ........................................ -- ៦០
៦- វិធីធ្វើឱ្យក្លាយពាក្យតាមសូរស័ព្ទនេះគ្មានវិធានជាឯកភាពរបស់វាទេ ........................................ -- ៦១
II- អំពីការទាញសូរស័ព្ទ ........................................ -- ៦២
III- ការសរសេរព្យញ្ជនៈរាយ និង ព្យញ្ជនៈតម្រួត ........................................ -- ៦៧
IV- ការបំបាត់ស្រៈពេញតួ ........................................ -- ៧០
V- អំពីការលុបបំបាត់ពាក្យបាលី និង សំស្ក្រឹត ........................................ -- ៧១
១- ផលវិបាកនៃការលុបពាក្យបាលី និង សំស្ក្រឹត នាំទៅរក "បារាំងនីយកម្ម" ឬ "អង់គ្លេសនីយកម្ម" នៃភាសាខ្មែរ ........................................ -- ៧៣
២- ការប្រើពាក្យខ្មែរជាពាក្យវិទ្យាសាស្ត្រនឹងធ្វើឱ្យខូចដល់ដំណើរការនៃខេមរយានកម្ម......... -- ៧៥
VI- អំពីព្រឹត្តិភាសា ........................................ -- ៧៧
VII- អំពីការប្រើបកតិសំខ្យា ........................................ -- ៧៨
VIII- អំពីភាសាសាស្ត្រ និង ប្រវត្តិនៃវចនានុក្រមខ្មែរ ........................................ -- ៨០
១- តើភាសាសាស្ត្រសិក្សាអំពីអ្វី? ........................................ -- ៨០
២- អំពីតួនាទីរបស់ភាសា ........................................ -- ៨០
៣- គុណូបការៈរបស់សម្ដេចសង្ឃរាជ ជួន ណាត ........................................ -- ៨១
៤- ប្រវត្តិនៃវចនានុក្រមខ្មែរ ........................................ -- ៨២
គន្ថនិទ្ទេស ........................................ -- ៨៥

# ការស្រាវជ្រាវទាក់ទងនិងកំណកំណើតវាក្យស័ព្ទតាមបម្រើបម្រាស់ផ្នត់នីយកម្ម នៅក្នុងភាសាខ្មែរបុរាណ

" Recherches sur la formation des mots par l'affixation dans le khmer ancien du VIè. au XIVè. siècles "

រៀបរៀង ដោយ បណ្ឌិត ឡុង សៀម(1)

លក្ខណៈសម្គាល់ដ៏សំខាន់មួយនៃភាសាខ្មែរបុរាណ គឺវិធីផ្នត់នីយកម្ម ។ វិធីនេះត្រូវបានគេប្រើ ដើម្បីបង្កើតពាក្យ ដើម្បីបម្រែបម្រួលពាក្យ និង ដើម្បីបង្កើតស្ថាននាមព្រមទាំងនរនាម។ មិនតែប៉ុណ្ណោះ វិធីផ្នត់នីយកម្ម និង ទ្វេនីយកម្ម (redoublement) នៃវាក្យស័ព្ទក៏មានទំនាក់ទំនងដ៏ជិតស្និទ្ធ ហើយជាបញ្ហាដ៏ស្មុគស្មាញមួយនៅក្នុងការសិក្សានិរុត្តិវិទ្យានៃភាសាខ្មែរ ។

តាមការសង្កេត វិធីផ្នត់ត្រូវបានគេប្រើប្រាស់ក្នុងគ្រប់ដំណាក់កាលនៃការរីកចំរើនរបស់ភាសា។ ជាក់ស្តែងដូចជានៅក្នុងសិលាចារឹកភាសាខ្មែរ ដែលមានការចុះកាលបរិច្ឆេទ ៦១១ គ.ស (K.600) គេសង្កេតឃើញមានផ្នត់មួយចំនួន (ផ្នត់ដើម និងផ្នត់ជែក) ។ នៅក្នុងអត្ថបទសិលាចារឹក ផ្នត់ចុងសឹងតែគ្មាន គឺមានសេសសល់ក្នុងពាក្យមួយចំនួនដំបូងៗនៃសតវត្សទី VII ។ គឺបានសេចក្តីថា ក្នុងភាសាខ្មែរបុរាណការប្រើប្រាស់ផ្នត់ចុងមានកម្រិត។ ក្រោយមក ផ្នត់ចុងត្រូវបាត់បង់ដោយសារការប្រើប្រាស់ផ្នត់ដើម និងផ្នត់ជែកកាន់តែច្រើនឡើងៗ និង ដោយសារការវិវឌ្ឍន៍ថ្មីៗរបស់វា។ ការវិភាគលំអិតទៅលើផ្នត់ ក្នុងភាសាខ្មែរបុរាណអនុញ្ញាតឱ្យយើងកំណត់បាននូវសកម្មភាពនៃនិន្នាការទៅរកលក្ខណៈវិភាគនិយម (ការប្រើប្រាស់ពាក្យជំនួយជំនួសផ្នត់មួយចំនួន) និង ឱ្យយើងស្រាវជ្រាវរកឃើញដាននៃរចនាសម្ព័ន្ធអាគ្លុយទីណង់ (agglutinant) បុរាណនៅក្នុងភាសាខ្មែរបុរាណ។ ការរក្សាដាននៃរចនាសម្ព័ន្ធអាគ្លុយទីណង់ក្នុងភាសាខ្មែរបុរាណ វាមានសារៈសំខាន់ណាស់ក្នុងការសិក្សាប្រៀបធៀបដំណាក់កាលផ្សេងៗ នៃការរីកចំរើននៃភាសាខ្មែរបុរាណក៏ដូចជាក្នុងភាសាអូស្ត្រូអាស៊ីដ៏ទៃទៀតដែរ ។

## ប្រភពនិងរចនាសម្ព័ន្ធផ្នត់

នៅក្នុងភាសាខ្មែរបុរាណបុព្វបទ ឬផ្នត់ទាំងឡាយដែលគ្មានលក្ខណៈជាព្យាង្គ (គឺថា ផ្នត់ដែលកើតឡើងដោយព្យញ្ជនៈតែមួយ (C) ស្រៈណឺតតែមួយ a អ (r) ឬមួយរួមផ្សំដោយព្យញ្ជនៈដើមព្យាង្គ និងស្រៈណឺត ( Cr ) អាចចាត់ទុកថាជាផ្នត់ដំបូងៗ។ ផ្នត់ទាំងនេះឆ្លើយស្របគ្នាទៅនឹងផ្នត់ទាំងឡាយនៅក្នុង

---

(1) - សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ជាប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា និងជាសាស្ត្រាចារ្យភាសាវិទ្យា និង សិលាចារឹកវិទ្យា នៅមហាវិទ្យាល័យបុរាណវិទ្យា នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ភ្នំពេញ ។

ភាសាអូស្ត្រូអាស៊ីដ៏ទៃទៀត។ ជាពិសេស ផ្នត់នៅក្នុងភាសាមនបុរាណ។ តាមតារាងប្រៀបធៀបដែលធ្វើឡើងដោយលោកស្រី Jacob Judith M. និង តាមលំដាប់នៃវចនានុក្រមមនបុរាណ របស់លោក Shorto H.L. នៅក្នុងភាសាខ្មែរ និង ភាសាមនបុរាណ គេប្រើផ្នត់សំរាប់បង្កើតនាមស័ព្ទ ដែលជាភ្នាក់ងារទង្វើសកម្មភាព មានផ្នត់ដែក-ម-,-ន-,(-m-,-mn-) គេប្រើផ្នត់សំរាប់បង្កើតនាមស័ព្ទដែលសម្គាល់វត្ថុ និង នាមស័ព្ទសំរាប់សម្គាល់ធាតុភូតធម្មជាតិ ( មានផ្នត់ p-,-n- និង បែបផែនផ្សេងៗ ឬ កលារូបស័ព្ទរបស់វា) និងសំរាប់បង្កើតផ្នត់ ដែលប្រើសំរាប់បង្កើតហេតុកិរិយា (p- និង កលារូបស័ព្ទផ្សេងៗរបស់វា) ។ ផ្នត់ដើម p- និង ផ្នត់ដែក -n- មានប្រភពមកពីភាសាអូស្ត្រូអាស៊ី ព្រោះវាមានភាពឆ្លើយគ្នាទៅនឹងផ្នត់ក្នុងភាសាអូស្ត្រូអាស៊ីដ៏ទៃទៀត ។

ផ្នត់ដើមមានរចនាសម្ព័ន្ធជាព្យាង្គ ដែលរួមផ្សំដោយព្យញ្ជនៈដើមព្យាង្គ ក្រៅពីព្យញ្ជនៈច្រមុះ (cn) ឬផ្សំឡើងដោយស្រៈណើតជាមួយនឹងព្យញ្ជនៈច្រមុះអាចចាត់ទុកបានថាជាផ្នត់បន្ទាប់ ឬផ្នត់ទីពីរ (secondaire) ដែលកើតឡើងដោយលទ្ធផលនៃនាសាទីយកម្ម ។ ធាតុភូតនេះកើតឡើងដោយសារមានសកម្មភាពរវាងស្រៈណើត និងស្រៈដើមព្យាង្គបន្ទាប់។ ហេតុនេះហើយ ផ្នត់ដើមបែប(Cvn)អាចកើតឡើងជាកលារូបស័ព្ទ (allomorphe) នៃផ្នត់ដើម (cv)។ ឧទាហរណ៍ ផ្នត់ដើមបញ្ជាក់ហេតុ p-/pa- មានកលារូបស័ព្ទ ដូចជា : paṅ - [បង់-], pañ- [បញ់-], pan- [បន់-], pam- [បំ-]។ កលារូបស័ព្ទទាំងនេះស្ថិតនៅខាងមុខព្យញ្ជនៈគល់អណ្តាត ព្យញ្ជនៈក្រអូម ព្យញ្ជនៈធ្មេញ និង ព្យញ្ជនៈបបូរមាត់នៃឬស ។

ផ្នត់ទាំងឡាយដែលកើតឡើងដោយការរួមផ្សំរវាងព្យញ្ជនៈដើមនិងព្យញ្ជនៈបែប (r,l) ឬ (ព្យញ្ជនៈរនាវ liquide) និងជាមួយស្រៈណើត (crv) (គេហៅថាផ្នត់រ៉ូតាស៊ិក rhotacique ជាបច្ចេកពាក្យបញ្ជាក់នូវផ្នត់ប្រកបដោយវត្តមានព្យញ្ជនៈ " រ " ) ក្នុងភាសាខ្មែរបុរាណ អាចមានទិដ្ឋភាព ដូចតទៅ : pra-[ប្រ-] , tra- [ត្រ -] , tra [ទ្រ-] , cra [ច្រ-] , kra [ក្រ-] , sra- [ស្រ-] , mra- [ម្រ-] ។ នៅក្នុងអត្ថបទសិលាចារឹកមុនសម័យអង្គរ ផ្នត់ដើមទាំងនេះគេកម្រជួបប្រទះណាស់។ ចំណែកឯក្នុងអត្ថបទសិលាចារឹកសម័យអង្គរ ផ្នត់ដើមទាំងនេះត្រូវបានគេប្រើញឹកញាប់ណាស់ទៅវិញ។ ក្នុងភាសាខ្មែរសម័យបច្ចុប្បន្ន ជាញឹកញាប់ណាស់ ផ្នត់ដើមទាំងនេះចូលរួមបង្កើតពាក្យដែលមានតួនាទីជាបម្រាប់ប្រធាន (prédicatif)។ ជាការចាំបាច់ណាស់ គេត្រូវពន្យល់អំពីប្រភព និង កំណកំណើតអង្កត់ (segment) [-ra-] ដែលស្ថិតនៅក្នុងផ្នត់ដើមទាំងនេះ អង្កត់ [-ra-] នេះ គឺជាផ្នត់ដែកបុរាណដែលមានទំរង់កលារូបស័ព្ទ [-al-],[-la-] ហើយគេសង្កេតឃើញមានក្នុងភាសាខ្មែរនាសម័យមុនអង្គរ ។

ឧទាហរណ៍ :

klamum K 243 ក្លមុំ > kramum "ក្រមុំ" (ភាសាខ្មែរសម័យបច្ចុប្បន្ន ឬសម័យទំនើប)។

kalmon K 125 កល្មន , kramuon "ក្រមួន" (ភាសាខ្មែរទំនើប)

ឧទាហរណ៍ទាំងនេះបង្ហាញអំពីការឆ្លងកាត់ផ្នត់ដែក -al-/-la- ទៅជា -ra-ដែលស្ថិតនៅក្នុងសមាសភាពនៃផ្នត់ដើមដែលមានរចនាសម្ព័ន្ធCrv។ រចនាសម្ព័ន្ធនេះ គឺជាលក្ខណៈសំគាល់មួយក្នុងភាសាខ្មែរសម័យបច្ចុប្បន្ន។

នៅក្នុងភាសាមន-ខ្មែរ អង្គត់ -al- / -la- គឺជាផ្នត់ដែក និងជាធាតុនៃព្យាង្គដើម (pré-syllable) ក្នុងភាសាប៉ាកូស និងភាសាហ្សែស ។

ផ្នត់ដើមបី ក្នុងភាសាបុរាណ មានដើមកំណើតចេញពីពាក្យខ្មែរបុរាណដែលមានន័យគ្រប់គ្រាន់។ ផ្នត់ដើមដំបូងដែលសំដែងធាតុ p-/pa- កើតចេញពីកិរិយាស័ព្ទខ្មែរបុរាណ pa: " ធ្វើ " ដែលប្រើក្នុងភាសាបុរាណ។ ពាក្យនេះអាចមានទំនាក់ទំនងទៅនឹងពាក្យ amve អំវេ K 71 , ambe អំពេ ដែលមានន័យថា "អំពើ" ទៅនឹងពាក្យដទៃទៀត ក្នុងភាសាខ្មែរបច្ចុប្បន្ន boe/pə : ពើ : "ធ្វើពើ" , dhvoe/ thvə: " ធ្វើ "។ ផ្នត់ដើម ta- បញ្ជាក់ន័យ "តភ្ជាប់" និងជាគុណចំណង។ បើតាមសង្កេតទៅ កាលដើមឡើយ ផ្នត់ដើម [ត-] នេះមានន័យថា "តភ្ជាប់" ពីព្រោះ ក្នុងភាសាខ្មែរសម័យថ្មីមានកិរិយាស័ព្ទ ta / ta : / " ត , បន្ត " ។ ទន្ទឹមនឹងវិធីបុរាណ ក្នុងការបង្កើតកិរិយាស័ព្ទហេតុដោយដាក់ផ្នត់ នៅក្នុងភាសាសម័យបច្ចុប្បន្ន គេសង្កេតឃើញនិន្នាការទៅរកវិធីវិភាគក្នុងការបង្កើតកិរិយាស័ព្ទ "ធ្វើ" ក្នុងតួនាទីជាការបង្ហាញហេតុ។ ផ្នត់ដើម mra-[ម្រ-] មានបែបផែនរចនាបថនិពន្ធខ្ពង់ខ្ពស់ និង ត្រូវបានគេប្រើប្រាស់សំរាប់បង្កើតឋានន្តរនាមមន្ត្រីសង្ឃ និងមន្ត្រីខ្ពង់ខ្ពស់ដទៃទៀត។ តាមការសង្កេត ផ្នត់ដើមនេះមានប្រភពចេញមកពីពាក្យបុរាណ * mrah ~ amrah K 138 ម្រះ~អំម្រះ : "ព្រះ , មេ"។ នៅក្នុងភាសាខ្មែរបុរាណ ជាទូទៅ នេះគឺជាការបង្ហាញអំពីឋានន្តរស័ក្តិជាន់ខ្ពស់ដោយប្រើវិធីផ្នត់ជាមួយពាក្យឬសដែលមានន័យថា "សំខាន់ ខ្ពង់ខ្ពស់ ព្រះថ្លៃវិសេស"។

ចំពោះពពួកផ្នត់ដែក ពួកវាគឺជាម៉រហ្វែមយថាប្រភេទនៃភាសាខ្មែរ ហើយការស្រាវជ្រាវរកជាតិស័ព្ទរបស់វាជាការពិបាក។ គេមិនបានដឹងពីប្រភពនៃផ្នត់ដែក(សំរាប់បង្កើតនាម-n-និង-m-)ទេ។ ផ្នត់ទាំងនេះអាចចាត់ទុកថាជាផ្នត់ចំណាស់ជាងគេ ហើយក្នុងភាសាខ្មែរបុរាណផ្នត់ទាំងនេះត្រូវបានគេនិយមប្រើច្រើនណាស់ ។

ក្នុងភាសាអូស្ត្រូអាស៊ី តាមការសង្កេតរបស់យើងផ្នត់ដែកបង្ហាញភ្នាក់ងារ (-m-) មានតែក្នុងភាសាខ្មែរ និង ភាសាមនប៉ុណ្ណោះ ។ នៅក្នុងអត្ថបទសិលាចារឹកសតវត្សទី VII គេប្រើប្រាស់ផ្នត់ដែកនេះដាច់ៗពីគ្នា ហើយគ្មានន័យគ្រប់គ្រាន់ជាភ្នាក់ងារនៃអ្នកធ្វើសកម្មភាពទេ តែមានតួនាទីជាភ្នាក់ងារវេយ្យាករណ៍សំរាប់

បង្ហាញទំនាក់ទំនងរវាងចំរាប់ប្រធាន និងប្រធានដែលជានាមជីវចល។ ឧទាហរណ៍ : ge cmer ajña ge danda K.940: គេ ច្មេរ អាជ្ញា គេទណ្ឌៈ "អ្នកណាមិនគោរពរាជបញ្ជា អ្នកនោះត្រូវផ្តន្ទាទោស"។ នៅក្នុងល្បះនេះ ពាក្យ ច្មេរ cmer កើតឡើងដោយកិរិយាស័ព្ទ ចេរ K 49 "មិនគោរព" ហើយពាក្យ ច្មេរ នេះ មិនមែនជានាមសំដែងភ្នាក់ងារទេ។ ផ្ទុយទៅវិញ នៅក្នុងកន្សោមពាក្យ cmam gui va men K.451 ឆ្មាំ គឺ វ មេន : "ឆ្មាំ ឈ្មោះចុះស វ មេន"។ ពាក្យ cmam : "ឆ្មាំ" គឺជានាមភ្នាក់ងារដែលក្លាយចេញមកពីពាក្យ cam : "ចាំ" ។

ផ្នត់មួយទៀតសំរាប់នាមនីយកម្ម ហើយដែលត្រូវគេប្រើសំរាប់បង្កើតនាមអរូបី និង នាមតាងរូបធាតុ គឺផ្នត់ដែក -amn-។ តាមការសង្កេត ផ្នត់ដែកនេះកើតចេញពីបន្សំផ្នត់ដែកជាមួយព្យញ្ជនៈច្រមុះពីរ គឺ-m- និង -n- ។ ដូច្នេះធាតុ -m- សំរាប់កត់សម្គាល់អ្នកធ្វើសកម្មភាព រីឯធាតុ -n- គឺសំរាប់សម្គាល់កម្មបទ ឬ លទ្ធផលនៃសកម្មភាពរបស់កិរិយាស័ព្ទ ។

តាមសិលាចារឹកមួយចំនួនទាសតវត្សទីVII ផ្នត់ដែក-anm-មិនប្រើក្នុងមុខងារជាកម្លាយធម្មតាទេ។ គេប្រើវាសំរាប់សំដែងអំពើ ទំរង់អកម្មនៃកិរិយាស័ព្ទ (le passif)។ ឧទាហរណ៍ : sre tnai ket travanæ poñ bhagayun damnuñ bhadraviçesa K.22 ស្រែ ថ្ងៃ កេត ត្រវង បោញ ភគយុន ទំនុញ ត បោញ ភទ្រកេស : "ស្រែខាងកើតត្រពាំង ប៉ោញ ភគយុន ត្រូវបានទិញពីប៉ោញភទ្រវិសេស"។ ដូច្នេះយើងឃើញថា នៅក្នុងល្បះខាងលើនេះ ពាក្យ ទំនុញ : "ត្រូវបានទិញ" អាចចាត់ទុកបានថា ជាទំរង់អកម្មនៃកិរិយាស័ព្ទ duñ : ទុញ : "ទិញ" ។

ក្នុងកន្សោមពាក្យ amnoy somakirtti ta vrah K.54 អំណោយ សោមកិរត្តិ ត វ្រះ "តង្វាយរបស់ សោមកិរត្តិ ថ្វាយដល់ព្រះ"។ ហេតុនេះពាក្យ amnoy មិនមែនជាទំរង់គុណនាម (participe) នៃកិរិយាស័ព្ទទេ តែគឺជានាមក្លាយចេញមកពីកិរិយាស័ព្ទ oy : "អោយ" K.54 ។

ដោយយោលតាមឧទាហរណ៍ខាងលើនេះ យើងឃើញច្បាស់ថា តួនាទីកម្លាយរបស់ផ្នត់ -m- និង -amn- កើតឡើងដោយសារផលវិបាកនៃភាពចុះខ្សោយនៃតួនាទីវេយ្យាករណ៍នៃផ្នត់ទាំងនេះ។ គេអាចចាត់ទុកថា ផ្នត់ដែក -m- មានន័យជាភ្នាក់ងារសំរាប់បង្ហាញនាមជាអ្នកធ្វើចលនាដោយសារបម្រែបម្រួលសេម៉ង់ទិចនៃតួនាទីវេយ្យាករណ៍របស់វា។ រីឯផ្នត់ដែក -amn- ទទួលន័យជាផ្នត់ដែកសំរាប់បង្កើតនាមអរូបី និង នាមតាងរូបធាតុដោយសារលទ្ធផលដែលទទួលបានពីបំលែងន័យនៃភាពអកម្ម ។

ផ្នត់ខ្មែរមួយចំនួនដ៏ទៃទៀត ដែលមានលក្ខណៈនាសានីយកម្ម គឺជាផ្នត់ដែលកើតចេញពីផ្នត់មានរចនាសម្ព័ន្ធព្យញ្ជនៈ ( c ) ។

**ផ្នត់និងកលារូបស័ព្ទរបស់វា** (allomorphes )

ការកំណត់និយមន័យនៃផ្នែកដំបូងនិងកលារូបស័ព្ទរបស់វា គឺអាស្រ័យទៅលើចំណាត់នៃពាក្យ ដែលមានន័យពេញលេញទៅតាមប្រភេទ និងទៅលើបំណកស្រាយសេម៉ង់ទិចនៃពាក្យដែលមានជាភស្តុតាង ។

កលារូបស័ព្ទគឺជាវ៉ារីយ៉ង់នៃផ្នត់មេ ( កើតឡើងដោយព្យញ្ជនៈមួយ) ហើយ មានលក្ខណៈទំរង់វិទ្យាអាស្រ័យតាមការកើតមានឡើងនៃកលារូបស័ព្ទតាមក្បួនច្បាប់ រួមផ្សំនៃព្យញ្ជនៈ និងគោលការណ៍ហេតុកម្មសេម៉ង់ទិច ក្នុងភាសាខ្មែរបុរាណ ។

នៅក្នុងឫសឯកព្យាង្គនៅក្នុងភាសាខ្មែរបុរាណក៏ដូចជាក្នុងភាសាសម័យថ្មីដែរ នៅដើមព្យាង្គ គេសង្កេតឃើញព្យញ្ជនៈមួយ ឬក្រុមព្យញ្ជនៈដែលមានសមាសភាពមិនលើសពីពីរដងទេ។ ដូច្នេះ វិធីសន្ធិនៃផ្នត់ដើម និង ការដាក់ផ្នត់ដែកទៅក្នុងឫសដែលមានក្រុមព្យញ្ជនៈនៅខាងដើមមិនអាចប្រព្រឹត្តិទៅបានទេ ប្រសិនបើនៅក្នុងភាសាគ្មានកលារូបស័ព្ទ គឺថា "ទំរង់ពង្រីក" នៃផ្នត់ដែលមានតែមួយព្យាង្គ។ ឫសឯកព្យាង្គ ដែលមានក្រុមព្យញ្ជនៈខាងដើម ពេលដែលគេដាក់កលារូបស័ព្ទនៃផ្នត់ទាំងនេះ វានឹងក្លាយទៅជាពាក្យកម្លាយមានពីរព្យាង្គ ហើយមានក្រុមព្យញ្ជនៈនៅខាងដើម ។

គេអាចសន្និដ្ឋានបានថា កលារូបស័ព្ទនៃផ្នត់សំខាន់ៗ (ជាពិសេសផ្នត់-p-,-m-,-n-) ត្រូវបានគេប្រើប្រាស់ ក្នុងការរួមផ្សំជាមួយឫសឯកព្យាង្គដែលមានក្រុមព្យញ្ជនៈនៅខាងដើម។ ឧទាហរណ៍ : ពាក្យកម្លាយ prap K.254 ប្រប : " ឈ្នះ " (ចេញពីពាក្យ rap រប " ឈ្នះ " IS ) យើងសង្កេតឃើញមានផ្នត់ដើម p- ហើយ ក្នុងពាក្យកម្លាយ samla p សំលាប់: "សំលាប់ " K.650 (ចេញមកពីពាក្យ sla p ស្លាបៈ "ស្លាប់" K.654 គេសង្កេតឃើញមានកលារូបស័ព្ទនៃផ្នត់ដែកដែលមានរចនាសម្ព័ន្ធ -am- ) ។

ជាទូទៅ គេសង្កេតឃើញផ្នត់បង្កើតនាម និងផ្នត់បង្កើតកិរិយាស័ព្ទនីមួយៗ មានកលារូបស័ព្ទរបស់វាមួយចំនួន :

១- ផ្នត់ដើមកិរិយាស័ព្ទហេតុ p- មានកលារូបស័ព្ទ ( ក្រៅពីកលារូបស័ព្ទនាសានីយកម្មដែលរៀបរាប់ខាងលើ ) ដូចតទៅ :

-អំ-,-am- , pamre បំរេ : " បំរើ " K.229 < pre ប្រេ : " ប្រើ " K.49

អំ-,am- , ampa n អំបាន " យកបាន " K . 956< pan " បាន " K.489 ;

-អ -,-a- , sarac សរច K.904 < srac ស្រច K.689 ;

នៅក្នុងភាសាបាខ្នា ( ជាភាសាមួយនៅក្នុងអំបូរមន-ខ្មែរ ) ផ្នត់ដែកដែលជាស្រៈ -a- មានតួនាទីជាភ្នាក់ងារបង្ហាញកិរិយាស័ព្ទហេតុ។ នៅក្នុងភាសាមនបុរាណ ផ្នត់ដែក -a- គឺជាកលារូបស័ព្ទនៃផ្នត់ដើម

សំដែងហេតុ p- ។

២- កលារូបស័ព្ទនៃផ្នត់ដែកបង្កើតនាមសំគាល់អ្នកធ្វើសកម្មភាព :

-ម-,-m- ,pamañ បមញ : "ទាហាន , អ្នកបាញ់ " K.298 (pañ បញ : "បាញ់")

-អំន-,-amn- ,pamnos បំនោស : "អ្នកបោស ", (pos : " បូស " K.44);

-អល ម -,-alm-,dalmak ទល្មក K.105 "ទ្រមាក់" ( dak " ទាក " , khm.mod.)

-អង ម -,-aṅ m-, raṅ hvai រង្វៃ K.137 " អ្នករវៃ" ( rvai : " រវៃ " , khm.mod. )

-អប -,-ap- rapam របាំ K 50 "អ្នករបាំ " ( ram : " រាំ " )

-ន-,-n- ,snam ស្នំ K .222 ( sam : " ផ្សំ " K.89 )

៣- កលារូបស័ព្ទរបស់ផ្នត់ដែក នៃនាមសម្គាល់រូបធាតុនិងនាមរូបី -amn-

-អំ-,-am-, campaṅ ចំបង K 292 " ចំបាំង " ( chpan ច្បង : " ច្បាំង")

៤- កលារូបស័ព្ទនៃផ្នត់ដែកនៃរូបី -p- មានពីរ :

-អន ប -,-anp- ,canpvar ចន្ប្វរ : " ចំបូរ " K.571 , ( cvar : " ជូរ " K.476 )

-អម ប -,-amp- , sampar សំបារ : " កូនឈើ " K.56 , (cpar ច្បារ : " ច្បារ " K.154 , car : "ចារ " k. 573 )

គេអាចនិយាយបានម្យ៉ាងទៀតបានថា រាល់កលារូបស័ព្ទខាងលើកើតឡើងដោយសារការរួមផ្សំផ្នត់ដែកពីរដែលបង្កើតនាម: -an- និង -p- ⇒ -anp-,-am- និង -p- ⇒ -amp- ។ ន័យ ដែលបានទទួលមកដោយការផ្សំន័យធាតុផ្សំរបស់ផ្នត់ទាំងនេះ មានសារៈសំខាន់ណាស់សំរាប់ការវិភាគ ។ គឺដោយសារមូលហេតុនីយកម្មនេះហើយ ទើបនាមដែលត្រូវបានបង្កើតឡើងដោយសារផ្នត់ទាំងនេះមានការរីកចំរើនដុះដាលជាងនាមទាំងឡាយ ដែលកើតឡើងដោយសារផ្នត់បុរាណដំបូង ( -n- និង -p- ) ។

៥- ផ្នត់ដើមបង្កើតនាម -n- ដែលបានចូលរួមបង្កើតនាមតាងវត្ថុ ( មានជាអាទិ៍ នាមតាងឧបករណ៍តាងបាតុភូតធម្មជាតិ ) មានកលារូបស័ព្ទ ដូចខាងក្រោម :

ផ្នត់ដែកដែលជាកលារូបស័ព្ទរបស់ -ន -,-n-

-ន -,-a-, sarom សរោម : " ស្រោម " K.263 ( srom K .227: " ស្រោម " )

-អង់-,-aṅ -,sankat សង្កត់ : "រយៈកាល " K.470: (skat: " ស្កាត់ " )

-អន-,-an- , kanlah កន្លះ : " កន្លះ " K .505 (khlah : " ខ្លះ " K .263 )

-រន-,-ran-, dranap ទ្រនាប : " ទមនប់ , ឧបសគ្គ " K .44 , ( dap : " ខ្ទប់ " K .49

-ល -,-l- ,plon : ប្លោន : " ផ្ទួន " ( ចំនួនសែសិប ) K.403 ( pon : " បួន " K . 90 )

-រ -,-r- ,vrek ព្រែក : " ព្រែក " K .219 , (vekk : " ញែក វែកញែក " K .107 )

ផ្នត់ដែលជា កលារូបស័ព្ទរបស់ -n-

អង -,aṅ -, aṅ veṅ K.872 អង្វេង : " ប្រវែង " ,veṅ : " វែង " K.291 )

អញ -,añ- ,añjul K.137 អញ្ជុល : " មូល " , ( jul " ជុល , ដេរ " khm.mod. )

អន -,an- , antaṃ K.54 អន្តំ : " ដំណាំ " , ( taṃ : " ដាំ " K.56 )

អំ-,am- ,am ruṅ K.79 អំរុង : " ទំហំ " ,( ruṅ : ធំ , ទូលាយ " K.76 )

ចន-,can- , canhor K.341 ចន្ហោរ : " ចង្ហូរ " ( hur: " ហូរ " khm.mod. )

ដោយឈរលើមូលដ្ឋាន នៃឧទាហរណ៍ខាងលើ យើងអាចធ្វើការសន្និដ្ឋាន ដូចតទៅ :

- កលារូបស័ព្ទ -a- ប្រើក្នុងករណីដែលក្រោយផ្នត់ដែកនេះ មានព្យញ្ជនៈ r ។

- ផ្នត់ដែក ( ឧទាហរណ៍ ផ្នត់ដែកបង្កើតនាម -n- ) អាចមានកលារូបស័ព្ទជាផ្នត់ដើម ។ ដូចនេះនៅក្នុងប្រព័ន្ធផ្នត់ខ្មែរ គ្មានទីកំណត់ច្បាស់លាស់ទេ រវាងផ្នត់ដែក និងផ្នត់ដើមមួយចំនួនទៀត ។

-ផ្នត់ដែកដែលជាកលារូបស័ព្ទរបស់ផ្នត់ដើមត្រូវបានគេប្រើក្នុងឫសសមាស ដែលនៅក្នុងនោះមានព្យញ្ជនៈដើមព្យាង្គច្រើន ។

- ផ្នត់ដើមដែលជាកលារូបស័ព្ទរបស់ផ្នត់ដែក ត្រូវបានគេប្រើប្រាស់ក្នុងឫសទាំងឡាយណាដែលមានព្យញ្ជនៈដើមព្យាង្គតែមួយ ហើយព្យញ្ជនៈនេះមិនផ្សំជាមួយនឹងផ្នត់ដែកនេះទេ ។

- គេប្រើកលារូបស័ព្ទនៃផ្នត់ ក្នុងករណីខ្លះៗដោយមិនគោរពគោលការណ៍ នៃទំរង់វិទ្យាទេ ។ តែគេប្រើក្នុងគោលបំណងចៀសវាងសទិសស័ព្ទរវាងពាក្យពីរ ដែលកើតឡើងពីឫសតែមួយ ។ ឧទាហរណ៍ : ចេញពីឫស dal ទល : " ស្ទះ , មាន ឧបសគ្គ " K.216 មានពាក្យកម្លាយពីរ : មួយជាពាក្យកម្លាយដោយផ្នត់ដែក -n- មួយ ទៀតដោយផ្នត់ដើមដែលជាកលារូបស័ព្ទរបស់ផ្នត់ដែក -n- នោះ ។

ឧទាហរណ៍ :

dal + -n- → dnal ទ្នល : " ទំទប់ " K. 18

dal + an- → andal អន្ទល : " ការដាក់ប្រឈមមុខ " IS ។

ប៉ុន្តែ នៅក្នុងករណីជាច្រើន នៅពេលដែលគេចៀសវាងសទិសស័ព្ទមិនរួចនៅក្នុងភាសានាំឱ្យកើតមានពាក្យកម្លាយថ្មី មានន័យថ្មី តែមានរចនាសម្ព័ន្ធសូរស័ព្ទដូចគ្នានឹងពាក្យដែលកើតមុន ។ ឧទាហរណ៍ : ដោយប្រើផ្នត់ដែក-n- ចេញឫស vekk វែក្ក : " បំបែក " K .107 គេអាចបង្កើតបានពាក្យ vnek វ្នែក :

"វិរកដូសសម្ព" K.342 ។

ផ្ទត់ជែក -n- មានកលារូបស័ព្ទច្រើនជាងគេ ហើយមួយចំនួនគឺជាសទិសស័ព្ទ ជាមួយនឹងផ្ទត់ដទៃទៀត។

## ចំណាត់ថ្នាក់នៃផ្ទត់

### I. ផ្ទត់ដើម :

ផ្ទត់ដើមសំខាន់ៗ និងសមូស័ព្ទរបស់វា នៅក្នុងភាសាខ្មែរបុរាណអាចធ្វើចំណាត់ថ្នាក់ដោយអនុលោមទៅតាមចំណាត់ថ្នាក់ជាប្រពៃណីនៃព្យញ្ជនៈ ដូចតទៅ :

| | អ-. a- | អង -.ań - | អញ-.añ- | អន -.an- | អម -.am- | ្រ-.-ra- | - |
|---|---|---|---|---|---|---|---|
| ក -,k- | ក-. ka- | កង -.kań - | កញ-. kañ- | កន -.kan- | កម -.kam- | ក្រ-.kra- | កល -.kal- |
| ច -,c- | ច-.ca- | ចង -.cań - | កញ-.cañ- | ចន -.can- | ចម -.cam- | ច្រ-.cra- | |
| ត -/t- | ត-.ta- | តង -.tań - | | តន -.tan- | តម -.tam- | ត្រ-.tra- | |
| | ទ-.da- | ទង -.dań - | | ទន -.dan- | ទម -.dam- | ទ្រ-.dra- | ទល -.dal- |
| ប -/p- | ប-.pa- | បង -.pań | បញ-.pañ- | បន -.pan- | បម -.pam- | ប្រ-.pra- | |
| រ -,r - | រ-.ra- | | | រន -.ran- | រម -.ram- | | |
| ស -,s- | ស-.sa- | សង -.sań | សញ-.sañ- | សន -.san- | សម -.sam- | ស្រ-.sra- | |
| ល -.l- | | លង ,lań | | លន -, lan- | លម -.lam- | | |
| វ -,v- | វ-.va- | | | | | វ្រ-.vra- | វល -.val- |

នៅក្នុងតារាងខាងលើដែលរៀបរៀងឡើងតាមធាតុបុរេព្យាង្គគេអាចបែងចែកដូចតទៅ :

- ផ្នត់ដើមជាផ្នត់ដែលគេហៅថាជាផ្នត់ដើមដំបូង ៖ ពេលដែលផ្នត់ដើមទាំងនេះចូលរួមផ្សំជាមួយនឹងព្យញ្ជនៈខាងដើមនៃឫស វាបង្កើតបានជាពាក្យកម្លាយឯកព្យាង្គ ដែលមានក្រុមព្យញ្ជនៈតម្រួតនៅខាងដើមព្យាង្គ ។

- ផ្នត់ដើមដែលជាព្យាង្គ ៖ ពេលវាផ្សំជាមួយនឹងឫសវាបង្កើតបានជាពាក្យកម្លាយទ្វេព្យាង្គ ។ ផ្នត់ដើមទាំងនេះអាចជា ឬមួយកលារូបស័ព្ទនៃផ្នត់ដើមដំបូង ឬមួយជាកលារូបស័ព្ទនៃផ្នត់ដែក-n-. ។ ផ្នត់ដើមដែលជាព្យាង្គអាចចែកជាបីក្រុម ៖ ផ្នត់ដើមដែលមានរចនាសម្ព័ន្ធ cv, ផ្នត់ដើមដែលមាននាសានីយកម្ម (ដែលត្រូវបញ្ចប់ដោយព្យញ្ជនៈច្រមុះ. បំពង់ក. ក្រអូមធ្មេញ. បបូរមាត់). ផ្នត់ដើមរ៉ូតាស៊ិក (ដែលមានខ្យល់ព្យញ្ជនៈ r ř) ។ ផ្នត់ដើម a- តាមការសង្កេត វាមានប្រភពជាច់ដោយឡែក ព្រោះថា ផ្នត់នេះបំពេញមុខងារពិសេសក្នុងការបង្កើតនាមអំបូរ ។

- ផ្នតដើម ka- [ក] ta- [ត] pa- [ប] អាចផ្សំជាមួយព្យញ្ជនៈនៅខាងដើមនៃឫស ។ ផ្នត់ដើម ca- [ច] da- [ទ] ra [រ] ត្រូវបានគេជួបប្រទះនៅក្នុងការបង្កើតពាក្យ ដោយវិធីស្ទួនហើយផ្នត់ដើម sa- [ស] ត្រូវបានគេជួបប្រទះតែក្នុងពាក្យកម្លាយដែលកើតឡើងពីឫសដែលផ្ដើមដោយស្រៈប៉ុណ្ណោះ។ នៅក្នុងភាសាខ្មែរសម័យបច្ចុប្បន្ន ផ្នត់ដើមជំពូក cv ក្លាយទៅជាផ្នត់ដើមបង្កើតកិរិយាស័ព្ទសំដែងន័យ ៖ "ញឹកញាប់ . រឿយៗ" ។

- ផ្នត់ដើមដែលមានព្យញ្ជនៈច្រមុះភាគច្រើនជាកលារូបស័ព្ទនៃផ្នត់ដើមដំបូងៗ ហើយត្រូវបានគេជួបប្រទះនៅក្នុងស្ថានភាព ដូចតទៅ ៖

cv (ń) នៅមុខព្យញ្ជនៈ k ក, g គ , t ត , n ន , s ស , h ហ

cv (ñ) នៅមុខព្យញ្ជនៈ c ច , j ជ , t ត , y យ , h ហ

cv (n) នៅមុខព្យញ្ជនៈ t ត , d ទ , j ជ , ñ ញ , m ម , y យ , r រ, l ល , s ស, h ហ ។

cv (m) នៅពីមុខព្យញ្ជនៈ p ប , c ច , j ជ , d ទ , t ត , n ន , y យ , r រ , v វ , s ស ។

- ផ្នត់ដើមរ៉ូតាស៊ិកមានប្រភពមិនសូវចំណាស់ប៉ុន្មានទេ នៅក្នុងភាសាខ្មែរបុរាណ ។ គេជួបប្រទះផ្នត់ទាំងនេះនៅក្នុងឫសទាំងឡាយណាដែលផ្ដើមដោយព្យញ្ជនៈមួយ ៖

ក្រ, kra- នៅមុខព្យញ្ជនៈ c ច , k ក , l ល , v វ , s ស , ។

ច្រ-, cra- នៅមុខមុខព្យញ្ជនៈ k ក,c ច,n ន,l ល ។

ត្រ-, tra- នៅមុខព្យញ្ជនៈ k ក , v វ , y យ , s ស , ។

ទ្រ-,dra- នៅពីមុខព្យញ្ជនៈ d ទ , n ន, ។

ប្រ-. pra-នៅមុខព្យញ្ជនៈ k ក .j ជ .t ត .d ទ .p ប .l ល .v វ . s ស . ។

sra- នៅពីមុខព្យញ្ជនៈ c ច . pប .m ម . l ល ។

- ផ្នត់ដើមសំរាប់បង្កើតឋានន្តរនាម mra- គេសង្កេតឃើញព្យញ្ជនៈ t ត . s ស . h ហ. ហើយអាចរាប់បញ្ចូលក្នុងបញ្ជីផ្នត់វូតាស៊ិក ។

- ផ្នត់ដើមដែលមានលក្ខណៈបុរាណ និង មិនទៀងទាត់ ព្រមទាំងផ្នត់ដើមទាំងឡាយដែលគ្មានក្នុងសម័យភាសាបច្ចុប្បន្ន យើងមិនបានរាប់បញ្ចូលទៅក្នុងតារាងទេ ហើយផ្នត់ដើមទាំងនេះមាន :

កុ-. ku- : kurun កុរុង : "ស្តេច" K.235 ,( run រុង" ខ្ពង់ខ្ពស់ "K 76 ) ។

ក្លួ-.kla- : klavum ក្លវុំ : "ក្រពុំ" . ( bum/ pum : " មូល . ពេញ " ) ។

ចិ .ci: ci cay ចិចាយ :" បំផ្លាញ .រុះរើ ." K .254 , (cay ចាយ :" បំ - ផ្លាញ "K. 383 ) ។

ទល-.dal- : daldval ទលទ្វល : " ទទួល " IS, ( dval ទ្វល :" ទទួល" K.265 ) ។

មិ-.mi- : ក្នុងពាក្យ mi moy មិមោយ : "រាល់.នីមួយៗ"K.30, (moy មោយ : "មួយ "K .80 ) ។

## II. ផ្នត់ដែក :

ផ្នត់ដែកក៏ដូចជាករណីផ្នត់ដើមដែរ ផ្នត់ដែកដំបូងៗ និង កលារូបស័ព្ទរបស់វា អាចធ្វើចំណាត់ថ្នាក់បានដោយអាស្រ័យទៅតាមរចនាសម្ព័ន្ធ ឯកព្យាង្គនិងពហុព្យាង្គនៃពាក្យកម្លាយ :

| | -ម-.-m- | -n-, -ន- | -អ-.-a- |
|---|---|---|---|
| -អ-.-a- | -អម --am- | -អន -.-an- | -អប -.-ap- |
| | -អំន -.-anm- | | -អនប -.-anp- |

ចំណែកកលារូបស័ព្ទដែលមានលក្ខណៈបុរាណ និងមិនទៀងទាត់យើងមិនបានបញ្ចូលទៅក្នុងតារាងទេ។ កលារូបរូបស័ព្ទនៃផ្នត់ដែកទាំងនេះមាន :

-អម -,-am- , -កល ម -.-alm- : កលារូបស័ព្ទផ្នត់ដែក -ម-.-m-

-អន -.-an- , -ល-.-l- : កលារូបស័ព្ទនៃផ្នត់ដែក -ន-. -n-

-អន ប -.-anp- , -អម ប -.-amp- : កលារូបស័ព្ទនៃផ្នត់ដែក -p- ។

ផ្នត់ដើមដំបូង ឬទីមួយដែលមានរចនាសម្ព័ន្ធជាព្យញ្ជនៈ ( -m-,-n-.-p- ) បង្កើតបានជាពាក្យកម្លាយឯកព្យាង្គដែលមានព្យញ្ជនៈដើមព្យាង្គពីរ ។ ផ្នត់ទាំងនេះផ្សំជាមួយនឹងឫសដែលមានព្យញ្ជនៈដើមព្យាង្គតែមួយ ។ ឧទាហរណ៍ :

cmam ថ្មំ : " ឆ្មាំ " K .826 , ( cam ចំ : " ចាំ " K .561 )

snan ស្នង : " ស្នង " K.137 , (san សង : " សង " K .878 )

thpir ថ្បិរ : " ក្រណាត់ដែលគេដេរ " K.693 ,( * tir : " ដេរ " khm.mod. )

ដូច្នេះ គេសង្កេតឃើញផ្នត់ដើមមកសណ្ឋិតនៅចន្លោះព្យញ្ជនៈដើមព្យាង្គ និងស្រៈនៃឫស ( នៅក្រោយព្យញ្ជនៈដើមព្យាង្គ និងស្រៈនៃឫស ) ។

ពាក្យកម្លាយដែលមានផ្នត់ដែកជាព្យញ្ជនៈច្រមុះមានរចនាសម្ព័ន្ធ c(n) vn ( n :ព្យញ្ជនៈច្រមុះ ) ។

ផ្នត់ដែកដែលជាកលារូបស័ព្ទមានរចនាសម្ព័ន្ធជាព្យាង្គ (-an-,-am-, -amn- ,-anp-, -amp-, -ap-, -alm- , -ran- ) និងកលារូបស័ព្ទត្រូវបានគេប្រើប្រាស់ជំនួសផ្នត់ដើមដំបូងៗ ក្នុងការបង្កើតពាក្យកម្លាយពីរព្យាង្គ ពីឫសដែលផ្ដើមដោយក្រុមព្យញ្ជនៈ ។ ក្នុងការបង្កើតពាក្យបែបនេះ ផ្នត់ដែកស្ថិតនៅចន្លោះព្យញ្ជនៈដើម និងព្យញ្ជនៈកណ្ដាលនៃឫស ។

តាមតារាងចំណាត់ថ្នាក់ដើមនិងផ្នត់ដែកទាំងពីរខាងលើ យើងអាចកត់សំគាល់ឃើញថា កលារូបស័ព្ទនៃផ្នត់មួយចំនួន តាមរចនាសម្ព័ន្ធសូរស័ព្ទ បានក្លាយទៅជាសទិសស័ព្ទ។ ឧទាហរណ៍ : អង្កត់ [-am-] អាចជាកលារូបស័ព្ទនៃផ្នត់ដែកភ្ជាក់ងារ-m- ឬអាចជាកលារូបស័ព្ទនៃផ្នតដើមសំដែងហេតុ p- ឬអាចជាកលារូបស័ព្ទរបស់ផ្នត់ដែក -amn- ។ ហេតុនេះ យើងអាចធ្វើការសន្និដ្ឋាន ដូចតទៅ :

- ចេញពីឫសតែមួយ គេអាចបង្កើតពាក្យកម្លាយផ្សេងគ្នាដែលជាសទិសស័ព្ទ ដោយដាក់ផ្នត់ជាសទិសស័ព្ទ ហើយន័យរបស់វាអាចកំណត់បានតែដោយសារទីសេចក្ដីរបស់ពាក្យកើតថ្មីតែប៉ុណ្ណោះ ។

ចេញពីពាក្យ chlak ឆ្លក K.397 មានពាក្យកម្លាយដែលជាសទិសស័ព្ទ ដូចតទៅ :

camlak ចំលក K.728 : " ឆ្លាក់ " (-am- ជាកលារូបស័ព្ទនៃផ្នត់ដើម p- )

camlak ចំលក K.21, K.165 : " រូបចំលាក់ " ( -am- ជាកលារូបស័ព្ទនៃ ផ្នត់ដែក -amn- )

camlak ចំលក K.192 : " អ្នក ឬជាងចំលាក់ " (-am-ជាកលារូបស័ព្ទនៃផ្នត់ដែកភ្នាក់ងារ -m-) ។

ហេតុនេះហើយបានជាចំណាត់ថ្នាក់ផ្នត់នៅក្នុងតារាងខាងលើ ធ្វើឡើងតាមរចនាសម្ព័ន្ធរបស់វា គឺមិនធ្វើតាមមុខងាររបស់វាទេ ដោយសារដូចយើងបានបង្ហាញរួចមកហើយថា រវាងផ្នត់ដើមនិងផ្នត់ដែក គ្មានដែនកំណត់ច្បាស់លាស់ទេ ។

## គន្ថនិទ្ទេស

ស្នាដៃជាភាសាខ្មែរ :

- ឡុង សៀម . បញ្ហាវចនស័ព្ទវិទ្យាខ្មែរ . ផ្សាយដោយអ្នកនិពន្ធ . ភ្នំពេញ ១៩៩៩ ;
- ឡុង សៀម . ស្ថាននាមវិទ្យាខ្មែរ . ពុទ្ធសាសនបណ្ឌិត្យ . ភ្នំពេញ ១៩៩៧ ;
- អៀវ កើស . ភាសាខ្មែរ . បណ្ណាគារ មិត្ត សេរី . ភ្នំពេញ ១៩៦៧ ;

ស្នាដៃជាភាសាបរទេស :

- Au, Chhieng; (1966) Etude de Philologie indo-khmère III., L'indo-européen grow vu à travers le khmer; Etudes de philologie indo-khmère IV. Un changement de toponyme ordonné par Jayavarman III,- Journal Asiatique CCL. 4 p. 575-591.
- Barth, A; (1885) Inscriptions sanscrites du Cambodge, avec Atlas. Paris
- Coedès, G; (1937) Inscriptions du Cambodge, BEFEO, Vol. 1, Hanoi; (1942) Inscriptions du Cambodge, BEFEO, Vol 2, Hanoi; (1951) Inscriptions du Cambodge, BEFEO, Vol 3, Paris (1952) Inscriptions du Cambodge, Vol. 4, Paris; (1953) Inscriptions du Cambodge, BEFEO, Vol. 5, Paris (1954) Inscriptions du Cambodge, BEFEO, Vol. 6, Paris; (1964) Inscriptions du Cambodge, BEFEO, Vol. 7, Paris; (1966) Inscriptions du Cambodge, BEFEO, Vol. 7, Paris;
- Jacob, J.M.; (1978) The Ecology of Angkor. Evidence from the Khmer Inscriptions - Nature and Man in South- East Asia, London, p. 109-127.
- Lewitz. S; (1967) la toponymie khmère, BEFEO.t.LIII, fase.2, Paris, p. 378-450.
- Long Seam; (1981) Contacts externes des langues Mon-Khmer, BEFEO, tome LXX, Paris, p/ 196-230.
- Long Seam; (1989) Toponymes et réalités socio-économiques et culturelles de l'ancien Cambodge (d'après les textes des Inscriptions)- Premier Symposium franco-soviétique sur l'Asie du Sud-Est : "la réappropriation du patrimoine culturel dans le contexte du mouvement nationaliste et de la colonisation en Asie du Sud-Est, Moscou, p. 144-150.
- Long Seam; (1994) Etudes de toponymie en ancien khmer, in cahiers d'études franco-Cambodgiens N2; édité par le Centre culturel et de coopération linguistique de l'Ambassade de France à Phnom Penh, 1994 ( 80 pages).
- Long Seam; (2000) Dictionnaire du khmer ancien (d'après les inscriptions du Cambodge du VIe-VIIIe.siècles) Phnom Penh.
- Pou, Saveros; (1992) Dictionnaire vieux Khmer-Français-Anglais, Paris;

## មាតិកា

ប្រភពនិងរចនាសម្ព័ន្ធផ្ទុត ........ ទំព័រ៨៩
ផ្ទុតនិងកលារូបស័ព្ទរបស់វា ........ -- ៩៣
ចំណាត់ថ្នាក់នៃផ្ទុត ........ -- ៩៦
I. ផ្ទុតដើម ........ -- ៩៦
II. ផ្ទុតដែក ........ -- ៩៨
គន្ថនិទ្ទេស ........ -- ១០០

# ការប្រែប្រួលសូរសំឡេងក្នុងភាសាខ្មែរ

**Modification Phonétique dans la Langue Khmère**

រៀបរៀង ដោយ សាស្ត្រាចារ្យ អុក ចួន[(1)]

ការប្រែប្រួលសូរសំឡេងគឺជាការបន្លឺពាក្យ ឬ កន្សោមពាក្យ ដែលមានការបញ្ចេញសូរវាលឃ្លាតវវាតខុសពីសញ្ញា ឬ សូរស័ព្ទដើមរបស់ពាក្យ ឬ កន្សោមពាក្យ ដែលជាឈ្មោះទីក្រុង ខេត្ត ស្រុក ភូមិ ឬ ឈ្មោះបុរាណដ្ឋានមាន ប្រាសាទជាដើម ។ ឈ្មោះទាំងនេះគឺជាឈ្មោះនាមដ្ឋានដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដ៏យូរលង់ណាស់មកហើយ ។ គោលបំណងសំខាន់គឺសាកល្បងលើកយកឈ្មោះនាមដ្ឋានខ្លះៗ យកមកសិក្សា តាមក្បួនខ្នាតវេយ្យាករណ៍ និង និរុត្តិវិទ្យា ដើម្បីឆ្លុះឱ្យឃើញ ឬ ក៏វិភាគឱ្យឃើញនូវការប្រែប្រួលសូរសំឡេង នៃនាមដ្ឋានទាំងនោះ ដែលស្ថិតនៅក្នុងតំណាក់កាល កកើត និង វិវត្តរបស់វា ។

ចំពោះវិធីសាស្ត្រ ឬ យុទ្ធសាស្ត្រ ដើម្បីពន្យល់អំពីលក្ខណៈបំរែបំរួលសូរ ពាក្យ ឬ កន្សោមពាក្យ ដែលជានាមដ្ឋាននោះគឺ : ក្បួនសូរវិទ្យា វចនវិទ្យា ន័យវិទ្យា និង វេយ្យាករណ៍វិទ្យា ជួនកាលប្រើប្រវត្តិវិធីក៏មានដែរ ។ តើការប្រែប្រួលសូរសំឡេងក្នុងភាសាខ្មែរបណ្តាលមកពីអ្វីខ្លះ ?

**១ - <u>ការប្រែប្រួលសូរសំឡេងក្នុងសូរវិទ្យា</u>** ( លើកយកតែបញ្ហាសូរស្រៈ និង ព្យញ្ជនៈខ្លះៗ មកពិនិត្យពិចារណា ) :

**ក - <u>អំពីសូរស្រៈ</u>** :

| | | | | |
|---|---|---|---|---|
| | ស្រៈ | អិ | > | ស្រៈ [ អី ] |
| ឧទាហរណ៍ : | | ពិត | > | [ ពីត ] |
| | | គិត | > | [ គីត ] |
| | | មិន | > | [ មីន ] |
| | | វិល | > | [ វីល ] |
| | | ទិស | > | [ ទីស ] |

បើយោងទៅតាមក្បួនសូរវិទ្យាខ្មែរ :

- ស្រៈ [ អិ ] ជាសូរស្រៈមុខបិទឥតមូល រង្វះបន្លឺ ១ ម.ម ។

- ព្យញ្ជនៈ ត ន ល ស ... ជាប្រភេទសូរព្យញ្ជនៈក្នុងក្រុមខុសគ្នាមែន ប៉ុន្តែបើពិនិត្យអំពីទីបន្លឺរបស់វា គឺស្ថិតនៅជិតៗគ្នា ហើយស្ទើរតែជាន់គ្នាទៀតផង ។

---

(1) - សាស្ត្រាចារ្យ អុក ចូន ជាប្រធានផ្នែកអក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

- រួមសេចក្តីមក ស្រៈ [អ៊ិ] ជាស្រៈមុខ ចំពោះព្យញ្ជនៈទាំងបួន ត ន ល ស ក៏ស្ថិតនៅក្រអូមមុខដែរ។ ដូចនេះដល់ពេលប្រកបសូរស្រៈ និង ព្យញ្ជនៈ ដែលមានទីបន្លឺជាន់គ្នា នេះជាហេតុធ្វើឱ្យពិបាកដល់គ្រឿង ប្រដាប់បន្លឺ ជាពិសេសគឺអណ្តាតនេះឯង ដែលត្រូវបំលាស់ទីរបស់ខ្លួនទៅរកទីកន្លែងស្រួលដោយខ្លួនវា " facilité de prononciation" ។ ក្នុងករណីនេះ ស្រៈ [អ៊ិ] ត្រូវដូរទៅស្រៈ [អ៊ី] ដែលជាស្រៈទោលកណ្តាល បិទឥតមូល លឺខ្ចីតាមរង្វះ ១ ម.ម ដើម្បីបើកលែង សន្ទុះខ្យល់បន្ទាប់ពីបរិវេងរបស់អណ្តាត ។

**ក.១- ស្រៈ [អើ] > ស្រៈ [ អេ ]**

ឧទាហរណ៍ : គេ > [កេ]

ពេល > [ ប៉េល ]

ទេ > [ តេ ] ... ។

ស្រៈទាំងពីរនេះតាមការពិនិត្យក្នុងសំដីនិយាយ គឺមិនខុសប៉ុន្មានទេ ( សូរប្រហាក់ប្រហែលគ្នា) ។ សូរស្រៈពួកអ និង ពួកអឺនេះ បើពិនិត្យទៅឃើញថា នៅមានសូរប្រហាក់ប្រហែលគ្នា ឬ ដូចគ្នាច្រើនទៀត។

**ក.២- ពាក្យដែលកើតពីស្រៈ [អា] [ iːə ] កាលបើប្រកបនឹង ត ន ប ល ស ត្រូវដូរជាសូរ [ អ័ ] = [oa]**

| | | |
|---|---|---|
| ឧទាហរណ៍ : គាត | → | គាត់ |
| មាន | → | មាន់ |
| រាប | → | រាប់ |
| គាល | → | គាល់ |
| ទាស | → | ទាស់ ... ។ |

ពាក្យទាំងនេះអាចមានសូរឃ្លាតពី [ អ៊ ] ខាងលើនេះទៀត អាស្រ័យទៅតាមតំបន់ខ្លះៗ ដូចជាខេត្តបាត់ដំបង ឬ នៅកម្ពុជាក្រោមជាដើម ។ នៅកម្ពុជាក្រោម ពាក្យ មាន់ អានថា មា'ន [miən] ។

**ក.៣- ស្រៈ[អ៊ី]ប្រកបនឹង ( ក) និង ( ង) លឺសូរថា ( ច) និង( ញ) :**

រីក > [រីច]

មឹង > [ មីញ ] ...

- ( ក) និង ( ង) មានទីបន្លឺនៅរនាំងក្រអូមគល់អណ្តាត
- ( ច) និង ( ញ) មានទីបន្លឺនៅក្រអូមកណ្តាល
- ស្រៈ [អ៊ី] ជាស្រៈមុខបិទឥតមូល លឺវែង ។

- កាលណាបន្លឺពាក្យ រឹក និង មឹង : ស្រៈ [អ៊ឺ] ធ្វើឱ្យខ្នងអណ្ដាតពង់ឡើងខ្ពស់ រួចទៅប៉ះនឹងក្រអូមកណ្ដាល ដែលជាទីបន្លឺរបស់ (ច) និង (ញ) ។ ពេលនោះសូរប្រកប "ច" និង "ញ" គឺបិទយកតែម្ដង ។ បើទំលាក់ខ្នងអណ្ដាត ហើយទៅចាប់សូរ (ក) និង (ង) ដែលនៅរនាំងក្រអូមវិញ ឃើញថាលំបាកដល់ការបន្លឺសូរប្រកប ( difficultè de prononciation ) ។

និយាយរួម គឺគ្រឿងប្រដាប់បន្លឺសូរសំឡេងទេ ដែលចេះសំរបសំរួលខ្លួនឯងទៅរកភាពងាយស្រួលរបស់វា ។

**ក.៩- ស្រៈខ្សោយ** [ ] ជាស្រៈកណ្ដាលបិទឥតមូលលឺខ្សោយតាមរង្វះមាត់ ៣.ម.ម ។ ស្រៈនេះមាននាទីសំរាប់បង្រួញ សូរស្រៈបើក ឬ ស្រៈបិទ ជាច្រើនក្នុងពាក្យពីរព្យាង្គ[(១)] ។

| | | | |
|---|---|---|---|
| ឧទាហរណ៍ : | ឥលូវ [ɛi|əu ] | > | [ ə|əu ] |
| | ក្រលា [ krɑ:la:] | > | [ krəla: ] |
| | បង្ខំ [baŋkac ] | > | [ beŋkham ] |
| | បង្កាច់ [baŋkac ] | > | [ bəŋkac ]... ។ |

**ខ - អំពីសូរព្យញ្ជនៈ**

ពាក្យដែលប្រកបជាមួយព្យញ្ជនៈខ្យល់ស្ទះឥតខ្យល់លឺ ដូចជា " ប ប៊ " និង " ដ.ឌ " ត្រូវដូរជាព្យញ្ជនៈខ្យល់ស្ទះ ឥតខ្យល់ថ្លង់វិញ ។

| | | | |
|---|---|---|---|
| ឧទាហរណ៍ : | បាប | > | [ ba:p ] |
| | មាឌ | > | [ mi:ət ] |

[p & t] : ជាសូរព្យញ្ជនៈខ្យល់ស្ទះឥតខ្យល់ថ្លង់ ។

**២ - ពាក្យដែលមានការប្រែប្រួលសូរ និង រូបរាងតាមដល់បាតិសេដើមរបស់ពាក្យ**

(ទំនងជាបណ្ដាលមកពីការធ្វើខ្មែរនីយកម្មពាក្យបាលីសំស្ក្រឹត) :

ឧទាហរណ៍ : ពាក្យ "ប្រសិទ្ធី "ដែលជាឈ្មោះភ្នំប្រសិទ្ធី ស្ថិតនៅទិសពាយ័ព្យនៃទីក្រុងភ្នំពេញ ។

ពាក្យនេះសព្វថ្ងៃទាំងនិយាយទាំងសរសេរនៅសល់តែ "បាសិត " ។ តើពាក្យនេះមានការប្រែប្រួលដូចម្ដេចខ្លះ ?

តាមការសាកល្បងរកហេតុផលនៃការប្រែប្រួលនោះ គឺដូចនេះ :

---

(១) - F.E Huffman and Im Prum "Modern Spoken Cambodian " 1977

+ **តំណាក់ទី១ :**

ពាក្យ " ប្រសិទ្ធិ " ព្យញ្ជនៈផ្សំ " ប្រ" គឺ ជើង ្រ ត្រូវជ្រុះបាត់ ដោយសារបន្ថើរស្នូរនៅព្យាង្គ ទី១ ។ ដូចនេះនៅសល់តែ " បសិទ្ធិ " ។

ឧទាហរណ៍ : ប្រអប់ > បអប់ > ប្អប់ [១]

+ **តំណាក់ទី២ :**

ស្រៈ អុិ ស្រៈចុងនៃព្យាង្គទី២ ត្រូវបដិសេធស្នូរចោល ។ ដូចនេះស្រៈនៅសល់តែ" បសិទ្ធ" ឧទាហរណ៍ : ជាតិ [jāti] > [ ci:ət ] [ ជាត ]...

+ **តំណាក់ទី៣ :**

ព្យញ្ជនៈតំរួត និង ជាព្យញ្ជនៈប្រកបនៃព្យាង្គទី២ :

ទ្ធ (ddh) កំណត់ស្នូរត្រឹមតែ ត [t] ។ ព្រោះ "ត" ក្តី "ទ" ក្តី កំណត់ស្នូរ [t]

ដូចនេះ "បសិទ្ធ" នៅសល់តែ "បសិត" ។

+ **តំណាក់ទី៤ :**

បសិត > បាសិត

អ > អា ស្រៈ អ រអិលទៅស្រៈអា ករណីនេះតែងមានជួបប្រទះជាញឹកញាប់ដូចជាក្នុងពាក្យ :

| | | | |
|---|---|---|---|
| សកល | > | សាកល | វចនានុក្រមខ្មែរ ទំព័រ ១២២៦ |
| សក្យ | > | សាក្យ | វចនានុក្រមខ្មែរ ទំព័រ ១២៣០ |
| ប្រស្រ័យ | > | ប្រាស្រ័យ | វចនានុក្រមខ្មែរ ទំព័រ ៦៧០ |

ដូចនេះរួមសេចក្តីមកពាក្យ ប្រសិទ្ធិ សព្វថ្ងៃនេះនៅសល់ស្នូរ និង រូប ត្រឹមតែបាសិតប៉ុណ្ណោះ ។

ប្រសិទ្ធិ < ប្រសិទ្ធ (កិ) ឬ ប្រសិទ្ធិ មានន័យដើមថា ធ្វើឱ្យខ្លាំងពូកែ [២] ។

**៣- ពាក្យជានាមឋាននុះដែលមានការប្រែប្រួលស្នូរ និង រូបរាងពាក្យ ស្ទើរតែពុំអាចពន្យល់បានតាមក្បួនវេយ្យាករណ៍ និង និរុត្តិវិទ្យា :**

ក- ឧទាហរណ៍ដូចជា ពាក្យ " សន្លុង " ដែលជាឃុំមួយក្នុងស្រុកទ្រាំង ខេត្តតាកែវ ។ ពាក្យនេះបើ

---

[១] ត្រឹង ងា ( អ្នកស្រី), អរិយធម៌ខ្មែរ, ទំព័រ ៨០, ឆ្នាំ ១៩៧៤ ។

[២] - រ គោ វិទ, វចនានុក្រមខ្មែរពិស្តារ, ទំព័រ ១៩៩២ ។

ពិនិត្យមើលឫសរបស់វា ដូចជាគ្មានន័យអ្វីទេ។ តែបើមើលតាមរឿងព្រេងភាគ៥ទំព័រ៧៤ "រឿងភ្នំបាយង់កោរ " បានបញ្ជាក់ថា ក្លាយមកពីពាក្យថា "សែនលង់" ។ ព្រោះសេចក្តីក្នុងរឿងនោះតំណាលថា សំពៅសៀម ដែលធ្វើដំណើរពីស្រុកសៀមមកភ្នំបាយង់កោរ តែងតែត្រូវព្យុះខ្យល់បោកបក់ឱ្យលិចលង់នៅម្តុំជិតភ្នំសន្លុង ក្នុងស្រុកទ្រាំង ខេត្តតាកែវ សព្វថ្ងៃនេះ ។ ពាក្យនេះបើអានបន្ធើរស្លូរ និង អានញាប់យូរៗទៅ គឺមានលក្ខណៈដូចនេះ សែនលង់ > សន់លង់ ( បន្ធើរស្លូរ) > សន្លង់ ( ប្រើវិធីតម្រូតព្យាង្គ) > សន្លុង [១] ។

ខ- "ព្រះដាក់ " ជាឈ្មោះឃុំមួយ និង ជាឈ្មោះសាលារៀនមួយ : "សាលារៀនព្រះដាក់" ស្ថិតនៅតាមផ្លូវទៅកាន់ប្រាសាទបន្ទាយស្រី តំបន់អង្គរខេត្តសៀមរាប ។

ការសរសេរដាក់ឈ្មោះថ្មីនេះឃើញថា មានរូបនិងសូរដូចជាខុសឆ្ងាយពីពាក្យដើមច្រើនពេក ។ តាមពិនិត្យពាក្យនេះក្លាយមកពី "តដាក" ដូចជាពាក្យថា ឥន្ទ្រតដាក [២] ។ តដាកនេះ គឺជាភាសាកួយមានន័យថា " ទឹក " ។

តដាក > បដាក > ព្រះដាក់

ហេតុអ្វីបានជា តដាក ក្លាយជា បដាក ? ត្រង់នេះ បើសិក្សាតាមសូរវិទ្យាខ្មែរ "ត" និង "ដ" មានទីបន្លឺជាន់គ្នា វាពិបាកអាន ( បន្លឺ) បន្តិច។ ចំពោះ "ប" និង "ដ" គឺ "ប" សូរបបូរមាត់ ( ស្ថិតនៅមុខ) និង "ដ" សូរគន្ទាក់ក្រអូម (ស្ថិតនៅក្រោយ)។ ដូចនេះ ការបន្លឺពី "ប" ទៅ "ដ" គឺស្រួលជាង ព្រោះសូរវាស្ថិតនៅទីតាំងបណ្តោយគ្នា ឬ ស្របគ្នា។ ឯ "ព្រះដាក់ " សរសេរបែបនេះ គឺខុសឆ្ងាយគ្នាទាំងសូរ ឆ្ងាយទាំងន័យសេចក្តី ។

ដូចនេះការដាក់ឈ្មោះទីតាំង ឬ កន្លែងនីមួយៗ គួរកុំចេះតែសរសេរតាមសូរអាន គួរពិចារណារកហេតុផលផង ។ ការដាក់ឈ្មោះនាមដ្ឋានមិនចំ វានាំឱ្យឃើញនូវល្បាយជនជាតិ ឬ ល្បាយភាសា ។ ឧទាហរណ៍ : ភ្នំដា , សៃវ៉ា , ក្រាំងយូវ , កុលាបប៉ៃលិន... ។

**៤- ពាក្យដែលមានសូរអានដោយសារកត់ត្រាតាមភាសាបរទេស :**

ឧទាហរណ៍ : អំពីប្រវត្តិពាក្យថា " ប៉ៃលិន " ដែលសព្វថ្ងៃជាទីក្រុងមួយស្ថិតនៅក្នុងស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

---

[១] - សិលាចារឹក នគរវត្ត Cedorex ទំព័រ ៣៤ ឆ្នាំ ១៩៨៤ " ឥស្សរកាលត លុង ទៅហោង " លង់ គឺ លុង បានជាសន្លុងសរសេរបែបនេះ ។

[២] - ត្រឹង ងា "អ្នកស្រី" ប្រវត្តិសាស្ត្រខ្មែរ ភាគ១ ទំព័រ ១៣៩។

...“ តាមសំដីអ្នកស្រុកបានអោយការណ៍មកថា ពាក្យ “ប៉ៃលិន” នេះក្លាយមកពីពាក្យ “ ភេលេង ” ព្រោះមានដើមរឿងនិទានបញ្ជាក់ថា :[១]

... “កាលនោះមានអ្នកស្រុកប្រមាញ់ដេញតាមដានសត្វព្រៃ ចេះតែឆ្ងាយទៅៗរហូតដល់ភូមិភាគប៉ៃលិនសព្វថ្ងៃនេះ ដែលគ្រានោះជាព្រៃស្រោង មានវាលចន្លោះខ្លះ តែត្រង់ប្រលាយទឹកដែលហៅថា “អូរ” មានអូរទុងជាដើម។ ក្បែរមាត់អូរនោះ អ្នកប្រមាញ់បានប្រទះឃើញសត្វភេកំពុងហែលទឹក។ លុះឃើញមនុស្សមកដល់ ភេក៏រត់បាត់ទៅ។ អ្នកប្រមាញ់ចូលទៅមើលត្រង់កន្លែងភេប្រលែងគ្នានោះក៏ឃើញដុំថ្មតូចៗមានពន្លឺភ្លែកៗ ក៏រើសយកម្នាក់មួយដុំៗ ទុកយកទៅបង្ហាញញាតិមិត្តឯស្រុកខ្លួនវិញ។ លុះទៅដល់ស្រុក អ្នកស្រុកនោះ (តាមនិយាយថាពួកកុឡា ដែលមករស់នៅក្នុងខេត្ត ចន្ទ បុរី ស្រុក សៀម) ស្គាល់ថាថ្មនេះមានតំលៃ គេក៏យកទៅបំបែក រូចច្នៃជាត្បូងឡើង ក៏ឃើញថាមានទឹកល្អ។ កាលបើដូចនោះគេក៏នាំគ្នាទៅសួរទិញពីពួកប្រមាញ់នោះទៀត។ ពួកប្រមាញ់យល់ថា ជាផ្លូវរកស៊ីមួយហើយ ក៏ព្យាយាមនាំគ្នាឆ្ពោះទៅយកថ្មនេះ ពីកន្លែងមុនជាញឹកញាប់ ទើបអ្នកទាំងនោះសន្មតឈ្មោះត្រង់កន្លែងនោះថា “កន្លែងភេលេង” យកតាមភាសាដែលគាត់ប្រទះឃើញជាដំបូង។ ប៉ុន្តែ ដោយហេតុពួកអ្នកទាំងនេះនៅស្រុកសៀម ក៏អានពាក្យនេះក្លាយទៅជាសំឡេងសៀមបន្តិចទៅ គឺ :

- “ ភេ ” ទៅជា “ផេ”
- ឯ “ លេង ” ទៅជា ឡេន ឬ ឡិន
- ដូចនេះរួមមកទៅជា “ ផេឡិន ”

លុះសម័យបារាំងចូលទៅកាន់កាប់កន្លែងតំបន់នេះ គេក៏សរសេរឈ្មោះនេះជាអក្សររ៉ូម៉ាំង តាមសូរផង និង តាមរូបពាក្យផង ជា PHAI-LIN គឺ :

| | | |
|---|---|---|
| PH | ជាអក្សរ | ផ |
| AI | ជាអក្សរ | អៃ |
| L | ជាអក្សរ | ល |
| I & N | ជាអក្សរ | អិន |

តែក្រោយមក ដើម្បីកុំឱ្យពិបាកសរសេរ គេក៏ដកសហសញ្ញា ឬ រជ្ជុសញ្ញា (-) ចេញ។ ហើយតៗមកបារាំងអានគ្មានខ្យល់ H។ គេក៏លុប H ចោលទៅ នៅសល់តែ PAILIN (ប៉ៃលិន)។

ដូចនេះឈ្មោះ“ប៉ៃលិន”នេះ កាលបើអានញាប់ឃ្លូវៗ ទៅជា “ ប៉ៃលិន ” រហូតមកដល់សព្វថ្ងៃនេះ ។

---

(១) – រឿងព្រេងភាគ ៥ ប្រជុំទំនៀមទំលាប់ខ្មែរ ទំព័រ ៥៣ ឆ្នាំ ១៩៩០។

**៥ - នៅមាននាមឋានជាច្រើនទៀតដែលក្នុងកន្សោមពាក្យនោះពាក្យដែលស្ថិតនៅកណ្តាល ត្រូវចុះបាត់សូរ ក្នុងសំនិយាយ :**

ឧទាហរណ៍ : បន្ទាយក្តី ( ប្រាសាទ) < បន្ទាយកាត់ក្តី

ពោធិ៍សាត់ < ពោធិ៍រសាត់ ( ដើមពោធិ៍រសាត់ )

ត្រពាំងពិស < ត្រពាំងពស់ត្រាំពិស

ព្រៃចាស់ ( វត្ត) < ព្រៃលាក់អង្គម្ចាស់ ( ក្នុងរឿងព្រះស្តេចកន)

ភ្នំសែនហាន < ភ្នំសែនក្លាហាន ( ខេត្តកំពត)

ពាមជីកង < ឬ ពាមជីកកង ? .... ។

ដូចនេះពាក្យទាំងនេះ សុទ្ធតែមានប្រវត្តិរបស់វាពិតប្រាកដហើយ ដែលយើងត្រូវចុះទៅស្រាវជ្រាវដល់ទីកន្លែងតែម្តង ។

**៦- សូរភាសាខ្មែរខ្លះទៀត ក្លាយមកពីភាសាប្រាក្រិត ឬ ភាសាបាលីសំស្ក្រឹតក្លាយ បានន័យថា យើងយកភាសា បាលី សំស្ក្រឹតនោះ មកបំលែងទៅជាសូរខ្មែរ ដើម្បីសំរួលក្នុងការអាន :**

ឧទាហរណ៍ : នគរវត្ត > អង្គរវត្ត

នង្គ័ល ( បា) > អង្គ័ល

លង្គ័ល( សំ) > អង្គ័ល

នគរបាល > អង្គរបាល... ។

**៧- សូរភាសាខ្មែរប្រែប្រួលទៅតាមតំបន់នីមួយៗដែលទៅអនាគត អ្នកភាសាវិទ្យាត្រូវចុះទៅធ្វើការស្ទាបស្ទង់ ( Survey = Songdage ) ដល់ទីកន្លែងផ្ទាល់ ដើម្បីធ្វើផែនទីភាសាវិទ្យា :**

ឧទាហរណ៍ : * ពាក្យ " ទឹក "

- តំបន់ខ្លះអានថា : ទឹក

: ទឹ

: តឹក ... ។

* ពាក្យ " ហើយ "

- តំបន់ខ្លះអានថា : ហើយ

: ហោយ ( ស្អាង-កណ្តាល)

: ហ៊ើយ ( ភ្នំស្រុក-បាត់ដំបង) ... ។

* ពាក្យ " កន្ទេល "

- តំបន់ខ្លះអានថា : កន្ទើល ( ព្រៃវែង-ទន្លេធំ) ... ។

* ពាក្យ " ច្រើន "

- តំបន់ខ្លះអានថា : ច្រើន

: ជ្រើន

: ជើន . ចើន ... ។

* ពាក្យ " ផ្ដើម "

- តំបន់ខ្លះអានថា : ផ្ញើម ( មុខកំពូល . កណ្ដាល)

* ពាក្យ " ដំឡូង "

- តំបន់ខ្លះអានថា : ដំឡូង

: តឡូង > តាឡូង

: អំឡូង ... ។

* ពាក្យ " ស្លាប់ "

- តំបន់ខ្លះអានថា : ឡាប់ ( កំពង់ធំ បារាយណ៍ . តាំងគោក )

* ពាក្យ " តំរៀប "

- តំបន់ខ្លះអានថា : តំរៀប

: តំម្សៀប ( កំពង់ចាម . ទន្លេធំ)

* អក្សរ " ឆ " អានសូរជា " ស"

ឆ្ងាញ់ > ស្ងាញ់

ឆ្នាំង > ស្នាំង

ឆ្កែ > ស្កែ ... ។ ( តាកែវ. កំពត . កំពង់ស្ពឺ)

* ស > ច

ស្រូវ > ច្រូវ

ស្រែ > ច្រែ ( ព្រៃកប្បាស . តាកែវ) ។

* ពាក្យ " ផឹក "

- តំបន់ខ្លះអានថា "ផី "( ភាគខ្លះនៃខេត្តបាត់ដំបង និង សៀមរាប) ។

- តំបន់ខ្លះទៀតអានថា " ផក់ " ( កំពង់ចាម . កណ្ដាល និង ព្រៃវែង ) ។ល។

នៅមានពាក្យជាច្រើនទៀត ដែលបន្លឺល្បៀងសូរគ្នាទៅតាមតំបន់នីមួយៗ ដែលយើងពុំបានលើកយកមកបង្ហាញក្នុងពេលនេះ ។

## ៤- សូរអានពាក្យបាលីសំស្ក្រឹតក្នុងភាសាខ្មែរ [១]

### ក- សូរអានប្រហាក់ប្រហែលគ្នា :

| អក្ខរាវិរុទ្ធ | សូរអានបែបបាលីសំស្ក្រឹត | សូរអានបែបខ្មែរ |
|---|---|---|
| មុនី | មុនី | មុនី |
| ហារី | ហារី | ហារី |
| ហរិ | ហរិ | ហារី |
| ចលនា | ចះលះន៉ា | ចល់លះន៉ា |
| ឆដា | ឆះដា | ឆដា |
| ចេតនា | ចេតះន៉ា | ចែតះន៉ា |
| តក្កមា | តះកះម៉ា | តក់កម៉ា |
| ថរិកា | ថរិកា | ថរីកា |
| សាធុ | សាធុ | សាធុ |
| វិត្ថា | វិថា | វិថា |

### ខ- សូរអានបែបខុសគ្នា :

| អក្ខរាវិរុទ្ធ | សូរអានបែបបាលី-សំស្ក្រឹត | សូរអានបែបខ្មែរ |
|---|---|---|
| ធាតុ | ធ្វាទុ | ធាត |
| កីឡា | គីឡ៉ា | កីឡ៉ា |
| មាលា | ម៉ាឡ៉ា | មាលា |
| ចិន្តា | ចិនតា | ចិនដា |
| ឋិតិ | ធិទិ | ថិតិ |

[១] - ព្រឹត្តិប័ត្រ វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ លេខ ១ ទំព័រ ២៧ ឆ្នាំ ១៩៨៩។

| | | |
|---|---|---|
| សីមា | ស៊ីម៉ា | សីម៉ា |
| ធិរវេលា | ធិរៈវេឡ៉ា | ធិរៈវេលា |
| ចតុ | ចៈទុ | ចៈតុ |
| លីលា | លីឡ៉ា | លីលា |
| ចាមរី | ចាម៉ៈរី | ចាម៉ៈរ៊ី |
| នាវា | ន៉ាវ៉ា | នាវា |
| គតិ | គៈទិ | គតិ |
| នានា | ន៉ាន៉ា | នានា |
| នាគា | ន៉ាហ្គា | នាគា |
| បាលី | ប៉ាលី | បាល៊ី |
| សាលី | សាលី | សាល៊ី |
| សាមី | សាមី | សាម៊ី |
| កិរិយា | គិរិយ៉ា | កិរ៊ិយ៉ា |
| បុរី | ពុរី | បុរ៊ី |
| នារី | ន៉ារី | នារី |

៩- <u>ការប្រែប្រួលសំនេរនិងសំនួរនៃភាសាខ្មែរបុរាណ</u> :

ក- **ការវិវត្តសូរស្រៈ :**

| សម័យបុរាណ | សម័យបច្ចុប្បន្ន | សិលាចារឹក | ពន្យល់ពាក្យ |
|---|---|---|---|
| ១ : ស្រៈ ៉ ̈ | ស្រៈ ̈ - ា ̈ | | |
| កច > ក័ច | កាច់ | វិមានអាកាស | កុំបីព្រះពាយកាច់ |
| មត្ត | មាត់ | បន្ទាយឆ្មារ | |
| បញ្ជ្យរ > ចរ ? | បញ្ជា | តាអន | បញ្ជាទូទៅ-បញ្ជាឱ្យទៅ |
| ចប >ច័ប | ចាប់ | បន្ទាយឆ្មារ | លុក. បំផ្លាញ .កំទេច |
| បញ | បាញ់ | វិមានអាកាស | |
| មន | មាន | តាកែវ | |

| | | | |
|---|---|---|---|
| ប្រក់ | ប្រាក់ | តាកែវ | |
| ករ | ការ | បន្ទាយឆ្មារ | |
| បត ( ប័ត) | បាត់ | វិមានអាកស | |
| ស្កត | ស្កាត់ | បន្ទាយឆ្មារ | |
| ស្រច | ស្រាច់, ស្រេច | បន្ទាយឆ្មារ | |
| ២ : ស្រះ "ា" | ស្រះ " -ាំ " | | |
| ធម | ធំា | កម្រៀង B | |
| ឆ្យង ( ឆ្យ័ង) | ច្បាំង | បន្ទាយឆ្មារ | |
| ប្រង ( ប្រ័ង) | ប្រាំង | តាកែវ | |
| ត្រវង > ត្រវាំង | ត្រពាំង | វត្តត្នោត | |
| ៣ : ស្រះ "ា" | ស្រះ " េ- " | | |
| ប្រ្ច | ព្រេច | វិមានអាកាស | |
| ស្តច > ស្ត័ច | ស្តេច | បន្ទាយឆ្មារ | |
| ៤ : ស្រះ "ា" | ស្រះ " ែ- " | | |
| វញ | វែង . បង្វែង | បន្ទាយឆ្មារ | |
| ៥ : ស្រះ "ា" | ស្រះ " -ី " | | |
| ទ្រនប់ | ទ្រនីប | គុហារលួង | រង្វាន់គ្រូមើលជំងឺ |
| ៦ : ស្រះ "ា" | ស្រះ " -ួ " | | |
| ផ្តល់ | ផ្តួល | បន្ទាយឆ្មារ | សំលាប់ធ្វើឱ្យដួល |
| ៧ : ស្រះ " -ា " | ស្រះ " -ាំ " | | |
| ល្វាង | រវាំង | គុហារលួង | ឃ្វាំ អ្នករវាំង ប្រយ័ត្ន អ្នកឃ្វាំ |
| ៨ : ស្រះ " -ា " | ស្រះ " -ួ " | | |
| ថលា | ទូល, ទូលគោក | គុហារលួង | |
| ៩ : ស្រះ " -ា " | ស្រះ " េ-ៀ " | | |
| ចន្យាទិ | ចិញ្ចៀន | តាអន | |
| ១០ : ស្រះ " -ិ " | ស្រះ " -ី " | | |

| | | | |
|---|---|---|---|
| បិង | បឹង | | |
| រិង | រឹង | អង្គរបុរី | រឹញ |
| ទិក្ក | ទឹក | បន្ទាយឆ្មារ | |
| ស្និក | ស្នឹក | កម្រៀង A | |
| លិង | ស្នឹង | តាកែវ | ប្រាក់ស១ស្នឹង |
| ១១ : ស្រះ " -ិ " | ស្រះ " -ី " | | |
| អរិ | អពី | តាកែវ | |
| បិ | បី | បន្ទាយឆ្មារ | |
| ជ្យង , ជិង , ជឹង | ជើង | វត្តឯក | |
| បាញ្ជិយ | បញ្ជី | បាសែត | |
| មន្ទិរ | មន្ទីរ | បន្ទាយឆ្មារ | |
| ១២ : ស្រះ " -ិ " | ស្រះ " -ឺ " | | |
| គិ | គឺ | បន្ទាយឆ្មារ | |
| ១៣ : ស្រះ " -ិ " | ស្រះ " េ- " | | |
| គិត តេក | ដេក | បាសែត B.B | |
| ១៤ : ស្រះ " -ិ " | ស្រះ " េ-ី " | | |
| ជិង | ជឹង > ជើង | វត្តឯក | |
| ១៥ : ស្រះ " -ុ " | ស្រះ " េ- " | | |
| កុល | កុលេ | បន្ទាយឆ្មារ | គោត្រកុល ញាតិ សន្តាន សាច់ញាតិ ញាតិវង្ស |
| ១៦ : ស្រះ " -ុ " | ស្រះ " -ឹ " | | |
| កុស | ក្រឹស | ក. A | |
| ១៧ : ស្រះ " -ុ " | ស្រះ " -ូ " | | |
| ចុរ | ចូរ | វិមានអាកាស | |
| ចុរ | ចោរ ( េ-ា) | គុ.លូង | បង្គាប់ឱ្យលួច |
| ជុន | ជូន .បញ្ជូន | ភូមិជ្រៃ | |
| ស្រុ | ស្រូវ | ក. A | |

| | | | |
|---|---|---|---|
| រាហុ | រាហូ | បន្ទាយឆ្មារ | |
| មុហ | ប្រមុះ ( -ុះ) | មុនសម័យអង្គរ | |
| ១៨ : ស្រះ " -ូ " | ស្រះ " -ួ " | | |
| តូល | ដួល | បន្ទាយឆ្មារ | |
| ១៩ : ស្រះ " -ូ " | ស្រះ " -ឹ " | | |
| ថ្លូង , ថ្លឹង | ថ្លឹង | វត្តឯក | រង្វាស់រង្វាល់ |
| ២០ : ស្រះ " េ- " | ស្រះ " េី " | | |
| កេត | កើត ,ខ្លើត | គុហារលួង | |
| កម្រេក | កម្រើក | វិមានអាកាស | |
| ចំចេំ | ចិញ្ចើម | វិមានអាកាស | |
| ច្រេន | ច្រើន | បន្ទាយឆ្មារ | |
| ឈេ | ឈើ | តាកែវ | ឧ:ឈេវ្រៃយ ឈើព្រៃឈ្មោះ នៃ ក្លោញម្នាក់ |
| ជេង | ជើង | បន្ទាយឆ្មារ | |
| ជេ-ជើ | កញ្ជើ | តាកែវ | ជារង្វាស់រង្វាល់កញ្ជើ |
| តេំ > តេម > ដេម | ដើម | ក. A | |
| ត្លេង > ថ្លេង | ថ្លើង >តម្លើង | បន្ទាយឆ្មារ | ឡើង ចូល លុក សម្រុក |
| ថ្វេ | ធ្វើ | បាសាក់ រំដួល | មកពីពាក្យ តំវេ |
| ថ្វេ | ធ្វើ | បន្ទាយឆ្មារ | |
| ទេប | ទើប | បាសែត | ទេបឱយតកូន : ទើបឱ្យដល់កូន |
| តំវេ > តង្វេ > ត្វេ | ថ្វេ > ធ្វើ | វត្តត្នោត | |
| លេយ | លើយ | បន្ទាយឆ្មារ | |
| ២១ : ស្រះ " េ- " | ស្រះ " ែ- " | | |
| កំស្តេង | កំស្តែង | បាសែត B.B | |
| លំវេង | លំពែង | បន្ទាយឆ្មារ | |
| ក្មេរ , ខ្មេរ > | ខ្មែរ | ជាន់ជុំ | |
| មេក | មែក | វិមានអាកាស | |

| | | | |
|---|---|---|---|
| ស្លេង | ស្លែង | ជាន់ជុំ | |
| ខ្មេរ | ខ្មែរ | បន្ទាយឆ្មារ | |
| ច្រេ | ឆ្កែ | អង្គរបុរី | |
| តេល | ដែល | បន្ទាយឆ្មារ | |
| វេង | វែង | បន្ទាយឆ្មារ | |
| ត្មេង | ត្មែង | តាកែវ | អ្នកតែង |
| ផ្លេយ | ផ្លែ | បាសែត | មកពីពាក្យ " ប្លែ " |
| ២២ : ស្រះ " េ- " | ស្រះ " ី ឺ " | | |
| ត្មេម < ទេម > ទិម | > ទឹម . នឹម | អង្គរបុរី | គោមួយនឹម |
| ទ្មេម > ទេម > ទិម | > ទឹម > ទ្នឹម > ធ្នឹម > នឹម | ភុមិជ្រៃ | ឧ: តួរទ្មេម៧ : គោ៧នឹម |
| អំបេល | អបិល | ចំណោម | |
| ២៣ : ស្រះ " េ- " | ស្រះ " េ-ា " | | |
| ស្មេយ | ស្មោយ | វិត្តនគរ | សោយ ឧ: សេយផលសមភាគ : សោយផលស្មើគ្នា |
| ២៤ : ស្រះ " េ-ា " | ស្រះ " អ " | | |
| ចំទោង | ជំទង់ | វិត្តឯក | |
| តំបោង | តំបង ដំបង | គុហារលួង | |
| ប្រកោប | ប្រកប | បន្ទាយឆ្មារ | អោយ ប្រទាន |
| ផោង | ផង | វិមានអាកាស | |
| ច្បោង | ច្បង | តាកែវ | |
| ២៥ : ស្រះ " េ-ា " | ស្រះ " ូ " | | |
| ជោន | ជូន | ចំណោម | |
| តោង | ដូង | វិត្តស្រែ | |
| ទោក | ទូក | គុហារលួង | |
| បោស | បួស | គុហារលួង | |
| តោន > តួន > តូន | ដូន | វិត្តត្មោត | ជីដូន យាយ " ឧ. កនមោយកំតោន ក្នុយជីដូន១ |
| ២៦ : ស្រះ " ំ " | ស្រះ " ុំ " | | |

| | | | |
|---|---|---|---|
| កំ | កុំ | វិមានអាកស | កុំបី |
| ២៧ : ជើង " ្វ " | ស្រះ " ូ " | | |
| រ្វត | រូត | វត្តឯក | បិរ្វត បីរូត |
| ឱ្វយ | ឱយ អោយ | វិមានអាកាស | ថ្វាយ ជូន ឱ្យ |
| កំទ្វាត | កន្ទូត | វត្តឯក | |
| ក្វន | កូន | បា-បាដ | |
| បទ្វល | បន្ទូល | បន្ទាយឆ្មារ | |
| ប្វស > ប្វាស > បួស | បួស > បួស | គុហារលួង | |

**ខ - ការវិវត្តសូរព្យញ្ជនៈ**

| សម័យបុរាណ | សម័យបច្ចុប្បន្ន | សិលាចារឹក | ពន្យល់ពាក្យ |
|---|---|---|---|
| ១- អក្សរ " ក " | អក្សរ "ខ" | | |
| ក្មី | ខ្មី | អង្គរបុរី | |
| ក្មាល | ខ្មាល | ភូមិជ្រៃ | ឈ្មោះនៃស្រីម្នាក់ |
| ក្មុង | ខ្មុង | ភូមិជ្រៃ | ឈ្មោះនៃស្រីម្នាក់ |
| ក្មុំ ខ្ញុំ | ខ្ញុំ | វត្តថ្កោត | ខ្ញុំកំដរ |
| ក្មស | ខ្មាស់ (ខ្ម័ស) | ភូមិជ្រៃ | ឈ្មោះនៃបុរសម្នាក់ |
| ក្មាយ | ខ្មាយ | អង្គរបុរី | |
| កនុរ | ខ្នុរ | អង្គរបុរី | |
| ក្មេរ | ខ្មែរ | ប្រាសាទជាន់ជុំ | |
| ក្មៅហ៊ូ | ខ្មៅហ៊ូ | គុហារលួង | ពណ៌ខ្មៅ |
| ២ :អក្សរ " ក " | អក្សរ " គ " | | |
| ក្រោង | គ្រោង | អង្គរបុរី | ធំ គ្រោងធំ |
| ៣ :អក្សរ " ច " | អក្សរ " ឆ " | | |
| ច្កេ | ឆ្កែ | អង្គរបុរី | |
| ច្អឹង | ឆ្អឹង , ស្អឹង | គុហារលួង | |
| ចី | ឆី | វិមានអាកាស | ស៊ី |

| | | | |
|---|---|---|---|
| ៤ :អក្សរ " ឆ " | អក្សរ " ច " | | |
| ឆ្យង | ច្បាំង | បន្ទាយឆ្មារ | |
| ៥ :អក្សរ " ជ " | អក្សរ " ឈ " | | |
| ជ្មោះ | ឈ្មោះ | បន្ទាយឆ្មារ | |
| ៦ :អក្សរ " ត " | អក្សរ " ដ " | | |
| តល | ដល់ | បន្ទាយឆ្មារ ,<br>វិមានអាកាស | ឧ. តអចស់ : ដីចាស់ |
| តប់ | ដប់ | បន្ទាយឆ្មារ | តប់ប្រំបិយ = ដប់ប្រាំបី |
| តល | ដល់ | បន្ទាយឆ្មារ | |
| តូល | ដួល | បន្ទាយឆ្មារ | |
| តាក់ | ដាក់ | បាសែត ប.ប | |
| តរាប | ដរាប | វត្តឯក | |
| តិង | ដឹង | វិមានអាកាស | ជ្រាប |
| តុត | ដុត | វិមានអាកាស | ឆេះ |
| តំ > តេម | ដេម > ដើម | ក. A | ដើមកំណើត ដើមឈើ |
| តេម | ដើម | វត្តអង្គក្មារ | ឧ. ពោងតេម១០ = ដូង១០ដើម |
| តេល | ដែល | បន្ទាយឆ្មារ | |
| តោង | ដូង | ភូមិជ្រៃ | |
| តោយ | ដោយ | បន្ទាយឆ្មារ | |
| តំបោង | ដំបង | គុហារលួង | |
| ៧ : អក្សរ " ត " | អក្សរ " ថ " | | |
| ត្ងៃ | ថ្ងៃ | វត្តត្នោត | |
| ត្លល | ថ្លល់ | អង្គក្មារ | |
| ត្លេង , ថ្លេង , ថ្លើង | តម្លើង | បន្ទាយឆ្មារ | ឡើង លុក សំរុក |
| ត្លោស | ថ្លោស | តាកែវ | ធំ , ទ្រើស |
| ៨ :អក្សរ " ថ " | អក្សរ " ត " | | |
| ថ្បូង | ត្បូង | បាសែត ប.ប | |

| | | | |
|---|---|---|---|
| ថ | ធ | | |
| ថ្ងៃ | ធ្ងៃ | បាសាក់ . រំដួល | មកពីពាក្យ តំរេ |
| ថ្ងៃ | ធ្ងៃ | បន្ទាយឆ្មារ | |
| ៩ :អក្សរ " វ " | អក្សរ " ព " | | |
| លំវែង | លំពែង | បន្ទាយឆ្មារ | |
| វល | ពល | បន្ទាយឆ្មារ | |
| វវេ | ពពែ | អង្គរបុរី | |
| វស | ពស់ | វត្តឯក | |
| វេត | ពេត . ពេក | វិមានអាកាស<br>វត្តភ្នោត | |
| វំ . ពំ . ព្ញំ | ពុំ | គុហារលួង | |
| ១០ : អក្សរ " វ " | អក្សរ " ផ " | | |
| វ្នោក | ផ្នុក | វត្តភ្នោត | ផ្នុកខ្សាច់ |
| វ្នូរ | ផ្នូរ | អង្គខ្មារ | |
| ១១ :អក្សរ " វ " | អក្សរ " ព " | | |
| វ្នែក | ភ្នែក | វិមានអាកាស | ឧ. តោយវ្នែក . ដោយភ្នែក |
| វ្នំ | ភ្នំ | បន្ទាយឆ្មារ | កនៅព្រៃភ្នំហៅថា ភ្នងពាក្យនេះអាច ពន្យល់ទៅជា ភ្នង > ព្នង ក៏បាន "ព្នង" ប្រែថា "អ្នកភ្នំ" |
| ១២ :អក្សរ " វ " | អក្សរ " ព " | | |
| វ្រិច | ព្រេច | វិមានអាកាស | ឧ. ដីព្រេច |
| វ្រទេង | ព្រេង | គុហារលួង | ពីព្រេង . ចាស់ |
| វ្រេង | ព្រេង | តាកែវ | ឈ្មោះនៃបោញម្នាក់ |
| វ្រៃ | ព្រៃ | គុហារលួង | ព្រៃតំបោង ឧ. ព្រៃដំបង |
| វ្រាង | ព្រោង | អង្គរបុរី | |
| វ្រៅ | ព្រៅ | ប្រាសាទប្រាំល្វែង | |
| វ្រះហ | ព្រះ | វត្តភ្នោត | |
| វង្ស > ព្រិង > ព្រឹង | ព្រឹង | បាសែត ប.ប | ឧ. វ្រះវង្ស : ព្រះព្រឹង |
| វ្លឹង. ព្លឹង | ព្លឹង . ភ្លើង | វិមានអាកាស | |

| | | | |
|---|---|---|---|
| វ៉ុះ > វ៉ោះ > ញោះ | ភ្ញោះ | តាកែវ | |
| ១៣ : អក្សរ " គ " ( ស.គ ) | អក្សរ "ស"(ស-ល) | | |
| គ ក | ស័ក | ក. A | ឆ្នាំ |
| គិ ល . គីល | សិល | ក. B | |
| គី រ | សិរ: | វត្តឯក | ព្រះសិរ: |
| គិ ប្ស | សិស្ស | វត្តឯក | |
| គុ ទ្ធ | សុទ្ធ | តាកែវ | ស្អាត |
| គ្រី | ស្រី > សិរី | បន្ទាយឆ្មារ | |
| ១៤ :អក្សរ "ប " ( ស-ប ) | អក្សរ "ស" (ស-ល) | | |
| វិប្ន | វិស្ន | ក A | |
| ១៥ :អក្សរ " ស " ( ស.ប ) | អក្សរ " ឆ " | | |
| សក . ចក | ឆក . ឆក់ | ក A | |
| ១៦ :ជើង " ្ន " | ជើង " ្ណ " | | |
| ក្សម្ទ | ក្សេ្ម | ក B ( កំរៀង A ) | ខាងខ្មៅ ងងឹត រនោច ផ្ទៃករនោច ខៃងងឹត |
| ១៧ :ជើង " ្ទ " | ជើង "្ត " | | |
| កម្ទុជ | កម្ពុជ: . កម្ពុជា | បន្ទាយឆ្មារ | |
| ១៨ : ន | ណ | | |
| ចំនត | ចំណត | បាសែត ប.ប | |

រួមសេចក្តីមក ការប្រែប្រួលសូរសំឡេងក្នុងភាសាខ្មែរ គឺមានលក្ខណ:គួរឱ្យកត់សំគាល់ ដូចខាងក្រោមនេះ :

១- លក្ខណ:សូរវិទ្យា ដែលស្ថិតនៅលើចលនានៃគ្រឿងប្រដាប់បន្លឺសំឡេង និងលក្ខណ:សូរនៃភាសា ។

២- លក្ខណ:ខ្មែរនីយកម្ម សូរពាក្យបាលីសំស្ក្រឹត ។

៣- លក្ខណ:ប្រែប្រួលទៅតាមការអាន ការហៅត១គ្នា យូរ១ទៅ អាចឱ្យបាត់សូរដើម ឬ រូបដើមរបស់ពាក្យក៏មាន ។

៤- ការប្រែប្រួលសូរខ្លះបណ្តាលមកពីកំនត់ត្រាភាសាតាមសម័យកាល ដូចជាសម័យកណ្តាល

ដែលអក្ខរាវិរុទ្ធច្រើនសរសេរតែតាមសូរអាន ។ ហេតុនេះបានជាសំនេរពាក្យក៏មានការប្រែប្រួលដែរ ។

៥- ការប្រែប្រួលសូរខ្លះបណ្ដាលពីភាសាសំនងបំនុល ( ពាក្យកំចី) ។ ជួនកាលក៏បណ្ដាលមកពីភាសាបរទេសណាមួយ ដូចភាសាបារាំងជាដើម ដែលមានលំអៀងសូរបន្តិចបន្តួច ។

៦- ការប្រែប្រួលសូរខ្លះបណ្ដាលមកពីភាសាបាលីសំស្ក្រឹតក្លាយ ( ភាសាប្រាក្រិត) ។

ឯសូរភាសាបាលី សំស្ក្រឹតមួយចំនួន ជួនកាលគោរពតាមក្បួនសូរខ្មែរ ជួនកាលគោរពតាមក្បួនភាសាបាលី សំស្ក្រឹត ដែលជាហេតុធ្វើឱ្យមានការលំបាក ក្នុងការបង្កើតក្បួនវេយ្យាករណ៍ខ្មែរ ។

៧- ការប្រែប្រួលសូរពាក្យដែលបន្លឺខុសគ្នា រឺ ល្បៀងគ្នាបន្តិចបន្តួចទៅតាមតំបន់នីមួយៗនៃប្រទេសកម្ពុជា ។

៨- ការប្រែប្រួលទាំងសំនួរ និងសំនេរ ពីបុរាណរហូតមកដល់បច្ចុប្បន្ន ហើយដែលយើងទុកជាបង្អែកនៃការស្រាវជ្រាវក្នុងភាសាជាតិយើងនោះ គឺ សំនេរតាមសិលាចារឹកនេះឯង ។

ដូចនេះការប្រែប្រួលសូរពាក្យ រឺកន្សោមពាក្យបណ្ដាលឱ្យមានការប្រែប្រួលរូបពាក្យ ។ ការសិក្សាពីរូបពាក្យនាំយើងដឹងពីប្រភព ឬ ឫសគល់ពាក្យ និង ការវិវត្តន៍របស់ពាក្យ ក្នុងតំណាក់កាលនីមួយៗ។ ហេតុនេះសូរសំឡេងជាមូលដ្ឋាននៃការសិក្សាភាសា។ កាលណាបន្លឺពាក្យបានត្រឹមត្រូវ គឺសរសេរបានត្រឹមត្រូវដែរ។ អាស្រ័យហេតុនេះ ក្នុងការចងវចនានុក្រមខ្មែរលើកក្រោយ គួរគប្បីកំនត់សូរអានឱ្យបានត្រឹមត្រូវផងដែរ ជាពិសេសពាក្យបាលី សំស្ក្រឹត ដែលចូលមកក្នុងភាសាខ្មែរ។ តើយើងគួរកំណត់អានបែបណាឱ្យមានឯកភាព ? ។

## គន្ថនិទ្ទេស


១- ឃួន សុខម្ភ " ទំរង់សូរវិទ្យាខ្មែរ ភាគ ១-២ " គ.ស ១៩៧០
២- ត្រឹង ងា "ប្រវត្តិសាស្ត្រខ្មែរ " ភាគ II ១៩៧៣
៣- ត្រឹង ងា ( អ្នកស្រី ) " អរិយធម៌ខ្មែរ " ឆ្នាំ ១៩៧៤
៤- ប្រជុំរឿងព្រេងខ្មែរ ភាគ៥ និងភាគ៦ រោងពុម្ពរស្មីបដិវត្ត ១៩៩០
៥- ព្រឹត្តិប័ត្រ វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ លេខ១ ១៩៨៩
៦- មុញ -សារី សាស្ត្រាចារ្យ " សទ្ទានុក្រម ពាក្យខ្មែរបុរាណ " ប្រើប្រាស់ផ្ទៃក្នុង ១៩៨៩
៧- រ-គោវិទ វចនានុក្រមខ្មែរពិស្ដារ ១៩៩២
៨- សម្ដេចសង្ឃ ជួន ណាត " វចនានុក្រមខ្មែរ " ឆ្នាំ ១៩៦៧
៩- សឿ កេត្យា ( អ្នកស្រី) សាស្ត្រាចារ្យ " រៀនភាសាខ្មែរ " ថ្នាក់ដំបូង សំរាប់ជនបរទេស ភាគ១ ១៩៩២
១០- អ្នក បាង ( បង) " ល្បើកអង្គរ " Cedorex 1972
១១- អៀវ កើស " ភាសាខ្មែរ " ភាគ ១-២ ឆ្នាំ ១៩៦៧
១២- E. MENETRIER " ពាក្យខ្មែរ " Vocabulaire Cambodgien , Cedorex 1933
១៣- F.E. Huffman and Im Prum "Modern Spoken Cambodian "1977

## មាតិការបស់អត្ថបទ


១- ការប្រែប្រួលសូរសំឡេងក្នុងសូរវិទ្យា ............................................... ទំព័រ១០១

ក- អំពីសូរស្រៈ.................................................................................. -- ១០១

ក.១. ស្រៈ [អើ] > ស្រៈ [អេ] .................................................................. -- ១០២

ក.២- ពាក្យដែលកើតពីស្រៈ [អា] [I: ] កាលបើប្រកបនឹង ត ន ប ល ស
ត្រូវដូរជាសូរ [ អ៊ី ] = [ oa] .......................................................... -- ១០២

ក.៣- ស្រៈ [អ៊ុ] ប្រកបនឹង (ក) និង (ង) លឺសូរជា (ច) និង (ញ) ...................-- ១០២

ក.៤- ស្រៈខ្សោយ [ ] ......................................................................... -- ១០៣

ខ- អំពីសូរព្យញ្ជនៈ .............................................................................. -- ១០៣

២- ពាក្យដែលមានការប្រែប្រួលសូរ និង រូបរហូតដល់បាត់រីសដើម របស់ពាក្យ............ -- ១០៣

៣- ពាក្យជានាមដ្ឋានខ្លះដែលមានការប្រែប្រួលសូរ និង រូបរាងពាក្យ ស្ទើរតែពុំអាច
ពន្យល់បានតាមក្បួនវេយ្យាករណ៍ និង និរុត្តិវិទ្យា ........................................ -- ១០៤

៤- ពាក្យដែលមានសូររាលដោយសារកត់ត្រាតាមភាសាបរទេស .................................. -- ១០៥

៥- នៅមាននាមដ្ឋានជាច្រើនទៀតដែលក្នុងកន្សោមពាក្យនោះពាក្យដែលស្ថិតនៅកណ្ដាល
ត្រូវជ្រុះបាត់សូរ ក្នុងសំដីនិយាយ ........................................................ -- ១០៧

៦- សូរភាសាខ្មែរខ្លះទៀតក្លាយមកពីភាសាប្រាក្រិត ឬ ភាសាបាលីសំស្ក្រឹតក្លាយ បានន័យថា
យើងយកភាសាបាលី/សំស្ក្រឹតនោះ មកបំលែងទៅជាសូរខ្មែរ ដើម្បីសំរួលក្នុងការអាន.. -- ១០៧

៧- សូរភាសាខ្មែរប្រែប្រួលទៅតាមតំបន់នីមួយៗដែលទៅអនាគតអ្នកភាសាវិទ្យាត្រូវចុះទៅធ្វើ
ការស្ទាបស្ទង់ ( Survey = Songdage ) ដល់ទីកន្លែងផ្ទាល់ ដើម្បីធ្វើផែនទីភាសាវិទ្យា -- ១០៧

៨- សូរអានពាក្យបាលីសំស្ក្រឹតក្នុងភាសាខ្មែរ .................................................. -- ១០៩

ក- សូរអានប្រហាក់ប្រហែលគ្នា .............................................................. -- ១០៩

ខ- សូរអានបែបខុសគ្នា ........................................................................ -- ១០៩

៩- ការប្រែប្រួលសំនេរនិងសំនួរនៃភាសាខ្មែរបុរាណ ........................................ -- ១១០

ក- ការវិវត្តសូរស្រៈ ........................................................................... -- ១១០

ខ- ការវិវត្តសូរព្យញ្ជនៈ ........................................................................ -- ១១៥

គន្ថនិទ្ទេស ....................................................................................... -- ១១៩

ដកស្រង់ និង អត្ថាធិប្បាយដោយ បណ្ឌិត ឆែល ថោង

**ខទី៣** : លោកឆ្ងល់ថា ខ្ញុំដូចជាចង់គ្រុន យកមកសួរធ្វើអីអញ្ចឹងនោះ មានពូម្នាក់គាត់ក្ដៅខ្លួនបន្តិចបន្តួច ទូលបង្គំសួរថាម៉េច ម៉េចទៅពូដូចជាមិនសូវស្រួលខ្លួនឬ?

គាត់ឆ្លើយថា : "ខ្ញុំដូចជាចង់រកគ្រុន" បើតាមចម្លើយនេះ គឺពូនោះគាត់ចង់គ្រុន ប៉ុន្តែបើតាមពិតសំដីគ្រុននោះ គឺជម្ងឺគ្រុនគ្មានមនុស្សណាម្នាក់ចង់បានទេ។ បើដូច្នេះនោះ ពុំគួរសោះ សំណួរនោះគួរឆ្លើយដូចម្ដេចទៅវិញ អញ្ចឹងក៏សួរគ្នាដែរ នេះគេហៅសំដីសាមញ្ញទេតើ សំដីនោះគេហៅគ្រាមភាសា សាមញ្ញភាសាគេចង់និយាយទៅ ទៅតាមទំលាប់ទៅ គេនិយាយថា បើឱ្យត្រូវសរសេរសំបុត្រស្នាម គេថា ខ្ញុំថ្ងៃនេះមិនសូវស្រួលខ្លួន ដូចជារកកលគ្រុន។ រកគឺជិត១ទឹងគ្រុន ផ្ដួចផ្ដើមរកកលគ្រុន គេនិយាយថា រកកលមិនមែនចង់គ្រុនទេ គ្មានអ្នកណាចង់គ្រុនទេ យី! ដូចចង់គ្រុនថ្ងៃនេះ ចង់នឹង គឺគ្រុនតើដែលចង់នឹងគាត់មានចង់ឯណាគាត់ អាហ្នឹងដូចជាគាត់ចង់គ្រុន មិនអីទេ ដោះស្រាយបានប៉ុណ្ណឹង ថារកកលគ្រុន។

**ខទី៤** : ថាខ្ញុំទៅមើលពេទ្យ ខ្ញុំទៅចាក់ពេទ្យ ខ្ញុំទៅចាក់ថ្នាំ អាហ្នឹងក៏ពុំបាច់ដែរ ពាក្យហ្នឹងជាធម្មតាទេ បានជាគាត់និយាយអញ្ចឹង មានពូម្នាក់គាត់ឈឺ ហើយគាត់ហ្នឹងទូលព្រះបង្គំជាខ្ញុំសួរថា ម៉េចទៅពូជម្ងឺនេះបានជាស្បើយហើយឬនៅ? គាត់ឆ្លើយថា ខ្ញុំបានទៅមើលពេទ្យ ទៅចាក់ថ្នាំ ទៅចាក់ពេទ្យអស់៥០០រៀល ហើយមិនទាន់ជាសោះ។

ចម្លើយនេះច្បាស់ណាស់ គឺពូនោះមិនមែនឱ្យពេទ្យមើល មិនមែនឱ្យពេទ្យចាក់ មិនមែនយកថ្នាំមកចាក់ខ្លួនគាត់ទេ។ អ្នកដែលឆ្លើយរបៀបនេះសឹងតែគ្រប់គ្នា។ សឹងតែហ្នឹង ក៏ប្រើណាស់ឥឡូវ។ សឹងតែ គេប្រើដោយឡែក គេមិនមែនយកមកប្រើអញ្ចឹងទេ សូមលោក **ផាន់**ជ្រាប។ អាហ្នឹងគេថា ស្ទើរតែ១ ស្ទើរ ស្ទើរតែ។ ឥឡូវនេះស្អីក៏សឹង ស្អីសឹងទាំងអស់ សឹងហ្នឹងស្រុកអាត្មា ស្រុកស្រែ គេមិននិយាយទាំងសឹងផង សុទ្ធតែស៊ឹង១... ហ៊ឺ! ពិបាកស៊ឹងនឹងងាប់ហើយវ៉ើយ។ គឺស្ទើរ ពាក្យហ្នឹងគេថា "ស្ទើរ" រកកល។ ឯសឹងនេះ គេនិយាយអញ្ចេះ គេថា យើងសព្វថ្ងៃ កុំទៅប្រចាំគ្នា ថាអ្នកណាឡើយតិច អ្នកណាឡើយច្រើនអ្វី មកធ្វើការរួមគ្នានេះ វាពិបាកសឹងតែទាំងអស់គ្នា។ គឺថា សុទ្ធតែនឹងបានគេនិយាយសឹង សុទ្ធសឹងតែ។ គេសួរថា ចុះមានអីវ៉ាន់អីនៅក្នុងបន្ទប់នោះខ្លះ? មានសុទ្ធសឹងតែការុងដាក់អង្ករ អង្ករការុង អាហ្នឹង ត្រូវនិយាយសឹង។ ពាក្យនេះគេនិយាយរាយរងតាមធម្មតាទេ បើនិយាយក្នុងសំបុត្រស្នាម យកមកប្រើ វាច្រឡំប្រើថាស្ទើរ តែនោះទើបបានវាច្បាស់។ ពិបាកស្ទើរស្លាប់ ស្ទើរនោះ វាមិនពេញជាគ្រប់គ្រាន់ទេ គឺវាស្ទាក់ស្ទើរ ស្រេចនឹង

ប្រើចុះអត់អីទេ។ ពាក្យអស់នេះក៏មិនត្រូវគួរនឹងសួរទេ ទៅចាក់ពេទ្យ ចាក់អីនេះ អ្នកនិយាយទេ...។ បើអញ្ចឹង សុំអាត្មាពន្យល់មួយ ឱ្យជាហេតុថា "ទៅណាហ្នឹង ទេទៅបាយសិន បាយឯណាថ្ងៃនេះ? ទៅផ្សារ"។ រួចទៅបាយយ៉ាងម៉េច? សួរគ្នាថា : បាយហើយនៅ? អាហ្នឹងជាពាក្យគេកាត់ គឺថាទទួលទានឬ បរិភោគ ឬពិសារបាយហើយឬនៅ? ប៉ុន្តែដល់គេនិយាយខ្លីទៅ គេថាបាយហើយនៅ វាមានតែបាយឯណា មានសម្ល ម្ហូប នំចំណី គ្រប់ហ្នឹងបាយមួយមុខ ជាមេរបស់ភោជន។ អានេះស្រេចនឹងគេប្រើទេ ទំលាប់ស្តាប់គ្នាបាន ទៅណាឯកឧត្តម។ បើបារាំងច្រើនណាស់ដែរហ្នឹង។ ឯកឧត្តមមានប្រសាសន៍បន្តិចមើល បារាំងគេថាម៉េច? បាយ គេពុំនិយាយឱ្យគ្រប់។ អត់ចេះបារាំង បញ្ជាក់ឃើញថា បារាំងក៏មានដែរ ជាតិណាក៏មានដែរ។ **au lit** (អូលី)ទទួលទានដំណេក។ អូលី គឺថាឯគ្រែ នេះឃើញទេ គេមិនថាដេកទេ មិនទទួលទានដំណេកទេ។ គេថា"ឯគ្រែ" បើពុំនោះសោត គេនិយាយថា ទៅរកគ្រែ។ នោះគឺវាដេកហើយ ទៅដេកហើយ។ នេះស្រេចនឹងគេសន្មតប្រើទេ លោកកុំឆ្ងល់ឡើយ។ ប៉ុន្តែ អាត្មាមិនដែលនិយាយនឹងគេទេ។ អាត្មាបង្រៀន កូនចៅថាកុំឱ្យនិយាយអញ្ចឹង កុំឱ្យថា "ទៅចាក់ពេទ្យអញ្ចឹង"។ វាទៅជាខ្លួនឯងយកស្ទីទៅចាក់ឱ្យពេទ្យទៅ វិញ ទៅចាក់ពេទ្យ ចាក់ពេទ្យ ចាក់ថ្នាំ។ អាហ្នឹងមិនបាច់សួរទេ ទុកជាចប់ប៉ុណ្ណោះទៅចុះ សូមឱ្យលោក **អ៊ុំ ផាន់** យល់យ៉ាងខ្លីប៉ុណ្ណោះទៅចុះ អាត្មាដោះស្រាយនេះល្មមជាយល់ហើយ ពីព្រោះវាមិនមែនជាការក្រទេ ប៉ុន្តែ ការដែលសួរមកនេះ មិនបន្ទោសទេ។

ឥឡូវអាត្មាសុំមើលសំបុត្ររបស់អ្នកឧបាសិកាមួយនេះ គួរដោះស្រាយឱ្យគាត់ទៅ ព្រោះគាត់ដូចជា ចង់ដឹងណាស់។ ឧបាសិកានេះ... គាត់សរសេរដៃគាត់ តែអក្សរក្រមុំច១ ដូចជាកន្ទុយកូនឆ្មាអញ្ចឹង។ ប៉ុន្តែ គួរស្ញើចគាត់ណាស់! សរសេរត្រឹមត្រូវផងដែរ នៅខាងស្រុកត្បូងឃ្មុំ នៅផ្សារសួង។ ចាំអាត្មាមើលទៅ មិនគាត់ដាក់ថា ទូលព្រះបង្គំជាខ្ញុំនាម។ អាត្មាមិនដែលនិយាយទេ ពីព្រោះអានេះ ប៉ះមកលើពាក្យអស់ អញ្ចឹង។ ប៉ុន្តែសុំជំរាបអ្នក ... អ្នក ឧបាសិកា **យូលី** គេមិនដែលនិយាយទូលព្រះបង្គំទេអ្នក និយាយនឹងហ្លួង និយាយនឹងស្តេចអីក៏ដោយ គេថាខ្ញុំម្ចាស់ បើស្រីគេថា ខ្ញុំម្ចាស់ ប៉ុន្តែគាត់មិនសួរយល់រាជស័ព្ទ មិនបន្ទោសទេ។ សុំឱ្យចាំទៅទាំងអស់លោកអ្នកស្តាប់។ ស្រីគេមិនដែលនិយាយថា ទូលព្រះបង្គំទេ ទូលព្រះបង្គំ បើស្រី គេថា ខ្ញុំម្ចាស់ ហើយខ្លះ ទៅដាក់ថា ទូលព្រះបង្គំជាខ្ញុំម្ចាស់ទៅទៀត វាស្រួលណាស់។ ឧបាសិកា **យូលី**អាយុ៥២ឆ្នាំ ជាតិខ្មែរ អឺ... នៅខាងលិចផ្សារសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។ ខ្ញុំម្ចាស់ (អាត្មាថាតាមទៅចុះ) សូមបង្អោនកាយវាចាចិត្ត មើលអេ! មិនឃើញអក្សរគាត់ ល្អិត១មើលមិនច្បាស់គាត់សួរខ្លីទេ បានជាយកមក ដោះស្រាយឱ្យគាត់។ លំអោនកាយវាចាចិត្តគោរពដ៏ជ្រាលជ្រៅចំពោះសម្តេចជាទីគោរព និង សូមក្រាបទូល អំពីភាសាខ្មែរយើង ទាំងអស់ពុំដឹងជាធំ ឬក៏វាត្រង់សេចក្តីដែលកូន ក្មួយហៅថា ឪពុកធំ និង ម្តាយធំ ថា

"ធំៗ" ទាំងអស់ ពុំដឹងថាធំស្រី ឬធំប្រុស ខាងម្ដាយ ឬខាងឪពុកទេ។ ចំណែក អ្នកនៅខាងស្រុកស្រែចំការច្រើនតែប្រើពាក្យ "ធំ" ពុំសូវមានពាក្យថា "អ៊ំ" ទេ (គាត់ដាក់ថាអ៊ំ) ដូចអ្នកនៅទីក្រុងទេ។ ខ្ញុំម្ចាស់ឆ្ងល់ណាស់ត្រង់ពាក្យ "អ៊ំ" នេះហេតុ ហេតុដូចម្ដេចចាស់ទុំពុំយកមកប្រើឱ្យបានច្រើន ដូចពាក្យ "ធំ" នេះផង។ ត្រង់ពាក្យនេះមួយណាប្រសើរជាងណា? ហេតុដូចម្ដេចបានជា "មា" ហៅថា "ពូ" ទៅវិញ? ចំពោះមានិងមីងហៅថា "មីងៗ" ពុំដឹងជាប្អូនម្ដាយទេ។ ចំណែកខាងបងថ្លៃប្រុស និង បងថ្លៃស្រី ក៏ហៅថា "អ្នក" ដូចគ្នាពុំដឹងថាបងថ្លៃនោះខាងណាទេ។ ខាងប្ដី ឬ ខាងប្រពន្ធក៏ពុំដឹង។ ម្យ៉ាងទៀតអស់លោកប្រុសៗហៅប្រពន្ធថា "អូន" (គាត់ឆ្ងល់អញ្ចឹង) ហើយប្រពន្ធហៅប្ដីថា "បង"។ នេះជាពាក្យល្អហើយ តែដូចជាច្រឡំថាបងប្អូនបង្កើត ច្រឡំថាបងប្អូនដែលកើតចេញពីពោះម្ដាយតែមួយ។ ខ្ញុំម្ចាស់សរសេរសំបុត្រនេះទាំងសេចក្ដីល្ងង់ខ្លៅពុំយល់ពាក្យរាក់ជ្រៅសោះ។ សេចក្ដីដូចក្រាបបង្គំទូលថ្វាយខាងលើនេះ សូមសម្ដេចជាម្ចាស់ទ្រង់វែកញែកពន្យល់ខ្ញុំម្ចាស់ឱ្យអស់សេចក្ដីសង្ស័យឱ្យទាន។ យី! គាត់សួរអញ្ចឹងតើ។ នៃអ្នក **យូលី** សួរអញ្ចឹង គាត់ឆ្ងល់មែនហើយ ប៉ុន្តែអាត្មាសុំដោះស្រាយទៅចុះ. នេះគឺស្រេចនឹងគេសន្មតហៅទេ ពីព្រោះខ្មែរយើងមិនដូចជាតិដទៃ មិនដូចបាលីទេ បាលីតែកាលគេឮឡើង គេដឹងថា ខាងឪពុក ឬខាងម្ដាយតែម្ដង រួចភាសាដទៃដូចចិន ដូចជាតិណាក៏គេ គេមានអញ្ចឹងច្រើន តែខ្មែរបើមីងនោះ គេសួរថា មីងនេះ ប្អូនឪ ឬប្អូនម៉ែ ថា មីងខាងម្ដាយ មីងខាងឪពុក មាខាងម្ដាយ មាខាងឪពុក អានោះគេដាក់បន្ថែម។ អាត្មាស្មានទៅ បុរាណយើងពីដើម មិនមែនល្ងង់សព្វបើប៉ុណ្ណោះទេ ប៉ុន្តែលោកមិនចង់ឱ្យយើងពិបាក ក៏គេហៅអញ្ចឹងតែម្ដងទៅ។ ឯពាក្យថា "អ៊ំ" ថា "អំ" ថា "អ៊ុំ" នេះ ពាក្យនេះទើបនឹងកើតមកក្នុងសម័យតមកក្នុងក្រុងទេ។ អ្នកស្រុកក្រៅគេពុំសូវដែលប្រើ ប៉ុន្តែបើ និយាយថាអី ថា "ឪពុកធំ" "ម្ដាយធំ" បើអ្នកគេរើសអើងគេថា "ហ៊ឺ សំដីអ្នកស្រែ"។ តាមការពិតទៅ វាពុំដឹងអ្នកស្រែអ្នកភ្នំពេញឯណាទេ។ ពាក្យ "អ៊ំ". "អ៊ុំ" នោះខ្លះហៅ "អ៊ុំ" ខ្លះហៅ "អ៊ំ" គេហៅពាក្យទំយើ ពាក្យលើកទំយើថ្នម។ ឯធំនោះគឺធំហើយ ប៉ុន្តែមិនហៅថាធំ ហៅ "អ៊ុំ" ខ្លះអ៊ុំ ខ្លះអ៊ំទៅ នោះពាក្យទំយើ ពាក្យទំយើនោះ ដូចគេនិយាយមនុស្សចាស់និយាយនឹងក្មេងតូចតាមអញ្ចឹង។ អាស្រ័យបរិភោគ ស៊ី ញុំា "ញុំា" នោះ គឺពាក្យទំយើ គេនិយាយតែក្មេងតូចៗទេ។ ទើបចេះស្ដី ឡិឡក់បន្តិចបន្តួចនោះ ម៉ែបងប្អូន នាងញុំាទៅ កូនញុំានេះទៅ។ តែដល់ពេញក្រមុំហើយ លែងញុំាហើយ។ រួចបើដេក គេថាគេង ហ្នឹងគេហៅពាក្យទំយើ ពាក្យថ្នម កាលណាវានៅតូច គេងទៅកូនគេងទៅ។ ហ្នឹងកាលវានៅតូច ចុះបើដល់វាធំហើយ កំលោះហើយ យី! អញទៅរកគេងសិនហើយ ដែលគេថានោះអាត្មាស្មានទៅទេ ដែលគេនិយាយថាគេងៗនោះ គេថាឱ្យគេមានអាយុវែង ព្រោះថាគេមិនចង់ចាស់។ ញុំាអីនោះ គេថាឱ្យគេនៅតែក្មេងអញ្ចឹង នេះបកស្រាយ

តាមយល់ទេ។ អញ្ជើញគេងទៅ! ក្មេងនិយាយនឹងចាស់ ពាក្យនឹងក៏ស្រេចនឹងគេប្រើចុះ យើងមិនបន្ទោសទេ ប៉ុន្តែគេហៅថាថ្នមវាហួស។ ដល់តា គាត់ថា "តាញុំបាយហើយ នៅតា"? តាគាត់មិនថាអីដែរ គាត់ចង់រស់យូរដែរ គាត់ថាវាហៅឯងដូចកូនក្មេងអញ្ចឹង។ បើតានោះ គាត់មានគំនិតជ្រៅ គាត់ថា វាហៅឯងដូចកូនក្មេង គាត់ថាយើ! ថាឱ្យឯងក្មេង វាឱ្យ ឱ្យឯងអាយុវែងឯតើ។ ប៉ុន្តែបើនិយាយតាមការពិតក្នុងសំបុត្រស្នាមគេមិនប្រើសោះហើយ គេហៅពាក្យទំយើ ពាក្យម៉្ងៃម៉្ងៃ។ ពាក្យហ្នឹង គេហៅពាក្យម៉្ងៃម៉្ងៃ មិនមែនតែមួយប៉ុណ្ណោះទេ បើបៅ ខ្លះថាអឹម ខ្លះថាប៉ឹម ទៅវាស្រេចនឹងគេសន្មតទេ។ អ្នកកុំឆ្ងល់អីអ្នក **យូលី** កុំឆ្ងល់អ្នកចង់និយាយម៉េចនិយាយទៅចុះ។ ប៉ុន្តែយើងធ្លាប់ ថា "ធំ" ធំទៅ។ រួចត្រង់ខាងម្ដាយខាងឪពុក ទៅមិនរួចទេ។ បើបាលីមាន"មាតុល" គឺមា ខាងម្ដាយ ឪពុកធំខាងម្ដាយ អញ្ចឹងដែរ បើឱ្យច្បាស់គេថា"មហាមាតុល" គឺឪពុកធំហើយហ្នឹងមើលថា "មាតុលៈ" ទទេគេថាមា។ ចុះបើជាស្ត្រីវិញ គឺ "មាតុច្ឆា"។ "មាតុច្ឆា" គឺម្ដាយមីងខាងម្ដាយ បើខាងឪពុកគឺ "បិតុច្ឆា" "បិតុច្ឆា" គឺម្ដាយមីងខាងឪពុក។ ហើយ "មាតុលៈ" មាខាងម្ដាយ "មហាមាតុលៈ" គឺឪពុកធំខាងម្ដាយ បើខាងឪពុក"បិតុលៈ"។ បានជាបុរាណគេហៅ ( ប៊ុ-ដុ លៈ ) ទេ គេថាបិដុលៈ ព្រះបិតុលៈ នោះគឺពាក្យរាជស័ព្ទ គឺថាពាក្យក្សត្រនោះ លោកត្រូវឪពុកធំខាងបិតា។ រួចឆ្ងល់មួយទៀតថា ពាក្យ"អ៊ុំ" នោះអ្នកគាត់ឆ្ងល់នឹងពាក្យ"អ៊ុំ" អន្តើ។ ឥឡូវអាត្មាដោះស្រាយប៉ុណ្ណឹងហើយ រួចត្រង់មា ត្រង់មីង នេហើយអ្នកសរសេរត្រូវមានខ្លះសរសេរ "មីញ" មីង អាន"មីង" អាន( មីញ ) មិនដឹងជាយ៉ាងម៉េច? មីងៗនោះ អាហ្នឹងដល់ត្រង់ហ្នឹងហេ! អាត្មាសុំថាមួយទៀតអំពីពាក្យ "មេ" និង "មី" ។ អ្នកភ្នំពេញនេះនិយាយមីច្រើនណាស់ មីនេះ មីនោះ មីឯង។ យ៉ាងម៉េចក៏ទៅជាមីទៅវិញ?... គឺមេបា។ អាត្មាដូចជាមិនចេះនិយាយតែម្ដង តាំងតែពីកាលក្មេងចេះស្ដីឡើង និយាយតែ"មេ" អញ្ចឹង។ បើកូនចៅគេហៅថា នែ! មីនេះមកណេះ គេមិនចេញឈ្មោះទេ ដល់វាស្និទ្ធជិតនោះ នេះ"មី" អត់ទេ មីនោះ តែមិនចាប់ខុសចាប់អីទេ ស្រេចនឹងប្រើចុះ។ រួចបើគេចង់និយាយថា កូនប្រុស កូនស្រី ដូនតា ដល់ដូននោះ គឺថាវាច្បាស់លាស់ថា ជាជីដូនហើយ ប៉ុន្តែពុំដឹងថាខាងឪពុក ឬ ខាងម្ដាយ តែអញ្ចឹង។ បុរាណគ្មានពាក្យយាយទេ មានតែដូន មានឈ្មោះស្រុក មានឈ្មោះស្រែ មានឈ្មោះភូមិអីសព្វថ្ងៃនេះ ដូចជា ដូនស្ដើង ព្រែកតាទែន ព្រែកដូនស្ដើងអីហ្នឹង។ គឺពីដើមគ្មានពាក្យយាយទេ យាយនេះទើបនឹងកើតខាងក្រោយទេ។ យាយហ្នឹង វាដោយមកពីភាសាជិតខាងយើង ដូចលាវ ដូចថៃជាដើម។ គេនិយាយប៉ុន្តែមិនច្រឡំទេថា "ពូយ៉ា តាយ៉ាយ" ពូយ៉ា តាយ៉ាយ គឺជីដូនជីតាខាងឪពុកខាងម្ដាយ គេហៅខុសគ្នា។ រួចលាវគេថា "ពូញ៉ា តាញ៉ាយ" គេហៅអញ្ចឹងទេ។ រួចយាយនោះ វាជាប់មកពីយ៉ាយៗនោះ យើងក៏យកមកប្រើខ្លះទៅ។ ឯពិតជាពាក្យខ្មែរបុរាណគេមិនដែលហៅយាយទេ

គេហៅតែដូន។ អញ្ជើញទៅណាដូន បើគួរសមបន្តិចទៅ អញ្ជើញទៅ ណាជីដូន? ឆ្លើយក៏ទាំងអញ្ចេះជីដូន។ ពាក្យថាជីដូនគឺ យាយនោះគាត់ចាស់ហើយគាត់កាន់សីលស្លៀកស ធ្វើដូចជាយាយជីអញ្ចឹង អាហ្នឹងគេហៅថា"ជីដូន" ជីនោះ ហ្នឹងជាពាក្យគោរពល្អណាស់។ បើបួសនេនសឹកមកហៅ"ជី" ឈ្មោះអីថាឈ្មោះ "ជីទេព" ឈ្មោះទេពហៅជីទេព។ បើបួសភិក្ខុ សឹកមកហៅថា "អ្នកទេព" រួចបើទើបនឹងសឹកថ្មីៗ ហៅថា "អនិ្ទត"។ អនិ្ទតមកពីពាក្យថា"បណ្ឌិត" ពីព្រោះគេថាពីរៀនសូត្រ ចេះដឹង ជាអ្នកមានការជ្រៅជ្រះ ហើយបានគេហៅបណ្ឌិត។ បណ្ឌិតហ្នឹងគ្មានបានដល់ថ្នាក់ **Doctor** "ដុកទ័រ" ទេ។ បណ្ឌិតហ្នឹងគឺថាចេះតែហៅទៅ ចង់អាត្មានសរសេរអក្សរមិនត្រូវក៏បណ្ឌិតដែរ បានជាចាស់ទុំហៅ បណ្ឌិត ក្លាយមកជាអនិ្ទត។ នែ!អ្នកអនិ្ទតមកពីណាហ្នឹង? ហ្នឹង គឺបួសភិក្ខុក៏ដោយ នេនក៏ដោយ។ បើទើបសឹកថ្មីៗ គេហៅអនិ្ទត។ ចុះបើហៅរូបរួម ហៅជី ហៅជីសមណៈ ជីព្រាហ្មណ៍ ដូនជី តាជី យាយជីគឺថា អ្នកត្រឹមត្រូវកាន់សីល អ្នកប្រព្រឹត្តត្រឹមត្រូវ គេហៅជីទាំងអស់។ រួចបានជាអនិ្ទតនេននោះ គេហៅថាជីព្រោះថាវាក្មេងទេ ប៉ុន្តែវាសឹកមក វាទើបនឹងសឹកពីផ្នួស វាត្រឹមត្រូវជាងក្មេងឯទៀត បានជាគេហៅជី។ ឥឡូវបាត់ហើយ នៅតែយាយជី តាជីនៅមាន បានជាពាក្យ ថាម៉េច? ថា កុំដើរពាកកុន កុំកាត់...ទេ អីយ៉ាខុសទេ "សមណៈជនជី កុំឱ្យក្តីត្រូវ" ពាក្យព្រះរាជសម្ភារក្រមព្រះរាជនិពន្ធ។ ព្រះរាជសម្ភារថា "សមណៈជនជី កុំឱ្យក្តីត្រូវ កុំងឿងដោយខ្យល់ កុំឱនពាក្យពល កុំខ្វល់ដោយស្រី កុំកាន់ពិសយង់ គប់នូវស្រ្តី សមណៈជនជី កុំឱ្យក្តីត្រូវ" ត្រង់នេះបានសេចក្តីថា "យាយជី តាបស លោកនេន លោកភិក្ខុ អ្នកបួស ប៉ុន្មានដែលហៅថា"សមណៈជន"នោះ គឺកុំទៅកើតក្តី កុំយកខ្លួនទៅពាល់ កុំឈ្លោះនឹងពួកហ្នឹងបានជាលោកថា "សាមណៈជនជី កុំឱ្យក្តីត្រូវ" កុំទៅរវើកនឹងលោក។ បុរាណគេថាភ្លើង។ បើអាណាចង់ប្តឹងអំពីលោក សង្ឃឈ្លោះប្រកែកអំពីនេះពីនោះ គេថា នាងអើយកុំពាល់ភ្លើងរើយក្តៅ... ណាំ។ ហ្នឹងគេ គេនិយាយ អីបុណ្យបាបវិញ គេថា "ចុះនរក...ណាំ" កុំទៅលេងនឹងពួកចីវរធំៗហ្នឹង។ ហ្នឹងពាក្យបុរាណ អស់ហើយអ្នក អាត្មាដោះស្រាយ ឱ្យអ្នកប៉ុណ្ណឹងហើយ ល្មមយល់ហើយ... ហាំ!

ហាំ! នៅអ្នកណាទៀត? នៅ ទៅបន្តិចទៀត នាងមួយនេះ កញ្ញានេះ... ចប់ហើយ កញ្ញានេះខ្លីៗទេ នៅកញ្ញាអីនេះ។ នេះដាក់"ទូលព្រះបង្គំនាងខ្ញុំម្ចាស់" នាងកញ្ញាយល់ខុសទេ... គេមិនដែលប្រើអញ្ចឹង ឈ្មោះ **ឥន្ទ ចាំ** ជាសិស្សថ្នាក់ទី២ក នៃវិទ្យាល័យព្រះស៊ីសុវត្ថិ។ ឥឡូវអាត្មាថា ខ្ញុំម្ចាស់ទៅចុះ លុប "ទូលបង្គំនាងខ្ញុំ" ចេញ។ ទូលព្រះបង្គំ ជាខ្ញុំ នាងខ្ញុំម្ចាស់... នែ!គេមិនដែលនិយាយទូលព្រះបង្គំទេ នាងឯងកុំនិយាយនឹងព្រះអង្គម្ចាស់ នឹងស្តេចនឹងអី ថាទូលបង្គំ គេថា ខ្ញុំម្ចាស់ អាត្មាប្រាប់ទៅចុះ។ ខ្ញុំម្ចាស់ឈ្មោះ **ឥន្ទ ចាំ** ជាសិស្ស ថ្នាក់ទី២ក នៃវិទ្យាល័យព្រះស៊ីសុវត្ថិ។ ខ្ញុំម្ចាស់មានសេចក្តីឆ្ងល់អំពីពាក្យមួយម៉ាត់ដែលហៅថា

"ពិសេស" និង "វិសេស" ដែល ក្រសួងឃោសនាការធ្លាប់តែផ្សាយតាមវិទ្យុជាញឹកញាប់។ ពាក្យនេះតាមសេចក្តីយល់របស់ខ្ញុំម្ចាស់ គួរទុកប្រើចំពោះពាក្យសម្តី វីរបុរសអង្គណាមួយ ដែលជាកំពូលនៃរដ្ឋ។ ឧទាហរណ៍ដូចជា : ព្រះរាជឱង្ការនៃសម្តេចព្រះប្រមុខរដ្ឋទើបសម មិនត្រូវយកមកប្រើជាសាធារណៈ ច្របូកច្របល់គ្នាឡើយ។ ដូចសព្វថ្ងៃនេះ ក្រសួងឃោសនាការតែងតែផ្សាយជាពត៌មាន ឮដំណឹងវិសេស ឬដំណឹងពិសេសរោងភាពយន្តសូរិយាលេងរឿងឥណ្ឌា រឿង"រស្មីចន្ទ្រាទូលតាពូង"។ ទេ! នាងកញ្ញាសរសេរខុសទេ។ គេមិនថាទូលតាពូងទេ មិនមែនតាឈ្មោះពូងគាត់ធ្វើទូលនោះឯណា។ មិនមែនទូលរបស់តាពូងទេ ទូលទំពូងពីព្រោះ ពីដើមវាមានដើមទំពូងដុះនៅឯហ្នឹង។ អាត្មានៅពីសាមណេរ លោកគ្រូប្រើទៅរកសំបកទំពូងនៅឯហ្នឹង។ ចាំច្បាស់ណាស់ ឥឡូវទៅជា "តាពូង តាពូង" អស់។ ទូលទំពូង គឺដើមទំពូង វាដុះនៅហ្នឹងពីដើម។ ឥឡូវថាទំពូងទៅចុះ។ ទូលទំពូងលេងរឿង "ព្រះជិនវង្ស" ឬវិថីទឹកឃ្មុំ មានបើកសាលារៀន កាត់ដេរ។ល។ ជាដើម។ តើហេតុអ្វីបានជា ក្រសួងឃោសនាការ ចេះតែផ្សាយពត៌មានឬដំណឹងពិសេស បើនិយាយពីរឿងកុនល្ខោនឯណោះទៅវិញ។ ខ្ញុំម្ចាស់ឮភ្ញាម១ ស្មានថាព្រះរាជឱង្ការនៃសម្តេចសហជីវិន។ អាត្មាមិនមើលពាក្យនាងកញ្ញាឯងអស់ទេ តែខំខ្លាចគេ...ពាក្យវាខ្លាំង១ អាត្មារំលងចោល។ ពាក្យនេះមានខ្លះដូចបែបកំសោក គំរោកខ្លាំងណាស់។ រួចទៅបន្ទោសលើឃោសនាការជាតិផង។ នែ! នែ! លោកឃោសនាការជាតិ នែនាងនោះបន្ទោសហើយ។ នែ! មើលខាងនេះទៀត ហេតុនេះសូមសម្តេចជាម្ចាស់ ទ្រង់មេត្តាយកពាក្យមួយម៉ាត់នេះទៅដាក់ក្នុងរបៀបវារៈ ប្រជុំអក្សរសាស្ត្រ ពិភាក្សាសំរេចឱ្យខ្ញុំម្ចាស់ផង។ វិសេស និងពិសេស ហ្នឹងនាងកុំឆ្ងល់ នាង **ឥន្ទ ចាំ** កុំឆ្ងល់....កំពុងរៀនផង។ អាត្មាសុំពន្យល់ពាក្យនេះតែមួយទេ អាត្មានឹងពន្យល់។ ពិសេស និងវិសេសហ្នឹង បើប្រែទៅវាមានច្រើនយ៉ាងណាស់មកអំពីរូបស័ព្ទដើម មកអំពី វិ ហើយនិង សេសៈ។ វិ ហ្នឹងគឺជាបុព្វបទ បាលីគេហៅថាបុព្វបទប្រែថាបទមកដាក់ ខាងដើមជាគូឧបសគ្គដែលបារាំងហៅ៉ា Préfix។ អាត្មាមិនសូវចេះបារាំង តែបើមួយម៉ាត់ មួយម៉ាត់ Préfix គេដាក់មក វិ ហើយនិងសេសៈ...វិ នោះប្រែថាផ្សេង១ ប្រែថា ជាក់ស្តែងប្រែថាណាស់ណា អីក៏បានដែរ។ វិ នេះជាសេចក្តីច្រើនណាស់។ រួចកាលណា វិ នោះ វានៅនឹងសេស"សេ-សៈ" សេស ប្រែថាសល់ ថាសំណល់ វាអញ្ចេះទៅវិញទេតើ។ ប៉ុន្តែបើ វិ វាមកនៅពីលើជាមួយនិង សេសទៅជាប្រែថាថ្លៃថ្លា ថាខ្ពង់ខ្ពស់ ថាប្លែក អញ្ចេះទៅវិញ។ សេស និង វិសេស ហ្នឹង ក៏ខ្មែរយកមកប្រើដើម្បីអោយបានទៅជាពីរន័យ។ គេយក "វ" ជា "ព" ទៅជាពិសេស(ពិសេ-សៈ) គេហៅថា ពិសេស "ពិ-សែស" មួយនៅជាវិសេស (វិ-សែស) ពាក្យថាវិសេស គេនិយាយពីរបស់ទ្រព្យអី ឬស្រុកទេសឬអ្វីដែលវាថ្លៃថ្លា វាខ្ពង់ខ្ពស់ វាមានតែមួយ សុទ្ធតែល្អហ្នឹង គេហៅថាវិសេស។ ពុំនោះសោត គម្ពីរដីកា

សៀវភៅច្បាប់ណាដែលវាក្រៅផ្លូវការ បើខាងពុទ្ធសាសនា គឺក្រៅពីព្រះត្រៃបិតក ក្រៅពីអដ្ឋកថា ពី commentaire របស់ព្រះត្រៃបិតក។ គម្ពីរនោះឯង គេហៅព្រះករណីវិសេស។ បើនិយាយជាពាក្យខ្មែរស្រលុកគេហៅថា "ព្រះករណីវិសេស" ព្រះករណៈហ្នឹង គឺព្រះករណីវិសេស ជាគម្ពីរ ដែលតែងឡើងក្រោយដោយវោហាររបស់អ្នកតែង មិនអាងដោយគម្ពីរដីកាអីគ្រប់គ្រាន់ទេ។ គេយកវោហារ យកមតិយោបល់ ដែលហៅអត្តនោម័តិនោះ យោបល់របស់ខ្លួនគេ យកមកតែង អាហ្នឹងគេហៅគម្ពីរវិសេសដែរ។ ប៉ុន្តែខ្មែរយកមកប្រើ គួរឱ្យឆ្ងល់ដែរ ពាក្យតែដដែលគ្រាន់តែយក "វ" ជា "ព" ទៅជា ពិសេស បានសេចក្ដីខុសគ្នានឹងពាក្យថា វិសេស។ ពាក្យនេះគេប្រើស្ទើរតែច្រើនណាស់ វាដូចជាគេឆ្លើយព្រះករុណា "ករុ-ណា" ជាម្ចាស់ជីវិតថា ព្រះករុណាថ្លៃវិសេស ព្រះករុណាថ្លៃវិសេសហ្នឹង ឆ្លើយថាឈ្មោះអី ថា នៃដូង! ដូងឯងមកណេះ ព្រះករុណាថ្លៃវិសេស ព្រះករុណាវិសេស អញ្ចេះក៏បាន។ ហ្នឹងគឺថាលើកហួងលើកព្រះអង្គហ្នឹង ថាជាព្រះករុណាហ្នឹង ហៅថា ព្រះករុណាហ្នឹងថាព្រះអង្គមានសេចក្ដីថា អាណិតគេ។ ដល់វាអស់ពី ករុណា ទៅជា "ព្រះករុ-ណា"ទៅ។ ថ្លៃវិសេសនោះ គឺបានសេចក្ដីថា ព្រះអង្គមានតម្លៃខ្ពង់ខ្ពស់ក្រៃលែង ជាងអ្នកដទៃ។ ព្រះករុណាថ្លៃវិសេស ជាពាក្យសទ្ទតរាជស័ព្ទ ។ ចុះបើមកជាពិសេសវិញប្រែថា ប្លែកដែរ គេបំប្លែងមកដើម្បីឱ្យមានសេចក្ដីថា ជាបច្ចេកទេស ថាជាដោយឡែក ថាជាអីអញ្ចេះទៅវិញ។ រួចអាត្មាសុំទាញឧទាហរណ៍ ដែលប្រើសព្វថ្ងៃនេះ ឧបមាថា ឯកឧត្តមនោះលោកមានរថយន្តបីគ្រឿង។ រថយន្តមួយនោះ ស៊ីត្រូអែន Citroën នោះ លោកទិញមកដើម្បីឱ្យកូនចៅប្រើទៅផ្សារទៅផ្សារឆក់កណ្ដៀតនាយអាយ តាមតែអ្នកណា ប្រើខ្លះអញ្ចឹងទៅ អាហ្នឹង គេហៅថារថយន្តសាមញ្ញ។ មានរថយន្តមួយនោះលោកប្រើផ្ទាល់ខ្លួនលោក គឺថាលោកទៅណាលោកប្រើតាមធម្មតា ទៅធ្វើការទៅការិយាល័យ ទៅប៊ុយរ៉ូ bureau លោក លោកជិះអាហ្នឹងទៅ។ អានេះជារថយន្តផ្ទាល់ខ្លួនលោក។ ន៎!មាន រថយន្តមួយនោះថ្លៃថ្នាបន្តិចមិនសូវប្រើទេ គឺលោកប្រើសំរាប់ចេញមុខចេញមាត់ ដូចទៅ កាន់ទីប្រជុំធំ ឬទៅគាល់ព្រះករុណាទៅព្រះរាជវាំងអី លោកប្រើរថហ្នឹង គេហៅរថយន្តពិសេស spécial អីឯកឧត្តម អើត្រូវនឹងបារាំង spécial speciaux ហ្នឹងហើយ។ អាហ្នឹង គេហៅពិសេស។

## សិក្សាអត្ថបទទី២ ខ្មែរអាត់ទី១

បញ្ហាដែលលើកយកមកពិចារណា ក្នុងពេលនេះគឺមាន :

បញ្ហាទី១- "ខ្ញុំទៅចាក់ពេទ្យ", "ទៅបាយ" និង "បាយឯណា"

បញ្ហាទី២- ការប្រើពាក្យ យាយ តា ជីដូន ជីតា

បញ្ហាទី៣- ប្រភពពាក្យ បណ្ឌិត និង អនិ្ទត

បញ្ហាទី៤- ការប្រើពាក្យ មេ និង មី

**បញ្ហាទី១- "ខ្ញុំទៅចាក់ពេទ្យ"**

អាចមានន័យពីរយ៉ាង គឺន័យតាមការបកស្រាយប្រយោគ តាមក្បួនវេយ្យាករណ៍ និងន័យរបស់អ្នកស្រុកប្រើប្រាស់ ដែលជាភាសានិយាយ ។

ន័យទី១គឺៈ ខ្ញុំជាបទប្រធានរបស់កិរិយាសព្ទ ទៅចាក់ ចំណែកឯពេទ្យ ជាបទកម្ម គឺរងនូវអំពើ ចាក់របស់ប្រធាន ។ ប្រយោគថា "ខ្ញុំទៅចាក់ពេទ្យ" គឺមិនអាចថែមថយ ពាក្យអ្វីផ្សេងទៀតបានទេ ។

ន័យទី២គឺៈ ខ្ញុំទៅរកពេទ្យ ខ្ញុំទៅជួបពេទ្យ ដើម្បីចាក់ថ្នាំ ឬដើម្បីអោយគ្រូពេទ្យ ចាក់ថ្នាំអោយ ។ ប្រយោគថា "ខ្ញុំទៅចាក់ពេទ្យ" ប្រើក្នុងន័យនេះ វេយ្យាករណ៍ប្រពៃណី មិនអាចមានវិធីធ្វើវិភាគពន្យល់បានទេ ។

យើងអាចចោទសួរដោយប្រយោលថាៈ នៅតាមផ្លូវទៅមន្ទីរពេទ្យ ពេលដែលបងប្អូន សាកសួរថា "បងអើយទៅណា?" អ្នកជម្ងឺនោះ ឆ្លើយថា "ខ្ញុំទៅចាក់ពេទ្យ" ។ យើងចង់ដឹងថា តើអ្នកជម្ងឺដដែលនេះ នឹងប្រើប្រយោគបែបខាងលើនេះ ជាចម្លើយ ចំពោះគ្រូពេទ្យដែរឬទេ នៅពេលគាត់ជួបគ្រូពេទ្យ ដែលសួរសំនួរដដែលនេះ ។ ចម្លើយអាចមានពីរបែប :

បែបទី១- "ខ្ញុំមកចាក់ពេទ្យ"

បែបទី២- ដោយមានការគួរសម "ខ្ញុំមកជួបគ្រូពេទ្យ ដើម្បីចាក់ថ្នាំ" រឺ "ខ្ញុំមកមន្ទីរពេទ្យ ដើម្បីអោយគ្រូពេទ្យចាក់ថ្នាំអោយ ។

**សម្មតិកម្មទី១:**

បើយើងសន្មតយកន័យ តាមចម្លើយបែបទី២ យើងអាចធ្វើសមត្ថិកម្មថាៈ ប្រយោគនេះ មានន័យផ្សេង គឺន័យបង្កប់ជាជម្រៅ "ន័យផ្ទៃក្រោម" ដែលពាក្យពេចន៍ របស់ប្រយោគ "ខ្ញុំទៅចាក់ពេទ្យ" ពុំបានឆ្លុះ បញ្ចាំង ។ ក្នុងន័យនេះ យើងអាចនិយាយថា ប្រយោគ "ខ្ញុំទៅចាក់ពេទ្យ" ជាប្រយោគបកស្រាយសម្ពន្ធផ្ទៃលើ ដែលមានសម្ពន្ធផ្ទៃក្រោមមួយទៀត សំរាប់ន័យផ្ទៃក្រោម ។

**សម្មតិកម្មទី២:**

បើអ្នកជម្ងឺ ប្រើចម្លើយបែបទី២ យើងអាចយល់ពីព្រំដែន នៃការប្រើប្រាស់ប្រយោគ "ខ្ញុំទៅចាក់ពេទ្យ" ថាជាភាសាសាមញ្ញ ដែលគេនិយមប្រើប្រាស់ត្រឹមតែនៅក្រៅរបងមន្ទីរពេទ្យ ក្រៅផ្លូវការ ក្រៅស្ថាប័ន របស់មន្ទីរពេទ្យ និងស្ថាប័នផ្សេងៗទៀតរបស់រដ្ឋ ។

**សម្មតិកម្មទី៧:**

តើប្រយោគ "ខ្ញុំទៅចាក់ពេទ្យ" ជាប្រយោគកម្មវាចកៈ រឺ កត្តុវាចក? បើសំអាងលើរូបរាងប្រយោគជាសម្ពន្ធផ្ទៃលើ ក្នុងទម្រង់ កន្សោមនាម + កន្សោមកិរិយា ហើយក្នុងនោះ មានបទប្រធាន "ធ្វើនូវអំពើ" កិរិយាសកម្ម និងបទកម្មរងនូវអំពើផង យើងអាចសន្និដ្ឋានថា ប្រយោគនេះ ជាប្រយោគកត្តុវាចកៈ។ បើសំអាងលើន័យរបស់ប្រយោគ ដែលអ្នកប្រើប្រាស់ មានបំណងអោយន័យនោះ វាអាចជាប្រយោគកម្មវាចកៈ។ វាប្រហាក់ប្រហែល ទៅនឹងប្រយោគថា "ខ្ញុំទៅចាក់ថ្នាំ" "ខ្ញុំទៅចាប់សរសៃ" "ខ្ញុំទៅកាត់សក់" "ខ្ញុំទៅអ៊ុតសក់" ។ល។

**"ទេទៅបាយសិន បាយឯណាថ្ងៃនេះ?:**

"ទៅបាយសិន និងបាយឯណា?" មានន័យថា ស៊ីបាយ ហូបបាយ ទទួលទានបាយ...បើសំអាងយកវេយ្យាករណ៍ ជាមធ្យោបាយវែកញែក "ទៅបាយ" និង "បាយឯណា" អាចពន្យល់ជាពីរបែប :

ទី១: "ទៅបាយ" និង "បាយឯណា" គឺជាប្រយោគធម្មតា ព្រោះ "បាយ" ជា កិរិយាស័ព្ទទី២បន្ទាប់ពីកិរិយាស័ព្ទទៅ ហើយជាកិរិយាស័ព្ទមានទីតាំងតបន្ទាប់គ្នា។ ចំណែកឯ "បាយ" ចាប់ផ្ដើមប្រយោគសំនួរក៏ជាកិរិយាស័ព្ទដែរ។

ទី២: "ទេទៅបាយសិន បាយឯណាថ្ងៃនេះ?" អាចចាត់ជាប្រយោគដែលគេបំបាត់ពាក្យថា ស៊ី ហូប បរិភោគ... បញ្ហាចោទចំពោះអ្នកសិក្សាភាសាគឺ ការចោទសួរថា: តើអ្វីជាគោលការ យកជាបន្ទាល់ដើម្បីវិនិច្ឆ័យថា ប្រយោគទាំងពីរនេះជា ភាសាអ្នកស្រុក រឺជាគ្រាមភាសា?

សព្វថ្ងៃនេះ គេនិយាយជាទូទៅរួចទៅហើយ ដោយយកនាមស័ព្ទដែលខ្ចីពីបាលី មកធ្វើជា កិរិយាសព្ទ ឧ. ខ្ញុំឯកភាព ជាមួយនឹងអ្នក។

បញ្ហាចោទជាចំបងមួយទៀតគឺ នៅពេលសើរើ រៀបចំវចនានុក្រមខ្មែរបោះពុម្ពជាថ្មីទៀត។ តើគណៈកម្មការនឹងសំរេចយកគោលការណា ដើម្បីបដិសេធ រឺមិនបដិសេធពាក្យទាំងនោះ។

**បញ្ហាទី២ - ការប្រើពាក្យ យាយ តា ជីដូន ជីតា**

ក្នុងបញ្ហាប្រើពាក្យផ្សេងគ្នា សំរាប់សំគាល់ញាតិ ជាមា ជាមីង ឪពុកធំ ម្ដាយធំ សម្ដេចលោកផ្ដល់យោបល់ថា: "អាត្មាស្មានទៅ បុរាណយើងពីដើម មិនមែនល្ងង់ សព្វបើ ប៉ុណ្ណោះទេ ប៉ុន្តែលោកមិនចង់ឱ្យយើងពិបាក ក៏គេហៅអញ្ចឹងតែម្ដងទៅ"។

ភាសាវិទូ អាចប្រើប្រាស់បញ្ហានេះ និងលក្ខណៈនេះ របស់ក្រុមភាសាអំបូរ មន-ខ្មែរ

ជាមធ្យោបាយពន្យល់ ពីសភាពផ្សេងគ្នារបស់ភាសា ដោយប្រៀបធៀបទៅនឹងអំបូរ ភាសាដទៃ។ យើងជាខ្មែរ បានដឹងនិង យល់ច្បាស់ថា ភាសាយើងមិនប្រើពាក្យផ្សេងគ្នា ដើម្បីសំគាល់ ដូន តា មាមីង ខាងឪពុក អោយប្លែកពី ខាងម្តាយទេ គឺយើងប្រើពាក្យតែមួយម៉ាត់ប៉ុណ្ណោះ។ តើពួកមននិងជនជាតិការ៉េន នៅប្រទេសភូមា គេមានប្រើពាក្យពិសេសដាច់គ្នា រឺទេ ដើម្បីសំគាល់ ដូនតា មាមីង ខាងឪពុក អោយប្លែកពីខាងម្តាយ រឺទេ?

ភាសាមនបុរាណមានប្រើពាក្យ kamwa / kɔma? / ដើម្បីសំគាល់ញាតិដែលជាប្អូនរបស់ឪពុក រឺរបស់ម្តាយ ហើយភាសាមនទំនើប គេប្រើពាក្យ tra /tra?/ (Hla, 1976, p. 899)។ ពាក្យនេះ វាស្មើនឹងពាក្យខ្មែរថា ពូ រឺ មា។ ចំណែកឯពួកការ៉េន គេប្រើពាក្យ hpa hti ដើម្បីសំគាល់ញាតិដែលជាប្អូន របស់ឪពុក រឺរបស់ម្តាយ។ គេប្រើពាក្យ hpü ដើម្បីសំគាល់ជីតា និងពាក្យថា hpi ដើម្បីសំគាល់ជីដូន ទោះខាងឪពុកក្តីខាង ម្តាយក្តី (Marshall, 1922, p. 135)។

សេចក្តីនេះ គ្រាន់តែជាការបំភ្លឺមួយផ្នែកតូចតែប៉ុណ្ណោះ ដោយពុំអាចអះអាងជាទូទៅបានទេ។ វាគ្រាន់តែជាការចង់ពន្យល់ថា ភាសាមន និងភាសាខ្មែរ ដែលជាសមាជិក ភាសានៃអំបូរ មន-ខ្មែរ គឺខុសគ្នាពីភាសា ចិន ភូមា ថៃ លាវ និងវៀតណាម ដែលជាសមាជិកភាសានៃអំបូរភាសា ស៊ីណូទីបេតែនតែប៉ុណ្ណោះ។ ភាសាទាំងប្រាំនេះ មានប្រើពាក្យផ្សេងៗគ្នា ដើម្បីសំគាល់ មាមីងខាងឪពុក និងខាងម្តាយ ជីដូនខាងឪពុក និងជីដូនខាងម្តាយ។ ដើម្បីអះអាងជាទូទៅបាន បញ្ហានេះតម្រូវអោយមាន ការសិក្សាជ្រៅជ្រះថែមទៀត លើភាសាទាំងអស់ ដែលគេបានចាត់ទុកថា ជាភាសាក្នុងអំបូរ មន-ខ្មែរ ដើម្បីបញ្ជាក់ថាតើនេះជាលក្ខណៈមួយទូទៅ របស់ភាសាទាំងនោះ ដូចភាសា ខ្មែរ មន និងការ៉េន ដែររឺទេ។

**បញ្ហាទី៩- ការប្រើពាក្យ បណ្ឌិត និង អន្ទិត**

សម្តេចលោកពន្យល់ថា: "អន្ទិត" មកពីពាក្យថា "បណ្ឌិត" ពីព្រោះគេថាពីរៀនសូត្រ ចេះដឹង ជាអ្នកមានការជ្រៅជ្រះហើយបានគេហៅបណ្ឌិត។ បណ្ឌិតហ្នឹងគ្មានបានដល់ថ្នាក់ **Doctor** "ដុកទ័រ" ទេ។ វចនានុក្រមខ្មែរ ទំព័រ ៩៤៣-៩៤៤ បានពន្យល់ថា: "ទើប សឹកចាកផ្នួសថ្មីៗ គេក៏ហៅពួកនោះថាបណ្ឌិតដែរ ហៅក្លាយមកជាបន្ទិត, ហៅក្លាយឃ្លាត មកថាអន្ទិត"។

យើងសង្កេតឃើញថា: បណ្ឌិត ក្លាយទៅជា បន្ទិត ហើយ បន្ទិត ទៅជា អន្ទិត ដោយប្តូរ ប ជា អ, ណ ជា ន និងប្តូរជើង "្ឌ" ទៅជាជើង "្ទ" ។

**សម្មតិកម្មទី១** តើមានពាក្យខ្មែរណា ដែលបានប្រើវិធីកម្លាយបែបនេះដែររឺទេ?

ពាក្យពីរម៉ាត់ ដែលសមស្របទៅតាមក្បួនកម្លាយ ដែលមានរួចមកហើយ គឺ

១- ដែត ក្នុងពាក្យ ត្រដែត បណ្ដែត និង អណ្ដែត

២- ដោត ក្នុងពាក្យ អណ្ដោត

ពាក្យទាំងពីរនេះ យើងអាចពន្យល់បាន ព្រោះវាស្របទៅតាមក្បួន ដែលជាធរមាន តាមភាសាវិទ្យាខ្មែរ។ ប៉ុន្តែក្នុងពាក្យ បន្ទិត និង អន្ទិត តើយើងអាចសំអាងទៅលើមូលសព្ទអ្វីជារឹសគល់របស់ពាក្យទាំងពីរនេះ ដើម្បីអនុវត្តក្បួនកម្លាយនេះកើត។

**សម្មតិកម្មទី២** បញ្ហាពាក្យថា บัณฑิต (បណ្ឌិត) និង ฑิต (ទិត) ក្នុងភាសាថៃ វចនានុក្រមថៃបានពន្យល់ថា ฑิต គឺជាជនដែលបានបួសរៀនសឹកលាចាកផ្នួស ន័យរបស់វាមកពីពាក្យថា บัณฑิต (បណ្ឌិត)។ បាលីយានកម្មនៃពាក្យ บัณฑิต របស់ថៃ គឺធ្វើឡើងដោយទម្លាក់ព្យាង្គដើម បណ អោយនៅត្រឹមតែ ฑิด (ឌិត) ដែលក្លាយទៅជា ฑิด ដោយរក្សាព្យញ្ជនៈប្រកបអោយ នៅដដែល។ បាលីយានកម្មរបស់ពាក្យ បណ្ឌិត ទៅជា ទិត បែបថៃនេះ ក៏គួរយល់បាន ល្មមទទួលបាន។

**សម្មតិកម្មទី៣** បញ្ហាពាក្យថា ទិត ក្នុង អន្ទិត

**សំនួរទី១** សួរថា តើបាលីយានកម្មខ្មែរ អនុវត្តបែបបទដូចថៃ នេះបានដែររឺទេ?

ចម្លើយទី១ ក្នុងរឿងកាត់ព្យាង្គមុខ រឺក្រោយចោល របស់ពាក្យបាលីខ្ចីចូលមកក្នុងភាសាខ្មែរ គឺធ្លាប់មានមកហើយ។ ដូច្នេះពាក្យថា បណ្ឌិត កាលបើកាត់ព្យាង្គ បណ ចេញទៅ វានៅ សល់ត្រឹមតែ ឌិត។

ចម្លើយទី២ ការប្ដូរ ឌ ជា ទ រឺជើង ឌ ជា ជើង ទ ក៏អាចធ្វើបានដែរ ដោយ សំអាងថា ទីបន្ទឺសូរ ឌ និង ទ វានៅក្បែរគ្នា។

**សំនួរទី២** តើព្យាង្គ អន ដែលប្រើដូចជា បុព្វបទនេះ បានមកពីណា?

ក្នុងភាសាខ្មែរ ព្យាង្គបុព្វបទ អន នេះ ត្រូវបានគេប្រើប្រាស់ជាយូរមកហើយ ដូចមានក្នុងពាក្យពីរម៉ាត់ជាឧទាហរណ៍ស្រាប់ : ដែត អណ្ដែត "ត្រដែត បណ្ដែត" និង ដោត អណ្ដោត។

**សំនួរទី៣** បាលីយានកម្ម ដូចបានរៀបរាប់មកហើយនេះ បើដូចតាមការសន្មតមែនថា ថៃក៏ដូចខ្មែរ ខ្មែរក៏ដូចថៃនោះ តើនរណាអនុវត្តមុននរណា ហើយនរណាខ្ចីពីនរណា រឺមួយថៃខ្ចីទៅពីខ្មែរ ហើយខ្មែរខ្ចីមកវិញ រឺមួយថៃខ្ចីទៅ តែខ្មែរពុំបានដឹង ដូចជាពាក្យថា ចោរ និង ខ្មួយ។

សមត្តិកម្មក្នុងទីនេះ ពុំអាចឆ្លើយសំនួរទី៣បានទេ។ ចម្លើយបែបសំនួរនេះ អាចរកឃើញ ខ្លះ.

លុះត្រាណាតែគេសិក្សា ជាតិសព្ទរបស់ពាក្យ បណ្ឌិត បន្ទិត និងអន្ទិត តាមកាល ប្រវត្តិរបស់វា (synchrony/diachrony)។ ពាក្យថា អន្ទិតក្នុងភាសាខ្មែរ ពុំទាន់បាន បញ្ចូលជាមេពាក្យ ក្នុងវចនានុក្រមខ្មែរនៅឡើយទេ ដោយគេយល់ថា ជាពាក្យប្រជាប្រិយ ក្រៅផ្លូវការ និងជាគ្រាមភាសាផង។

## បញ្ហាទី៩- ការប្រើពាក្យ មិ មី មេ អមេ ម៉ែ និង មី

យើងចង់ដឹង ថាតើពាក្យថា មេ ពាក្យថា មី មានប្រើ រឺទេ នៅសម័យអង្គរ និងសម័យលង្វែក។ ដើម្បីជាពន្លឺ យើងសំអាងលើអត្ថបទសិលាចារឹកខ្មែរខ្លះ.។

### ពាក្យថា មិ និង មី "សម័យអង្គរ"

សិលាចារឹក (k. 904, stèle du Baray occidental, çaka 639, Inscription du Cambodge, vol. 4, p. 59) មានប្រយោគមួយដែលប្រើពាក្យ មី ក្នុងន័យថា មួយ១ រឺជិតខាង (prasāda daṅ sre sāmanta mī kandaṅṅ) ពាក្យថា មី មានប្រើក្នុងសិលាចារឹក k. 30 ដែរក្នុងពាក្យថា "មិមោយ" ដែលមានន័យថា មួយ១ រឺនិមួយ១ (ឡុង, ២០០០, ទំ.៨៦៤)។ ពាក្យថា មី នេះ មិនមែនមានន័យដូចពាក្យថា មី ក្នុងពាក្យថា មីនេះ មីនោះ ដែលយើង ប្រើប្រាស់សព្វថ្ងៃនេះទេ។

### ពាក្យថា មេ

ឡុង. (២០០០) ទំ. ៨៦៦ បានពន្យល់ពាក្យ មេ នេះថា "ពាក្យសំរាប់ហៅស្ត្រីចំណាស់ នារីចំណាស់"។ មេក្នុងទីនេះ មានន័យថា ម៉ែ [ ku me bhe (k. 137, Inscription du Cambodge, vol. 2, p. 116)]

### ពាក្យថា អមេ ªme

ក្រៅពីពាក្យថា មេ បុរាណលោកប្រើពាក្យមួយម៉ាត់ទៀត គឺ អមេ។ អមេ មានឃើញប្រើ ក្នុងឃ្លា "វាប ធម្ម នុ អមេ វាប ធម្ម" [vāp dharmma nu ªme vāp dharmma (k. 349, inscription de Prasat Ta Ros, Inscription du Cambodge, vol. 5, pp. 108-113)]
ប្រយោគនេះ និយាយអំពីការទិញដីនៅខាងត្បូងព្រៃផ្ដៅ ថ្វាយដល់ យសោធរាស្រម តាមព្រះរាជក្រិត្យ ព្រះបាទរាជេន្ទ្រស្រីវរ្ម្មទេវ នៅឆ្នាំ ៨៧៦ ស.ក.។ ដីនេះទិញពី វាបធម្ម និង ម៉ែ "របស់" វាបធម្ម។ ពាក្យថា អមេ មានឃើញប្រើក្នុងប្រយោគច្រើនទៀត។ ឧទាហរណ៍មួយទៀត ដែលបកប្រែជាភាសាបារាំង មានន័យថា រូបសំណាក របស់ម៉ែខ្ញុំ "une image de ma mère" [rūpa ªme añ (k. 697, stèle de Ban T'at T'ong, Inscription du Cambodge, vol. 7, pp. 94-98)]។

**ឋានៈរបស់ពាក្យ មេ និង អមេ**

សិលាចារឹកប្រាសាទ តាគាំ Inscription de Prasat Tā Köm [cau ta jmoḥ me sok (k. 245, xiè,] Inscription du Cambodge, vol. 3, pp. 89-93) មានប្រយោគដែលប្រើពាក្យថា មេ ជាពាក្យគួរសមថ្លៃថ្នូរ (ចៅ ដ ឈ្មោះ មេ សុក) ជាចៅស្រីរបស់អ្នករាជការជាន់ខ្ពស់ដែលមានងារជា ម្រតាញ នៅសម័យកាលព្រះបាទសុរិយាវរ្ម័នទី១។ លុះមកដល់សម័យលង្វែក ពាក្យថា មេមានន័យ អន់ថយ គឺធ្លាក់ពីវណ្ណៈអភិជន មកជាវណ្ណៈទាសភាពទៅវិញ។ ក្នុងសម័យលង្វែក សិលាចារឹកនគរវត្ត លេខ៤ ទំ. ១៣-១៤ ស.ក. ១៤៨៨ (គ.ស. ១៥៦៦ មានប្រើពាក្យ មេ ដើម្បីហៅឈ្មោះស្រីដែលជាអ្នកបំរើ "មេសុត១ មេអន១..."។ បើប្រុសគេហៅថា អា ដូចជា ពាក្យថា "អានោក១ អាកន១ អាសែន១..."។ សិលាចារឹកនគរវត្ត លេខ៨ ទំ. ២២ ស.ក. ១៥៤៧ មានប្រើពាក្យថា "ព្រពុនឈ្មោះមេអេព្ត..."។ ពាក្យថា មេ ដែលប្រើប្រាស់ក្នុងសម័យបច្ចុប្បន្ននេះ មានន័យថ្មីទៀត ដូចជាពាក្យថា មេស្រុក មេឃុំ មេទ័ព មេភូមិ មេបា មេផ្ទះ មេទឹក មេក្រុម មេវត្ត មេគោ និង ប្អូនមេ ។ល។

**ពាក្យថា មេ និង មី "សម័យភ្នំពេញ"**

ពាក្យទាំងពីរនេះ គេប្រើផ្លាស់ប្ដូរគ្នា ក្នុងសំដីរបស់អ្នកស្រុក ឧទាហរណ៍ថា មេនេះ មេនោះ មីនេះ មីនោះ រឺក្នុងពាក្យជេរថា មេចោរ.រឺ មីចោរ.។ ពាក្យថា មី នេះគឺកើតក្រោយ ហើយវា អាចក្លាយមកពីពាក្យថា មេ។

**ប្រភេទរបស់ពាក្យ មេ អមេ ម៉ែ និង មី តាមភាសាវិទ្យា**

